**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Economiques**
**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការទទួលខុសត្រូវរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតចំពោះពន្ធ និង អាករនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ភុំ រាត្រី**
**សន មុន្នីនាត**

សាស្ត្រាចារ្យណែនាំ
លោកស្រី **ម៉ូលី បញ្ញា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **សន មុន្នីនាត** និងខ្ញុំបាទឈ្មោះ **គាំ រាត្រី** យើងខ្ញុំទាំងពីរនាក់ ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី១៩ ថ្នាក់សិក្សាបង់ថ្លៃ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៥-២០១៩។

**យើងខ្ញុំទាំងពីរ សូមលំឱនកាយវាចាចិត្តដើម្បី សម្តែងការគោរព ការដឹងគុណ និង កតញ្ញូតាធម៌ យ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះ៖**

**លោកឪពុក អ៊ូច ស៊ិនដារ៉ូ** **លោកឪពុក លន់ សេន**

**អ្នកម្តាយ សេង សំណាង** **អ្នកម្តាយ ប៊ុត រស់**

ដែលបានផ្តល់កំណើតយើងខ្ញុំទាំងពីរអ្នក ចិញ្ចឹមបីបាច់ថែរក្សា ប្រៀនប្រដៅ ទំនុកបម្រុងគ្រប់យ៉ាង ឲ្យកូនៗក្លាយជាសិស្សល្អ និស្សិតល្អ ពលរដ្ឋល្អ លើសពីនេះទៅទៀតលោកទាំងពីរបានបញ្ជូនពួកយើងខ្ញុំឲ្យទទួលបានការសិក្សាអប់រំរហូតបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រដោយជោគជ័យ ។ គុណូបការៈរបស់លោកទាំងបួនមានទំហំធំធេង ដែលយើងខ្ញុំទាំងពីរ ពិតជាមានសេចក្តីរីករាយពេកក្រៃ និងសោមនោសតតក្រៃលែង ដែលធ្វើអោយពួកយើងជាកូនៗចងចាំជានិច្ចនូវកិច្ចចិញ្ចឹមបីបាច់ ទំនុកបម្រុងទាំងប៉ុន្មានដែលលោកទាំងបួនផ្តល់អោយពួកយើងម្នាក់ៗ រហូតគាត់តែងឡើងចេញជា សៀវភៅសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ ដែលធ្វើឲ្យលោកទាំងបួនមើលឃើញពីកិច្ចខិតខំប្រឹងប្រែងរបស់ពួកយើង និងមានមោទនភាពចំពោះពួកយើងទាំងពីរ នូវអ្វីដែលគាត់បានជួយជ្រោម ជ្រែងពីក្រោយ។

ផងដែរនោះ យើងទាំងពីរ ក៏សូមធ្វើការថ្លែងអំណរគុណចំពោះបងប្អូនប្រុសស្រី មិត្តភក្តិទាំងអស់គ្នាដែលបានជួយជ្រោមជ្រែងផ្តល់ជាកម្លាំងចិត្ត សំភារៈ និងផ្តល់ជាការប្រឹក្សាដល់ពួកយើងជានិច្ច ។

ចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកព្រឹទ្ធបុរស លោកព្រឹទ្ធបុរសរង លោក លោកស្រីប្រធានការិយាល័យស្រាវជ្រាវ ប្រធានការិយាល័យសិក្សា** និងលោក លោកស្រីសាស្ត្រាចារ្យ និងមន្ត្រីរាជការទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀន ពន្យល់ណែនាំនូវមុខវិជ្ជាជំនាញផ្សេងៗ ខាងផ្នែកនីតិសាស្ត្រដល់យើងខ្ញុំ ក្នុងរយៈពេល ៤ ឆ្នាំមកនេះ ដែលពីមុនមិនធ្លាប់បានយល់និងសិក្សាពីមុនមក ឲ្យបានចេះដឹងរហូតទទួលបានលទ្ធផលជាទីគាប់ចិត្ត ។

ចំពោះលោកស្រីសាស្ត្រាចារ្យ **ម៉ូលី បញ្ញា** ដែលជាសាស្ត្រចារ្យ ផ្តល់ការណែនាំដល់ការសរសេរសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ នឹងបានចំណាយពេលវេលាយ៉ាងមានតម្លៃ ណែនាំពន្យល់ ផ្តល់យោបល់ និងកែកំហុសឆ្គងនានា ក្នុងគោលបំណងជួយឲ្យសារណាបញ្ចប់ការសិក្សាដល់ពួកយើង ប្រសូត្រចេញជារូបរាងឡើង និងបានបញ្ចប់ដោយជោគជ័យ។ ជាមួយគ្នានេះ យើងទាំងពីរក៏សុំធ្វើការសុំខុមាលទោសចំពោះការរាំងស្ទះផ្សេងៗ ដែលបង្កឡើងដោយពួកយើងទាំងពីរអ្នក ចំពោះអ្នកគ្រូសាស្ត្រាចារ្យ **ម៉ូលី បញ្ញា** ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរអ្នកសូមជូនពរចំពោះ លោកឪពុក អ្នកម្តាយ ញាតិមិត្ត បងប្អូន ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រីសាស្ត្រាចារ្យ មន្ត្រី និងបុគ្គលិកទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឲ្យជួបតែនឹងនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ជានិរន្តតរៀងទៅកុំបីក្លាយជាបការៈដទៃឡើយ។

# អារម្ភកថា

យើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាន់ទី ១៩ ដែលបានសិក្សាផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ ២០១៩ ដែលនៅក្នុងឆ្នាំ២០១៩ នេះជាឆ្នាំបញ្ចប់ថ្នាក់បរិញ្ញាបត្រ។ យើងខ្ញុំទាំងពីរនាក់បានរួមគំនិតគ្នា ក្នុងការសរសេរសារណាមួយនេះឡើងដែលចង្អុលបង្ហាញ និងជាជំនួយទៅដល់អ្នកអានឲ្យបានយល់អំពីសិទ្ធិ និងកាតព្វកិច្ចនានាចំពោះពន្ធ និងអាករ របស់នីតិបុគ្គលដែលធ្វើការប្រកបអាជីវកម្មនៅកម្ពុជា។ ដោយយល់ឃើញដូច្នេះ យើងខ្ញុំទាំងពីរនាក់ក៏បានសម្រេចជ្រើសរើសយកនូវប្រធានបទមួយដែលមានចំណងជើងថា "**ការទទួលខុសត្រូវរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតចំពោះពន្ធ និងអាករនៅកម្ពុជា**" យកមកធ្វើការសរសេរដើម្បីបញ្ចប់នូវថ្នាក់បរិញ្ញាបត្រនីតិសាស្ត្ររបស់ពួកយើងទាំងពីរនាក់។

ប្រធានបទមួយនេះយើងខ្ញុំមានគោលបំណង ដើម្បីឱ្យអ្នកអានសារណាមួយនេះបានយល់អំពីទំហំនៃសិទ្ធិរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ថានឹងទទួលបានក្នុងនាមជាអ្នកជាប់ពន្ធ ក៏ដូចជាទំហំនៃកាតព្វកិច្ចរបស់នីតិបុគ្គលដែលត្រូវបំពេញចំពោះរដ្ឋបាលសារពើពន្ធ ក្នុងនាមជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស និងមានរួមបញ្ចូលទាំងការទទួលខុសត្រូវខាងរដ្ឋបាលក៏ដូចជាខាងព្រហ្មទណ្ឌចំពោះការមិនអនុវត្តកាតព្វកិច្ចសារពើពន្ធ។ ពួកយើងខ្ញុំបានដឹងយ៉ាងច្បាស់ថា រាល់ការបកស្រាយលើប្រធានបទមួយនេះនៅមានកម្រិតនៅឡើយ ហើយវាអាចនឹងបង្កឲ្យមានភាពខ្វះខាតនៅក្នុងចំណុចមួយចំនួនដែលយើងខ្ញុំមិនអាចបំពេញចន្លោះបាន។ លើការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះពិតជាបានដាស់តឿន គ្រើនរំលឹកដល់ក្រុមយើងខ្ញុំជាច្រើន ដែលវាបានផ្តល់ជាចំណេះដឹងថ្មីដល់ក្រុមយើងខ្ញុំ ក៏ដូចជាបានរំលឹកនូវកាតព្វដែលពួកយើង ត្រូវបំពេញនៅពេលយើងខ្ញុំចង់ប្រកបអាជីវកម្មអ្វីមួយ។ សម្រាប់ការចងក្រងចេញជាសៀវភៅមួយនេះ ក្រុមយើងខ្ញុំក៏ដឹងច្បាស់ថាវាពុំទាន់មានលក្ខណៈគ្រប់គ្រាន់ ជាក់ច្បាស់ជាមានចំណុចខ្វះខាត ត្រង់ចំណុចណាមួយជាក់ជាមិនខាន។ យ៉ាងណាក៏ដោយ ពួកយើងពិតជាសង្ឃឹមថា វានឹងអាចក្លាយជាឯកសារជំនួយ ដល់សិស្សនិស្សិតឯទៀតក្នុងការសិក្សា ក៏ដូចជាការផ្តល់ជាពត៌មាន និងចំណេះដឹងបន្ថែមដល់អ្នកអានទាំងអស់គ្នាផលដែរ។

ប៉ុន្តែទោះបីជាមានឧបសគ្គបែបណាក៏ដោយ ក៏យើងខ្ញុំទាំងពីរអ្នកនៅតែព្យាយាមជានិច្ច ក្នុងការស្វែងរកឯកសារផ្សេងៗ ដើម្បីយកមកចងក្រង ហើយបង្កើតទៅជាសារណាមួយនេះឡើង ដើម្បី

ធ្វើការបញ្ចប់ការសិក្សា ព្រមទាំងដើម្បីឲ្យនិស្សិតដែលសិក្សាក្រោយក្រោយទៀតបានទទួល បាននូវចំណេះដឹងថ្មីមួយ ដែលយើងខ្ញុំបានសរសេរ និងចែករំលែកនៅក្នុងសារណានេះផងដែរ។

យ៉ាងណាមិញយើងខ្ញុំសូមធ្វើការអធ្យាស្រ័យទុកជាមុននូវរាល់ចំណុចខ្វះខាត ដែលយើងខ្ញុំមិនអាចបំពេញបានដោយអចេតនាក្តី ឬចេតនាក្តី ព្រមទាំងសង្ឃឹមថាមិត្តអ្នកអានទាំងអស់ចូលរួមវាយតម្លៃ និងបញ្ចេញមតិរិះគន់ក្នុងន័យស្ថាបនាឲ្យបានទាំងអស់គ្នា ក្នុងចក្ខុវិស័យកែលម្អឲ្យប្រធានបទមួយនេះរួមចំណែកនៅក្នុងការជួយទៅដល់ ការសិក្សាស្រាវជ្រាវរបស់និស្សិតដែលស្វែងរកឯកសារទាក់ទងជាមួយនឹងប្រធានបទមួយនេះ។

# មាតិកា

ឆាឆា❀ល៧ល៧

**សេចក្តីផ្តើម** ........ ១

## ជំពូកទី ១
## ការទទួលខុសត្រូវរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ចំពោះពន្ធ
### ផ្នែកទី ១៖ កាតព្វកិច្ចចុះឈ្មោះក្នុងបញ្ជីរដ្ឋបាលសារពើពន្ធ

**កថាខណ្ឌទី ១ ៖ កាតព្វកិច្ចចុះបញ្ជី និងការធ្វើបច្ចុប្បន្នភាព** ........ ៤

ក. ការចុះបញ្ជីពន្ធដារ ........ ៤

ខ. ការធ្វើបច្ចុប្បន្នភាពពត៌មានសហគ្រាសចុះបញ្ជី ........ ៧

គ. ឯកសារផ្លូវការដែលទទួលបានបន្ទាប់ពីចុះបញ្ជី ........ ៩

**កថាខណ្ឌទី២ ៖ សិទ្ធ និងកាតព្វកិច្ចរបស់ក្រុមហ៊ុនឯកជនទទួខុសត្រូវមានកម្រិត** ........ ៩

ក. សិទ្ធិទូទៅដែលក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ........ ៩

ខ. កាតព្វកិច្ចរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ........ ១២

### ផ្នែកទី ២ កាតព្វកច្ចដាក់លិខិតប្រកាសសារពើពន្ធ និង បង់ប្រាក់ពន្ធ

**កថាខណ្ឌទី ០១ លិខិតប្រកាសពន្ធប្រចាំខែ** ........ ១៤

ក. ពន្ធកាត់ទុក ........ ១៤

ខ. ប្រាក់ពន្ធរំដោះពន្ធលើប្រាក់ចំនេញ ........ ១៩

គ. ពន្ធលើប្រាក់បៀវត្ស ........ ២០

**កថាខណ្ឌទី ២ លិខិតប្រកាសពន្ធប្រចាំឆ្នាំ** ........ ២៦

ក. ពន្ធលើប្រាក់ចំណូល ........ ២៦

ខ. ពន្ធអប្បបរមា ........ ៣២

គ. ពន្ធប៉ាតង់ ........ ៣៣

ឃ. ពន្ធលើតែមប្រ៍សារពើពន្ធ ........ ៣៥

ង. ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ........ ៤០

### ផ្នែកទី ០៣ ៖ ការទទួលបានការអនុវត្តពន្ធពិសេស សម្រាប់អ្នកជាប់ពន្ធ

**កថាខណ្ឌទី ០១  ការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់វិស័យអធិភាព** ........ ៤៥

ក. ការទទួលបានការលើកទឹកចិត្តចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្ត ........ ៤៥

ខ. ការទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារក្នុងវិស័យអាទិភាព ................ ៤៧
គ. ការលើកទឹកចិត្តពន្ធបន្ថែមចំពោះការដាំដុះស្រូវ ការប្រមូលទិញស្រូវ និងការផលិតអង្ករនាំចេញ ................ ៥០
**កថាខណ្ឌទី០២៖ការលើកទឹកចិត្តផ្នែកពន្ធសម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់** ................ ៥១
ក. កម្មវត្ថុនៃការទទួលបានការលើកទឹកចិត្ត ................ ៥១
ខ. ការលើកទឹកចិត្តផ្នែកពន្ធដារ ................ ៥១
**ជំពូកទី ០២**
**ការទទួលខុសត្រូវរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតចំពោះអាករ**
**ផ្នែកទី ០១ ភាតព្វកិច្ចប្រមូលអាករពីអ្នកប្រើប្រាស់ និង ការដាក់លិខិតប្រកាស និង បង់ប្រាក់អាករ ស្របតាមសកម្មភាពអាជីវកម្ម**
**កថាខណ្ឌទី ០១ ប្រភេទនៃអាករទទួលបន្ទុក និងការប្រមូលអាករ** ................ ៥៤
ក. អាករលើតំលៃបន្ថែម ................ ៥៤
ខ. អាករពិសេស ................ ៦៤
គ. អាករលើការស្នាក់នៅ ................ ៦៩
ឃ. អាករបំភ្លឺសាធារណៈ ................ ៧១
**កថាខណ្ឌទី ០២ ការប្រើប្រាស់វិធានវិក័យបត្រ អ.ត.ប ក្នុងការប្រមូលអាករ** ................ ៧៣
**ផ្នែកទី ០២៖ ការទទួលបានការអនុគ្រោះ និង ការអនុវត្តពិសេសចំពោះអាករ**
**កថាខណ្ឌទី០១៖ ការលើកលែងប្រាក់អាករចំពោះក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត** ................ ៨២
ក. ការទទួលបានការអនុវត្តពិសេសចំពោះអាជីវកម្មមានកម្មវត្ថុជាការដាំដុះស្រូវ ការប្រមូលទិញស្រូវ និងការផលិតអង្ករនាំចេញ ................ ៨២
ខ. ការទទួលបានការអនុវត្តពិសេសចំពោះអាករលើតម្លៃបន្ថែមសម្រាប់កាតនាំចូល និងផ្គត់ផ្គង់ទំនិញមួយចំនួន ................ ៨៣
គ. ការលើកលែងអាករលើតម្លៃបន្ថែមលើមុខទំនិញដែលជាអាហារជាមូលដ្ឋានសម្រាប់ការរស់នៅ ................ ៨៤
**កថាខណ្ឌទី០២៖ ការទទួលបានការអនុវត្តពិសេសចំពោះសកម្មភាពវិនិយោគដែលមានគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់** ................ ៨៥

ក. ការលើកទឹកចិត្តសម្រាប់ការនាំចូល ........ ៨៥
ខ. នីតិវិធីនាំចូលសម្រាប់ គ.ល.គ ........ ៨៦

**ជំពូកទី ០៣**

**ទោសទណ្ឌរដ្ឋបាលនៃបទបញ្ញាត្តិពន្ធដារ**

**ផ្នែកទី ០១ ៖ប្រភេទនៃកំហុសរដ្ឋបាល និង ការទទួលខុសត្រូវស្តីពីបទប្បញ្ញត្តពន្ធដារ**

**កថាខណ្ឌទី ០១៖ ប្រភេទនៃកំហុសរដ្ឋបាល នៃបញ្ញាត្តពន្ធដារ** ........ ៨៩
ក. ការធ្វេសប្រហែស ........ ៨៩
ខ. ការគេចវេសពន្ធ ........ ៨៩
គ. អំពើរាំងស្ទះការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារ ........ ៩០

**កថាខណ្ឌទី០២ ៖ ទំនួលខុសត្រូវរបស់អ្នកជាប់ពន្ធ** ........ ៩១
ក. ការទទួលខុសត្រូវផ្នែករដ្ឋបាល ........ ៩១
ខ. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនៃបទប្បញ្ញត្តិពន្ធដារ ........ ៩៦

**ផ្នែកទី ០២ ៖ សិទ្ធិប្តឹងតវ៉ាទៅនឹងនីតិវិធីរបស់រដ្ឋបាលសារពើពន្ធ**

**កថាខណ្ឌទី ០១៖ នីតិវិធីបណ្តឹងតវ៉ាទៅរដ្ឋបាលសារពើពន្ធ** ........ ៩៧
ក. នីតិវិធីដាក់ពាក្យបណ្តឹងតវ៉ា ........ ៩៧
ខ. ខ្លឹមសារនៃបណ្តឹង និង បន្ទុកភស្តុតាង ........ ៩៨
គ. នីតិវិធីដោះស្រាយបណ្តឹងតវ៉ា ........ ៩៩

**កថាខណ្ឌទី ០២៖ការដាក់ពាក្យបណ្តឹងទៅតុលាការ** ........ ១០០
ក. នីតិវិធីប្តឹងទៅតុលាការ ........ ១០០
ខ. ខ្លឹមសារនៃបណ្តឹង ........ ១០១

**សេចក្តីសន្និដ្ឋាន** ........ ១០២

**អនុសាសន៍** ........ ១០៤

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ចំណូលថវិការជាតិ គឺជាចំណូលដែលរួមចំណែក និងដើរតួយ៉ាងសំខាន់ក្នុងកិច្ចការនានាក្នុងការអភិវឌ្ឍន៍ប្រទេស ឆ្ពោះទៅកាន់ភាពរីកចម្រើន និងការអភិវឌ្ឍន៍ស្របតាមស្ថានភាពនៃសកលភាវូពាណិជ្ជកម្ម។ ដូចនេះ ការគ្រប់គ្រង់ និងការរៀបចំប្រព្រឹត្តទៅនៃប្រភពចំណូលថវិកាជាតិ ជាកិច្ចដែលសំខាន់ មិនអាចធ្វេសប្រហែសបាន។ **តើអ្វីទៅជាចំណូលថវិកាជាតិ?** ចំណូលថវិកាជាតិ គឺជាការរួមបញ្ចូលនូវចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។ ចំពោះចំណូលដែលមិនមែនសារពើពន្ធ គឺចំណូលទាំងឡាយណាដែលបានមកពី ការរុករកធនធានធម្មជាតិ វិស័យទេសចរណ៍ សម្បទានដីសេដ្ឋកិច្ច ប្រៃសណីយ៍ ប្រព័ន្ធទូរគមនាគមន៍ សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈ...។[1] ចំណែកឯចំណូលសារពើពន្ធ គឺជាចំណូលដែលបានពីប្រភពសំខាន់ពីរ គឺប្រភពចំណូលពន្ធដារនិងប្រភពចំណូលពន្ធគយនិងអាករ។ បើស្របទៅតាមស្ថានភាពប្រទេសជាតិជាក់ស្តែង អគ្គនាយកដ្ឋានពន្ធដារប្រៀបបានជាដៃឆ្វេងរបស់រាជរដ្ឋាភិបាល ក្នុងការទាញយកផលប្រយោជន៍នៃចំណូលថវិកាចូលក្នុងឃ្លាំងជាតិដើម្បីធ្វើជាកញ្ចប់ថវិកាសម្រាប់ប្រើប្រាស់លើគ្រប់វិស័យសំខាន់ៗ ដែលរដ្ឋយល់ឃើញថាជាកាតព្វកិច្ចដែលត្រូវអនុវត្តពុំអាចខ្វះបាន ដើម្បីផលប្រយោជន៍ជាតិ រីឯអគ្គនាយកដ្ឋានពន្ធគយ និងរដ្ឋាករ ប្រៀបបានជាដៃស្តាំរបស់រដ្ឋក្នុងការស្រូបចូលប្រភពចំណូលយ៉ាងសំខាន់តាមរយៈការនាំចេញនិងការនាំចូលស្របតាមការកំនត់នៃច្បាប់ជាធរមាន។ ដើម្បីធានាបានថាកម្ពុជាឆ្ពោះទៅមុខជាមួយការស្ថិតនៅក្នុងបរិការណ៍សុខសន្តិភាព ស្ថិរភាពនយោបាយ និងរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់៧% ជាមធ្យមក្នុងមួយឆ្នាំ និងរក្សាបាននូវកំណើន១,៩ពិន្ទុភាគរយនៃផ.ស.ស ឬទទួលបានទ្វេដងលើសពីផែនការនៃការអនុវត្តយុត្តិ-សាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨រាជរដ្ឋាភិបាលកម្ពុជានៅក្នុងនីតិកាលទី ៦ នៃរដ្ឋសភានេះ បានបន្តរៀបចំនិងដាក់ចេញអោយប្រើប្រាស់ នូវយុត្តិសាស្ត្រកៀរគរចំណូល ២០១៩-២០២៣។ ផងដែរនោះក៏ដើម្បីបន្តធានាបានកំណើនសេដ្ឋកិច្ចរក្សាបាន នូវចីរភាពចំណូលធានានូវយុត្តិធម៌ទទួលចំណូលសមធម៌រវាងអ្នកជាប់ពន្ធ នឹងដើម្បីឆ្លើយតប ទៅនឹងតម្រូវការចំណាយរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តយុត្តិសាស្ត្រចតុកោណ-ដំណាក់កាលទី៤។[2]

[1] សៀវភៅសិក្សាស្តីពី សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ នៃសាលាជាតិពន្ធដារ បោះពុម្ពថ្ងៃទី៩ កញ្ញា ២០១៨

[2] សៀវភៅយុត្តិសាស្ត្រគៀគរចំណូល ២០១៩-២០២៣ ចុះថ្ងៃទី ១៦ ឧសភា ២០១៩

គួយ៉ាងនៅរយៈបីខែដំបូងនៃឆ្នាំ២០១៩នេះពោលរាប់ចាប់ពីខែមករា ដល់ខែមីនាតាមរយៈរបាយការណ៍ពីអគ្គនាយកដ្ឋានពន្ធដារអគ្គនាយកដ្ឋានពន្ធដារ បានប្រមូលចំណូលពន្ធនិងអាករបានប្រមាណជាង៨០០លានដុល្លារដែលស្មើនឹងជាង៣៦%នៃផែនការប្រចាំឆ្នាំ។[3] ពាក្យ **ពន្ធ** សំដៅដល់ពន្ធនិងអាករដែលមានពន្ធផ្ទាល់ និងពន្ធប្រយោល។ **ពន្ធ** គឺជាបន្ទុករបស់ប្រជាពលរដ្ឋ បង់ចូលថវិកាជាតិ ។ ប្រជាពលរដ្ឋតាមរយៈទំនិញឬសេវាសារធារណៈ។ **ពន្ធ** គឺជាឧបករណ៍របស់រដ្ឋាភិបាលដែលបានបង្កើតឡើងដើម្បីកៀរគរចំណូលចូលថវិកា ជាតិសម្រាប់ចំណាយសេវាសារធារណៈ។

ដោយដឹងហើយថាពន្ធគឺជាបន្ទុករបស់ប្រជាពលរដ្ឋគ្រប់រូប ដែលក្នុងនោះក៏បានរួមបញ្ចូលទាំងនីតិបុគ្គលដែលកំពុងធ្វើសកម្មភាពសេដ្ឋកិច្ចនៅក្នុងទឹកដីកម្ពុជា។ នីតីបុគ្គលគ្រប់រូបដែលកំពុងប្រកបអាជីវកម្មឬសកម្មភាពសេដ្ឋកិច្ចនៅប្រទេសកម្ពុជាគឺមានកាតព្វកិច្ច ដែលខកខានមិនអាចបាននោះគឺការបង់ពន្ធនិងអាករជូនខាងរដ្ឋសារពើពន្ធ។ ប៉ុន្តែបើទោះបីជាការគ្រប់គ្រង់អ្នកជាប់ពន្ធរដោយ ស្ថាប័នពន្ធដារមានការកែប្រែប្រសើរឡើងជាងមុនក៏ដោយ ក៏បច្ចុប្បន្ននេះនៅមាននីតិបុគ្គលមួយចំនួន ឬហៅថាក្រុមពាណិជ្ជករ អាជីវករ ដែលកំពុងប្រកបអាជីវកម្មឬមានបំណងចង់ធ្វើពាណិជ្ជកិច្ចនៅមិនទាន់បានមកធ្វើការចុះបញ្ជីពន្ធដារដើម្បីបំពេញកាតព្វកិច្ចសារពើពន្ធរបស់ខ្លួននៅឡើយទេ។ ការមិនបានបំពេញកាតព្វកិច្ចសារពើពន្ធនេះ អាចបណ្តាលមកពី នីតិបុគ្គលទាំងនេះមិនទាន់បានយល់ជាក់ច្បាស់ស្តីពីកាតព្វកិច្ចរបស់ខ្លួនចំពោះវិស័យសារពើពន្ធ។ ជាមួយគ្នាសម្រាប់ផ្នត់គំនិតនៃការប្រមូលពន្ធ ក៏នៅមានប្រជាពលរដ្ឋមួយចំនួននៅតែបញ្ចេញការយល់ឃើញថា វាជាការគាបសង្កត់ជញ្ជក់ញើស ឈាមរាស្ត្រជាដើម...។ ដោយការមើលឃើញនូវបញ្ហាមួយនេះហើយទើបពួកយើងទាំពីរអ្នកបាន ជ្រើសរើសយកប្រធានបទមួយដែលមានចំណងជើងថា **“ការទទួលខុសត្រូវរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតចំពោះពន្ធ និងអាករនៅកម្ពុជា”** មកធ្វើការសរសេរជាសារណាមួយនេះឡើងក្នុងគោលបំណង់ចង់បង្ហាញឲ្យប្អូនៗនិស្សិតមិត្តអ្នកអានបានដឹងអំពី និងយល់កាន់តែជាក់ច្បាស់មួយកម្រិតទៀត អំពីបញ្ហាដូចខាងក្រោម ៖

- តើក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវមកធ្វើការចុះបញ្ជីពន្ធដារនៅពេលណា?

[3]វេបសាយពត៌មាន ខេមបូណូមីស ចំណូលពន្ធដារ ប្រមូលបានជាង ៨០០ លានដុល្លារ នៅត្រីមាសទី១ ឆ្នាំ ២០១៩ ចូលមើលថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ ២០១៩-cambonomist.com

- តើនីតិបុគ្គលនេះត្រូវបំពេញកាតព្វកិច្ចអ្វីខ្លះក្នុងដំណាក់ការចុះបញ្ជី ?
- តើនីតិបុគ្គលនេះនឹងទទួលបាននូវសិទ្ធ និងកាតព្វកិច្ចអ្វីខ្លះបន្ទាប់ពីចុះបញ្ជី ?
- តើនីតិបុគ្គលនេះត្រូវបំពេញកាតព្វកិច្ចអ្វីខ្លះជាប្រចាំខែ?
- តើនីតិបុគ្គលនេះត្រូវបំពេញកាតព្វកិច្ចអ្វីខ្លះជាប្រចាំឆ្នាំ?
- តើនីតិបុគ្គលនេះនឹងទទួលបានការលើកទឹកចិត្តអ្វីខ្លះពីខាងរដ្ឋបាលសារពើពន្ធ ?
- នៅពេលដែលនីតិបុគ្គលនេះមិនបានបំពេញកាតព្វកិច្ចសារពើពន្ធរបស់ខ្លួនតើនីតិបុគ្គលនេះនឹងត្រូវទទួលទោសទាន់ និងការពិន័យអ្វីខ្លះ?

នៅពេលចាប់ផ្តើមអាជីវកម្មរបស់ខ្លួនបន្ទាប់ពីបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម និងក្រសួងពាក់ព័ន្ធក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកមក្រិត ត្រូវមានកាតព្វកិច្ចចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ និងត្រូវបន្តនូវការបំពេញនូវកាតព្វកិច្ចនានារបស់ខ្លួនតាមការកំណត់ពីខាងរដ្ឋបាលសារពន្ធ និងវិធានបទបញ្ញាត្តិជាធរមាន។ ផងដែរនេះគោលបំណងនៃសៀវភៅសារណារបស់ពួកយើងទាំងពីរអ្នក គឺចង់ឲ្យមិត្តនិស្សិតនិងអ្នកអានទាំងអស់បានដឹងនិងយល់ពីសិទ្ធិ និងកាតព្វកិច្ចរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងការទទួលខុសត្រូវរបស់ពួកគេនៅពេលដែលមានការប្រព្រឹត្តកំហុសឆ្គង ដែលផ្ទុយទៅនឹងការកំណត់នៃច្បាប់សារពើពន្ធ។ គោលដៅចម្បងនៃសៀវភៅមួយនេះនឹងធ្វើការផ្តោតទៅលើ៣ជំពូកធំៗ គឺ៖

ជំពូកទី ១ ៖ ការទទួលខុសត្រូវរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតចំពោះពន្ធ

ជំពូកទី ២ ៖ ការទទួលខុសត្រូវរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតចំពោះអាករ

ជំពូកទី៣៖ ទោសទណ្ឌរដ្ឋបាលនៃបទបញ្ញត្តិពន្ធដារ។

# ជំពូកទី ១
# ការទទួលខុសត្រូវរបស់
# ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតចំពោះពន្ធ

# ជំពូកទី១៖ការទទួលខុសត្រូវរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតចំពោះពន្ធ

## ផ្នែកទី ១ ៖ កាតព្វកិច្ចចុះឈ្មោះក្នុងបញ្ជីរបស់រដ្ឋបាលសារពើពន្ធ

### កថាខណ្ឌទី ១ ៖ កាតព្វកិច្ចចុះបញ្ជី និងការធ្វើបច្ចុប្បន្នភាព

នៅពេលដែលក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតបាបចាប់ផ្តើមប្រកបអាជីវកម្ម របស់ខ្លួន នៅលើទឹកដីនៃប្រទេសកម្ពុជា នីតិបុគ្គលនោះ គឺបានចាប់ផ្តើមចងភ្ជាប់ខ្លួនជាមួយកាតព្វកិច្ចក្នុងការបង្កើតចំណូលថវិការជូនកម្ពុជា។ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតបានក្លាយជាចំណែកមួយក្នុងការបង្កើនចំណូលថវិការជាតិ គឺតាមរយៈការបង់ពន្ធ និង អាករជូនដល់រដ្ឋបាលសារពើពន្ធ ។ មុននឹងឈានទៅដល់កាតព្វកិច្ចក្នុងការបងពន្ធអាករជំបូងបង្អស់ នៅពេលបង្កើតក្រុមហ៊ុននីតិបុគ្គលនេះត្រូវមានកាតព្វកិច្ចក្នុងការចុះឈ្មោះក្រុមហ៊ុន នៅក្នុងបញ្ជីរដ្ឋបាលសារពើពន្ធក្នុងរយៈពេល ១៥ ថ្ងៃនៃថ្ងៃធ្វើការក្រោយពីបុគ្គលនេះបានចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬ ក្រោយពីពេលទទួលបានលិខិតបញ្ជាក់ការចុះបញ្ជី ឬ លិខិត អនុញ្ញាតចេញដោយ ក្រសួង ឬស្ថាប័នពាក់ព័ន្ធ ។[4]

**ក. ការកិច្ចចុះបញ្ជីពន្ធដារ**

**១. សំណុំបែបបទក្នុងការចុះបញ្ជី**

ក្រុមហាហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវធ្វើការស្នើសុំចុះបញ្ជីដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ ឬតាមប្រព័ន្ធអេឡិចត្រូនិក (E-registration) ដោយត្រូវបំពេញទម្រង់ចុះបញ្ជី ដែលបានកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ និង តម្រូវឱ្យភ្ជាប់មកជាមួយនូវឯកសារ ដូចមានកំណត់ក្នុងប្រកាសស្តីពីការចុះបញ្ជីពន្ធដារចុះថ្ងៃទី ០៦ ខែសីហាឆ្នាំ ២០១៦ ។ នៅក្នុងវិស័យពន្ធដារ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតត្រូវបានចាត់ថ្នាក់ចូលទៅក្នុងប្រភេទអ្នកជាប់ពន្ធមធ្យម[5] ឬ ជាអ្នកជាប់

[4] ប្រការ ៥ នៃប្រកាសស្តីពីការចុះបញ្ជីពន្ធដារ ចុះថ្ងៃទី ០៦ ខែសីហាឆ្នាំ ២០១៦

[5]ពាក្យ (អ្នកជាប់ពន្ធមធ្យម) តាមរយៈប្រការ ៤ ចំណុច២ នៃប្រកាសស្តីពីការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ២០១៨ បានកំណត់ថាអ្នកជាប់ពន្ធមធ្យម គឺជា៖

- សហគ្រាសដែលមានផលរបរប្រចាំឆ្នាំលើសពី ៧០០លានរៀល ដល់ ៤ ០០០ លានរៀល ឬ
- សហគ្រាសដែលបានចុះបញ្ជីជានីតិបុគ្គល ការិយាល័យតំណាង ឬ
- (...)

ពន្ធធំ[6] ។ ដើម្បីធ្វើការចុះបញ្ជី នីតិបុគ្គលនេះត្រូវធ្វើការបង់កម្រៃសេវាចុះបញ្ជីពន្ធដារ ចំនួន ៤០០,០០០ រៀល ដែលជាតម្លៃកំណត់សម្រាប់អ្នកជាប់ពន្ធមធ្យម ឬ អ្នកជាប់ពន្ធធំ។[7]

នៅក្នុងការចុះបញ្ជីនីតិបុគ្គលនេះត្រូវតម្រូវឲ្យប្រធានក្រុមប្រឹក្សាភិបាល អភិបាល កម្មសិទ្ធិករ ឬម្ចាស់ភាគហ៊ុន បណ្ណាធិការ ឬអ្នកតំណាង ត្រូវបំពេញពត៌មានក្នុងទម្រង់ដែល បានកំណត់ដោយរដ្ឋបាលសារពើពន្ធ ដោយភ្ជាប់មកជាមួយនូវច្បាប់ដើម ឬច្បាប់ចម្លងនៃឯកសារទាំងឡាយដែលមានការបញ្ជាក់ទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច ដូចខាងក្រោម ៖[8]

- **ឯកសារចុះបញ្ជីចេញដោយ ក្រសួង ឬស្ថាប័នពាក់ព័ន្ធ**
  - លិចខិតអនុញ្ញាត ឬលិខិតបញ្ជាក់ការចុះបញ្ជីចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ឬ/និង
  - លិខិតទទួលចុះបញ្ជីនូវការបង្កើតសាខា ចេញដោយក្រសួង ឬ ស្ថាប័នពាក់ព័ន្ធ (សម្រាប់ការចុះបញ្ជីសាខា) ឬ/និង
  - លក្ខន្តិកៈក្រុមហ៊ុន ឬ/និង
  - ពត៌មានគណនីធនាគាររបស់សហគ្រាស ដូចជាលិខិតបញ្ជាក់ គណនីធនាគារ របាយការណ៍ធនាគារ ឬសៀវភៅគណនីដែលចេញដោយធនាគារ ។
- **ឯកសារបញ្ជាក់អត្តសញ្ញាណរបស់ប្រធានក្រុមប្រឹក្សាភិបាល អភិបាល កម្មសិទ្ធិករ ឬម្ចាស់ភាគហ៊ុន បណ្ណាធិការ អ្នកតំណាង និងអ្នកគ្រប់គ្រងសាខា**
  - អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនដែលមានសពុលភាព

---

[6] ពាក្យ (អ្នកជាប់ពន្ធធំ) តាមរយៈប្រការ ៤ ចំណុច៣ នៃប្រកាសស្តីពីការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ២០១៨ បានកំណត់ថាអ្នកជាប់ពន្ធធំ គឺជាៈ

- សហគ្រាសដែលមានផលរបរប្រចាំឆ្នាំលើសពី ៤ ០០០ លានរៀល ឬ
- បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនពហុជាតិ សាខាក្រុមហ៊ុនបរទេស ឬ
- សហគ្រាសដែលបានចុះបញ្ជីជាគម្រោងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

[7] ប្រការ ៩ ចំណុចទី ១ នៃប្រកាសស្តីពីការចុះបញ្ជីពន្ធដារ ចុះថ្ងៃទី ០៦ ខែសីហាឆ្នាំ ២០១៦

[8] ប្រការ ៧ ចំណុច ខ នៃប្រកាសស្តីពីការចុះបញ្ជីពន្ធដារ ចុះថ្ងៃទី ០៦ ខែសីហាឆ្នាំ ២០១៦

- o រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ៣ខែ ដែលមានទំហំ ៣៥ x ៤៥ មីលីម៉ែត្រ និងមានផ្ទៃខាងក្រោយពណ៌សចំនួន ០២សន្លឹក ដែលមានការបញ្ជាក់ឈ្មោះ ម្ចាស់រូប- ថត និងចុះហត្ថលេខាទទួលខុសត្រូវដោយប្រធានក្រុមប្រឹក្សាភិបាល ។

- **ឯកសារបញ្ជាក់ទីតាំងទីចាត់ការសហគ្រាស អាជីវកម្មគោលដើម សាខាសហគ្រាស និងឃ្លាំង**
  - o ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម
  - o លិខិតបញ្ជាក់ការបងប្រាក់ពន្ធអចលនទ្រព្យ ឬពតិមានអចលនទ្រព្យ
- **ឯកសារផ្សេងៗ**
  - o វិញ្ញាបនបត្រចុះបញ្ជីរបស់គណៈកម្មការវិយោគកម្ពុជា ឬ គណៈកម្មាធិការថ្នាក់តំបន់សេដ្ឋកិច្ចពិសេសនៃក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា ឬ អនុគណៈកម្មាធិការវិនិយោគ រាជធានី-ខេត្ត (សម្រាប់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់)
  - o អជ្ញាប័ណ្ណដែលចេញដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ច (បើមាន)

**២. ការថតរូប និងស្កេនម្រាមដៃ**

នៅក្នុងដំណើរការនៃការចុះបញ្ជីក្រុមហ៊ុន គឺតម្រូវអោយមានការចូលរួមផ្ទាល់ដោយប្រធានក្រុមប្រឹក្សាភិបាល ឬ ម្ចាស់នៃក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត ត្រូវបានតម្រូវឲ្យមក ថតរូប និងស្កេនម្រាមដៃ ដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ ។

ប៉ុន្តែប្រសិនបើក្នុងករណីប្រធានក្រុមប្រឹក្សាភិបាលនោះ ឬ ម្ចាស់សហគ្រាសដែលមានសញ្ជាតិបរទេស ហើយស្នាក់នៅក្រៅព្រះរាជាណាចក្រកម្ពុជា ដែលមិនអាចអញ្ជើញមកថត់រូប និងស្កេនម្រាមដៃ គឺត្រូវ ធ្វើលិខិតផ្ទេរសិទ្ធិឲ្យអ្នកទំណាងណាមួយនៅក្នុងក្រុមប្រឹក្សាភិបាលរបស់ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនដែលបានទទួលស្គាល់ដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធមក ថតរូប និងស្កេនម្រាមដៃជំនួសបាន និងត្រូវសហការផ្តល់នូវឯកសារពាក់ព័ន្ធដូចមានកំណត់ខាងលើ ដើម្បីឲ្យទទួលបាននូវប័ណ្ណពន្ធប៉ាតង់ ឬ/និង វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ឬ/និង ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ។ រីឯចំពោះប្រធានក្រុមប្រឹក្សាភិបាល ឬ ម្ចាស់សហគ្រាសដែលមានសញ្ជាតិបរទេសតែស្នាក់នៅអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ប្រធានក្រុមប្រឹក្សាភិបាល ឬ ម្ចាស់សហគ្រាសមានសញ្ជាតិ ខ្មែរត្រូវបានតម្រូវឲ្យមកថតរូប និងស្កេនម្រាមដៃ និងត្រូវសហការផ្តល់នូវឯកសារពាក់ព័ន្ធ

ដើម្បីទទួលបាននូវប័ណ្ណពន្ធប៉ាតង់ ឬ/និង វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ឬ/និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ ។[9]

ក្នុងករណីចាំបាច់អ្នកជាប់ពន្ធអាចស្នើសុំឲ្យរដ្ឋបាលសារពើពន្ធផ្តល់សេវាទៅថតរូប និងស្កេនម្រាមដៃ ដល់ទីតាំងសហគ្រាស ឬទីកន្លែងសមស្របណាមួយ ។

បន្ទាប់ពីបានបំពេញរួចរាល់អស់ នូវសំណុំឯកសារស្នើសុំចុះបញ្ជីពន្ធដារ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតនឹងទទួលបាននូវលិខិតបញ្ជាក់ការទទួលសំណុំឯកសារស្នើសុំចុះបញ្ជីពន្ធដារចេញដោយរដ្ឋបាលសារពើពន្ធ ដែលមានបញ្ជាក់កាលបរិច្ឆេទទទួលសំណុំឯកសារបន្ទាប់ពីបានពិនិត្យឃើញថាសំណុំឯកសារស្នើសុំចុះបញ្ជីពន្ធដារនោះត្រឹមត្រូវ និង គ្រប់គ្រាន់តាមការកំណត់ក្នុងការចុះបញ្ជីពន្ធដារ ។

**ខ. ការស្នើសុំធ្វើបច្ចុប្បន្នភាពពត៌មានសហគ្រាសដែលបានចុះបញ្ជី**

បន្ទាប់ពីបានសម្រេចក្នុងការចុះបញ្ជីសហគ្រាស ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតអាចនឹងមានកាតព្វកិច្ចមួយទៀត គឺការធ្វើបច្ចុប្បន្នភាពពត៌មានក្រុមហ៊ុនប្រសិនបើមានស្ថានភាពមួយក្នុងចំណោមពីរខាងក្រោមកើតឡើង។ ដោយនៅក្នុងការធ្វើបច្ចុប្បន្នភាពពត៌មាន សហគ្រាស ឬក្រុមហ៊ុន ត្រូវធ្វើការបង់កម្រៃសេវា ២០០ ០០០ រៀល។[10] ស្ថានភាពទាំងពីរ ដែលបណ្តាលឲ្យកើតមានការធ្វើបច្ចុប្បន្នភាពពត៌មានសហគ្រាសនោះមានដូចជា ៖[11]

១. នៅពេលដែលក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត បានចុះបញ្ជីពន្ធដាររួចរាល់ហើយ ត្រូវតម្រូវឲ្យធ្វើបច្ចុប្បន្នភាពពត៌មានសហគ្រាស ក្នុងករណីដែលពត៌មានណាមួយ ក្នុងចំណោមពត៌មានខាងក្រោមនេះត្រូវបានផ្លាស់ប្តូរ ៖

- នាមករណ៍សហគ្រាស
- អាស័យដ្ឋានទីចាត់ការសហគ្រាស កន្លែងប្រកបអាជីវកម្មជាគោលដើម ឬសាខាឃ្លាំងរបស់សហគ្រាស
- អាសយដ្ឋានម្ចាស់សហគ្រាស អភិបាល ឬបណ្ណាធិការ របស់សហគ្រាស

[9] ប្រការ ៧ ចំណុច ខ នៃប្រកាសស្តីពីការចុះបញ្ជីពន្ធដារ ចុះថ្ងៃទី ០៦ ខែសីហាឆ្នាំ ២០១៦

[10] ប្រការ ៩ ចំណុចទី ២ នៃប្រកាសស្តីពីការចុះបញ្ជីពន្ធដារ ចុះថ្ងៃទី ០៦ ខែសីហាឆ្នាំ ២០១៦

[11] ប្រការ ៨ ចំណុច ខ នៃប្រកាសស្តីពីការចុះបញ្ជីពន្ធដារ ចុះថ្ងៃទី ០៦ ខែសីហាឆ្នាំ ២០១៦

- ទ្រង់ទ្រាយគតិយុត្តិរបស់សហគ្រាស
- កម្មវត្ថុអាជីវកម្ម
- ការផ្ទេរ ការបញ្ឈប់អាជីវកម្ម
- សមាសភាពអ្នកគ្រប់គ្រង
- អ្នកទទួលបន្ទុកកិច្ចការពន្ធ
- លេខគណនីធនាគារសហគ្រាស
- លេខទំនាក់ទំនង (លេខទូរស័ព្ទ សារអេឡិកត្រូនិក) ។

អ្នកជាប់ពន្ធត្រូវស្នើសុំមករដ្ឋបាលសារពើពន្ធ ក្នុងរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីមានការផ្លាស់ប្តូរពត៌មានដូចមានកំណត់ខាងលើ ដើម្បីធ្វើបច្ចុប្បន្នភាពនៃការចុះបញ្ជីពន្ធដារឡើងវិញ ដោយត្រូវគោរពតាមលក្ខខណ្ឌ និងភ្ជាប់មកនូវច្បាប់ដើម ឬ ច្បាប់ចម្លងនៃឯកសារ ចុងក្រោយនៃឯកសារនានាដែលបានតម្រូវក្នុងការចុះបញ្ជី ។ ប្រសិនបើក្នុងករណីក្រុមហ៊ុនឯក ជនទទួលខុស ត្រូវមានកម្រិតមានការផ្លាស់ប្តូរអាសយដ្ឋានទីចាត់ការសហគ្រាស ឬ ទ្រង់ទ្រាយគតិយុត្ត របស់សហគ្រាស ដែលនាំឲ្យមានការផ្លាស់ប្តូរពីការគ្រប់គ្រងរបស់អង្គភាពពន្ធដារមួយ ទៅអង្គភាពពន្ធដារមួយទៀត ត្រូវធ្វើការស្នើសុំផ្លាស់ប្តូរអង្គភាពទៅតាមទម្រង់ ដែលបានកំណត់ដោយរដ្ឋបាល សារពើពន្ធ ។

២.ប្រសិនបើក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតបានចុះបញ្ជីពន្ធដារមុនថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ២០១៤ ប្រធានក្រុមប្រឹក្សាភិបាល ឬម្ចាស់សហគ្រាស ត្រូវមកធ្វើបច្ចុប្បន្នភាពនៃការចុះបញ្ជីពន្ធដារឡើងវិញ ដោយត្រូវគោរពតាមលក្ខខណ្ឌនិងភ្ជាប់មកជាមួយនូវច្បាប់ដើម ឬច្បាប់ចម្លងនៃឯកសារចុងក្រោយនៃឯកសារនានាដែលបានតម្រូវក្នុងការចុះបញ្ជី ។

លើសពីនេះទៅទៀត នីតិបុគ្គលនេះនឹងត្រូវចំណាយថ្លៃសេវា ២០០,០០០រៀល ដូចគ្នាប្រសិនបើមានករណីដូចខាងក្រោម ៖

- ការផ្លាស់ប្តូរពត៌មាននៅលើប័ណ្ណពន្ធប៉ាតង
- ការផ្លាស់ប្តូរពត៌មាននៅលើវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ
- ការផ្លាស់ប្តូរពត៌មាននៅលើវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម
- ការផ្លាស់ប្តូរពត៌មាននៅលើលិខិតបញ្ជាក់ពីការចុះបញ្ជីពន្ធដារ
- ការស្នើសុំបោះពុម្ពឡើងវិញនូវប័ណ្ណពន្ធប៉ាតង
- ការស្នើសុំបោះពុម្ពឡើងវិញនូវវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ

- ការស្នើសុំបោះពុម្ភឡើងវិញនូវវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម
- ការស្នើសុំបោះពុម្ភឡើងវិញនូវលិខិតបញ្ជាក់ពីការចុះបញ្ជីពន្ធដារ ។

**គ. ឯកសារផ្លូវការដែលទទួលបានបន្ទាប់ពីចុះបញ្ជី**

បន្ទាប់ពីធ្វើការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពសហគ្រាស ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត អាចនឹងទទួលបានសេចក្តីសម្រេចចុះបញ្ជីពន្ធដារ ឬការធ្វើបច្ចុប្បន្នភាពពត៌មានសហគ្រាសក្នុងរយៈពេល ៖[12]

- ០១ថ្ងៃ ទៅ ០៧ថ្ងៃ នៃថ្ងៃធ្វើការចំពោះការចុះបញ្ជីតាមរយៈប្រព័ន្ធអេឡិកត្រូនិក (E-registration )
- ០៧ថ្ងៃ ទៅ ១០ថ្ងៃនៃថ្ងៃធ្វើការចំពោះការចុះបញ្ជីដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ

ក្រោយពេលនីតិបុគ្គលនេះចុះបញ្ជីពន្ធដារ ឬ ធ្វើបច្ចុប្បន្នភាពពត៌មានសហគ្រាសរួចរាល់នឹងមានការចុះមកដល់ទីតាំងផ្ទាល់របស់សហគ្រាស ពីសំណាក់រដ្ឋបាលសារពើពន្ធដើម្បី ធ្វើការថត រូបទីតាំង និងកត់ត្រាទិន្នន័យរបស់ទីតាំងសហគ្រាស (GPS) ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ បន្ទាប់មកខាងក្រុមហ៊ុននឹងត្រូវចុះហត្ថលេខាទទួល ឯកសារផ្លូវការដែលបានចេញដោយរដ្ឋបាលសារពើពន្ធ ។[13] ឯកសារផ្លូវការ នៃការចុះបញ្ជីពន្ធដារ ឬការធ្វើបច្ចុប្បន្នភាពពត៌មានសហគ្រាសដែលនីតិបុគ្គលនេះទទួលបានមានដូចជា ៖[14]

- វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ឬ/និង
- ប័ណ្ណសម្គាល់ការចុះញ្ជីពន្ធដារ ឬ/និង
- ប័ណ្ណពន្ធប៉ាតង ឬ/និង
- លិខិតជូនដំណឹងស្តីពីការដាក់លិខិតប្រកាសពន្ធ

## កថាខណ្ឌទី ២ ៖ សិទ្ធ និងភាតព្វកិច្ចរបស់ក្រុមហ៊ុនឯកជនទទួខុសត្រូវមាន កម្រិត

**ក. សិទ្ធិទូទៅដែលក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត**

[12] ប្រការ ១១ ចំណុចទី ១ នៃប្រកាសស្តីពីការចុះបញ្ជីពន្ធដារ ចុះថ្ងៃទី ០៦ ខែសីហាឆ្នាំ ២០១៦

[13] ប្រការ ១១ ចំណុចទី ២ នៃប្រកាសស្តីពីការចុះបញ្ជីពន្ធដារ ចុះថ្ងៃទី ០៦ ខែសីហាឆ្នាំ ២០១៦

[14] ប្រការ ១១ ចំណុចទី ៣ នៃប្រកាសស្តីពីការចុះបញ្ជីពន្ធដារ ចុះថ្ងៃទី ០៦ ខែសីហាឆ្នាំ ២០១៦

- **ទទួលបានការរក្សាទុកជាការសម្ងាត់នូវរាល់ពត៌មាន**

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតនឹងទទួលបានការរក្សាទុកជាការសម្ងាត់នូវរាល់ព័ត៌មានដែលអ្នកជាប់ពន្ធបានផ្តល់ជូនរដ្ឋបាលសារពើពន្ធ ។[15] រដ្ឋបាលសារពើពន្ធទទួលព័ត៌មានពីអ្នកជាប់ពន្ធ ឬពីតតិយជន ត្រូវរក្សាការសម្ងាត់ហើយអាចផ្តល់ព័ត៌មានទៅអោយតែបុគ្គល ដែលច្បាប់ស្តីពីសារពើពន្ធ បានអនុញ្ញាតមានដូចជា៖

- មន្ត្រី និង ភ្នាក់ងាររបស់រដ្ឋបាលសារពើពន្ធក្នុងពេលបំពេញភារកិច្ច
- អាជ្ញាធរព្រហ្មទណ្ឌគោលដៅបទល្មើសពន្ធដារ
- តុលាការក្នុងដំណាក់កាលជំរះក្តីអំពីពន្ធដារ
- អាជ្ញាធរពន្ធដាររបស់ប្រទេសណាមួយទៀតស្របតាមកិច្ចព្រមព្រៀងអន្តរជាតិ
- មានការយល់ព្រមពីអ្នកជាប់ពនញធជាលាយលក្ខណ៍អក្សរ

ករណីមានការបំពារបំពានត្រូវដោះស្រាយជាមួយមន្ត្រីពាក់ព័ន្ធផ្ទាល់ ឬ ប្រធានអង្គភាពនៃរដ្ឋបាលសារពើពន្ធគ្រប់កម្រិត ។

- **ការទទួលបានការពន្យល់ណែនាំ**

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតមានសិទ្ធិទទួលបាន ការផ្តល់សេវាប្រកបដោយវិជ្ជាជីវៈ និងមានការជួយពន្យល់ណែនាំឲ្យបានយល់អំពីកិច្ចដំណើរការ នៃប្រព័ន្ធពន្ធដារ នីតិវិធីសារពើពន្ធ និង ការអនុវត្តកាតព្វកិច្ចសារពើពន្ធ ដូចជា ៖

- រដ្ឋបាលសារពើពន្ធរៀបចំសៀវភៅពន្យល់នៃប្រភេទពន្ធនីមួយៗ[16]
- អ្នកជាប់ពន្ធមានសិទ្ធិទទួលបានការពន្យល់ណែនាំការទំនាក់ទំនងទាមទារ ឲ្យបង្ហាញលិខិតបេសកកម្ម ឬ លិខិតឧទ្ទេសនាម ការឆ្លើយតបសំណួរ និង សំណូមពរដោយមន្ត្រីពន្ធអំពីកិច្ចការពន្ធដារ
- អ្នកជាប់ពន្ធអាចស្វែងរកការណែនាំ និង ព័ត៌មាន ៖ បើកមើលគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh ឬធ្វើលិខិតសុំយោបល់ផ្ទាល់មាត់តាមទូរស័ព្ទលេខ ដូជមានបង្ហាញក្នុងវេបសាយ

[15] មាត្រា ៩៨ នៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

[16] មាត្រា ៩៦ នៃច្បាប់ស្តីពីសារពើពន្ធចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

- ការផ្ដល់ពត៌មានដល់អ្នកជាប់ពន្ធ ៖ លិខិតស្នាម ឬលិខិតជូនដំណឹង ដែលរដ្ឋបាលសារពើពន្ធផ្ដល់ទៅឲ្យអ្នកជាប់ពន្ធនោះ មានកាតព្វកិច្ចចំពោះរដ្ឋបាល លុះត្រាតែធ្វើជាលាយលក្ខណ៍អក្សរ និង ត្រូវប្រគល់ឲ្យដល់អ្នកជាប់ពន្ធ (ឲ្យដល់បុគ្គលផ្ទាល់ ឬតាមរយៈប្រៃសណីយ៍ ឬ បិទភ្ជាប់ទៅនឹងទ្វា និវាសនដ្ឋាន ឬកន្លែងប្រកបអាជីវកម្ម ឬផ្សព្វផ្សាយតាមសារព័ត៌មាន) ។

- **ទទួលបានការពន្យល់រាល់សេចក្ដីសម្រេចរបស់រដ្ឋបាលសារពើពន្ធចំពោះកិច្ចការសារពើពន្ធ**

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មានសិទ្ធទទួលបានការពន្យលរាល់សេចក្ដីសម្រេចរបស់រដ្ឋបាលសារពើពន្ធចំពោះកិច្ចការសារពើពន្ធ ដែលអ្នកជាប់ពន្ធយល់ថាមានភាពមិនច្បាស់លាស់ និងមានការភ័ន្តច្រឡំ។ ជាទូទៅរដ្ឋបាលសារពើពន្ធពន្យល់ពីសេចក្ដីសម្រេច របស់ខ្លួនឲ្យបានច្បាស់លាស់ និងជាលាយលក្ខណ៍អក្សរ ករណីអ្នកជាប់ពន្ធមានសំណួរ ឬមិនយល់ ឬមិនឯកភាព ទាក់ទងនឹងមន្ត្រីទទួលបន្ទុកកិច្ចការនោះ។ បើមានការមិនពេញចិត្ត នីតិបុគ្គលនេះ អាចធ្វើការជំទាស់នឹងសេចក្ដីសម្រេចរបស់រដ្ឋបាលសារពើពន្ធបាន ។

- **សិទ្ធិក្នុងការប្ដឹងតវ៉ាចំពោះរាល់សេចក្ដីសម្រេចរបស់រដ្ឋបាលសារពើពន្ធ**

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតមានសិទ្ធិដាក់ពាក្យបណ្ដឹងតវ៉ា ជំទាស់នឹងសេចក្ដីសម្រេចផ្សេងៗ ឬ អំពើខុសឆ្គងណាមួយរបស់រដ្ឋបាលសារពើពន្ធ ។ ដោយដំបូងអាចធ្វើការដោះស្រាយជាមួយមន្ត្រីពាក់ព័ន្ធផ្ទាល់ ឬ ប្រធានអង្គភាពនៃរដ្ឋបាលសារពើពន្ធគ្រប់កម្រិត (សាខា ពន្ធដារខេត្ត-ខណ្ឌ និង អគ្គនាយកដ្ឋានពន្ធដារ) គណៈកម្មាធិការសម្រុះសម្រួល សារពើពន្ធ និង តុលាការ ។

- **មានការទទួលស្គាល់តំណាងស្របច្បាប់របស់អ្នកជាប់ពន្ធ**

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតមានសិទ្ធិក្នុងការជ្រើសរើស និង ដាក់ឲ្យទទួលស្គាល់នូវតំណាងស្របច្បាប់របស់ខ្លួន ដើម្បីផ្ដល់យោបល់អំពីកិច្ចការសារពើពន្ធ ។ អ្នកតំណាងស្របច្បាប់គឺមិនមែនមន្ត្រីពន្ធដារទេ គឺអ្នកតំណាងណាម្នាក់ដែលនីតិបុគ្គលជ្រើសរើស នឹងទទួលបានការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ ដោយមានកំណត់ព្រំដែននៃសិទ្ធិអំណាច។ អ្នកជាប់ពន្ធត្រូវទទួលខុសត្រូវផ្ទាល់រាល់សកម្មភាពអ្នកតំណាង ។ កិច្ចការ ដែលអ្នក តំណាងអាចធ្វើមានដូចជា ៖[17]

[17] មាត្រា ១០៦ នៃច្បាប់ស្ដីពីសារពើពន្ធចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

- ដាក់លិខិតប្រកាសសារពើពន្ធ
- រៀបចំបញ្ជីគណនេយ្យ
- ទំនាក់ទំនងឆ្លើយចំពោះការស្នើសុំព័ត៌មានពីរដ្ឋបាលសារពើពន្ធ
- បង្ហាញរបាយការណ៍ និងឯកសារផ្សេងៗ
- បង់ពន្ធអាករទាំងឡាយ
- ធ្វើបណ្តឹងតវ៉ា និងបណ្តឹងឧទ្ធរណ៍
- តំណាងនៅតុលាការ និង បំពេញរាល់កាតព្វកិច្ចពន្ធ ។

- **ទទួលបានការអនុវត្តដោយមានតម្លាភាព និង គ្មានភាពលម្អៀងពីសំណាក់រដ្ឋបាលសារពើពន្ធ**

រដ្ឋបាលសារពើពន្ធ ត្រូវមានឥរិយាបថសុភាពរាបសា គោរពរាប់អាន អនុវត្តមិនលម្អៀង ចេញ-សេចក្តីសម្រេចដែលមានតម្លាភាព សមធម៌តាមច្បាប់ ដោះស្រាយរាល់បញ្ហាឲ្យបានឆាប់រហ័ស ។

- **ទទួលបានការទទួលស្គាល់អំពីភាពស្មោះត្រង់ក្នុងការអនុវត្តកាតព្វកិច្ចសារពើពន្ធ**

រដ្ឋបាលសារពើពន្ធមានជំនឿជាមុនថា អ្នកជាប់ពន្ធផ្តល់នូវព័ត៌មានផ្ទុយពីនេះចែកដាច់ពីគ្នារវាងការយល់ខុស និង អំពើដោយចេតនាទទួលនូវការអះអាងអំពីការយល់ខុសមកធ្វើការពិចារណាគ្រប់ទិដ្ឋភាពច្បាស់ ។

**ខ. កាតព្វកិច្ចរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត**

- **ចុះឈ្មោះក្នុងបញ្ជីរបស់រដ្ឋបាលសារពើពន្ធ**

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវធ្វើការចុះបញ្ជីក្នុងកំឡុងពេល ១៥ ថ្ងៃក្រោយពីចាប់ផ្តើមធ្វើកម្មភាពសេដ្ឋកិច្ច ឬ បន្ទាប់ពីចុះបញ្ជីពាណិជ្ជកម្ម និងជូនដំណឹងទៅរដ្ឋបាលសារពើពន្ធក្នុងរយៈពេល១៥ថ្ងៃ ក្រោយពីផ្លាស់ប្តូរអាសយដ្ឋាន ទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម ការផ្ទេរការបញ្ឈប់អាជីវកម្ម សមាសភាពអ្នកគ្រប់គ្រង ឬអ្នកទទួលបន្ទុកកិច្ចការពន្ធដាររបស់ សហគ្រាស ។[18]

- **ដាក់លិខិតប្រកាសសារពើពន្ធ និង ផ្តល់ព័ត៌មានតាមការតម្រូវ**

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតត្រូវដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ពេលវេលា និងទីកន្លែងដែលបានកំណត់ (ប្រចាំខែ-ប្រចាំឆ្នាំ) ។[19]

[18] មាត្រា ១០១ នៃច្បាប់ស្តីពីសារពើពន្ធចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

[19] មាត្រា ១០៤ នៃច្បាប់ស្តីពីសារពើពន្ធចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

- **បង់ពន្ធតាមកាលបរិច្ឆេទកំណត់**

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតត្រូវធ្វើការបង់ ពន្ធលើប្រាក់បៀវត្ស អាករលើតម្លៃ-បន្ថែម ពន្ធកាត់ទុកទូទៅ អាករបំភ្លឺសាធារណៈ អាករពិសេសលើទំនិញ និង សេវាមួយចំនួនអាករលើការស្នាក់នៅ និង ពន្ធដ៏ទៃទៀតយ៉ាងយឺតបំផុតត្រឹម ថ្ងៃទី ២០ នៃខែបន្ទាប់។ និងត្រូវធ្វើការបង់ពន្ធប៉ាតង់ ពន្ធលើប្រាក់ចំណូល យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣១ ខែមីនា។

- **កាន់កាប់ថែរក្សា និង ត្រូវបង្ហាញបញ្ជីលិខិតយុត្តិការ និង ឯកសារផ្សេងៗ ដល់រដ្ឋបាលសារពើពន្ធ**

មាត្រា៩៨ នៃច្បាប់ស្តីពីសារពើពន្ធ៖ អ្នកជាប់ពន្ធត្រូវកាន់កាប់ កត់ត្រា និង រក្សាទុកបញ្ជីលិខិតយុត្តិការ និង ឯកសារហិរញ្ញវត្ថុផ្សេងៗ (១០ឆ្នាំ) និង ត្រូវដាក់បញ្ជី និង ឯកសារទាំងនោះ តាមការតម្រូវជូនរដ្ឋបាល សារពើពន្ធ ដើម្បីពិនិត្យ ។

- **បង្ហាញខ្លួនចំពោះរដ្ឋបាលសារពើពន្ធតាមកាលបរិច្ឆេទ ដែលមានចុះនៅក្នុងលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ**

យោងតាមមាត្រា ៩៩ នៃច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធត្រូវបង្ហាញខ្លួនទៅតាម ពេលវេលា និង ទីកន្លែងដែលមានបញ្ជាក់ក្នុងលិខិត ជូនដំណឹងដើម្បីផ្តល់ព័ត៌មាន ឯកសារ ទិន្នន័យ ក្នុងគោលដៅកំណត់ប្រាក់ពន្ធ ឬ ប្រមូលពន្ធ ។

- **បង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និង ការប្រាក់ផ្សេងៗ**

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវធ្វើការបង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និង ការប្រាក់ផ្សេងៗដែលរដ្ឋបាលសារពើពន្ធបានកំណត់ឲ្យបង់ ទៅតាមកាលបរិច្ឆេទដូចមានចែងនៅក្នុងបទប្បញ្ញត្តិស្តីពីសារពើពន្ធបានជូនដំណឹងជាលាយលក្ខណ៍អក្សរ ។

- **ត្រូវមានភាពស្មោះត្រង់ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ**

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតត្រូវផ្តល់ព័ត៌មាន និង ឆ្លើយសំណួររបស់រដ្ឋបាលសារ ពើពន្ធដោយពេញលេញ ត្រឹមត្រូវ និងស្មោះត្រង់ ។

- **ត្រូវមានកិច្ចសហប្រតិបត្តិការជាមួយរដ្ឋបាលសារពើពន្ធក្នុងការបំពេញកាតព្វកិច្ច**

អ្នកជាប់ពន្ធត្រូវធ្វើទំនាក់ទំនង និង ផ្តល់កិច្ចសហការជាមួយរដ្ឋបាលសារពើពន្ធដោយ សុច្ចរិតសុភាពរាបសា និង គោរពដូចដែលអ្នកជាប់ពន្ធទទួលពីរដ្ឋបាលសារពើពន្ធ ។

## ផ្នែកទី ២៖ កាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធ និង បង់ប្រាក់ពន្ធ

## កថាខណ្ឌទី ០១៖ លិខិតប្រកាសពន្ធប្រចាំខែ

### ក. ពន្ធកាត់ទុក

យោងតាមច្បាប់ស្តីពីសារពើពន្ធ បានចែងថា អ្នកជាប់ពន្ធនិវាសនជនដែលបានប្រកបអាជីវកម្ម ដែលបានធ្វើការទូទាត់ជាសាច់ប្រាក់ ឬ ជាវត្ថុឱ្យដល់អ្នកជាប់ពន្ធនិវាសនជនត្រូវកាត់ទុក និង បង់ប្រាក់ពន្ធទៅតាមអត្រាកំណត់លើការទូទាត់មុនការកាត់ទុកប្រាក់ពន្ធ។

រាល់ចំណាយទាំងឡាយ ដែលបានកត់ត្រាទុកក្នុងបញ្ជីគណនេយ្យត្រូវចាត់ទុកថាបានទូទាត់ ។

*តើអ្វីទៅគឺជាពន្ធកាត់ទុក?*

**ពន្ធកាត់ទុក** គឺជាប្រភេទពន្ធដែលកើតមានឡើងនៅរៀងរាល់ពេល ដែលការចំណាយកើតមានឡើង ។ តាមរយៈសៀវភៅណែនាំស្តីពី "ពន្ធកាត់ទុកលើ និវាសនជន និង អនិវាសនជន " បានឲ្យនិយមន័យទៅលើពាក្យ **ពន្ធកាត់ទុក** គឺជាពន្ធដែលត្រូវបានកាត់ទុកដោយអ្នកជាប់ពន្ធ និវាសនជនលើការទូទាត់មួយចំនួនដែលធ្វើឡើងជាសាច់ប្រាក់ ឬ ជាវត្ថុអោយទៅអ្នកជាប់ពន្ធនិវាសនជន និង អនិវាសនជន ។

**ពន្ធកាត់ទុក** នេះត្រូវបានប្រមូលដោយ អ្នកជាប់ពន្ធនិវាសនជន[20] ពីអ្នកផ្គត់ផ្គង់ក្នុងនាមជាភ្នាក់ងារកាត់ទុក ។ អ្នកជាប់ពន្ធនិវាសនជន ដែលប្រកបអាជីវកម្មទាំងអស់ត្រូវធ្វើការប្រមូលប្រាក់ពន្ធ និង ធ្វើការបង់ប្រាក់ពន្ធកាត់ទុក ដែលប្រមូលបានទាំងអស់ទៅអោយ អគ្គនាយកដ្ឋានពន្ធដារជារៀងរាល់ខែ ។ ពន្ធកាត់ទុក លើការទូទាត់ឲ្យទៅដល់អ្នកជាប់ពន្ធនិវាសនជន និង ការទូទាត់ឲ្យទៅដល់អ្នកជាប់ពន្ធអនិវាសនជនត្រូវចាត់ទុកថាជាពន្ធចុងក្រោយសម្រាប់ អ្នកទទួលការទូទាត់។[21]

#### ១. និយមន័យ

- **អ្នកជាប់ពន្ធនិវាសនជន**[22]
  - រូបវន្តបុគ្គលដែលមាននិវាសនដ្ឋាន ឬ មានកន្លែងស្នាក់នៅក្នុងកម្ពុជាលើសពី ១៨២ ថ្ងៃនៅក្នុងរយៈពេល ១២ខែណាមួយ

[20] (អ្នកជាប់ពន្ធនិវាសជន) សំដៅដល់នីតិបុគ្គលដែលមានលក្ខណៈសម្បត្តិជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ហើយបានធ្វើពាណិជ្ជកិច្ច ឬប្រកបអាជីវកម្មនៅលើទឹកដីកម្ពុជា ។

[21] មាត្រា ២៧ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០០៣

[22] មាត្រា ៣(ថ្មី) ចំណុច ១ នៃច្បាប់ស្តីពីសារពើពន្ធរចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០០៣

➢ នីតិបុគ្គល ឬ ក្រុមអាជីវកម្មដែលត្រូវបានបង្កើត ឬ ត្រូវបានគ្រប់គ្រងនៅក្នុង កម្ពុជា ឬ ដែលមានកន្លែងប្រកបអាជីវកម្មជាគោលដើមនៅកម្ពុជា

- **អ្នកជាប់ពន្ធអនិវាសនជន**[23] បុគ្គលណាមួយមិនមែនជាអ្នកជាប់ពន្ធនិវាសនជន និងទទួលបានប្រាក់ចំណូលប្រភពកម្ពុជា ។

- **សេវា** សំដៅដល់ការគ្រប់គ្រង ឬការពិគ្រោះយោលបល់ ឬសេវាប្រហាក់ប្រហែល ។

**២. កម្មវត្ថុក្នុងការប្រមូលពន្ធកាត់ទុក**

**២.១. ការទូទាត់ពន្ធកាត់ទុកឲ្យដល់អ្នកជាប់ពន្ធនិវាសនជន**

និវាសនជន ឬ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវធ្វើការកាត់ទុកនូវប្រាក់ពន្ធតាមអត្រាកំណត់ចំពោះរាល់ការទូទាត់ទាំងដែលជាសាច់ប្រាក់ ឬ ជាវត្ថុឲ្យទៅអ្នកជាប់ពន្ធ និវាសនជនដែលប្រកបអាជីវកម្ម ទាំងឡាយដែលជាកម្មវត្ថុនៃការជាប់ពន្ធកាត់ទុក ។ មានដូចជា ៖

☞**សេវាកម្ម** ប្រាក់ចំណូលដែលរូបវន្តបុគ្គលបានទទួលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោលបល់ ឬសេវាប្រហាក់ប្រហែល ត្រូវជាប់អត្រាពន្ធកាត់ទុក ១៥%[24]។

សេវាទាំងនេះរួមមានសកម្មភាពសេដ្ឋកិច្ចរបស់រូបវន្តបុគ្គលក្រៅពី ការផលិត និង ការលក់ទំនិញ ភតិសន្យាការជួល ឬការលក់នូវទ្រព្យសម្បត្តិ និងក្រៅពីសកម្មភាពបម្រើការងារដែលជាប់ពន្ធលើប្រាក់បៀវត្សរ៍។[25] ប្រាក់ចំណូលនេះមានជាអាទិ៍ ប្រាក់ចំណូលពីកំរៃជើងសារ ឬជើងសារជំនួញ ប្រាក់ចំណូលពីសកម្មភាពដឹកជញ្ជូន ជួសជុល សាងសង់ គ្រប់គ្រង ឬពិគ្រោះប្រឹក្សាយោបល់ ប្រាក់ចំណូលបានពីសេវាវិទ្យាសាស្ត្របច្ចេកទេស សិល្បៈ ឬការអប់រំ ប្រាក់ចំណូលបានពីសេវាខាង

[23] មាត្រា ៣(ថ្មី) ចំណុច ២ នៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០០៣

[24] មាត្រា ២៥(ថ្មី) នៃច្បាប់ស្តីពីសារពើពន្ធចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០០៣

[25] ទំព័រ១ នៃសៀវភៅណែនាំស្តីពីពន្ធកាត់ទុកលើនិវាសនជន និង អនិវាសនជន របស់អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច ឆ្នាំ២០១៣

វេជ្ជសាស្ត្រ ទន្តសាស្ត្រ នីតិសាស្ត្រ វិស្វកម្ម ស្ថាបត្យកម្ម ការសិក្សា និង ការស្រាវជ្រាវគណនេយ្យ។ល។[26]

ಣ**សួយសារ** មានពីរៈ សួយសារពីទ្រព្យសកម្មអរូបី និង សួយសារពីភាគកម្មក្នុងធនធានរ៉ែ។ ចំពោះទ្រព្យអរូបី និង ភាគកម្មក្នុងធនធានរ៉ែ ហើយនិងការប្រាក់ដែលអ្នកជាប់ពន្ធនិវាសជនដែលប្រកបអាជីវកម្មដែលមិនមែនជា ធនាគារក្នុងស្រុក បង់ឲ្យទៅអ្នកជាប់ពន្ធ និវាសនជន ត្រូវជាប់អត្រាពន្ធកាត់ទុក ១៥% ។[27]

សម្រាប់គោលដៅនៃពន្ធកាត់ទុក **សួយសារពីទ្រព្យសកម្មអរូបី** គឺសំដៅដល់ចំណូល បានមកពីការអនុញ្ញាតឲ្យប្រើប្រាស់សិទ្ធបោះពុម្ពផ្សាយលក់ស្នាដៃ អក្សរសាស្ត្រសិល្បៈ វិទ្យាសាស្ត្រ ឬ សិទ្ធិប្រហាក់ប្រហែល (ក្នុងនោះមានរាប់បញ្ចូលទាំងសិទ្ធថតចម្លង និង ផ្សាយ ខ្សែអាត់សម្លេង ឬវីដេអូ) ចំណេះដឹង ឬ ចំណេះធ្វើ ឬ ពត៌មានទាក់ទិននឹងបទពិសោធន៍ផ្សេងៗក្នុងវិស័យ ឧស្សាហកម្ម ពាណិជ្ជកម្ម វិទ្យាសាស្ត្របច្ចេកទេស។ល។ ការផ្ទេរសិទ្ធិលើចំណេះ ការផ្តល់យោបល់ ការផ្តល់សេវាទាក់ទិននឹងការអនុវត្ត ឬ ជាកាប្រើប្រាស់សិទ្ធិដូចដែលមាន រៀបរាប់ខាងលើ ។ រីឯ **សួយសារពីភាគកម្ម ក្នុងធនធានរ៉ែ** គឺសំដៅដល់រាល់អត្ថប្រយោជន៍ជាប្រាក់ ឬ ជាវត្ថុដែលទទួល បានទាក់ទិននឹងភាគកម្មនេះ ក្រៅតែពីប្រាក់ចំណេញបានមកពីអាជីវកម្មលើធនធាននេះ និងភាគលាភ ដែលត្រូវជាប់ពន្ធតាមបទប្បញ្ញត្តិដោយឡែក ។

ಣ**ថ្លៃឈ្នួល** សំដៅដល់សាច់ប្រាក់ ឬវត្ថុដែលទទួលបានពីការជួលចលនវត្ថុ (ដីធ្លី ផ្ទះ ឬ សំណង់ផ្សេងៗ) ឬ អចលនវត្ថុ ។ ប្រាក់ចំណូលដែលទទួលបានពីការជួល ត្រូវបានជាប់ពន្ធកាត់ទុកក្នុងអត្រា ១០% ។

**២.២. ការទូទាត់ពន្ធកាត់ទុកឲ្យដល់អ្នកជាប់ពន្ធអនិវាសនជន**

[26] ទំព័រ២ នៃសៀវភៅណែនាំស្តីពីពន្ធកាត់ទុកលើនិវាសនជន និង អនិវាសនជន របស់អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច ឆ្នាំ២០១៣

[27] មាត្រា ២៥(ថ្មី) នៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

អ្នកជាប់ពន្ធនិវាសនជន ឬ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែលបាន ទូទាត់ប្រាក់ចំណូលប្រភពកម្ពុជាអោយទៅអនិវាសជន ដែលលើកលែងតែសេវាធានារ៉ាប់រងបន្ត ចំពោះហានិភ័យនៅក្នុងកម្ពុជា ត្រូវជាប់ពន្ធកាត់ទុកក្នុងអត្រា ១៤% ។

- ☞ ការទូទាត់របស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែលត្រូវធ្វើការកាត់ទុកក្នុងអត្រា១៤% មានដូចជា ៖[28]
  - សួយសារ ថ្លៃឈ្នួល និង ប្រាក់ចំណូលផ្សេងៗទាក់ទិននឹងការប្រើប្រាស់ ទ្រព្យសម្បត្តិ
  - ការទូទាត់ចំពោះសេវាគ្រប់គ្រង និងសេវាបច្ចេកទេសនានា
  - ភាគលាភ។

### ៣. ការលើកលែងពន្ធកាត់ទុក

ដោយមានការកំណែទម្រង់បទដ្ឋានគតិយុត្ត ដែលគ្រប់គ្រង លើការប្រមូលពន្ធនៅក្នុងដែនដីព្រះរាជាណាចក្រកម្ពុជា សកម្មភាពអាជីវកម្មមួយចំនួនត្រូវបានលើកលែងពន្ធកាត់ទុក តាមរយៈប្រកាសស្តីពីពន្ធលើប្រាក់ចំណេញនៃក្រសួងសេដ្ឋកិច្ច ដែលចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣។ ដោយអនុលោម តាមប្រកាសនេះយើងអាចធ្វើការកំណត់បានថា ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវបានទទួលការលើកលែង កាតព្វកិច្ចក្នុងការបង់ និងការប្រមូលពន្ធកាត់ទុក ចំពោះការទូទាត់ទៅលើសកម្មភាពអាជីវកម្មមួយចំនួន ដូចខាងក្រោម[29] ៖

- ➢ ការប្រាក់ដែលបង់ទៅឲ្យធានាគារ និង ស្ថាប័នសញ្ជ័យធនក្នុងស្រុក និងការទូទាត់ចំពោះប្រាក់ចំណូលលើកលែងពន្ធដូច មានចែងក្នុងមាត្រា៩(ថ្មី) នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ ។
- ➢ ការបើក ឬ ការទូទាត់ទៅឲ្យរាជរដ្ឋាភិបាល ឬ ស្ថាប័ននៃរាជរដ្ឋាភិបាលនូវសួយសារ ឬ ប្រាក់ថ្លៃឈ្នួលលើចលនទ្រព្យ ឬ អចលនទ្រព្យ (ក្នុងនេះមានរួមបញ្ចូលផងដែរនូវប្រាក់បងលើ ឡូន៍នេសាទ ព្រៃគុប កំពង់ដរ ភាស៊ីផ្សារ...) ដែលបានបំពេញបាននូវល័ក្ខខ័ណ្ឌទាំងពីរដូចតទៅ ៖

[28] មាត្រា ២៦(ថ្មី) នៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

[29] ផ្នែកទី ៨.៤ នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ ឆ្នាំ២០០៣

- ការបើកឬការទូទាត់នេះត្រូវទាក់ទិននឹងចលនទ្រព្យ ឬ អចលនទ្រព្យបានកត់ត្រាជាទ្រព្យសម្បត្តិរដ្ឋ នៅក្នុងបញ្ជីសារពើភ័ណ្ឌដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគ្រប់គ្រង
- ប្រាក់បើកឬទូទាត់ត្រូវមានការបញ្ជាក់ពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ថាជាចំណូលបង់ចូលថវិការរដ្ឋ

➢ ការបើក ឬ ទូទាត់នូវប្រាក់ចំណូលដែលជាប់បន្ទុលើប្រាក់បៀវត្ស ឬ ពន្ធលើអត្ថប្រយោជន៍បន្ថែម (ដូចមានចែងក្នុងប្រកាសស្តីពីពន្ធលើប្រាក់បៀវត្ស លេខ ៣៩៦ ប្រក.សហវ.ពដ ចុះថ្ងៃទី២៧ មិថុនា ឆ្នាំ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)

២. ពន្ធកាត់ទុកមិនត្រូវអនុវត្តទេ ចំពោះប្រាក់ចំណូលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ ឬសេវាប្រហាក់ប្រហែល របស់សហគ្រាសនីតិបុគ្គលដែលបានចុះបញ្ជីជាសហគ្រាសជាប់ពន្ធតាមរបបពិត។ ទឹកប្រាក់ទាំងនោះ ត្រូវបានកត់ត្រាក្នុងវិក្កយបត្រដែលចេញដោយអ្នកទទួលប្រាក់ និង ដែលបានសរសេរបំពេញគ្រប់និទ្ទេសបានត្រឹមត្រូវ និងច្បាស់លាស់។

**៤. ការគណនាប្រាក់ពន្ធកាត់ទុក**

ដើម្បីធ្វើការគណនាទៅលើប្រាក់ពន្ធកាត់ទុក គឺត្រូវយកមូលដ្ឋានគិតពន្ធទៅគុណ នឹងអត្រាពន្ធដែលអនុវត្ត ។

- **មូលដ្ឋានគិតពន្ធ** ពន្ធកាត់ទុក ត្រូវបានគណនាទៅលើចំនួនទឹកប្រាក់ដុល ដែលត្រូវទូទាត់ទៅឲ្យបុគ្គលណាមួយ។ រីឯចំពោះចំពោះការបើក ឬទូទាត់ប្រាក់ឲ្យបុគ្គលអនិវាសនជនដែលមានទាក់ទិនដល់ការផ្គត់ផ្គង់សំភារៈបរិក្ខារផង និងសេវាផង ដូចជានៅក្នុងការទូទាត់ចំណាយទិញម៉ាស៊ីន ពីក្រៅប្រទេសដែលរួមមានថ្លៃទិញម៉ាស៊ីន និងថ្លៃសេវាផ្គុំដំឡើងដោយអ្នកបច្ចេកទេសជាបុគ្គលអនិវាសនជន ផ្តល់ដោយអ្នកលក់ (សំរាប់ដំណើរការដំបូងនៃម៉ាស៊ីន) មូលដ្ឋានសំរាប់គិតពន្ធកាត់ទិក គឺជាចំណែកប្រាក់ដែល ទាក់ទិននឹងសេវាផ្គុំដំលើងនេះតែប៉ុណ្ណោះ។[30]

- **អត្រាប្រាក់ពន្ធ**

[30] ផ្នែកទី ៨.៥ នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណោញ ឆ្នាំ២០០៣

| អត្រាពន្ធ | ប្រភេទនៃការទូទាត់ |
|---|---|
| ១០% | • ចំណូលពីការជួលចលនទ្រព្យ ឬអចលនទ្រព្យ |
| ១៤% | • ការទូទាត់ឲ្យទៅអនិវាសនជន |
| ១៥% | • ការទូទាត់ឲ្យទៅថ្លៃសេវា និងសួយសារ |

**ខ. ប្រាក់ពន្ធរំដោះពន្ធលើប្រាក់ចំនេញ**

សម្រាប់ប្រាក់ចំណូលដែលរកបាន ចំពោះក្រុមហ៊ុនឯកជនទទួលខុសត្រូវមាន កម្រិតក្រៅពីមានការតព្វកិច្ច ក្នុងការបងពន្ធលើប្រាក់ចំណូលជាប្រចាំឆ្នាំហើយនោះ នីតិបុគ្គលនេះក៏នៅមានការតព្វកិច្ចជាប្រចាំខែ ចំពោះប្រាក់ចំណូលដែលខ្លួនទទួលបានដោយ ត្រូវធ្វើការបង់នូវ ប្រាក់រំដោះពន្ធលើប្រាក់ចំណេញជារៀងរាល់ខែដោយយ៉ាងយឺតបំផុត ត្រឹម ថ្ងៃទី ២០ នៃខែបន្ទាប់ ។ ស្របគ្នានេះដែលដោយអនុវត្តតាមគោលការណ៍ច្បាប់នៃ ព្រះរាជាណាចក្រកម្ពុជា សហគ្រាសដែលជាប់ពន្ធលើប្រាក់ចំណេញតាមរបបពិត រួមទាំង គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលជាប់ពន្ធលើប្រាក់ចំណេញតាម អត្រា ៩% មានកាតព្វកិច្ច បង់ប្រាក់រំដោះប្រចាំខែសម្រាប់ពន្ធលើប្រាក់-ចំណេញតាមអត្រា ១% នៃផលរបរគិត រួមបញ្ចូលទាំងពន្ធអាករទាំងអស់វៀលែងតែអាករលើតម្លៃ-បន្ថែមដែលសម្រេចបានក្នុងខែមុន ។ ប្រាក់រំដោះនឹងត្រូវបានយកមកកាត់ កងពីពន្ធលើប្រាក់ ចំណេញនៅពេលធ្វើការទូទាត់ ប្រចាំឆ្នាំ។[31]

ឧទាហរណ៍: ក្រុមហ៊ុន សបគគ បានលក់ទំនិញឲ្យអតិថិជនដែលមានចំណូល រួមអាករ ១០០ ដុល្លា ។ ចូលគណនារកប្រាក់រំដោះពន្ធលើប្រាក់ចំណេញ។

[31] មាត្រា ២៨(ថ្មី) នៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

ដំណោះស្រាយ

ដំបូងអ្នកត្រូវគណនារកចំណូលមិនរួមអាករជាមុនសិន

ចំណូលមិនរួមអាករ = ចំណូលរួមអាករ ៖ (1+10%)

= 100 / 1.1

= 90.91ដុល្លា

យើងបាន

ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ = ចំណូលមិនរួមអាករ * អត្រាប្រាក់រំពន្ធ (អត្រា= 1%)

= 90.91 * 0.01

ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ = 9.09 ដុល្លា

**គ. ពន្ធលើប្រាក់បៀវត្ស**

រាល់ប្រាក់ចំណូល ឬ កម្រៃដែលនិយោជិតទទួលបានជាតម្លៃតបស្នងពីការប្រកបការងារក្នុងស្ថាប័នមួយត្រូវមានកាតព្វកិច្ចជាប់ពន្ធលើប្រាក់បៀវត្ស។ ដោយ**រូបវន្តបុគ្គលនិវាសនជន**[32] ត្រូវជាប់ពន្ធលើប្រាក់បៀវត្សប្រភពកម្ពុជា និងប្រាក់បៀវត្សប្រភពបរទេស ចំណែកឯ**រូបវន្តបុគ្គលអនិវាសនជន** (ជនបរទេស) ត្រូវជាប់ពន្ធលើប្រាក់បៀវត្សប្រភពកម្ពុជា។[33]

**ប្រាក់បៀវត្ស** គឺត្រូវបានសំដៅដល់បៀវត្ស លាភការ ប្រាក់បំណាច់ បុព្វលាភ ប្រាក់ម៉ោងបន្ថែម និងប្រាក់ប៉ះប៉ូវនានា ដែលទូទាត់ឲ្យដល់និយោជិក ឬដែលបានទូទាត់ដើម្បីជាប្រយោជន៍ផ្ទាល់ ឬដោយប្រយោល ដល់និយោជិកចំពោះការបំពេញសកម្មភាពការងារ។[34]

**១. កម្មវត្ថុនៃការប្រមូលពន្ធលើប្រាក់បៀវត្ស**

---

[32] (និវាសនជន) តាមរយៈចំណុច ១ នៃមាត្រា ៤២(ថ្មី) នៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ពីសារពើពន្ធពាក្យនិវាសនជន ក្នុងករណីដែលប្រើចំពោះនិយោជិតអ្នកជាប់ពន្ធ ឬ រូបវន្តបុគ្គល មានន័យថាដែលមាននិវាសនដ្ឋាន ឬមានកន្លែងស្នាក់នៅជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ដែលមានវត្តមាននៅក្នុង ព្រះរាជាណាចក្រកម្ពុជាលើសពី ១៨២ ថ្ងៃនៅក្នុងរយៈពេល ១២ ខែណាមួយដែលបានបញ្ចប់ក្នុងឆ្នាំសារពើពន្ធចរន្ត ។

[33] មាត្រា ៤១ នៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

[34] មាត្រា ៤២(ថ្មី) នៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

**ពន្ធលើប្រាក់បៀវត្ស ៖** ពន្ធលើប្រាក់បៀវត្ស គឺជាពន្ធប្រចាំខែដោយកំណត់លើប្រាក់បៀវត្ស ដែលបានទទួលក្នុងក្របខណ្ឌ នៃការបំពេញសកម្មភាព បម្រើការងារ។ ប្រាក់ចំណូលបៀវត្សទាំងអស់ ដែលបានទទួលសពីសកម្មភាពការងារនានា ត្រូវជាប់ពន្ធលើប្រាក់បៀវត្ស។ ប្រាក់ពន្ធលើប្រាក់បៀវត្ស នេះ ត្រូវបានប្រមូលតាមរបៀបកាត់ទុកដោយនិយោជក[35] ជារៀងរាល់ខែនៅពេលបើកប្រាក់បៀវត្ស ។[36] ក្នុងនេះដែលប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ របស់និយោជិតនិវាសនជន មិនត្រឹមតែគិតពីប្រាក់បៀវត្សដែលបានទទួលពីប្រភពកម្ពុជានោះទេ ព្រមទាំងប្រាក់បៀវត្សដែលបានទទួលពីប្រភពបរទេសផងដែរ ប៉ុន្តែក៏ត្រូវបូកបញ្ចូលបន្ថែមនូវប្រាក់បុរេប្រទាន ប្រាក់ឲ្យខ្ចី ឬ ប្រាក់រំដោះដែលនិយោជកបានបើកឲ្យនិយោជិត។ ប្រាក់បុរេប្រទាន ប្រាក់ឲ្យខ្ចី ឬប្រាក់រំដោះត្រូវបូកបន្ថែមលើបៀវត្សជាប់ពន្ធនៃខែដែល ប្រាក់ទាំងនោះបានបើក ហើយត្រូវកាត់បន្ថយពីប្រាក់បៀវត្សក្នុងខែ ដែលនិយោជិតបានបង់សងវិញ ។[37]

ចំពោះស្ថានភាពបម្រើការងារ និយោជិត គឺត្រូវបានសំដៅដល់រូបវន្តបុគ្គល ដែលទទួលប្រាក់បៀវត្សអំពីសកម្មភាពបំរើការងាររបស់ខ្លួន រួមបញ្ចូលទាំងអ្នកទទួលខុសត្រូវ ឬប្រធានក្រុមប្រឹក្សាភិបាល អភិបាលរបស់សហគ្រាស។[38] ប្រសិនបើធៀបទៅនឹងសកម្មភាព វិជ្ជាជីវៈ ឬ សកម្មភាពនានាឯទៀត សកម្មភាពបំរើការងារមានលក្ខណៈ សំគាល់តាមស្ថានភាព ដែលនិយោជិកបំពេញសកម្មភាពបំរើការងាររបស់ខ្លួននៅក្រោមឱវាទ របស់និយោជក ។ ត្រូវបានចាត់ទុក ថាជានិយោជិត ហើយត្រូវជាប់ពបវ[39] បើសិនជារូបវន្តបុគ្គលណាម្នាក់នោះ មានស្ថានភាពបំរើការងារ ស្របតាមល័ក្ខខ័ណ្ឌចំនួនពីរក្នុងចំណោមលក្ខណ្ឌទាំងឡាយខាងក្រោមនេះ ៖[40]

ក. គ្មានហានិភ័យនៃការមិនទទួលប្រាក់ទូទាត់ ចំពោះសកម្មភាពបំរើការងាររបស់ខ្លួន ឡើយ កាលបើរូបវន្តបុគ្គលនោះ បានមកធ្វើការតាមទីកន្លែង ដែលបានកំណត់ ហើយនឹងបានបំពេញការងារដូចមានចែងក្នុងកិច្ចព្រមព្រៀងបំរើការងារជាទូទៅមួយទោះធ្វើ ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរក្ដី

[35] ( និយោជក) តាមរយៈចំណុច៤ នៃមាត្រា ៤២(ថ្មី) នៃច្បាប់ស្តីពីសារពើពន្ធ និង ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសារពើពន្ធ ពាក្យនិយោជក គឺរួមមាន ស្ថាប័នរដ្ឋ នីតិបុគ្គលនិវាសនជន ក្រុមអាជីវកម្មនីវាសនជន គ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុង ព្រះរាជាណាចក្រកម្ពុជា អង្គការមិនស្វែងរកប្រាក់ចំណេញ ឬរូបវន្តបុគ្គលនិវាសនជនដែលប្រកបអាជីវកម្ម ។

[36] មាត្រា ២៦(ថ្មី) នៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

[37] មាត្រា ៤៦ នៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

[38] មាត្រា ៤២(ថ្មី) នៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

[39] ពបវ គឺសំដៅដល់ពាក្យពន្ធលើប្រាក់បៀវត្ស

[40] ផ្នែកទី ១.២ នៃប្រកាសស្តីពីពន្ធលើប្រាក់បៀវត្ស

ខ. រូបវន្តបុគ្គលមិនអាចកំណត់ពេលវេលា និង ទីកន្លែងសម្រាប់បំពេញសកម្មភាពបំរើការ-ងារដោយខ្លួនឯងទេ

គ. រូបវន្តបុគ្គលពុំបាច់ចំណាយដើមទុនច្រើន ដើម្បីទិញឧបករណ៍ដែលត្រូវប្រើប្រាស់សម្រាប់បំពេញសកម្មភាពបំរើការងារឡើយ

ឃ. រូបវន្តបុគ្គលមិនបំពេញសកម្មភាពបំរើការងារ ឲ្យបុគ្គលច្រើនអ្នក ក្នុងពេលតែមួយទេ។

## ២. ការកំណត់ពន្ធលើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ

ក្នុងការដំណើរការអាជីវកម្មរបស់ខ្លួន ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតមានតួនាទីក្នុងការកាត់ទុកប្រាក់ពន្ធពីប្រាក់បៀវត្សរបស់បុគ្គលិក រាល់មុនពេលដែលបើកប្រាក់បៀវត្ស ជារៀងរាល់ខែ។ ពន្ធលើប្រាក់បៀវត្ស ដែលប្រមូលបានពីប្រាក់ចំណូលបៀវត្សទាំងអស់ នឹងដែលបានទទួលពីសកម្មភាពបំរើការងារនានា គឺត្រូវកំណត់ថាជាពន្ធប្រចាំខែ។ ប៉ុន្តែប្រសិនបើក្នុងករណីដែលនិយោជកនៃក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ស្នាក់នៅបរទេស គឺតម្រូវឲ្យមានអ្នកតំណាងសារពើពន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលនិយោជកនោះបានចាត់តាំង។ អ្នកចាត់តាំងនោះ គឺជាអ្នកទទួលភារៈកាត់ទុកពន្ធលើប្រាក់បៀវត្សមុនពេលបើកប្រាក់បៀវត្ស ទៅឲ្យនិយោជិត និង បង់ប្រាក់ពន្ធទាំងនោះជូនរដ្ឋ។ និយោជក ឬ តំណាងនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់និយោជកបរទេសហើយនិង និយោជិត ត្រូវទទួលខុសត្រូវរួមគ្នាក្នុងការបង់ ពន្ធលើប្រាក់បៀវត្សក្នុងព្រះរាជាណាចក្រ-កម្ពុជា ដោយពុំកំណត់ថាប្រាក់បៀវត្សបានបើក ឲ្យនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬបរទេសឡើយ។ ក្នុងករណីមិនបានកាត់ទុកប្រាក់ពន្ធលើប្រាក់បៀវត្ស និយោជកត្រូវទទួលខុសត្រូវចំពោះ ច្បាប់ទោះបីប្រាក់ពន្ធត្រូវបានបង់ ដោយនិយោជិតរួចហើយក្តី ។[41] ជារៀងរាល់ខែបន្ទាប់ពី បានកាត់ទុកប្រាក់ពន្ធពីប្រាក់បៀវត្សរបស់បុគ្គលិកនិយោជក ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាស (ពបវ) យ៉ាងយឺតយ៉ាវបំផុតត្រឹមថ្ងៃទី ២០ នៃខែបន្ទាប់ពីខែដែលបានប្រតិបត្តិការទាក់ទិនបានកើតឡើង។[42]

## ២.១ ការគណនាពន្ធលើប្រាក់បៀវត្ស

វៀរលែងតែអត្ថប្រយោជន៍បន្ថែមដែលត្រូវកំណត់ពន្ធតាមអត្រា ២០% មូលដ្ឋានគិតពន្ធ ប្រចាំខែរបស់និវាសនជន គឺ ជាប្រាក់បៀវត្សជាប់ពន្ធ ដោយផាត់ចេញនូវ ៖[43]

- ប្រាក់កាត់ទុក ដែលជាកាតព្វកិច្ចក្នុងការប្រតិបត្តិតាមច្បាប់ការងារ ដើម្បីបង្កើតប្រាក់បេឡាសោធននិវត្តន៍ និងធានាសុខុមាលភាពសង្គម ។

[41] មាត្រា ៥២ នៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

[42] ប្រការ ៤ នៃប្រកាសស្តីពីការកែសម្រួលការបរិច្ឆេទដាក់លិខិតប្រកាសពន្ធប្រចាំខែ

[43] មាត្រា ៩៥ នៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

➢ ការទូទាត់នានាដែលត្រូវបានលើកលែងពន្ធជាដើម។

ក្នុងការកំណត់ប្រាក់ពន្ធប្រចាំខែ ដែលត្រូវកាត់ទុក និយោជកត្រូវប្រើអត្រាកំណើនតាមថ្នាក់(...)។[44] ហេតុដូចនេះដើម្បីអាចធ្វើការគណនាពន្ធលើប្រាក់បៀវត្សជាប់ពន្ធរបស់ និយោជិតនិវាសនជន ត្រូវរកមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សដោយយកចំនួនប្រាក់វត្សជាប់ពន្ធសរុប ដកចេញនូវទាយជ្ជទានសម្រាប់សហព័ទ្ធនិងកូនស្ថិនក្នុងបន្ទុក[45] ។ ដោយឡែក ចំពោះកម្មករនិយោជិត រោងចក្រ សហគ្រាស ប្រាក់បៀវត្សជាប់ពន្ធ ត្រូវបានអនុញ្ញាតឲ្យ ដកចេញបន្ថែមទៀតនូវប្រាក់ឧបត្ថមដែលទទួលបានពីការបំពេញការងារ ដូចមានចែងក្នុងសារាចរលេខ ០១១ សហវ ចុះថ្ងៃទី ០៦ ខេតុលា ឆ្នាំ ២០១៦ ស្តីពីការអនុវត្តកាតព្វកិច្ចកាត់ទុកលើប្រាក់ពន្ធលើអត្ថប្រយោជន៍បន្ថែម។

បន្ទាប់មក ត្រូវពិនិត្យមើលថា តើមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សស្ថិតក្នុងថ្នាក់អត្រាពន្ធណា? ទើបយកមូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សនោះ ទៅគុណនឹងអត្រា ហើយដកចេញនូវលម្អៀងលើប្រាក់ពន្ធ[46] សម្រាប់ថ្នាក់អាត្រាពន្ធនោះ។ [47]

*តារាងអត្រាកំណើនតាមថ្នាក់ និង លម្អៀងលើប្រាក់ពន្ធតាមថ្នាក់នីមួយៗសម្រាប់ និយោជិតនិវាសនជន ៖*

| **ភាគបៀវត្សជាប់ពន្ធប្រចាំខែ** | **អត្រា** | **លម្អៀងលើសប្រាក់ពន្ធ តាមថ្នាក់ នីមួយៗ** |
|---|---|---|
| ពី 0៛ ដល់ ១ ២00 000៛ | 0% | 0៛ |
| ពី ១ ២00 00១៛ ដល់ ២ 000 000៛ | ៥% | ៦0 000៛ |
| ពី ២ 000 00១៛ ដល់ ៨ ៥00 000៛ | ១0% | ១៦0 000៛ |
| ពី ៨ ៥00 00១៛ ដល់ ១២ ៥00 000៛ | ១៥% | ៥៨៥ 000៛ |
| លើសពី ១២ ៥00 000៛ | ២0% | ១ ២១0 000៛ |

ចំពោះអ្នកជាប់ពន្ធអនិវាសនជនវិញ ប្រាក់ពន្ធត្រូវកាត់ទុកដោយអ្នកបើកប្រាក់ឲ្យ តាមអត្រា ២០% លើរាល់ការទូទាត់ប្រាក់បៀវត្សប្រភពកម្ពុជា ។[48]

[44] ផ្នែកទី ២.៣ នៃប្រកាសស្តីពីពន្ធលើប្រាក់បៀវត្ស

[45] (ទាយជ្ជទានសម្រាប់សហព័ទ្ធនិងកូនក្នុងបន្ទុក) គឺ = ១៥០ ០០០៛ x សហព័ទ្ធនិងកូនក្នុងបន្ទុក

[46] (លម្អៀងលើសប្រាក់ពន្ធ) តាមថ្នាក់នីមួយៗគឺ ជាផលបូកនៃពន្ធលើសប្រាក់បៀវត្សដែលបានលើកលែងចំពោះប្រាក់បៀវត្ស ១ ២០០ ០០០ រៀល ដំបូង និង លម្អៀងលើសនៃប្រាក់ពន្ធតាមថ្នាក់នីមួយៗ ។

[47] ចំណុច ៣ នៃសេចក្តីណែនាំ ស្តីពីការអនុវត្តអាត្រាពន្ធលើប្រាក់បៀវត្សថ្មី

[48] មាត្រា ៤៩(ថ្មី) នៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

## ២.២ ការកំណត់ប្រាក់ពន្ធលើអត្ថប្រយោជន៍បន្ថែម

ចំពោះអត្ថប្រយោជន៍បន្ថែម ជារៀងរាល់ខែ និយោជកត្រូវកាត់ទុក និង បង់ប្រាក់ពន្ធ ទៅតាមកាលកំណត់ និងតាមអត្រា ២០% នៃតម្លៃសរុបរបស់អត្ថប្រយោជបន្ថែម ដែលបានផ្តល់ឲ្យនិយោជិតទាំងអស់។ តម្លៃនៃអត្ថប្រយោជន៍បន្ថែម គឺជាតម្លៃទីផ្សារ រួមទាំងពន្ធអាករទាំងអស់។[49] ដូចដែលមានចែងក្នុង កថាខណ្ឌ ៨ នៃមាត្រា ៤២(ថ្មី) នៃច្បាប់ស្តីពីសារពើពន្ធ អត្ថប្រយោជន៍បន្ថែមរួមមានទំនិញ សេវា ឬអត្ថប្រយោជន៍ជាសាច់ប្រាក់ ឬជាវត្ថុផ្សេងទៀត ដែលនិយោជកផ្តល់ឲ្យដោយផ្ទាល់ ឬ ដោយប្រយោលដល់រូបវន្តបុគ្គលចំពោះសកម្មភាពបំរើការងារ ដែលរូបវន្តបុគ្គលនោះ បានបំពេញដើម្បីជាប្រយោជន៍ដល់និយោជក ។[50]

អត្ថប្រយោជន៍ដែលនិយោជកផ្តល់ឲ្យដោយផ្ទាល់ ឬ តាមរយៈតតិយជនដល់រូបវន្តបុគ្គលត្រូវជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែម ដែលអត្ថប្រយោជន៍ទាំងនោះ មានដូចជា ៖

- យានជំនិះគ្រប់ប្រភេទ
- ម្ហូបអាហារ
- លំនៅដ្ឋាន ការស្នាក់នៅ
- ទឹក ភ្លើង ទូរស័ព្ទ
- អ្នកបម្រើការងារក្នុងលំនៅដ្ឋាន
- ប្រាក់ឲ្យខ្ចីដោយគិតការប្រាក់ទាបជាងទីផ្សារ (អត្រាការប្រាក់ទីផ្សារ ដែលត្រូវយកមកអនុវត្តត្រូវ កំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)
- ការលក់ទំនិញចុះថ្លៃ
- ជំនួយផ្នែកអប់រំសម្រាប់និយោជិតដែលមិនមែនជាចំណែកណាមួយ នៃកម្មវិធីបណ្តុះបណ្តាលទាក់ទិនដោយផ្ទាល់ទៅនឹងការបំពេញការងាររបស់និយោជិតនោះ
- ជំនួយផ្នែកអប់រំសម្រាប់កូនរបស់និយោជិត
- បុព្វលាភធានារ៉ាប់រងអាយុជីវិត ឬសុខភាព លើកលែងតែមានផ្តល់អត្ថប្រយោជន៍បន្ថែមដូចគ្នាឲ្យដល់និយោជិតគ្រប់គ្នាដោយគ្មានការបែងចែកតាមតួនាទី ឬ មុខងារ
- ចំណែកនៃការឧបត្ថម្ភលើចំណាយដែលមិនសមហេតុផល និងមិនចាំបាច់សម្រាប់អាជីវកម្មរបស់និយោជក
- ចំនួនប្រាក់ដែលបង់ចូលក្នុងមូលនិធិសុខុមាលភាពសង្គម ដែលលើសពីកំរិត ដែលច្បាប់បានអនុញ្ញាត

[49] មាត្រា ៤៨ នៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

[50] ផ្នែកទី ៣.១ នៃប្រកាសស្តីពីពន្ធលើប្រាក់បៀវត្ស

- ចំនួនប្រាក់បង់ចូលបេឡាសោធន ដែលលើសពី ១០% នៃប្រាក់បៀវត្សប្រចាំខែ ដោយគ្មានប្ដូកអត្ថប្រយោជន៍បន្ថែមរបស់និយោជិត
- ចំណាយសម្រាប់ការទទួលភ្ញៀវ ការកំសាន្ត ការសំរាកលំហែល ឬការប្រើប្រាស់មធ្យោបាយណាមួយដែលទាក់ទិននឹងសកម្មភាពទាំងនេះ ដែលមិនមែនជាចំណែកណាមួយនៃទំនាក់ទំនងបម្រើការងារ។

៦ សំគាល់ ៖ ការប្រើប្រាស់យានយន្តក្នុងការដឹកនិយោជិត មិនត្រូវជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែមទេ ប្រសិនជា៖[51]

- ➢ យានយន្តត្រូវបានចតទុកនៅក្នុងទីកន្លែងធ្វើអាជីវកម្ម នៅក្រោយពេលម៉ោងធ្វើការ និងនៅក្នុងថ្ងៃឈប់សម្រាកការងារ។
- ➢ យានយន្តមិនត្រូវបានប្រគល់យ៉ាងជាក់លាក់ទៅឲ្យនិយោជិតណាម្នាក់ ឬសមាជិកគ្រួសាររបស់និយោជិតណាម្នាក់នៅក្រោយពេលម៉ោងធ្វើការ។

## ២.៣ ការលើកលែងពន្ធលើប្រាក់បៀវត្ស

ដើម្បីលើកកម្ពស់ជីវភាពរស់នៅ និង ការប្រកបការងារប្រចាំថ្ងៃរបស់កម្មករនិយោជិតនៃរោងចក្រ សហគ្រាសទាំងអស់ ប្រាក់ឧបត្ថម្ភមួយចំនួនដែលកម្មករនិយោជិតទទួលបាន ពីការបំពេញការងារ ត្រូវបានអនុគ្រោះដោយមិនគិតបញ្ចូលទៅក្នុងមូលដ្ឋានគិតពន្ធលើ ប្រាក់បៀវត្ស និងមិនមែនជាកម្មវត្ថុនៃពន្ធលើអត្ថប្រយោជន៍បន្ថែមទេ។ ហើយដើម្បីអាច ទទួលបានការអនុគ្រោះទាំងនោះ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវដាក់ជូនអង្គនាយកដ្ឋានពន្ធដារនូវឯកសារ ដែលជាគោលនយោបាយឧបត្ថម្ភដល់កម្មករនិយោជិត របស់ខ្លួនសម្រាប់រយៈពេលកំណត់នីមួយៗ។

ប្រាក់ឧបត្ថម្ភ ទាំងនោះមានដូចជា៖[52]

- សៅហ៊ុយធ្វើដំណើរ ពីទីកន្លែងស្នាក់នៅទៅទីកន្លែងធ្វើការ និងពីទីកន្លែងធ្វើការ ទៅកន្លែងស្នាក់នៅ ព្រមទាំងការឧបត្ថម្ភថ្លៃស្នាក់នៅ ឬការផ្ដល់កន្លែងស្នាក់នៅក្នុង បរិវេណទីកន្លែងធ្វើការស្រប់តាមបញ្ញត្តិនៃច្បាប់ស្ដីពីការងារ ។
- ប្រាក់ថ្លៃបាយដែលផ្ដល់ឲ្យកម្មករនិយោជិតទាំងអស់ដោយគ្មានបែងចែកតាមតួនាទី ឬមុខងារ ។
- មូលនិធិបេឡាសន្តិសុខសង្គម ឬ មូលនិធិសុខមាភាពសង្គមក្នុងកម្រិតដែលបានចែងក្នុងច្បាប់ ។

[51] ផ្នែកទី ៣.២ នៃប្រកាសស្ដីពីពន្ធលើប្រាក់បៀវត្ស ចុះថ្ងៃទី៣១ ខែធ្នូ ២០០៣

[52] សារាចរលេខ ០១១ សហវ ស្ដីពីការអនុវត្តកាតព្វកិច្ច កាត់ទុកលើប្រាក់ពន្ធលើអត្ថប្រាយោជន៍បន្ថែមចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ ២០១៦

- ប្រាក់ធានារ៉ាប់រងសុខភាព ឬ បុព្វលាភធានារ៉ាប់រងអាយុជីវិត ឬ សុខុមាលភាពដែលផ្តល់ឲ្យដល់កម្មករនិយោជិតគ្រប់គ្នាដោយគ្មានបែងចែកតាមតួនាទី ឬមុខងារ ។
- ប្រាក់ឧបត្ថម្ភទារក ឬ ចំណាយទារកដ្ឋាន ដែលមានចែងក្នុងបទបញ្ញត្តិនៃច្បាប់ការងារ ។
- ប្រាក់បំណាច់បញ្ចប់កិច្ចសន្យា ឬ ប្រាក់បំណាច់នៃការបញ្ឈប់លែងឲ្យធ្វើការក្នុង កម្រិតដែលបានបញ្ញាត្តិក្នុងច្បាប់ការងារ ។

៦ <u>ប្រាក់បៀវត្សលើកលែងពន្ធរបស់និយោជិត</u>

និយោជកនៃក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត នឹងមិនមានកាតព្វកិច្ចកាត់ទុកប្រាក់ពន្ធឡើយ ប្រសិនបើប្រាក់ចំណូលរបស់និយោជិតទាំងនោះបានកើតមានឡើង ក្នុងករណីដូចខាងក្រោម ៖[53]

១. ប្រាក់សំណងដោយពិតប្រាកដនូវចំណាយខាងវិជ្ជាជីវៈ ដែលបានចាយដោយនិយោជិតតាមសេចក្តីបង្គាប់ និងសម្រាប់ជាប្រយោជន៍នៃនិយោជក ហើយដែលបានបំពេញបានលក្ខខណ្ឌ ៣ ដូចតទៅ ៖
   - បានចាយក្នុងផលប្រយោជន៍ផ្ទាល់ និង ដាច់ខាតរបស់សហគ្រាស
   - មិនបានបង្ហាញលក្ខណៈហួសប្រមាណ ឬស្តុកស្តម្ភហួសហេតុ
   - បានបង្ហាញជាភស្តុតាងដោយវិក្កយបត្ររាយលំអិត និងបានទូទាត់ ស្រេចបាច់ហើយដែលបានធ្វើ ក្នុងនាមអ្នកបានទទួលប្រាក់សំណងនូវ ចំណាយពិតប្រាកដ។

២. ប្រាក់បំណាច់នៃការបញ្ឈប់លែងអោយធ្វើការ ក្នុងកំរិតដែលបានបញ្ញត្តិក្នុងច្បាប់ការងារ។

៣. លាភការបន្ថែមមានលក្ខណៈខាងសង្គមកិច្ចក្នុងករណីដែលបានបញ្ញត្តិក្នុងច្បាប់ការងារ។

៤. ការផ្គត់ផ្គង់ឲ្យដោយឥតយកថ្លៃ ឬយកថ្លៃទាបជាងថ្លៃដើមនូវឯកសណ្ឋាន ឬជាសំភារៈបរិក្ខារ សម្រាប់វិជ្ជាជីវៈពិសេស ។

៥. ប្រាក់បំណាច់មៅការសម្រាប់ចំណាយបេសកកម្ម និងការធ្វើដំណើរ ។ ប្រាក់បំណាច់នេះមិនត្រូវបានយកត្រួតគ្នាជាមួយប្រាក់សំណង ពិតប្រាកដនូវចំណាយ ដូចមានចែងក្នុងមាត្រានេះឡើយ ។

## កថាខណ្ឌទី ០២ ៖ លិខិតប្រកាសពន្ធប្រចាំឆ្នាំ

### ក. ពន្ធលើប្រាក់ចំណូល

ពន្ធលើប្រាក់ចំណូល គឺជាពន្ធប្រចាំឆ្នាំ ដែលពន្ធលើប្រាក់ចំណូលនេះ គឺជាបំណុលរបស់អ្នកជាប់ពន្ធចំពោះចំណូលប្រភពកម្ពុជា[54] និងប្រាក់ចំណូលប្រភពបរទេស[55]។ ក្រុមហ៊ុនឯកជនទទួលខុស

[53] មាត្រា ៥៤ នៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

ត្រូវមានកម្រិត ត្រូវមានកាតព្វកិច្ចក្នុងការបង់ពន្ធលើប្រាក់ចំណូល ចំពោះប្រាក់ចំណូលរបស់ខ្លួន។ ចំពោះពន្ធលើប្រាក់ចំណូល ក្នុងនាមជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ក្រុមហ៊ុនឯកជនទទួលខុស-ត្រូវមានកម្រិត ត្រូវធ្វើការគណនាចេញនូវលទ្ធផលនៃតុល្យការសម្រេចបាន ក្នុងឆ្នាំសារពើពន្ធកន្លងទៅ ។ ប្រសិនជាពុំមានតុល្យកាលណាមួយបានបញ្ឈប់ក្នុងកំឡុងនៃឆ្នាំណាមួយទេនោះ ពន្ធដែលត្រូវបង់សម្រាប់ឆ្នាំបន្ទាប់ គឺត្រូវគិតយកលើប្រាក់ចំណូលក្នុងរយៈពេល ដែលកន្លងទៅ ចាប់តាំងពីថ្ងៃផុតរយៈពេលជាប់ពន្ធដែលកន្លងហួសទៅនោះ។ ចំពោះក្រុមហ៊ុន ដែលទើបតែបង្កើតថ្មី ប្រាក់ចំណូលជាប់ពន្ធត្រូវគិតចាប់តាំងពីថ្ងៃដែលផ្ដើមធ្វើប្រតិបត្តិការមកទល់ នឹងថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដែលត្រូវគិតពន្ធ ។[56]

**១. ប្រាក់ចំណូលជាប់ពន្ធ**

ប្រាក់ចំណូលជាប់ពន្ធ គឺជាប្រាក់ចំណេញសុទ្ធបានមកពីលទ្ធផលទាំងអស់នៃប្រតិបត្តិការគ្រប់ប្រភេទដែលសហគ្រាស សម្រេចបាន រួមបញ្ចូលទាំងតម្លៃលើសបានមកពីការលក់ចំណែកនានានៃទ្រព្យសកម្មក្នុងពេលកំពុងប្រកបអាជីវកម្ម ឬ នៅពេលបញ្ចប់អាជីវកម្ម ព្រមទាំងប្រាក់ចំណូលអំពីកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ឬវិនិយោគ ការប្រាក់ ថ្លៃឈ្នួល និងសួយសារផង។[57] តាមនិយមន័យនេះ ការធ្វើអាជីវកម្ម អ្វីមួយដែលខុសច្បាប់ គ្មានឥទ្ធិពលអ្វីទៅលើភាពត្រូវជាប់ពន្ធលើប្រាក់ចំណូលនោះទេ ។[58]

ប្រាក់ចំណូលជាប់ពន្ធកើតចេញពីចំនន្ទួនលើសនៃផលដុល ឬ ចំណូលដុលដែលសំរេចបាន អាស្រ័យដោយមានការចំណាយ ដើម្បីនាំមកវិញ និងរក្សាទុកនូវចំណេញ ។[59] ដូច្នេះប្រាក់ចំណូលជាប់ពន្ធកើតចេញពីការកាត់កងគ្នារវាងចំណូលដុល និង បន្ទុកទាំងអស់ដែលមានប្រភពពីប្រតិបត្តិការគ្រប់ប្រភេទរបស់សហគ្រាសក្នុងរយៈកាលកំពុងដំណើរការ ឬ នៅពេលបញ្ចប់អាជីវកម្ម។

[54] ផ្នែកទី ១.៣ ប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០០៣

[55] ផ្នែកទី ១.៤ ប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០០៣

[56] មាត្រា ៥ នៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

[57] មាត្រា ៧ នៃច្បាប់ស្តីពីសារពើពន្ធចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

[58] ផ្នែកទី ២.២ ប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០០៣

[59] មាត្រា ៨ នៃនៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

តាមន័យគណនេយ្យ ប្រាក់ចំណេញនេះ គឺជាសមតុល្យនៃគណនីលទ្ធផល។ ប្រតិបត្តិការដែលសហគ្រាសសំរេចបាន អាចទាក់ទងដោយផ្ទាល់នឹងកម្មវត្ថុរបស់សហគ្រាស ឬ អាចមិនទាក់ទងដោយផ្ទាល់នឹងសកម្មភាពរបស់សហគ្រាស ។ ប្រតិបត្តិការនេះអាចប្រព្រឹត្តទៅក្នុងលក្ខណៈ ជាគោល ដើម ឬក្នុងលក្ខណៈបន្ទាប់បន្សំ ។ ប្រតិបត្តិការទាំង នេះមានជាអាទិ៍ ៖[60]

- ✓ ការលក់ ការផ្គត់ផ្គង់សេវា ការងារផ្សេងៗ ឬប្រតិបត្តិការដទៃទៀត (ជំនួញជើង សារ ការងារយកកំរៃជើងសារ សម្បទានសិទ្ធិនៃកម្មសិទ្ធិឧស្សាហាកម្ម ...)
- ✓ ការបញ្ចេញចំណែកណាមួយនៃទ្រព្យសកម្ម ។ ក្នុងន័យនេះការបញ្ចេញ គឺគ្រប់ប្រតិបត្តិការ ឬ គ្រប់ព្រឹត្តិការណ៍ដែលនាំដល់ការបញ្ចេញចំណែកណាមួយ នៃទ្រព្យសកម្មរបស់សហគ្រាស (ការលក់ ការដកហូតទ្រព្យសម្បត្តិតាមផ្លូវច្បាប់ ការដោះដូរ ការបែងចែកអំណោយ ការដក់ចេញនូវទ្រព្យសកម្ម ...) ។

ប្រាក់ចំណូលជាប់ពន្ធ គឺជាចំនួនលំអៀងរវាងតំលៃនៃទ្រព្យសកម្មសុទ្ធនាពេលបិទ និងពេលបើកនៃរយៈកាលកំណត់ពន្ធ ។ ដោយត្រូវដកចេញនូវឧបហារិតបន្ថែម និង បូកចូលនូវរាល់ការដកយកមកប្រើប្រាស់ផ្ទាល់ខ្លួន ឬ ការកាត់យកមុនដែលម្ចាស់សហគ្រាសបានធ្វើនៅក្នុងគ្រា ។

ចំពោះផលអាជីវកម្ម ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតក្នុងនាមជាភ្នាក់ងារជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវធ្វើការអនុវត្តតាមគោលការណ៍គណនេយ្យទូទៅ ដែលចំណូលត្រូវកត់បញ្ចូលនៅក្នុងការិយបរិច្ឆេទដែលខ្ទង់ចំណូលនោះបានកើនឡើង ទោះបីប្រាក់ចំណូលនោះបានទូទាត់ ឬមិនបានទូទាត់ក្តី ។ នៅពេលដែលនីតិបុគ្គលនេះបានធ្វើការផ្គត់ផ្គង់ទំនិញ ឬសេវា ក្រុមហ៊ុនត្រូវធ្វើការកត់ត្រាថា ជាចំណូលនពេលផ្គត់ផ្គង់ដែលបានដូចជា ៖[61]

- ពេលត្រូវចេញវិក្កយបត្រ ឬបានចេញវិក្កយបត្រ
- យកទៅប្រើប្រាសផ្ទាល់ខ្លួន
- ការផ្តល់ជាអំណោយ
- ការផ្គត់ផ្គង់ទំនិញ ឬសេវា

[60] ផ្នែកទី ២.២ កថាខណ្ឌ ២ ប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០០៣

[61] ផ្នែកទី ៤.១ ប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០០៣

ប្រាក់ចំណូលជាប់ពន្ធ របស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ក្រៅពីប្រាក់ចំណូលដែលទទួលបានពីកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុនហើយ ប្រាក់ចំណូលនៃនីតិបុគ្គលនេះគឺ រួមមានទាំងប្រាក់ចំណូលបន្ទាប់បន្សំ និងប្រាក់ចំណូលផ្សេងៗទៀត ។ **ចំណូលបន្ទាប់បន្សំ** គឺជាចំណូលទាំងឡាយដែលមិនផ្សារភ្ជាប់ទៅនឹងសកម្មភាពជាគោលដើម របស់សហគ្រាស និង ដែលត្រូវគិតបញ្ចូលផងដែរក្នុងលទ្ធផលរបស់សហគ្រាស ។ ចំណូលបន្ទាប់បន្សំមានដូចជា ៖ ចំណូលពីអចលនទ្រព្យ ចំណូលពីមូលប័ត្រ និងភាគហ៊ុន ចំណូលពីឥណទេយ្យ (ប្រាក់ធានា គណនីសន្សំ...) សួយសារ អំណោយ និងឧបត្ថម្ភធន និងរួមទាំងចំណូលបន្ទាប់បន្សំផ្សេងទៀត ។[62] **ចំណូលផ្សេងៗ** គឺជាចំណូល ក្រៅពីចំណូលអាជីវកម្មជាគោលដើម និង ចំណូលបន្ទាប់បន្សំ នៅក្នុងចំណូលជាប់ពន្ធរបស់ក្រុមហ៊ុននៅមានចំណូលផ្សេងៗជាច្រើនទៀតដូចជា៖ សំណងធានារ៉ាប់រង, សំណងចំពោះ ការកេណ្ឌប្រមូល សំណងពីការលក់កិច្ចសន្យា, សំណងផ្តល់ឲ្យជាជំងឺចិត្ត, សំណងការខូចខាត ដោយការធ្វើអាជីវកម្មប្រកួតប្រជែងគ្មានមិនស្មោះត្រង់, ការបន្ធូរបន្ថយនូវពន្ធអាករដែលកាលពីមុនបានកាត់ចេញពីប្រាក់ចំណេញជាប់ពន្ធ, ការបន្ថយបំណុលដែលអ្នកផ្គត់ផ្គង់ ឬតតិយជនបានយល់ព្រមផ្តល់ឲ្យ ។[63]

**២. ចំណាយអាជីវកម្ម**

ការចំណាយរបស់ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដែលត្រូវបានចាត់ទុកថាជាការចំណាយអាជីវកម្ម គឺជាចំណាយទាំងឡាយដែលមានរៀបរាប់នៅខាងក្រោម ៖[64]

- ចំណាយដែលត្រូវបានអនុញ្ញាឲ្យកាត់កង គឺបានទូទាត់ ឬត្រូវសងនៅក្នុងឆ្នាំជាប់ពន្ធដែលអ្នកជាប់ពន្ធបានធ្វើឡើងដើម្បីប្រកបអាជីវកម្ម និងដែលគ្មានការបញ្ចូលសំរាប់ជាថ្នូរមកវិញក្នុងទ្រព្យសកម្មនូវទ្រព្យសកម្មណាមួយ ឬ ដែលគ្មានការលុបបំណុលណាមួយ ឬ ដែលគ្មានការលុបបំណុលណាមួយខាង ទ្រព្យអកម្ម ។
- ចំណាយបានទូទាត់ ឬ ត្រូវសងនៅក្នុងឆ្នាំជាប់ពន្ធ គឺចំណាយណាមួយអាចកាត់កងបានតែពីលទ្ធផលនៃការិយបរិច្ឆេទ ។

[62] ផ្នែកទី ៤.៣ នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០០៣

[63] ផ្នែកទី ៤.១០ នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០០៣

[64] ផ្នែកទី ៥.១ នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០០៣

- ចំណាយដើម្បីប្រកបអាជីវកម្ម (ត្រូវបានអនុញ្ញាតឲ្យកាត់កងបានតែចំណាយណា ដែលបានធ្វើដើម្បីបំរើ ឬ ជាប្រយោជន៍នៃអាជីវកម្ម ។

**២.១ ចំណាយអាចកាត់កងបាន**

ចំណាយរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែលអាចកាត់កង់បាន គឺជា ចំណាយទាំងឡាយណាដែលត្រូវបានបំពេញនូវលក្ខខណ្ឌតាំង ៣ដូចខាងក្រោម ៖[65]

- ហេតុការណ៍ដែលបញ្ជាក់នូវបន្ទុក ឬ ចំណាយរបស់អ្នកជាប់ពន្ធបានកើតឡើង
- លទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចដែលជាប់ទាក់ទងដល់ខ្ទង់ចំណាយនោះបានកើត ឡើង ។
- បន្ទុករបស់អ្នកជាប់ពន្ធត្រូវបានកំណត់ច្បាស់លាស់ (ត្រូវបានធ្វើគណនេយ្យកម្មក្នុងអំឡុងនៃការិយបរិច្ឆេទ និងត្រូវមានភស្តុតាងបញ្ជាក់ត្រឹមត្រូវពីចំនួនទឹកប្រាក់ច្បាស់លាស់)

ចំណាយដែលអាចកាត់កងបានមានដូចជា ៖ សោហ៊ុយបង្កើតសហគ្រាស, ការទិញ, បន្ទុកសាវាខាងក្រៅ, ពន្ធ និងអាករ, បៀវត្ស និងបន្ទុកប្រហាក់ប្រហែល, វិភាគទានសប្បុរសធម៌, ការប្រាក់ ។

**២.២ ចំណាយមិនអាចកាត់កងបាន**

ចំណាយរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដែលមិនអាចធ្វើការកាត់កងបានគឺជាប្រភេទចំណាយទាំងឡាយណាដែលក្រៅពីចំណាយដែលបំពេញលក្ខខណ្ឌអាចកាត់កងបាន និងចំពោះរំលស់ ឬសំវិធានធនដែលកត់ត្រាខុសគោលការណ៍ ឬកត់ត្រាលើស (សហគ្រាសត្រូវ បញ្ចូនមកវិញជាលទ្ធផលសារពើពន្ធ) ។[66] ការចំណាយរបស់នីតិបុគ្គលនេះដែលមិនអនុញ្ញាត ឲ្យដាត់ចេញមានដូចជា ៖ ចំណាយគ្មានសក្ខីបត្រ, ចំណាមិនពាក់ព័ន្ធសកម្មភាពអាជីវកម្ម, ចំណាយមិនបានទូទាត់ពេលបិទការិយបរិច្ឆេទមុន, ចំណាយនៃការិយបរិច្ឆេទបន្ទាប, ចំណាយ សម្រាប់ការរស់នៅផ្ទាល់ខ្លួន ឬក្រុមគ្រួសារ, ចំណាយពន្ធ-អាករ,..។

**៣. ការគណនាទឹកប្រាក់ពន្ធលើប្រាក់ចំណូល**

**៣.១. អត្រាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ**

ប្រាក់ចំណូលរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវជាប់ពន្ធលើប្រាក់ចំណូលក្នុងអត្រាដូចខាងក្រោម ៖

---

[65] ផ្នែកទី ៥.២ នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០០៣

[66] ផ្នែកទី ៥.៣ នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០០៣

- អត្រា ២០% ចំពោះប្រាក់ចំណេញដែលសម្រេចបានដោយនីតិបុគ្គល ។
- អត្រា ៣០% ចំពោះប្រាក់ចំណូលដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាត និងឧស្ម័នធម្មជាតិ ឬ សម្រេចបានពីការធ្វើអាជីវកម្ម ធនធាន ធម្មជាតិរួមទាំងព្រៃឈើ រ៉ែ មាស ឬត្បូងថ្មមានតម្លៃនានា ។
- អត្រា ៩% ចំពោះចំណូលរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលទទួលស្គាល់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្រាប់រយៈពេលអន្តរកាល ៥ ឆ្នាំ ដោយគិតចាប់ផ្តើមពីថ្ងៃប្រកាសឲ្យប្រើច្បាប់ស្តីវិសោធនកម្មនៃ ច្បាប់ស្តីពី វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។
- អាត្រា ០% ចំពោះគម្រោងវិនិយោកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលស្ថិតនៅក្នុងរយៈពេល លើកលែងពន្ធដែលកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

### ៣.២. ការគណនាទឹកប្រាក់ពន្ធលើប្រាក់ចំណូល

ចំពោះក្រុមហ៊ុនឯកជនទទួលខិសត្រូវមានកម្រិត ដើម្បីធ្វើការគណនាប្រាក់ចំណូលជាប់ពន្ធនៃឆ្នាំជាប់ពន្ធណាមួយ ក្រុមហ៊ុនត្រូវយកលទ្ធផលគណនេយ្យនៃឆ្នាំជាប់ពន្ធ( ដែលអាចជាចំណេញពិត ឬខាតពិត ) មកធ្វើការកែតម្រូវផ្សេងៗដូចខាងក្រោម ៖[67]

(១) ការបញ្ចូលមកវិញ និងការកាត់ចេញ

- **បូក** ចំណាយមិនអាចកាត់កងបាន
- **បូក** ចំណូលជាប់ពន្ធតែមិនបានកត់ក្នុងបញ្ជីគណនេយ្យ
- **ដក** ចំណាយមិនបានកត់ត្រាក្នុងបញ្ជីគណនេយ្យ តែជាចំណាយកាត់កងបានក្នុងឆ្នាំ
- **ដក** ចំណូលបានកត់ត្រាក្នុងបញ្ជីគណនេយ្យ តែជាចំណូលមិនត្រូវជាប់ពន្ធ

(២) បន្ទាប់ពីបានកែតម្រូវលទ្ធផលគណនេយ្យ(ចំណេញ ឬខាត) ក្រុមហ៊ុនត្រូវគណនាវិភាគទានសម្បុរសធម៌អតិបរមាដែលអាចកាត់កងបានសម្រាប់ឆ្នាំជាប់ពន្ធ ដោយក្រុមហ៊ុនត្រូវ ៖

- **បូក** ចំណាយសប្បុរសធម៌ដែលមិនឲ្យកាត់កង

(៣) ប្រាក់ចំណេញ (ខាត) មុននិយ័តកម្មលើការប្រាក់

- **បូក/( ដក)** និយ័តកម្មលើការប្រាក់

[67] ផ្នែកទី ៩.១ នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០០៣

(៥) ប្រាក់ចំណេញ ឬ(ខាត)ក្នុងការិយបរិច្ឆេទ

- **(ដក)** ខាតយោងពីឆ្នាំមុនអនុញ្ញាត

បន្ទាប់ពីបានធ្វើការកែតម្រូវនូវលទ្ធផលគណនេយ្យ ក្រុមហ៊ុននឹងទទួលបាន *ប្រាក់ចំណូលជាប់ពន្ធសំរាប់គណនាពន្ធលើប្រាក់ចំណូល* តាមរយៈលទ្ធផលពន្ធដារ។

❖ ការគណនាប្រាក់ពន្ធ

➢ រកប្រាក់ពន្ធលើប្រាក់ចំណូល

ពន្ធលើប្រាក់ចំណូល = (ប្រាក់ចំណូលជាប់ពន្ធ x អត្រាពន្ធ) - ឥណទានពន្ធបរទេស

-ឥណទានពន្ធបន្ថែមលើការបែងចែកភាគលាភក្នុងឆ្នាំ

➢ រកបំណុលពន្ធលើប្រាក់ចំណូល/ ពន្ធអប្បបរមា (ណាមួយខ្ពស់ជាងគេ)

- ដក ឥណទានពន្ធកាត់ទុក
- ដក ប្រាក់រំដោះពន្ធលើប្រាក់ចំណូល
- ដក ឥណទានពន្ធលើប្រាក់ចំណូលយោងពីឆ្នាំមុន

*នាំឲ្យបាន ប្រាក់ពន្ធត្រូវបង់ ឬយោងទៅឆ្នាំក្រោយ*

**ខ. ពន្ធអប្បបរមា**

ពន្ធអប្បបរមា ត្រូវបានកំណត់លើអ្នកជាប់ពន្ធតាមរបបពិត ។ ពន្ធនេះគឺជាពន្ធដោយឡែក និងផ្សេងពីពន្ធលើប្រាក់ចំណេញ ។[68] ក្នុងនាមក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស នីតិបុគ្គលនេះត្រូវបង់ពន្ធអប្បបរមាដែលលើកលែងតែ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។ ពន្ធអប្បបរមាត្រូវបានកំណត់បានកំណត់ស្មើនឹង ១%នៃផលរបរប្រចាំឆ្នាំរួមបញ្ចូលពន្ធអាករនានាវៀរលែងតែអាករលើតម្លៃបន្ថែម ។ ពន្ធអប្ប បរមាត្រូវបង់សម្រាប់ឆ្នាំជាប់ពន្ធណាមួយ អាចត្រូវបានកាត់បន្ថយដោយពន្ធលើប្រាក់ចំណូល ដែលបានបង់ជាក់ស្តែងក្នុងឆ្នាំ ជាប់ពន្ធនោះ។[69] សម្រាប់ការគណនាប្រាក់ពន្ធអប្បបរមា ប្រាក់ពន្ធត្រូវបង់ ឬឥណទានពន្ធសម្រាប់ឆ្នាំជាប់ ពន្ធត្រូវបានកំណត់ដូចតទៅ ៖[70]

[68] មាត្រា ២៥(ថ្មី) នៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

[69] មាត្រា ២៥ថ្មី (ពីរ)នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧

[70] មាត្រា ៣៩ នៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

- អ្នកជាប់ពន្ធត្រូវបង់ពន្ធអប្បបរមា នៅពេលធ្វើការទូទាត់ប្រាក់ពន្ធលើប្រាក់ចំណេញ ។ ពន្ធអប្បបរមាត្រូវបង់ អាចត្រូវបានកាត់បន្ថយដោយបំណុលពន្ធលើប្រាក់ ចំណូលក្នុងឆ្នាំជាប់ពន្ធជាមួយគ្នា ។
- ក្នុងករណីបំណុលពន្ធលើប្រាក់ចំណេញលើសពីបំណុលពន្ធអប្បរមា៖
    - o អ្នកជាប់ពន្ធត្រូវទូទាត់ប្រាក់ពន្ធត្រូវបង់តាមរបៀបការគណនាចំណូលពន្ធលើប្រាក់ចំណូល នៅពេលដាក់លិខិតប្រាកាសសារពើពន្ធ
    - o ប្រសិនបើចំនួនទឹកប្រាក់ដែលបានកាត់ទុកតាមការកាត់ទុកតាមមាត្រា២៥ និង មាត្រា២៨ នៃច្បាប់ស្តីពីសារពើពន្ធ មានចំនួនលើសពីបំណុលពន្ធ អប្បបរមា អ្នកជាប់ពន្ធអាចស្នើសុំឥណទានបាន
    - o ក្នុងករណីបំណុលពន្ធលើប្រាក់ចំណេញលើសពីបំណុលពន្ធអប្បរមា អ្នកជាប់ពន្ធមិនជាប់ពន្ធអប្បបរមាទេ ។
- ប្រសិនបើបំណុលពន្ធលើប្រាក់ចំណេញ តិចជាងបំណុលពន្ធអប្បបរមាអ្នកជាប់ពន្ធត្រូវជាប់ពន្ធអប្បបរមា ។

**គ. ពន្ធប៉ាតង់**

**១. កម្មវត្ថុនៃការប្រមូលពន្ធកាត់ទុក**

ពន្ធប៉ាតង់គឺ ជាពន្ធប្រចាំឆ្នាំ ។ ពន្ធនេះត្រូវបានប្រមូលសម្រាប់ជាគុណប្រយោជន៍ថវិកាថ្នាក់ក្រោមជាតិ ។ ពន្ធប៉ាតង់ ត្រូវបានប្រមូលដោយកំណត់លើសកម្មភាពអាជីវកម្ម ដោយផ្អែកលើប្រភេទអ្នកជាប់ពន្ធ និង កម្រិតផលរបរ ។ ស្របគ្នានេះដែល ចំពោះកម្មវត្ថុអាជីវកម្មរបស់នីតិបុគ្គលនេះដែលតម្រូវឲ្យធ្វើការបង់ពន្ធប៉ាតង់គឺ ត្រូវអនុវត្តទៅតាមបែបបទនៃការបង់ពន្ធដូចខាងក្រោម ៖[71]

- អ្នកជាប់ពន្ធមានសកម្មភាពអាជីវកម្មច្រើន ត្រូវបង់ពន្ធប៉ាតង់ផ្សេងៗគ្នា ទៅតាមសកម្មភាពអាជីវកម្មនីមួយ ។

*ឧទាហរណ៍ ៖ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មួយដែលមានសកម្មភាពអាជីវកម្មនីហារ័ណ-អាហារ័ណ ដឹកជញ្ជូន និង សណ្ឋាគារត្រូវបង់ពន្ធប៉ាតង់សម្រាប់ ៣ សកម្មភាពអាជីវកម្មផ្សេងគ្នា។*

[71] ប្រការ ៥ នៃប្រកាសស្តីពីវិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ ២៥ ធ្នូ ២០១៥

- ចំពោះសកម្មភាពទាំងនោះគឺជាឧបសម្ព័ន្ធនានានៃសកម្មភាពអាជីវកម្ម នោះត្រូវបានចាត់ទុកថាជាសម្មភាពអាជីវកម្មតែមួយ ។
- អ្នកជាប់ពន្ធដែលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់សកម្មភាព អាជីវកម្មតែមួយនៅក្នុងរាជធានីភ្នំពេញ-ខេត្តតែមួយ ត្រូវបង់ពន្ធប៉ាតង់តែមួយ ។
- អ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មនៅក្នុងរាជធានី-ខេត្តផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់ទៅតាមរាជធានី-ខេត្តដែលអាជីវកម្មនោះស្ថិតនៅ ។

**២. ការប្រកាសពន្ធ និងការបង់ពន្ធ**

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវបង់ពន្ធប៉ាតង់ នៅពេលចាប់ផ្តើមប្រកបពាណិជ្ជកិច្ច និង ក្នុងអំឡុងពេលចាប់ ផ្តើមពីថ្ងៃទី ០១ ខែ មករា ដល់ ថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ ។ ពន្ធនេះត្រូវបង់នៅរដ្ឋបាលសារពើពន្ធដែលអ្នកជាប់ពន្ធមានទីកន្លែងប្រកបអាជីវកម្មពិតប្រាកដ ។ [72]

នៅពេលដែលក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតចាប់ផ្តើមប្រកបអាជីវកម្ម ក្នុងរយៈពេល៦ខែដើមឆ្នាំត្រូវមានកាតព្វកិច្ចបង់ប្រាក់ពន្ធប៉ាតង់ពេញមួយឆ្នាំ ។ ប៉ុន្តែប្រសិនបើ នីតិបុគ្គលនេះចាប់ផ្តើមប្រកបអាជីវកម្មរបស់ខ្លួនក្នុងរយៈពេល ៦ខែចុងឆ្នាំ អ្នកជាប់ពន្ធត្រូវបង់ប្រាក់ពន្ធប៉ាតង់ ត្រឹមពាក់កណ្តាលនៃប្រាក់ពេញមួយឆ្នាំ ។[73]

☞ *កម្រិតប្រាក់ប៉ាតង់ត្រូវបង់*

- o អ្នកជាប់ពន្ធតូច ត្រូវបង់ពន្ធប៉ាតងប្រចាំឆ្នាំចំនួន ៤០០ ០០០ រៀល
- o អ្នកជាបពន្ធមធ្យម ត្រូវបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ១ ២០០ ០០០ រៀល
- o អ្នកជាប់ពន្ធធំដែលមានផលរបរ ៖
  - ក. លើសពី ២០០០ លានរៀល ដល់ ១០ ០០០លានរៀល ត្រូវបង់ពន្ធ ប៉ាតង់ប្រចាំឆ្នាំចំនួន ៣ ០០០ ០០០ រៀល
  - ខ. លើសពី ១០ ០០០ លានរៀលត្រូវបង់ពន្ធប៉ាបងប្រចាំឆ្នាំចំនួន៥០០០ ០០០រៀល ។

---

[72] ប្រការ ៧ នៃប្រកាសស្តីពីវិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ ២៥ ធ្នូ ២០១៥

[73] ប្រការ ៧ នៃប្រកាសស្តីពីវិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ ២៥ ធ្នូ ២០១៥

អ្នកជាប់ពន្ធធំដែលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់សកម្មភាពអាជីវកម្មតែមួយ ដែលស្ថិតនៅតាមរាជធានី-ខេត្តផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់ចំនួន ៣ ០០០ ០០០ រៀល នៅតាមរាជធានី-ខេត្តដែលអាជីវកម្មនោះស្ថិតនៅ ។

**៣. ប័ណ្ណប៉ាតង់**

បន្ទាប់ពីបានបង់ពន្ធរួចរាល់ ក្រុមហ៊ុននឹងទទួលបាននូវប័ណ្ណប៉ាតង់សម្រាប់បញ្ជាក់ថាក្រុមហ៊ុនបានបងពន្ធរួចរាល់ទៅលើប្រភេទអាជីវកម្មរបស់ខ្លួន ។ បន្ទាប់ពីទទួលបាននូវប័ណ្ណប៉ាតង់ក្រុមហ៊ុន ត្រូវមានកាតព្វកិច្ច ក្នុងការដាក់តាំងបង្ហាញនូវប័ណ្ណប៉ាតង់ ដែលមានសពុលភាពនោះនៅតាមទីតាំងប្រកបអាជីវកម្មរបស់ខ្លួន ។

ប៉ុន្តែក្នុងករណីខាងក្រោមទាំងនេះចំពោះអាជីវកម្មដែលបានបង់ពន្ធប៉ាតង់រួចហើយ ក៏ក្រុមហ៊ុនត្រូវធ្វើការបង់ពន្ធប៉ាតង់ជាថ្មីម្តងទៀត ប្រសិនបើមាន ៖

- ការផ្លាស់ប្តូរទីកន្លែងគោលដៅ ទៅរាជធានី - ឬខេត្តផ្សេងៗ
- មានការផ្លាស់ប្តូរកម្មវត្ថុអាជីវកម្ម
- មានការចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងថ្លៃ ក្នុងការផ្គត់ផ្គង់ទំនិញ ឬសេវា ត្រូវមានប័ណ្ណប៉ាតងដែលមានសកម្មភាពស្របនឹងកម្មវត្ថុទាំងនោះ ។

ជាទូទៅប័ណ្ណប៉ាតងមួយ គឺមានតម្លៃចំពោះតែអ្នកជាប់ពន្ធដែលមានឈ្មោះលើប័ណ្ណប៉ាតង់នោះតែប៉ុណ្ណោះ ។ ហេតុនេះហើយនៅរាល់ពេលដែលមានការផ្លាស់ប្តូរម្ចាស់អាជីវកម្មថ្មី គឺត្រូវតម្រូវឲ្យមានការបង់ពន្ធប៉ាតង់សារជាថ្មី ។ ប៉ុន្តែការបង់ពន្ធប៉ាតង់ថ្មីនេះនឹង ត្រូវបានលើកលែងប្រសិន បើមានការផ្លាស់ប្តូរម្ចាស់អាជីវកម្មថ្មីនោះមានគ្រប់នូវលក្ខណៈពីរ សំខាន់ៗ ខាងក្រោម ៖[74]

- មិនបានផ្លាស់ប្តូរសកម្មភាពអាជីវកម្ម
- ម្ចាស់ថ្មីគឺជា ឪពុក ម្តាយ ប្តី ប្រពន្ធ កូន ឬអ្នកស្នងស្របច្បាប់របស់ម្ចាស់អាជីវកម្មចាស់ ។

## ឃ. ពន្ធលើតែមប្រ៍សារពើពន្ធ

ក្រៅពីកាតព្វកិច្ចក្នុងការបង់ពន្ធផ្សេងៗទៅលើការប្រកបអាជីវកម្មហើយ ក្រុមហ៊ុនទ្រង់ទ្រាយនេះដែរ ត្រូវមានកាតព្វកិច្ចក្នុងការបង់ពន្ធទៅលើការផ្សព្វផ្សាយមួយមុខទៀត នោះគឺ កាតព្វកិច្ចក្នុងការបង់ពន្ធតែមប្រ៍ (ស្លាក់យីហោ និង ផ្ទាំងផ្សព្វផ្សាយពាណិជ្ជកម្ម) ។ ពន្ធតែមប្រ៍ ត្រូវបានយក

[74] ប្រការ ៩ នៃប្រកាសស្តីពីវិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ ២៥ ធ្នូ ២០១៥

មកអនុវត្តលើប័ណ្ណប្រកាសពាណិជ្ជកម្ម ស្លាកអាជីវកម្ម (យីហោ) ផ្ទាំងអក្សរ ផ្ទាំងរូបភាពក្នុងគោលបំណងផ្សាយពាណិជ្ជកម្ម ។

**១. និយមន័យ**

នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តពន្ធលើតែមប្រ៊ី បច្ចេកស័ព្ទខាងក្រោមត្រូវបានកំណត់ និយមន័យដូចតទៅ ៖ [75]

- *ប័ណ្ណប្រកាស* គឺសំដៅដល់ប័ណ្ណ ស្លាក ឬផ្ទាំង ដែលមានអក្សរ គំនូស និង/ឬ រូបភាពជីវចល ឬ អជីវចលសម្រាប់គោលបំណងផ្សព្វផ្សាយពាណិជ្ជកម្ម ដើម្បីឲ្យ អតិថិជន ឬសាធារណជនបានស្គាល់ជាអាទ៍អំពីផលិតផល សេវាកម្ម និងពត៌មានផ្សេងៗទៀត ពាក់ព័ន្ធអាជីវកម្មរបស់អ្នកជាប់ពន្ធ ដែលរួមមាន ៖
    - ➢ ប័ណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើដោយក្រដាសធម្មតា
    - ➢ ក្រណាត់ ឬវត្ថុផ្សេងៗ
    - ➢ ស្លាកអាជីវកម្មដ្ឋាន
    - ➢ ផ្ទាំងអក្សរ ឬផ្ទាំងរូបភាពសម្រាប់គោលបំណងផ្សាយពាណិជ្ជកម្ម
- ***ប័ណ្ណប្រកាសមានពន្លឺ*** គឺសំដៅដល់ប័ណ្ណប្រកាស ដែលមានប្រភពពន្លឺពីក្នុង ឬ ប្រភពពន្លឺពីខាងក្រៅដែលអាចមើលឃើញប័ណ្ណប្រកាសនោះនៅទីងងឹត ។
- ***ប័ណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើពីក្រដាសធម្មតា*** គឺសំដៅដល់ប័ណ្ណប្រកាស ដែលមានអក្សរ គំនូស និង/ឬ រូបភាពត្រូវបានបោះពុម្ព ឬគូរលើក្រដាសធម្មតា សម្រាប់ការផ្សព្វផ្សាយពាណិជ្ជកម្ម ក្នុងរយៈពេលតិចជាង ឬស្មើ ៩០ថ្ងៃ ។
- ***ប័ណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើដោយក្រណាត់ ឬវត្ថុផ្សេងៗ*** គឺជាប័ណ្ណប្រកាស ដែលអក្សរ គំនូស និង/ឬ រូបភាព ត្រូវបានបោះពុម្ព ឬភ្ជួសលើក្រណាត់ ឬវត្ថុផ្សេងៗ ដែលផ្ទៃក្រឡាមិនលើសពី១០០ដេស៊ីម៉េតក្រឡា សម្រាប់ការផ្សព្វផ្សាយពាណិជ្ជកម្ម ក្នុងរយៈពេលតិចជាង ឬស្មើ ៩០ថ្ងៃ ។

[75] ប្រការ ៤ នៃ ប្រកាសស្តីពី ការអនុវត្តអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលតារាងពន្ធតែមប្រ៍សារពើពន្ធ ចុះថ្ងៃទី ១៨ សីហា ឆ្នាំ២០១៥

- ***ស្លាកអាជីវកម្មដ្ឋាន*** គឺសំដៅដល់ប័ណ្ណប្រកាស សម្រាប់សម្គាល់ឈ្មោះ ទីតាំង ចរិតលក្ខណៈ អាជីវកម្ម អាសយដ្ឋាន នៃសហគ្រាស ឬ អាជីវកម្មដ្ឋាន និងត្រូវដាក់ភ្ជាប់នឹងអគារដែលស្ថិតនៅច្រកចេញចូលអាគារ ឬខ្លោងទ្វារ នៃសហគ្រាស ឬអាជីវកម្មដ្ឋាននោះ ដោយសហគ្រាស ឬអាជីវកម្មដ្ឋានមួយត្រូវមានស្លាក់អាជីវកម្មដ្ឋាននៃកម្មវត្ថុដែលចុះបញ្ជីតែមួយប៉ុណ្ណោះ ។
- ***ផ្ទាំងអក្សរ ឬផ្ទាំងរូបភាពសម្រាប់គោលបំណងផ្សាយពាណិជ្ជកម្ម*** គឺសំដៅដល់ ប័ណ្ណប្រកាស ដែលពុំមែនជាប្រភេទប័ណ្ណប្រកាសដូចបានរៀបរាប់ខាងលើហើយដែលផ្សព្វផ្សាយពាណិជ្ជកម្ម ជាសាធារណៈ ដោយមធ្យោបាយអចល័ត ឬ ចល័ត ។
- ***ផ្ទាំងអក្សរ ឬផ្ទាំងរូបភាពចល័ត*** សំដៅដល់ប័ណ្ណប្រកាសដែលមានផ្ទាំងអក្សរ ឬផ្ទាំងរូបភាព ដែលដាក់ភ្ជាប់ តភ្ជាប់ ឬគូសផ្ទាល់នឹងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទមានដូចជា រថយន្ត រថភ្លើង កប៉ាល់ រឺម៉កម៉ូតូ ទោចក្រយានយន្ត ។

**២. ការគណនា ការប្រកាស និងការបង់ពន្ធ**

**២.១ ការគណនាពន្ធ**[76]

☞ *មូលដ្ឋានគិតពន្ធ និង អត្រាពន្ធ នៃប័ណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើដោយ ក្រដាស៖*

| ប្រភេទប័ណ្ណ | អត្រា |
|---|---|
| ផ្ទៃក្រឡាមិនលើសពី ៤០ ដេស៊ីម៉ែត្រក្រឡា | ៥០០៛/ទំព័រ |
| បើមានអក្សរបរទេស | ១,៥០០៛/ទព័រ |
| ផ្ទៃក្រឡាលើសពី ៤០ ដេស៊ីម៉ែត្រក្រឡា | ៧០០៛/ទំព័រ |
| បើមានអក្សរបរទេស | ២,១០០៛/ទំព័រ |

☞ *មូលដ្ឋានគិតពន្ធ និង អត្រាពន្ធ នៃប័ណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើដោយ ក្រណាត់ ឬ វត្ថុផ្សេងៗ ៖*

| ប្រភេទប័ណ្ណ | អត្រា |
|---|---|
| ផ្ទៃក្រឡាមិនលើសពី ៤០ ដេស៊ីម៉ែត្រក្រឡា | ៧០០៛/ផ្ទាំង |

[76] ប្រការ ៦ នៃ ប្រកាសស្តីពី ការអនុវត្តអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលតារាងពន្ធតែមប្រ៍សារពើពន្ធ ចុះថ្ងៃទី ១៨ សីហា ឆ្នាំ២០១៥

| | |
|---|---|
| បើមានអក្សរបរទេស | ២,១០០៛/ផ្ទាំង |
| ផ្ទៃក្រឡាលើសពី ៥០ ដល់ ១០០ ដេស៊ីម៉ែត្រក្រឡា | ១,០០០៛/ផ្ទាំង |
| បើមានអក្សរបរទេស | ៣,០០០៛/ផ្ទាំង |
| ក្រឡាមិនលើសពី ១០០ ដម ត្រូវគិតជាផ្ទាំងអក្សរ | |

☞ *មូលដ្ឋានគិតពន្ធ និង អត្រាពន្ធ នៃស្លាកអាជីវកម្មដ្ឋាននានា ៖*

| **ប្រភេទប័ណ្ណ** | **អត្រា/ដម$^{២}$/ឆ្នាំ** | **អក្សរបរទេស** |
|---|---|---|
| គ្មានពន្លឺស្របតាមដងផ្លូវសាធារណៈ | ១០០៛/ដម$^{២}$ | ២០០៛/១តួ/ដម |
| គ្មានពន្លឺកែងដងផ្លូវសាធារណៈ | ១៥០៛/ដម$^{២}$ | ៣០០៛/១តួ/ដម |
| មានពន្លឺស្របតាមដងផ្លូវសាធារណៈ | ២០០៛/ដម$^{២}$ | ៤០០៛/១តួ/ដម |
| មានពន្លឺកែងដងផ្លូវសាធារណៈ | ២៥០៛/ដម$^{២}$ | ៥០០៛/១តួ/ដម |

☞ *មូលដ្ឋានគិតពន្ធ និងអត្រាពន្ធនៃផ្ទាំងអក្សរ ឬផ្ទាំងរូបភាពសម្រាប់គោលបំណងផ្សាយពាណិជ្ជកម្ម ៖*

| **ប្រភេទប័ណ្ណ** | **អត្រា/ដម$^{២}$/ឆ្នាំ** | **អក្សរបរទេស** |
|---|---|---|
| គ្មានពន្លឺស្របតាមដងផ្លូវសាធារណៈ | ៥០០៛/ដម$^{២}$ | ១,០០០៛/១តួ/ដម |
| គ្មានពន្លឺកែងដងផ្លូវសាធារណៈ | ៧០០៛/ដម$^{២}$ | ១,៤០០៛/១តួ/ដម |
| មានពន្លឺស្របតាមដងផ្លូវសាធារណៈ | ៧០០៛/ដម$^{២}$ | ១,៤០០៛/១តួ/ដម |
| មានពន្លឺកែងដងផ្លូវសាធារណៈ | ១,០០០៛/ដម$^{២}$ | ២,០០០៛/១តួ/ដម |
| ដាក់ភ្ជាប់មធ្យោបាយដឹកជញ្ជូន | ១,៥០០៛/ដម$^{២}$ | ៣,០០០៛/១តួ/ដម |

ក្រៅពីជាប់ពន្ធតែមប្រិ៍សារពើពន្ធទៅលើការផ្សព្វផ្សាយពាណិជ្ជកម្មហើយ ក្រុមហ៊ុនទ្រង់ទ្រាយនេះក៏ជាប់ពន្ធទៅលើលិខិតបទដ្ឋានគតិយុត្តតាមអត្រា ០៛ ដូចមានចែងក្នុងមាត្រា ១ ចំណុច ក នៃអនុក្រឹត្យលេខ ៤០ អនក្រ. បក ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលតារាងពន្ធតែមប្រិ៍សារពើពន្ធ មិនត្រូវបានតម្រូវឲ្យបិទសន្លឹកតែមប្រិ៍ សារពើពន្ធ មានដូចខាងក្រោម ៖

➢ លិខិតស្នើសុំបង្កើតក្រុមហ៊ុន អាហារ័ណ-ណីហារ័ណ សណ្ឋាគារ វិនិយោគទុន បរទេស
➢ លិខិតស្នើសុំប្រកបអាជីវកម្ម

- លិខិតស្នើសុំផ្តល់ស្លាកលេខសម្គាល់យានយន្ត/ជលយានយន្តគ្រប់ប្រភេទ
- ពាកយបណ្តឹងគ្រប់ប្រភេទ
- លក្ខន្តិក:ក្រុមហ៊ុនអាជីវកម្មនានា(ដើម ឬចម្លង )

**២.២ ការប្រកាស និងការបងពន្ធ**

ចំពោះពន្ធលើតែមប្រ៍សារពើពន្ធ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតត្រូវមានកាតព្វកិច្ចក្នុងការដាក់លិខិតប្រកាស និងធ្វើការបងពន្ធដូចតទៅ ៖[77]

ក. ចំពោះប័ណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើដោយក្រដាសធម្មតា និងប័ណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើដោយក្រណាត់ ឬវត្ថុផ្សេងៗ ម្ចាស់ប័ណ្ណប្រកាស ត្រូវដាក់លិខិតប្រកាសពន្ធ ទៅកាន់អគ្គនាយកដ្ឋានពន្ធដារ សម្រាប់ប័ណ្ណប្រកាសដែលត្រូវបានផ្សព្វផ្សាយនៅរាជធានីភ្នំពេញ ឬសាខាពន្ធដារខេត្តក្រុង សម្រាប់ប័ណ្ណប្រកាសដែលត្រូវបានផ្សព្វផ្សាយនៅខេត្តពាក់ព័ន្ធនោះ ទៅតាមអត្រា និងលក្ខខណ្ឌដោយអនុលោមតាមបទបញ្ញត្តិជាធរមាន ។ រីឯចំពោះប័ណ្ណប្រកាសផ្សាយពាណិជ្ជកម្មដែលមានអក្សរបរទេស ដោយមិនរាប់បញ្ចូល នាមករណ៍ អាសយដ្ឋាន លេខទូរស័ព្ទ និងគេហ-ទំព័ររបស់សហគ្រាស ត្រូវស្ថិតនៅក្នុង លក្ខខណ្ឌបន្ថែមណោខាងលើ ។

ខ. ចំពោះស្លាកអាជីវកម្មដ្ឋាន ម្ចាស់ប័ណ្ណប្រកាស (ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត) មានភារកិច្ចដាក់លិខិតប្រកាស និងបង់ពន្ធ នៅសាខាពន្ធដារដែលស្លាក់អាជីវកម្មដ្ឋាន នោះតាំងនៅទៅតាមអត្រា និង លក្ខខណ្ឌដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន ។ ប៉ុន្តែ ក្នុងករណីស្លាក់អាជីវ-កម្មដ្ឋានមានភ្ជាប់ប័ណ្ណប្រកាសសហគ្រាស ឬ អាជីវកម្មដ្ឋានផ្សេង គឺត្រូវគិត ពន្ធទៅតាមចំណែកនៃសាមីសហគ្រាស ឬ អាជីវកម្មដ្ឋាននោះព្រមទាំងទៅតាមប្រភេទប័ណ្ណ ប្រកាស ។

គ. ចំពោះ ផ្ទាំងអក្សរ ឬផ្ទាំងរូបភាពសម្រាប់គោលបំណងពាណិជ្ជកម្ម ម្ចាស់ប័ណ្ណប្រកាសត្រូវដាក់លិខិតប្រកាស និង បង់ពន្ធនៅអគ្គនាយយកដ្ឋានពន្ធដារសម្រាប់ផ្ទាំងអក្សរ ឬ រូបភាព ដែលត្រូវបានផ្សព្វផ្សាយនៅរាជធានីភ្នំពេញ ឬសាខាពន្ធដារខេត្ត សម្រាប់ផ្ទាំងអក្សរ ឬ រូបភាពដែល ត្រូវបានផ្សព្វផ្សាយនៅខេត្តពាក់ព័ន្ធនោះ ។

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតត្រូវធ្វើការដាក់លិខិតប្រកាសពន្ធតែមប្រ៍ សារពើពន្ធតាមរយៈពេលកំណត់ដូចខាងក្រោម ៖[78]

[77] ប្រការ៧ នៃ ប្រកាសស្តីពី ការអនុវត្តអនុក្រឹត្យលេខ៩០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលតារាងពន្ធតែមប្រ៍សារពើពន្ធ ចុះថ្ងៃទី ១៨ សីហា ឆ្នាំ២០១៥

- ចំពោះប័ណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើដោយក្រដាសធម្មតា ប័ណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើដោយក្រណាត់ ឬវត្ថុផ្សេងៗ ម្ចាស់ប័ណ្ណប្រកាស ត្រូវដាក់លិខិតប្រកាស និង បង់ពន្ធក្នុងរយៈពេល ១៥ថ្ងៃ ក្រោយពីធ្វើការធ្វើការប្រកាសផ្សាយពាណិជ្ជកម្ម ។
- ចំពោះស្លាកអាជីវកម្មដ្ឋាន និងផ្ទាំងអក្សរ ឬ ផ្ទាំងរូបភាពសម្រាប់គោលបំណង ពាណិជ្ជកម្ម ម្ចាស់ប័ណ្ណប្រកាសត្រូវដាក់លិខិតប្រកាស និងបង់ពន្ធក្នុងរយៈពេលចាប់ពី ថ្ងៃទី ០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា នៃឆ្នាំសារពើពន្ធ ។
- ចំពោះស្លាកអាជីវកម្មដ្ឋាន និង ផ្ទាំងអក្សរ ឬផ្ទាំងរូបភាពសម្រាប់គោលបំណង ពាណិជ្ជកម្ម ដែលផលិតថ្មី ក្រោយថ្ងៃទី៣១ ខែមីនា នៃឆ្នាំសារពើពន្ធ ម្ចាស់ប័ណ្ណប្រកាសត្រូវដាក់លិខិតប្រកាស និងបង់ពន្ធ ក្នុងរយៈពេល ១៥ថ្ងៃក្រោយពីធ្វើការ ផ្សព្វផ្សាយពាណិជ្ជកម្ម ។
- ចំពោះស្លាកអាជីវកម្មដ្ឋាន និង ផ្ទាំងអក្សរ ឬផ្ទាំងរូបភាពសម្រាប់គោលបំណង ពាណិជ្ជកម្ម ដែលផលិតថ្មីរយៈពេល ៦ខែចុងឆ្នាំសារពើពន្ធ ម្ចាស់ប័ណ្ណប្រកាស (ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត) ត្រូវបង់ពន្ធ៥០% នៃប្រាក់ពន្ធត្រូវបង់ ហើយត្រូវដាក់លិខិតប្រកាស និងបង់ពន្ធ ក្នុងរយៈពេល ១៥ថ្ងៃ ក្រោយពីធ្វើការផ្សព្វផ្សាយពាណិជ្ជកម្ម ។

**ង. ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ**

នៅពេលដែលក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតមានកម្មវត្ថុអាជីវកម្មជាការ ដឹកជញ្ជូន មិនថាជាទំនិញ ឬជាមនុស្ស ឬមានយានជំនិះជាកម្មសិទ្ធិរបស់ក្រុមហ៊ុន នីតិបុគ្គល នេះត្រូវមានកាតព្វកិច្ចក្នុងការជាប់ពន្ធលើបធ្យោបាយដឹកជញ្ជូន និងយានជំនិះ គ្រប់ប្រភេទ ។ លើសពីនេះទៅទៀតនៅពេលដែលកម្មវត្ថុអាជីវកម្មនសក្រុមហ៊ុនប្រភេទ នេះមានការនាំចូល រថយន្តមកដាក់លក់នៅក្នុងឃ្លាំង ឬក្រុមហ៊ុន រថយន្តនោះក៏ត្រូវយកមកធ្វើការប្រកាសពន្ធលើ មធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទឲ្យបានទាន់ពេលវេលានៃឆ្នាំប្រមូលពន្ធ ព្រោះថារថយន្តទាំងនេះនាំចូលមក ក្នុងគោលបំណងដាក់ឲ្យចរាចរទាំងអស់ ។ ប៉ុន្តែកាតព្វកិច្ចពន្ធនេះ នឹងទទួលបានការលើកលែង ប្រសិនបើក្រុមហ៊ុននេះគឺជាសាខាក្រុមហ៊ុនដែលបានប្រកាស ជាសន្និធិរបស់ឃ្លាំង ឬក្រុមហ៊ុនដែល មានសកម្មភាពអាជីវកម្មទិញ-លក់រថយន្ត និងបានចុះបញ្ជី ព្រមទាំងបានដាក់លិខិត ប្រកាសបង់ពន្ធ នៅរដ្ឋបាលសារពើពន្ធ

[78] ប្រការ ៨ នៃ ប្រកាសស្តីពី ការអនុវត្តអនុក្រឹត្យលេខ៨០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលតារាងពន្ធតែមប្រ៍សារពើពន្ធ ចុះថ្ងៃទី ១៨ សីហា ឆ្នាំ២០១៥

។[79] ពន្ធប្រភេទនេះ គឺជាពន្ធប្រចាំឆ្នាំ ដែលត្រូវអនុវត្តលើមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ[80] ដែលរួមមានដូចជា ៖

- រថយន្តដឹកទំនិញ និងរ៉ឺម៉កសណ្តោង
- រថយន្តដឹកអ្នកដំណើរ
- រថយន្តទេសចរណ៍
- ជលយានយន្ត ឬជលយានយន្តផ្លូវទន្លេ និងសមុទ្រ

ដោយពន្ធនេះជាពន្ធប្រចាំឆ្នាំ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតអាចធ្វើការបងពន្ធចាប់ពីថ្ងៃទី ០១ ខែមិថុនា រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិការ នៃឆ្នាំនីមួយៗ ដើម្បីជាគុណដើម្បីជាគុណប្រយោជន៍ដល់ថ្នាក់ក្រោមជាតិ ។ ដោយក្រុមហ៊ុនអាចបង់ពន្ធនេះ នៅតាម សាខាពន្ធដារខេត្ត-ខណ្ឌ ឬ នៅធនាគារកាណាឌីយ៉ា ក.អ ឬ នៅធនាគារអេស៊ីលីដាភីអិលស៊ី ឬនៅធនាគារកម្ពុជាសាធារណៈភីអិលស៊ី ឬនៅធនាគារវឌ្ឍនៈ ឬនៅធនាគារអេអិនហ្សិតរ៉ូយ៉ាល ឬនៅតាមធនាគារដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នា ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[81] ក្រោយពីបានបង់ពន្ធរួចរាល់ហើយ ក្រុមហ៊ុននឹងទទួលបានបង្កាន់ដៃទទួលប្រាក់ពន្ធមធ្យោបាយដឹកជញ្ជូនមួយសន្លឹក ចេញពីប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ និង ក្រដាសតែម៍ម្រាប់បិទភ្ជាប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះមួយសន្លឹក ។ ក្រុមហ៊ុនត្រូវរក្សាបង្កាន់ដៃ ទទួលប្រាក់ពន្ធនេះទុកជាប់នឹងយានយន្តសម្រាប់បង្ហាញមន្ត្រីមានសមត្ថកិច្ច និង អាចជាឯកសារ សម្រាប់ប្រកាសបង់ពន្ធនៅ ឆ្នាំបន្ទាប់ ។[82]

[79] ចំណុច III នៃសេចក្តីណែនាំ ស្តីពីការអនុវត្តប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទប្រចាំឆ្នាំ ចុះថ្ងៃទី២២ មិថុនា ២០១៨

[80] ពាក្យ ( មធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ ) អាចស្វែងយល់អត្ថន័យបន្ថែមជាក់លាក់នៃប្រភេទមធ្យោបាយដឹកជញ្ជូននីមួយៗបាននៅក្នុង ផ្នែក IV នៃនៃសេចក្តីណែនាំ ស្តីពីការអនុវត្តប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទប្រចាំឆ្នាំ ចុះថ្ងៃទី២២ មិថុនា ២០១៨

[81] ចំណុច I នៃសេចក្តីណែនាំ ស្តីពីការអនុវត្តប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទប្រចាំឆ្នាំ ចុះថ្ងៃទី២២ មិថុនា ២០១៨

[82] ចំណុច VI នៃសេចក្តីណែនាំ ស្តីពីការអនុវត្តប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទប្រចាំឆ្នាំ ចុះថ្ងៃទី២២ មិថុនា ២០១៨

### ១. នីតិវិធីនៃការបង់ពន្ធ

ដើម្បីធ្វើការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទប្រចាំឆ្នាំ ក្រុមហ៊ុន ឬម្ចាស់យានយន្តត្រូវអនុវត្តដូចខាងក្រោម ៖

➢ ***ចំពោះយានយន្តដែលមានប័ណ្ណសម្គាល់ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ៖***

- ត្រូវភ្ជាប់មកជាមួយនូវប័ណ្ណសម្គាល់ការបង់ពន្ធនេះ ដោយមិនចាំបាច់ធ្វើការដាក់លិខិតប្រកាសពន្ធនោះទេ
- ករណីបាត់ប័ណ្ណសម្គាល់ការបង់ពន្ធនេះ ម្ចាស់យានយន្តត្រូវដាក់ពាក្យស្នើសុំបោះពុម្ពប័ណ្ណបង់ពន្ធសាជាថ្មី នៅសាខាពន្ធដារខេត្ត-ខណ្ឌ ឬធនាគារ ពាណិជ្ជណាមួយដូចរៀបរាប់ខាងលើ ដោយត្រូវបង់កម្រៃសេវាក្នុងការធ្វើប័ណ្ណនេះ ចំនួន ៥ ០០០ រៀល ។

➢ ***ចំពោះយាយន្តដែលមិនមានប័ណ្ណសម្គាល់ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ៖***

- ត្រូវបំពេញ និងដាក់លិខិតប្រកាសបងពន្ធចំនួន ០២សន្លឹក ទៅតាមទម្រង់ដែលចេញដោយអគ្គនាយអគ្គនាយកដ្ឋានពន្ធដារដោយភ្ជាប់មកជាមួយនូវឯកសារ បង់ពន្ធឆ្នាំចុងក្រោយ
- ករណីបាត់ឯកសារបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំនោះ ម្ចាស់យានយន្តត្រូវយកប័ណ្ណសម្គាល់យានយន្តមក បង្ហាញមន្ត្រីពន្ធដារទទួលបន្ទុកនៅសាខាពន្ធដារខេត្ត-ខណ្ឌពិនិត្យ និងផ្ទៀងផ្ទាត់ទិន្ន័យក្នុងប្រព័ន្ធ គ្រប់គ្រងពន្ធមធ្យោបាយរបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីបញ្ជាក់អំពីការបង់ពន្ធ ។ នៅក្នុងពេលពិនិត្យឃើញថា យានយន្តនេះ បានបង់ពន្ធពិតប្រាកដមែន ម្ចាស់យានយន្ត ត្រូវដាក់ស្នើសុំលិខិតបញ្ជាក់ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទនៃឆ្នាំកន្លងមក សម្រាប់ជំនួសឯកសារដែលបានបាត់ ទើបអនុញ្ញាតឲ្យបង់ពន្ធសម្រាប់ឆ្នាំបច្ចុប្បន្ន ។

➢ ***ចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដែលទើបមកប្រកាសបង់ពន្ធលើកដំបូង ៖***

ត្រូវបំពេញ និងដាក់លិខិតប្រកាសបង់ពន្ធចំនួន ០២សន្លឹក តាមទម្រង់ដែលចេញ ដោយស្ថាប័នអគ្គនាយកដ្ឋានពន្ធដារ និងភ្ជាប់មកជាមួយនូវឯកសារ ដូចខាងក្រោម ៖

- ប័ណ្ណសម្គាល់យានយន្ត ឬ
- វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ដែលចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន ឬ
- បង្កាន់ដៃបងពន្ធនាំចូល ឬ
- លិខិតបញ្ជាក់ការប្រើប្រាស់យានយន្តចេញដោយឃុំ សង្កាត់ ចំពោះយានយន្តកែឆ្នៃក្នុងស្រុក និង
- វិញ្ញាបនបត្រអាករលើតម្លៃបន្ថែម។

➢ ***ចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដែលបានបង់ពន្ធឆ្នាំ កន្លងមក ហើយត្រូវបានប្តូរប័ណ្ណសម្គាល់យានយន្តថ្មី ៖***

  - ម្ចាស់យានយន្តត្រូវធ្វើបច្ចុប្បន្នភាពពត៌មានយានយន្ត នៅសាខាពន្ធដារខេត្ត- ខណ្ឌណាមួយ ដើម្បីប្រកាសបង់ពន្ធបន្ត និង
  - ប្តូរប័ណ្ណសម្គាល់ការបង់ពន្ធក្នុងករណីរថយន្តនោះត្រូវបានប្តូរពត៌មាន ដូចជាផ្លាកលេខ ឬម៉ាស៊ីន... ។

ប៉ុន្តែបើមានការរកឃើញថាមានមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទទាំងឡាយណាដែលមិនបានបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទនៅក្នុងឆ្នាំកន្លងមក ក្រុមហ៊ុនត្រូវធ្វើការបង់ប្រាក់ពន្ធ និងប្រាក់ពិន័យតាមបណ្តាលឆ្នាំទាំងនោះឲ្យបានរួចរាល់ ជាមុនសិនទើបអាចអនុញ្ញាតឲ្យធ្វើការបងពន្ធសម្រាប់ឆ្នាំបច្ចុប្បន្ន ។[83]

[83] ចំណុច III នៃសេចក្តីណែនាំ ស្តីពីការអនុវត្តប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទប្រចាំឆ្នាំ ចុះថ្ងៃទី២២ មិថុនា ២០១៨

☞ សំគាល់ ៖ ចំពោះមធ្យោបាយដឹកជញ្ជូន និង យាជំនិះគ្រប់ប្រភេទទាំងឡាយណា ដែលមានបង្កាន់ដៃបង់ពន្ធនាំចូលដែលចេញក្នុងខែធ្នូ ត្រូវបានអនុញ្ញាតឲ្យបង់ពន្ធនៅក្នុងឆ្នាំបន្ទាប់ ។ ការអនុញ្ញាត នេះមិនមានអានុភាពប្រតិសកម្មចំពោះប្រាក់ពន្ធដែលបានបង់រួចហើយនោះទេ ។ ការ អនុញ្ញាតនេះ គឺទទួលស្គាល់តែការបរច្ឆេតនៃបង្កាន់ដៃបងពន្ធនាំចូល តែប៉ុណ្ណោះ ។

ដើម្បីមានភាពងាយស្រួលក្នុងការប្រកាសបង់ពន្ធប្រភេទនេះ នៅឆ្នាំបន្តបន្ទាប់ខាងមុខម្ចាស់យានយន្តអាចស្នើសុំធ្វើប័ណ្ណសម្គាល់ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ ប្រភេទ ដោយគ្រាន់តែ គូសក្នុងប្រអប់ដូចមានបង្ហាញក្នុងលិខិតប្រកាសបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ។ ការស្នើសុំបោះពុម្ពប័ណ្ណនេះ ក្រុមហ៊ុនត្រូវធ្វើការបង់ថ្លៃសេវាចំនួន ៥០០០ ៛ ។

**២. អត្រាពន្ធ និង ការគណនាប្រាក់ពន្ធ**

- ***ការកំណត់ប្រាក់ពន្ធតាមប្រភេទមធ្យោបាយ ដឹកជញ្ជូន ក្រៅពីរថយន្តទេសចរណ៍***

ដោយអនុលោមតាម ឧបសម្ព័ន្ធ I ស្តីពីការកំណត់ប្រាក់ពន្ធតាមប្រភេទមធ្យោបាយ ដឹកជញ្ជូន ក្រៅពីរថយន្តទេសចរណ៍ នៃប្រកាសស្តីពី«ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទប្រចាំឆ្នាំ» ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨ ។ មាននៅក្នុងឧបសម្ព័ន្ធ នៃសៀវភៅនេះ ។

- ***ការកំណត់ប្រាក់ពន្ធតាម ទំហំស៊ីឡាំងរបស់ រថយន្តទេសចរណ៍***

ដោយអនុលោមតាម ឧបសម្ព័ន្ធ II ស្តីពីការកំណត់ប្រាក់ពន្ធតាម ទំហំស៊ីឡាំងរបស់រថយន្តទេសចរណ៍នៃប្រកាសស្តីពី «ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទប្រចាំឆ្នាំ» ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨ បានធ្វើការកំណត់ដូចតទៅ ៖

ឯកតា ÷ រៀល

| ល.រ | ទំហំស៊ីឡាំងគិតជា ស.ម³ "CC" | គិតពីឆ្នាំផលិត | | |
|---|---|---|---|---|
| | | ដល់ ៥ឆ្នាំ | លើសពី៥ឆ្នាំ ដល់១០ឆ្នាំ | លើសពី ១០ឆ្នាំ |
| ១ | ដល់ ១ ៥០០ស.ម³ | ១៥០ ០០០ | ១០០ ០០០ | ៨០ ០០០ |
| ២ | លើសពី ១ ៥០០ស.ម³ ដល់ ២ ០០០ស.ម³ | ២០០ ០០០ | ១៥០ ០០០ | ១០០ ០០០ |
| ៣ | លើសពី ២ ០០០ស.ម³ ដល់ ២ ៩០០ស.ម³ | ៦០០ ០០០ | ៤០០ ០០០ | ២៥០ ០០០ |
| ៤ | លើសពី ២ ៩០០ស.ម³ ដល់ ៤ ០០០ស.ម³ | ១ ៦០០ ០០០ | ១ ០០០ ០០០ | ៦០០ ០០០ |
| ៥ | លើសពី ៤ ០០០ស.ម³ ឡើងទៅ | ២ ០០០ ០០០ | ១ ២០០ ០០០ | ៨០០ ០០០ |

## ផ្នែកទី ០៣ ៖ ការទទួលបានការអនុវត្តពន្ធពិសេស សម្រាប់អ្នកជាប់ពន្ធ

### កថាខណ្ឌទី ០១ ៖ ការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់វិស័យអទិភាព

រាល់សកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត សុទ្ធសឹងតែជាកម្មវត្ថុនៃការប្រមូលពន្ធ ដែលជាប្រភពចំណូលក្នុងការអភិវឌ្ឍន៍ជាតិ ។ ប៉ុន្តែបើទោះបីជាគ្រប់សកម្មភាពអាជីវកម្មនៃនីតិបុគ្គលនេះ គឺជាកម្មវត្ថុនៃការប្រមូលពន្ធក៏ដោយ ក៏នីតិបុគ្គលនេះនៅតែមានឱកាសក្នុងការទទួលបានការលើលែកពន្ធ តាមរយៈការលើកទឹកចិត្តផ្នែកពន្ធដារ ។ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតនឹងទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារ នៅពេលដែលការដំណើរការសកម្មភាពអាជីវកម្មរបស់នីតិបុគ្គលនេះ បានប្រព្រឹត្តិទៅក្នុងទម្រង់ពីរខាងក្រោម ៖

- ការទទួលបានការលើទឹកចិត្តចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្ត
- ការទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារក្នុងវិស័យអាទិភាព

#### ក. ការទទួលបានការលើកទឹកចិត្តចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្ត

#### ១. កម្មវត្ថុនៃការទទួលបានការលើកទឹកចិត្តចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្ត

នៅថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០០៧ អនុក្រឹត្យស្តីពី “ ការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្តរបស់សហគ្រាសធុនតូច និង សហគ្រាសធុនមធ្យម” បានលេចរូបរាងឡើងក្នុងគោលបំណងដាក់ចេញនូវវិធានការលើកទឹកចិត្តផ្នែកពន្ធដាររបស់រាជរដ្ឋាភិបាល ដើម្បីចូលរួមជាចំណែកអភិវឌ្ឍន៍សហគ្រាសធុនតូច និង សហគ្រាសធុនមធ្យម តារយៈការចុះបញ្ជីដោយស្ម័គ្រចិត្ត ។[84] ការធ្វើបែបនេះ គឺមានគោលដៅកំណត់នូវយន្តការលើកទឹកចិត្តផ្នែកពន្ធដារដល់សហគ្រាស ធុនតូច និងសហគ្រាសធុនមធ្យម ដែលពុំទាន់បានចុះបញ្ជីពន្ធដាដោយស្ម័គ្រចិត្ត មកចុះបញ្ជីបំពេញកាតព្វកិច្ចសារពើពន្ធ ដើម្បីបង្កើតបរិយាកាសបង់ពន្ធ ប្រកបដោយតម្លាភាព និងសមធម៌ ។[85]

[84] មាត្រា ១ នៃអនុក្រឹត្យស្តីពី ការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្តរបស់សហគ្រាសធុនតូច និង សហគ្រាសធុនមធ្យម ចុះថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១៧

[85] មាត្រា ២ នៃអនុក្រឹត្យស្តីពី ការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្តរបស់សហគ្រាសធុនតូច និង សហគ្រាសធុនមធ្យម ចុះថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១៧

ដូចដែលធ្លាប់បានរៀបរាប់នៅខាងលើ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតត្រូវបានកំណត់ថាជានីតិបុគ្គលដែលស្ថិតក្នុងចំណាត់ថ្នាក់ជាអ្នកជាប់ពន្ធមធ្យម ដូចនេះក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មានសិទ្ធិគ្រប់គ្រាន់ក្នុងការទទួលបានការលើកទឹកចិត្តតាមរយៈអនុក្រឹត្តនេះ ។

**២. លក្ខខ័ណ្ឌក្នុងការទទួលបានការលើកលែងពន្ធ**

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត អាចទទួលបានការលើកលែងពន្ធនេះក្នុងនាមតែជាអ្នកជាប់ពន្ធមធ្យម ដែលបានចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្តក្នុងអំឡុងពេលចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៧ រហូតដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ តែប៉ុណ្ណោះ ។[86] ការលើកទឹកចិត្តផ្នែកពន្ធដារ មានដូចខាងក្រោម ៖[87]

- ✓ ត្រូវបានលើកលែងពន្ធលើប្រាក់ចំណូលចំនួន ២ឆ្នាំ ដោយគិតចាប់ពីឆ្នាំដែលទទួលបានប្រាក់ចំណូលដំបូងចំពោះករណីនីតិបុគ្គលនេះពុំទាន់មានប្រាក់ចំណូល ឬចាប់ពីឆ្នាំដែលចុះបញ្ជីពន្ធដារចំពោះក្រុមហ៊ុនដែលមានប្រាក់ចំណូលរួចហើយ ។
- ✓ ក្នុងរយៈពេលទទួលបានលើកលែងពន្ធលើប្រាក់ចំណូលនេះ ក្រុមហ៊ុនឯកជនទទួល-ខុសត្រូវមានកម្រិត ត្រូវបានលើកលែងពីការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា ។

ដើម្បីឲ្យការលើកទឹកចិត្តផ្នែកពន្ធដារនេះអនុវត្តដោយប្រសិទ្ធភាពខ្ពស់ ក្រុមហ៊ុនឯកជនទទួល-ខុសត្រូវមានកម្រិត ត្រូវមានលិខិតបញ្ជាក់អំពីការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត ព្រមទាំងការលើកទឹកចិត្ត ដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ ។[88] ចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្តក្នុងឆ្នាំ២០១៧ ដែលបានធ្វើឡើងមុនការបរិច្ឆេតនៃការចេញប្រកាសលេខ ៥០២ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែមេសា

[86] ចំនុច ២ នៃសេចក្តីណែនាំស្តីពីការអនុវត្តការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះសហគ្រាសធុនតូចនិងសហគ្រាសធុនមធ្យមដែលបានចុះបញ្ជីដោយស្ម័គ្រចិត្ត ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧

[87] មាត្រា ៥ នៃអនុក្រឹត្យស្តីពី ការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្តរបស់សហគ្រាសធុនតូច និងសហគ្រាសធុនមធ្យម ចុះថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១៧

[88] ចំណុច ៣ នៃសេចក្តីណែនាំស្តីពីការអនុវត្តការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះសហគ្រាសធុនតូច និងសហគ្រាសធុនមធ្យមដែលបានចុះបញ្ជីដោយស្ម័គ្រចិត្ត ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧

ឆ្នាំ២០១៧ ក៏ត្រូវទទួលបានការលើកទឹកចិត្តដូចគ្នាដែរ ប៉ុន្តែ ប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំខែដែលបានដាក់លិខិតប្រកាស និង បង់រួចមុន នឹងទទួលបានលិខិតបញ្ជាក់ការលើកទឹកចិត្តផ្នែកពន្ធដារ មិនត្រូវបានអនុញ្ញាតជាឥណទានទេ ។[89]

### ៣. ការតព្វកិច្ចសារពើពន្ធ

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំទៅតាមកាលកំណត់ជូនរដ្ឋបាលសារពើពន្ធ ទោះបីជាត្រូវបានលើកលែងពន្ធលើប្រាក់ចំណូលដូចបានលើកឡើងខាងលើ ត្រូវដាក់លិខិតប្រកាសបង់ពន្ធអាករដទៃទៀតតាមច្បាប់ និង បទប្បញ្ញត្តិស្តីពីពន្ធដារ ។[90] ចំពោះក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ក្នុងករណីដែលខកខានមិនបានចុះបញ្ជីពន្ធដារ ត្រូវចាត់ទុកថាបានប្រព្រឹត្តអំពើរាំងស្ទះ និងត្រូវអនុវត្តដោយម៉ឺងម៉ាត់តាមតាមច្បាប់ស្តីពីសារពើពន្ធ ។[91]

បន្ទាប់ពីផុតរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតត្រូវបង់ពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមាទៅតាមលក្ខខណ្ឌដែលកំណត់ ។[92]

## ខ. ការទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារក្នុងវិស័យអាទិភាព

### ១. កម្មវត្ថុនៃការទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារក្នុងវិស័អាទិភាព

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត នឹងទទួលបានការលើកលែងផ្នែពន្ធដារចំពោះវិស័យអាទិភាព គឺចំពោះតែក្នុងនាមជាអ្នកជាប់ពន្ធមធ្យមតែប៉ុណ្ណោះ ។ គោលបំណងនៃការដាក់ឲ្យប្រើប្រាស់

[89] ចំណុច ៤ នៃសេចក្តីណែនាំស្តីពីការអនុវត្តការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះសហគ្រាសធុនតូច និងសហ គ្រាសធុនមធ្យមដែលបានចុះបញ្ជីដោយស្ម័គ្រចិត្ត ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧

[90] មាត្រា ៦ នៃអអនុក្រឹត្យស្តីពី ការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្តរបស់សហគ្រាសធុនតូច និងសហគ្រាសធុនមធ្យម ចុះថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១៧

[91] មាត្រា ៧ នៃអអនុក្រឹត្យស្តីពី ការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្តរបស់សហគ្រាសធុនតូច និងសហគ្រាសធុនមធ្យម ចុះថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១៧

[92] មាត្រា ៥ នៃអអនុក្រឹត្យស្តីពី ការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្តរបស់សហគ្រាសធុនតូច និងសហគ្រាសធុនមធ្យម ចុះថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១៧

ការលើកទឹកចិត្តផ្នែកពន្ធដារចំពោះវិស័យអាទិភាពនេះ គឺមានគោលបំណងលើកកម្ពស់ការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ដើម្បីបង្កើតការងារ ព្រមទាំងបង្កើនសមត្ថភាពផលិតកម្មក្នុងស្រុក ។[93] ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតអាចទទួលបានការលើលែងតាមច្បាប់នេះ ប្រសិនបើកម្មវត្ថុអាជីវកម្មរបស់នីតិបុគ្គលនេះ គឺជាប្រភេទអាជីវកម្មដែលជាវិស័យអាទិភាព ។ វិស័យអាទិភាពត្រូវបានកំណត់ដូចខាងក្រោម ៖[94]

- ✓ ផលិតផលកសិកម្ម ឬកសិ-ឧស្សាហកម្ម
- ✓ ផលិត និងកែច្នៃម្ហូបអាហារ
- ✓ កម្មន្តសាលដែលផលិតទំនិញប្រើប្រាស់ក្នុងស្រុក, កែច្នៃកាកសំណល់, និងផលិតទំនិញសម្រាប់វិស័យទេសចរណ៍
- ✓ កម្មន្តសាលដែលផលិតនូវផលិតផលសម្រេច ឬផ្នែក ឬគ្រឿងបង្គុំ ដើម្បីផ្គត់ផ្គង់ឲ្យកម្មន្តសាលដទៃទៀត
- ✓ ស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាពត៌មាន រួមទាំងការផ្គត់ផ្គង់សេវាគ្រប់គ្រងតាមប្រព័ន្ធបច្ចេកវិទ្យាពត៌មាន ដែលមានលក្ខណៈនវានុវត្តន៍
- ✓ សហគ្រាសដែលស្ថិតក្នុងតំបន់ប្រមូលផ្តុំសហគ្រាសតូច និងមធ្យម និងសហគ្រាសដែលអភិវឌ្ឍតំបន់នេះ។

វិស័យអាទិភាពនេះ មិនរួមបញ្ចូលវិស័យដែលប៉ះពាល់ដល់សន្តិសុខសង្គម សុខភាព បរិស្ថាន ។

### ២. ការលើទឹកចិត្តផ្នែកពន្ធដារ

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដែលបានបំពេញនូវលក្ខខណ្ឌខាងលើ នឹងទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារដូចខាងក្រោម ៖

- ការលើកលែងពន្ធលើប្រាក់ចំណូលរយៈពេល ៣ឆ្នាំ ដោយគិតចាប់ពីថ្ងៃ ដែលចុះបញ្ជីពន្ធដារសម្រាប់ការចុះបញ្ជីថ្មី ឬចាប់ពីថ្ងៃដែលនីតិបុគ្គលនោះ បានមកធ្វើបច្ចុប្បន្នកម្ម

[93] មាត្រា ១ នៃអនុក្រឹត្យស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់សហគ្រាសធុនតូច និងមធ្យម ក្នុងវិស័យអាទិភាព ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៨

[94] មាត្រា ៥ នៃអនុក្រឹត្យស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់សហគ្រាសធុនតូច និងមធ្យម ក្នុងវិស័យអាទិភាព ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៨

សម្រាប់ក្រុមហ៊ុនដែលបានចុះបញ្ជីពន្ធដាររួចហើយ ចាប់ពីពេល ដែលអនុក្រឹត្យស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់សហគ្រាសធុនតូច និង មធ្យមក្នុងវិស័យអាទិភាព ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៨ ចូលជាធរមាន ឬ

- លើលែងពន្ធលើប្រាក់ចំណូលរយៈពេល ៥ ឆ្នាំ ដោយគិតចាប់ពីថ្ងៃ ដែលចុះបញ្ជីពន្ធដារសម្រាប់ក្រុមហ៊ុនចុះបញ្ជីថ្មី ឬចាប់ពីថ្ងៃដែលសហគ្រាសមកធ្វើបច្ចុប្បន្នកម្មសម្រាប់ក្រុមហ៊ុនដែលបានចុះបញ្ជីពន្ធដាររួចហើយ ចាប់ពីពេលអនុក្រឹត្យខាងលើចូលជាធរមាន ដែលបំពេញលក្ខខណ្ឌណាមួយដូចខាងក្រោម ៖[95]

✓ ប្រើវត្ថុធាតុដើមក្នុងស្រុក ចាប់ពី ៦០% ឡើងទៅ ឬ

✓ បង្កើនចំនួននិយោជិតបន្ថែមយ៉ាងតិច ២០% ឬ

✓ មានទីតាំងក្នុងតំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យម(SME Cluster)

នៅក្នុងរយៈពេលនៃការលើកលែងពន្ធលើប្រាក់ចំណូល ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត នឹងទទួលបានលើកលែងការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បរមាដែរ ។ ក្រៅពីទទួលបានការលើកលែងក្នុងការបង់ពន្ធលើប្រាក់ចំណូលហើយ នីតិបុគ្គលនេះក៏នឹងទទួលបានការលើកទឹងចិត្តបន្ថែមទៀតចំពោះចំណាយដែលអាចកាត់កងបាន ។ ការលើកទឹកចិត្តទាំងនេះ មានដូចជា ៖

✓ អនុញ្ញាតកាត់កងចំណាយ ២០០% ចំពោះចំណាយលើការប្រើប្រាសបញ្ជីគណនេយ្យតាមប្រព័ន្ធបច្ចេកវិទ្យាពត៌មាន

✓ អនុញ្ញាតកាត់កងចំណាយ ២០០% ចំពោះចំណាយលើការបណ្តុះបណ្តាលការកាន់កាប់បញ្ជីគណនេយ្យ ឬការបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់និយោជិត

✓ អនុញ្ញាតកាត់កងចំណាយ ១៥០% ចំពោះចំណាយវិនិយោគលើម៉ាស៊ីន ឬឧបករណ៍បច្ចេកវិទ្យា ដែលមានល្ខណៈនវានុវត្តន៍សម្រាប់បម្រើ និងលើកកម្ពស់ផលិតភាពផលិតកម្ម ។

## ៣. កាតព្វកិច្ចសារពើពន្ធ

[95] មាត្រា ៦ នៃអនុក្រឹត្យស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់សហគ្រាសធុនតូច និងមធ្យម ក្នុងវិស័យអាទិភាព ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៨

ក្នុងការទទួលបានការលើកលែង និងលើកទឹកចិត្តដូចបានរៀបរាប់ខាងលើ, ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវកាន់កាប់បញ្ជីគណនេយ្យ និងដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ទៅតាមកាលកំណត់ជូនរដ្ឋបាលសារពើពន្ធ ទោះបីជាត្រូវបានលើកលែងពន្ធលើប្រាក់ចំណូល និងត្រូវដាក់លិខិតប្រកាសបង់ពន្ធអាករដទៃទៀតតាមច្បាប់ និងបទប្បញ្ញត្តិស្ដីពីពន្ធដារជាធរមាន ។ ផ្ទុយទៅវិញ បើនីតិបុគ្គលនេះ មិនបានបំពេញលក្ខខណ្ឌដូចបានកំណត់នៅក្នុងអនុក្រឹត្យនេះ ឬខកខានមិនបានបំពេញកាតព្វកិច្ចសារពើពន្ធនានា ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិស្ដីពីពន្ធដារ ការលើកទឹកចិត្តដែលបានផ្តល់ជូននឹងត្រូវបានដកហូតវិញ ។[96]

### គ. ការលើកទឹកចិត្តពន្ធបន្ថែមចំពោះការដាំដុះស្រូវ ការប្រមូលទិញស្រូវ និង ការផលិតអង្ករនាំចេញ

ស្របតាមគោលនយោបាយស្ដីពីការជំរុញផលិតកម្មស្រូវអង្ករ និង ការនាំចេញស្រូវអង្កររបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ចេញនូវយន្តការលើកទឹកចិត្តពន្ធ ចំពោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា ចំពោះសហគ្រាសដាំដុះស្រូវ ប្រមូលទិញស្រូវ និងផលិតផលអង្ករនាំចេញ ដូចខាងក្រោម ៖[97]

- លើកលែងពន្ធអប្បរមា ១% លើផលរបរប្រចាំឆ្នាំ ។
- រយៈពេលលើកលែងពន្ធលើប្រាក់ចំណូលជាអតិបរមាដែលក្នុងនោះមាន ៖ រយៈពេលគន្លឹះបូករយៈពេល ៣ឆ្នាំ បូកនឹងរយៈពេលអទិភាព ៣ឆ្នាំ ។

ដើម្បីទទួលបានការលើកទឹកចិត្ត ពន្ធលើប្រាក់ចំណេញ និងពន្ធអប្បរមា ដូចមានបានកំណត់ខាងលើនេះ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដែលដាំដុះស្រូវ ប្រមូលទិញស្រូវ និងផលិតអង្ករនាំចេញត្រូវស្នើសុំ ចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារ ។ បន្ទាប់ពីក្រុមហ៊ុនទទួលបានការលើក

[96] មាត្រា ៨ នៃអនុក្រឹត្យស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់សហគ្រាសធុនតូច និងមធ្យម ក្នុងវិស័យអាទិភាព ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៨

[97] ប្រការ១ នៃប្រកាសស្តីពីការលើកទឹកចិត្តពន្ធបន្ថែមចំពោះការដាំដុះស្រូវ ការប្រមូលទិញស្រូវ និងការផលិតអង្ករនាំចេញ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១

ទឹកចិត្តដូចខាងលើ នីតិបុគ្គលនោះត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ ប្រចាំឆ្នាំ និងបង់ប្រាក់ពន្ធ ឬអាករដទៃទៀត ស្របតាមបទប្បញ្ញត្តិស្តីពីសារពើពន្ធជាធរមាន ។ [98]

## កថាខណ្ឌទី ០២ ៖ ការលើកទឹកចិត្តផ្នែកពន្ធសម្រាប់គម្រោងវនិយោគមានលក្ខណៈ សម្បត្តគ្រប់គ្រាន់

### ក. កម្មវត្ថុនៃការទទួលបានការលើកទឹកចិត្ត

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ហៅកាត់ថា (គ.ល.គ) មានន័យថាជា គម្រោងវិនិយោគដែលទទួលបានវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ ។ ដើម្បីទទួលស្គាល់ជា គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អ្នកវិនិយោគត្រូវដាក់សំណើវិនិយោគនៅ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក) ឬ អនុគណៈកម្មាធិការវិនិយោគ ខេត្ត រាជធានី និងទទួលបានវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ ។ គម្រោងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មាន បីប្រភេទគឺ ៖

- គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ បម្រើទីផ្សារក្នុងស្រុក
- គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឲ្យការនាំចេញ
- គម្រោងវិនិយោគ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាឧស្សាហកម្មគាំទ្រ។

ចំពោះក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតមួយ ដើម្បីទទួលបានគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ឬហៅកាត់ថា "គ.ល.គ" ដែលមានសិទ្ធិទទួលការលើកទឹកចិត្តវិនិយោគគឺត្រូវមានដើមទុនវិនិយោគលើសពី ១.០០០.០០០ (មួយលាន) ដុល្លារអាមេរិកហើយចំនួនដើមទុនវិនិយោគច្រើនជាងកម្រិតកំណត់នេះ ជាទូទៅតម្រូវអោយមាន។ "គ.ល.គ" និងតម្រូវឱ្យចុះបញ្ជីវិនិយោគនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា "ក.អ.ក" ឬនៅអនុគណាធម្មាធិការវិនិយោគខេត្ត-ក្រុង "អ.គ.វ.ខ.ក" អាស្រ័យលើប្រភេទនៃការវិនិយោគ ។ នៅក្នុងពេលដែលក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ទទួលបាននីតិបុគ្គលិកលក្ខណៈ ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្រុមហ៊ុន នឹងទទួលបានការលើចិត្តពីច្បាប់ចំពោះការ បង់ពន្ធ ។

### ខ. ការលើកទឹកចិត្តផ្នែកពន្ធដារ

[98] ប្រការ២ នៃប្រកាសស្តីពីការលើកទឹកចិត្តពន្ធបន្ថែមចំពោះការដាំដុះស្រូវ ការប្រមូលទិញស្រូវ និងការផលិតអង្ករនាំចេញ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១

ក្នុងនាមក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដែលទទួលបាននីតិបុគ្គលិកលក្ខណៈជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្រុមហ៊ុនអាចនឹងទទួលបានការលើលែងផ្នែកពន្ធដារលើកលែងពន្ធលើប្រាក់ចំណូល។

- រយៈពេលនៃការលើកលែងពន្ធរួមមាន ៖[99]

រយៈពេលគន្លឹះ + រយៈពេល៣ឆ្នាំ +រយៈពេលអទិភាព

- ***រយៈពេលគន្លិះ*** គឺចាប់ផ្ដើមចេញពីថ្ងៃចេញវិញ្ញាបនបត្រចុះបញ្ជីស្ថាពរ និងនៅថ្ងៃចុងក្រោយនៃឆ្នាំសារពើពន្ធណាមួយដែលឆាប់ជាង៖
    - មានប្រាក់ចំណេញដំបូង
    - មានប្រាក់ចំណូល(ផលរបរ)៣ឆ្នាំ គិតចាប់ពីមានប្រាក់ចំណូលដំបូង
- ***រយៈពេល៣ឆ្នាំ*** គឺចាប់ផ្ដើមគិតភ្លាមពីឆ្នាំសារពើពន្ធ បន្ទាប់ពីរយៈពេលឆ្នាំគន្លឹះ និង ២ឆ្នាំបន្ទាប់មកទៀត ។[100]
- ***រយៈពេលអាទិភាព*** ត្រូវចាប់ផ្ដើមគិតភ្លាមបន្ទាប់ពីឆ្នាំសារពើពន្ធទី៣នៃរយៈពេល០៣ឆ្នាំ ។[101]

ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ សម្រាប់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលបានចុះបញ្ជីក្រោយថ្ងៃប្រកាសឲ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីវិនិយោគ ៖ ប្រាក់រំដោះពន្ធលើប្រាក់ចំណូលមិនត្រូវអនុវត្តចំពោះគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលទទួលបានការលើកលែងពន្ធលើប្រាក់ចំណូល។[102]

[99] មាត្រា ១៤ ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីវិនិយោគកម្ពុជា ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣

[100] មាត្រា ១៥.៣ នៃអនុក្រឹត្យស្ដីពី ការអនុវត្តច្បាប់ស្ដីពីវិសោធនកម្ម នៃច្បាប់ស្ដីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥

[101] មាត្រា ១៥.៤ នៃអនុក្រឹត្យស្ដីពី ការអនុវត្តច្បាប់ស្ដីពីវិសោធនកម្ម នៃច្បាប់ស្ដីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥

[102] មាត្រា ១៥.៥ នៃអនុក្រឹត្យស្ដីពី ការអនុវត្តច្បាប់ស្ដីពីវិសោធនកម្ម នៃច្បាប់ស្ដីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥

# ជំពូកទី ០២
# ការទទួលខុសត្រូវរបស់
# ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតចំពោះអាករ

# ជំពូកទី ០២ ៖ ការទទួលខុសត្រូវរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ចំពោះអាករ

## ផ្នែកទី ០១ ៖ កាតព្វកិច្ចប្រមូលអាករពីការផ្គត់ផ្គង់ និងការដាក់លិខិតប្រកាស និងបង់ប្រាក់អាករ ស្របតាមសកម្មភាពអាជីវកម្ម

ចំពោះអាករ កាតព្វកិច្ចដែលក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មាន គឺមិនខុសពីកាតព្វកិច្ចដូចបានបង្ហាញក្នុងកថាខណ្ឌ ២ នៃជំពូកទី១ ខាងលើនោះទេ។ ប៉ុន្តែកាតព្វកិច្ចសំខាន់ៗដែលក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតត្រូវប្រតិបត្តិ ចំពោះវិស័យអាករ នោះគឺ ធ្វើការចុះបញ្ជីអាករលើតម្លៃបន្ថែម, ធ្វើការប្រមូលប្រាក់អាករពីរាល់សកម្មភាពអាជីវកម្មគ្រប់ប្រភេទដែលបានផ្គត់ផ្គង់, ដាក់លិខិតប្រកាសអាករជាប្រចាំខែ និងបង់ប្រាក់អាករជូនអគ្គនាយកដ្ឋានពន្ធដារ ទៅតាមពេលវេលា និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់ វៀរលែងតែមានអនុគ្រោះ ឬ ការអនុវត្តពិសេសទៅលើប្រភេទអាករនីមួយៗតែប៉ុណ្ណោះ ទើបក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ពុំមានកិច្ចការងារលើកិច្ចទាំងនោះ។

### កថាខណ្ឌទី ០១ ៖ ប្រភេទនៃអាករ ទទួលបន្ទុក

#### ក. អាករលើតំលៃបន្ថែម

អនុឡោមតាមច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧ អាករលើតំលៃបន្ថែម ត្រូវបានបង្កើតអោយប្រើប្រាស់ដើម្បីជាគុណប្រយោជន៍ដល់ថវិការដ្ឋ នៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៨ ហើយចាប់ផ្តើមអនុវត្តនៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៩[103] លើការផ្គត់ផ្គង់ទំនិញឬសេវាកម្ម[104] ជាប់អាករ នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ អាករលើតំលៃបន្ថែម ឬអាចហៅកាត់បានថា **(អ.ត.ប)**[105] ជាប្រភេទអាករនៃអាករឯទៀតដែល **(អ.ត.ប)** នេះជាប្រភេទពន្ធប្រយោល ដែលអ្នកជាប់អាករតាមរបបពិត ឬរបបស្វ័យប្រកាស[106] មានកាតព្វកិច្ចក្នុងការចុះបញ្ជី, ប្រមូលប្រាក់អាករ, បង់ប្រាក់អាករ, និងដាក់លិខិតប្រកាសជារៀងរាល់ខែ។

---

[103] បទបង្ហាញស្តីពីអាករលើតម្លៃបន្ថែម រៀបរៀងដោយអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[104] កថាខណ្ឌ ១. ,២ មាត្រា ៥៦ និយមន័យ ជំពូកទី ៣ ស្តីពី (អ.ត.ប) នៃច្បាប់ស្តីពីសារពើពន្ធ- សេវាកម្ម ដំដៅដល់ការផ្តល់អ្វីមួយដែលមានតម្លៃក្រៅពីទំនិញ ដីធ្លី និងប្រាក់កាស។ ទំនិញសំដៅដល់ទ្រព្យរូបី ក្រៅពីដីធ្លី និង ប្រាក់កាស

[105] មាត្រា ១. ជំពូកទី ០១ នៃអនុក្រឹត្យស្តីពីអាករលើតំលៃ បន្ថែមលេខ ១១៤ អនក្រ.ប្រក ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៩

[106] មាត្រា ៩. ជំពូកទី ០៣ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ចុះថ្ងៃទី ១៤ ធ្នូ ២០១៦ នស/រកម/១២១៦/០១៩

### ក.១. បុគ្គលជាប់អាករ

បុគ្គលជាប់អាករ គឺសំដៅដល់បុគ្គលដែលត្រូវជាប់ពន្ធតាមរបបពិត ឬរបបស្វ័យប្រកាស ហើយដែលធ្វើការផ្គត់ផ្គង់ជាប់អាករ ដូចមានចែងក្នុងមាត្រា ៦០ នៃច្បាប់សារពើពន្ធឆ្នាំ ១៩៩៧។ តាមរយៈបទបញ្ញាត្តិសារពើពន្ធ បុគ្គលជាប់អាករតាមរបបពិត ឬរបបស្វ័យប្រកាស ទាំងនោះរួមមានដូចជា៖ [107]

ក. ក្រុមហ៊ុនគ្រប់ប្រភេទ សហគ្រាសនិហ័រណអាហ័រណ និងសហគ្រាសវិនិយោគទាំងអស់

ខ. សហគ្រាសដទៃទៀតដែលមាន ៣ ចំណាត់ថ្នាក់ ជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលមានផលរបរប្រចាំឆ្នាំពីការផ្គត់ផ្គង់ទំនិញ ឬសេវាដូចជា៖

- អ្នកជាប់ពន្ធតូច ជាសហគ្រាសឯកបុគ្គល ឬ សហគ្រាសសហកម្មសិទ្ធិដែលមាន:
  - ☞ មានផលរបរប្រចាំឆ្នាំចាប់ពី ២៥០ លានរៀល ដល់ ៧០០លានរៀល
  - ☞ មានផលរបរក្នុងរយៈពេល ៣ ខែ ជាប់គ្នាណាមួយ ដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្ត ចាប់ពី ៦០ លានរៀល ឬ
  - ☞ រំពឹងថាមានផលរបរក្នុងរយៈពេល បី ខែ ជាប់គ្នាខាងមុខ ចាប់ពី ៦០លានរៀល ឡើងទៅ ឬ
  - ☞ ចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងថ្លៃ ក្នុងការផ្គត់ផ្គង់ទំនិញឬសេវា រួមទាំងភាស៊ី។
- អ្នកជាប់ពន្ធមធ្យម គឺជា:
  - ☞ សហគ្រាសដែលមានផលរបរប្រចាំឆ្នាំលើសពី ៧០០ លានរៀល ដល់ ៤០០០ លានរៀល
  - ☞ សហគ្រាសដែលបានចុះបញ្ជីជានីតិបុគ្គល ការិយាល័យទំណាង ឬ
  - ☞ ស្ថាប័នរដ្ឋថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការឬសមាគមគ្រប់ប្រភេទរួមទាំងអង្គការ មិនមែនរដ្ឋាភិបាល ឬ
  - ☞ បេសកម្មទូតនិងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិ-ការបច្ចេកទេសរបស់រដ្ឋាភិបាលនានា។
- អ្នកជាប់ពន្ធធំ គឺជា:
  - ☞ សហគ្រាសដែលមានផលរបរប្រចាំឆ្នាំលើសពី ៤០០០លានរៀល ឬ
  - ☞ បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនពហុជាតិ សាខាក្រុមហ៊ុនបរទេស ឬ
  - ☞ សហគ្រាសដែលបានចុះបញ្ជី ជាគម្រោងវិនិយោគដែលមានលក្ខណ: សម្បត្តិគ្រប់គ្រាន់។[108]

[107] មាត្រា ២. កថាខណ្ឌ ០១ ជំពូកទី ២ នៃអនុក្រឹត្យស្តីពីអាករលើតំលៃ បន្ថែមលេខ ១១៤ អនក្រ.ប្រក ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៩

គ. សហគ្រាសដទៃទៀតអាចចុះបញ្ជី អតប ដោយស្ម័គ្រចិត្ត ប្រសិនបើវាមានផលប្រយោជន៍ដល់ខ្លួន

ឃ. ស្ថាប័នរដ្ឋទាំងអស់ដែលធ្វើសកម្មភាពអាជីវកម្ម ត្រូវសុំចុះបញ្ជីអតប

ង. បុគ្គលដទៃទៀតដែល អគ្គនាយកដ្ឋានពន្ធដារ ចុះបញ្ជីជាឯកតោភាគី។

**ក.២. ការចុះបញ្ជី (អ.ត.ប)**

បុគ្គលជាប់អាករធ្វើការផ្គត់ផ្គង់ជាប់អាករត្រូវស្នើសុំចុះបញ្ជី (អ.ត.ប) ៖[109]

- មុនពេលចាប់ផ្តើមសកម្មភាពអាជីវកម្មរបស់ខ្លួនសម្រាប់ក្រុមហ៊ុនមូលធន សហគ្រាសវិនិយោគ សហគ្រាសនិហារ៍ណ អាហារ៍ណ។
- ក្នុងរយៈពេល ៣០ថ្ងៃ ចាប់ពីពេលក្លាយជាបុគ្គលជាប់អាករសម្រាប់សហគ្រាសដទៃ ទៀត។
- ពេលចាប់ផ្តើមនៃរយៈពេលបីខែប្រតិទិនជាប់គ្នា សម្រាប់កិច្ចសន្យាជាមួយរដ្ឋ ដែលមានផលរបរជាប់ (អ.ត.ប) លើសពី៣០លានរៀល។

ពាក្យថា **ផលរបរជាប់អ.ត.ប** សំដៅដល់ផលរបរដែលបានមកពីការផ្គត់ផ្គង់ជាប់អតបនូវទំនិញឬសេវា ឬការចុះកិច្ចសន្យាជាមួយរដ្ឋ ដោយមិនទាន់បញ្ចូល (**អ.ត.ប**) ខ្លួនឯង។

**ក.៣. ការផ្គត់ផ្គង់ជាប់អតប**

ការផ្គត់ផ្គង់ជាប់អាករ គឺសំដៅដល់ការផ្គត់ផ្គង់ទាំងឡាយណាដែលមានលក្ខណៈ ទ្រង់ទ្រាយ និងសកម្មភាពដូចខាងក្រោម៖

- ការផ្គត់ផ្គង់ទំនិញ ឬសេវា ដោយបុគ្គលជាប់អាករនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ការដកយកទំនិញមកប្រើប្រាស់ផ្ទាល់ខ្លួនដោយបុគ្គលជាប់អាករ
- ការផ្តល់ជាអំណោច ឬផ្គត់ផ្គង់ក្រោមតម្លៃពិតនូវទំនិញ និងសេវា ដោយបុគ្គលជាប់ (អ.ត.ប)
- ការនាំចូលទំនិញចូលមកក្នុងតំបន់ត្រួតពិនិត្យគយនៃព្រះរាជាណាចក្រកម្ពុជា។[110]

**ក.៤. ការផ្គត់ផ្គង់មិនជាប់អាករ**

[108] ប្រការ ៦ ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស នៃប្រកាសស្តីពីការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស លេខ០២៥ ចុះថ្ងៃទី ២៤ មករា ២០១៨

[109] មាត្រា ២ ជំពូកទី២ វិធាននិងនីតិវិធីសម្រាប់ការចុះបញ្ជីបុគ្គលជាប់អាករ នៃអនុក្រឹត្យស្តីពីអាករលើតំលៃបន្ថែម លេខ៖ ១១៤ អនក្រ.បក ចុះថ្ងៃទី ២៤ ធ្នូ ១៩៩៩

[110] មាត្រា ៦០ ផ្នែកទី ២ គោលការណ៍ទូទៅនៃអាករលើតម្លៃបន្ថែម ជំពូកទី៣: នៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

រាល់សកម្មភាពផ្គត់ផ្គង់ទំនិញ ឬសេវាដែលនឹងរៀបរាប់ខាងក្រោមនេះ គឺជាការផ្គត់ផ្គង់មិនជាប់អាករ។ ការផ្គត់ផ្គង់មិនជាប់អាករមានដូចជា៖[111]

- សេវាប្រៃសណីយ៍សាធារណៈ
- សេវារបស់មន្ទីរពេទ្យ និងគ្លីនិក សេវាខាងវេជ្ជសាស្ត្រ និងទន្តសាស្ត្រ និងការលក់ទំនិញបន្ទាប់បន្សំខាងវេជ្ជសាស្ត្រ និងទន្តសាស្ត្រដែលទាក់ទិននឹងការបំពេញសេវា ទាំងនេះ។
- សេវាដឹកជញ្ជូនអ្នកដំណើរដោយប្រព័ន្ធដឹកជញ្ជូនសាធារណៈ ដែលជាកម្មសិទ្ធិទាំងស្រុងរបស់រដ្ឋ។
- សេវាកម្មធានារ៉ាប់រង
- សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុ[112]
- ការនាំចូលរបស់របរប្រើប្រាស់ផ្ទាល់ខ្លួន ដែលរួចពន្ធគយ ក្នុងកម្រិតតម្លៃដែលត្រូវកំនត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សកម្មភាពមិនស្វែងរកប្រាក់ចំនេញដើម្បីប្រយោជន៍សាធារណៈ ដែលបានទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។[113]
- ការផ្គត់ផ្គង់ផលិតផលកសិកម្មមិនទាន់កែច្នៃ[114]

---

[111] ប្រការ ៥ និយមន័យ នៃប្រកាសលេខ ៥៥៩ សហវ.ប្រក ស្ដីពីការណែនាំអនុវត្តអាករលើ តម្លៃបន្ថែមចំពោះការផ្គត់ផ្គង់មិនជាប់អាករ ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៧

[112] សេវាមូលដ្ឋានខាងហិរញ្ញវត្ថុ សំដៅដល់សេវាខាងហិរញ្ញវត្ថុដែលទាញយកកម្រិតប្រាក់លម្អៀងជាប្រាក់ចំនេញ ជាអាទ៍មាន៖ (យោងតាមប្រការ ៤ កថាខណ្ឌ ០២ និយមន័យ នៃប្រកាសលេខ ៥៥៩ សហវ.ប្រក ស្ដីពីការណែនាំអនុវត្តអាករលើតម្លៃបន្ថែមចំពោះការផ្គត់ផ្គង់មិនជាប់អាករ ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៧)

ក. ប្រតិបត្តិការទទួលប្រាក់បញ្ញើ ផ្តល់ឥណទានឬឲ្យខ្ចីបុល ប៉ុន្តែមិនរួមបញ្ចូលកម្រៃសេវាដែលទាក់ទិននឹងការផ្តល់នូវឥណទានឬខ្ចីបុល

ខ. ការបោះផ្សាយលក់មូលបត្រក្នុងទីផ្សារដំបូង ការជួញដូរមូលបត្រឬឧបករណ៍ហិរញ្ញវត្ថុដទៃទៀត និងសេវាផាត់ទាត់ និងទូលទាត់ក្នុងទីផ្សារមូលបត្រកម្ពុជា

គ. សេវាប្តូរប្រាក់

ឃ. សេវាប្រាតិភោគ

ង. ការជួញដូរមាសដែលមិនទាន់កែច្នៃជាគ្រឿងអលង្ការ។

[113] មាត្រា ៥៧ ការផ្គត់ផ្គង់មិនជាប់អាករ ជំពូកទី ៣ បទបញ្ញាត្តិស្តីពីអាករលើតម្លៃបន្ថែម នៃច្បាប់សារពើពន្ធ ចុះថ្ងៃទី២៤ កុម្ភៈ ១៩៩៧

- សេវាសិក្សាអប់រំ
- ថាមពលអគ្គិសនី និង ទឹកស្អាត[115]
- សេវាប្រមូល ឬសម្អាតកាកសំណល់រឹង-រាវ[116] [117]
- ការនាំចូល ឬទិញទំនិញសម្រាប់ យកមកបំពេញមុខងារជាផ្លូវការរបស់បេសកម្ម ការទូត និង កុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការ បច្ចេកទេសរបស់រដ្ឋនានា។ ដែលការផ្តល់អោយនេះតែក្នុងករណី ដែលមានការបញ្ជាក់ពីប្រធានបេសកកម្ម និងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជូននាយកដ្ឋានពន្ធដារ ថាទំនិញទាំងនោះ ត្រូវបាននាំចូលមកសម្រាប់គោលដៅនៃការប្រើប្រាស់ដូចខាងលើនេះមែន។[118]

**ក.៥. ការលុបចោលការចុះបញ្ជីអតប**

ប្រសិនបើបុគ្គលជាប់អ.ត.ប ឈប់ធ្វើការផ្គត់ផ្គង់ទំនិញ ឬសេវាដោយមានតម្លៃដែលជាចំណែកមួយនៃសកម្មភាពអាជីវកម្មរបស់ខ្លួននោះ ត្រូវតែធ្វើការស្នើសុំជាលាយល័ក្ខអក្សរទៅអគ្គនាយកដ្ឋានពន្ធដារ អោយលុបចោលការចុះបញ្ជីរបស់ខ្លួន ចេញពីប្រព័ន្ធការគ្រប់គ្រងអ្នកជាប់ពន្ធទូទាំងប្រទេស។ ផងដែរនោះ បើបុគ្គលជាប់អាករ មានកម្រិតផលរបរជាប់អ.ត.ប របស់

[114] ផលិតផលកសិកម្មមិនទាន់កែច្នៃ សំដៅដល់ ដើម សំបក ស្លឹក ផ្កា ផ្លែ គ្រាប់ ឬស មើម ឬជ័រនៃរុក្ខជាតិដែលបានមកពីការធ្វើកសិកម្មដាំដុះក្នុងស្រុក ទោះត្រូវបាន ឬមិនទាន់បានហាន់ ឬកិនបំបែកក្តី និងដែលមិនទាន់ត្រូវបានយកទៅកែច្នៃជាផលិតផលសម្រេច។ (យោងតាមប្រការ ៤ កថាខណ្ឌ ០៥ និយមន័យ នៃប្រកាសលេខ ៥៥៩ សហវ.ប្រក ស្តីពីការណែនាំអនុវត្តអាករលើ តម្លៃបន្ថែមចំពោះការផ្គត់ផ្គង់មិនជាប់អាករ ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៧)

[115] ថាមពលអគ្គសនី សំដៅដល់ថាមពលអគ្គិសនី ដែលត្រូវបានផ្គត់ផ្គង់សម្រាប់ការប្រើប្រាស់ក្នុងជីវភាពរស់នៅ ឬការប្រកបអាជីវកម្ម។ ការផ្គត់ផ្គង់មិនរាប់បញ្ចូលទេ នូវការតបណ្តាញនិងឧបករណ៍វាស់ស្ទង់នានា។ ទឹកស្អាត សំដៅដល់ ទឹកស្អាតដែលត្រូវបានផ្គត់ផ្គង់សម្រាប់ការប្រើប្រាស់ក្នុងជីវភាពរស់នៅ ឬការប្រកបអាជីវកម្ម វៀរលែងតែទឹកផលិតសម្រាប់ទទួលទានគ្រប់ប្រភេទ។ ការផ្គត់ផ្គង់ទឹកស្អាតមិនរាប់បញ្ចូលទេ នូវការដាក់បំពង់បង្ហូរ និង ឧបករណ៍វាស់ស្ទង់ នានា។ (យោងតាមប្រការ ៤ កថាខណ្ឌ ០៣ និយមន័យ នៃប្រកាសលេខ ៥៥៩ សហវ.ប្រក ស្តីពីការណែនាំអនុវត្តអាករលើតម្លៃបន្ថែមចំពោះការផ្គត់ផ្គង់មិនជាប់អាករ ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៧)

[116] កាកសំណល់រឹង រាវ សំដៅដល់ វត្ថុឬសារធាតុរឹង រាវដែលលែងមានប្រយោជន៍ ឬត្រូវបានឈប់ប្រើប្រាស់ ឬតម្រូវអោយបោះបង់ (យោងតាមប្រការ ៤ កថាខណ្ឌ ០៦ និយមន័យ នៃប្រកាសលេខ ៥៥៩ សហវ.ប្រក ស្តីពីការណែនាំអនុវត្តអាករលើតម្លៃបន្ថែមចំពោះការផ្គត់ផ្គង់មិនជាប់អាករ ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៧)

[117] ប្រការ ៥. ការផ្គត់ផ្គង់ទំនិញ ឬសេវាដែលជាផ្គត់ផ្គង់មិនជាប់អាករ នៃប្រកាសស្តីពីការណែនាំអនុវត្តអាករលើតម្លៃបន្ថែមចំពោះការផ្គត់ផ្គង់មិនជាប់អាករ លេខ៥៥៩ សហវ.ប្រក ចុះថ្ងៃទី ២៥ ឧសភា ១៩៩៧

[118] មាត្រា ៤៣ ជំពូកទី ៨ ការផ្គត់ផ្គង់មិនជាប់អ.ត.ប ចំពោះបេសកកម្មទូត និងអង្គការអន្តរជាតិ នៃនៃអនុក្រឹត្យលេខ ១១៤ អនក្រ.បក ស្តីពីអាករលើ តម្លៃបន្ថែម ចុះថ្ងៃទី ២៤ ធ្នូ ១៩៩៩

ខ្លួនក្នុងរយៈពេល ៣ខែប្រតិទិនចុងក្រោយ មានចំនួនមិនលើសពីកម្រិតអប្បបរមាននៃ ផលរបរត្រូវចុះបញ្ជីតាមរបបស្វ័យប្រកាស ឬប្រសិនបើកម្រិតផលរបរជាប់អ.ត.ប ក្នុងរយៈ ពេល១២ខែប្រតិទិនចុងក្រោយ មានចំនួនមិនលើសពី ៧៥% នៃកម្រិតអប្បបរមានៃផលរបរប្រចាំឆ្នាំត្រូវចុះបញ្ជីតាមរបបស្វ័យប្រកាស។ ជាមួយគ្នានេះ បុគ្គលជាប់អ.ត.ប អាចធ្វើ ការស្នើសុំការលុបចោលទៅបាន លុះត្រាតែការផ្គត់ផ្គង់ទំនិញឬសេវានោះ ធ្វើឡើងក្រោយរយៈពេល២ឆ្នាំនៃកាលបរិច្ឆេទចុះបញ្ជីប៉ុណ្ណោះ។[119]

## ក.៦. អត្រាអាករ និង មូលដ្ឋានអាករ

### ក.៦.១. អាត្រាអាករ

សម្រាប់អាត្រាអាករ ដែលបទបញ្ញាត្តិអនុញ្ញាតអោយធ្វើការប្រមូលពីរការផ្គត់ផ្គង់នៃទំនិញ ឬសេវាជាប់អ.ត.ប ត្រូវបានកំណត់ជា២ប្រភេទ៖[120]

១. អត្រា ១០ ភាគរយ (១០%) លើតម្លៃជាប់អាករនៃការផ្គត់ផ្គង់ជាប់អាករនីមួយៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២. អត្រា ០ ភាគរយ (0%) លើតម្លៃជាប់អាករនៃការផ្គត់ផ្គង់ជាប់អាករនីមួយៗចំពោះទំនិញនាំចេញពីព្រះរាជាណាចក្រកម្ពុជា ហើយនិងការផ្គត់ផ្គង់សេវាជាប់អាករ ដែលបានបំពេញនៅក្រៅព្រះរាជាណាចក្រកម្ពុជាដូចមានចែងក្នុងមាត្រា ៦៣ នៃច្បាប់សារពើពន្ធនេះ។ ផងដែរនោះសេវាទាក់ទីននឹងការដឹកជញ្ជូនអ្នកដំណើរ និងទំនិញជាអន្តរជាតិតាមផ្លូវបូករួមការផ្គត់ផ្គង់សេវាដែលទាក់ទិននឹងការដឹកជញ្ជូនអ្នកដំណើរ និងទំនិញជាអន្តរជាតិ។[121] សម្រាប់គោលដៅនៃការដឹកជញ្ជូនអ្នកដំណើរ និងទំនិញ តាមផ្លូវគោល ទឹក អាកាស គឺជាការដឹកជញ្ជូនអត្តរជាតិ បើសិនជាការដឹកជញ្ជូននោះធ្វើឡើង:

- ពីកន្លែងមួយក្នុងកម្ពុជា ទៅក្រៅកម្ពុជា
- ពីកន្លែងមួយនៅក្រៅកម្ពុជា មកក្នុងកម្ពុជា
- ពីកន្លែងមួយនៅក្រៅកម្ពុជា ទៅក្រៅកម្ពុជា ក្នុងករណីជាការដឹកជញ្ជូនឬចំណែកណាមួយ

[119] មាត្រា ១៨, ១៩, ២០, ជំពូកទី ៥ ការលុបចោលការចុះបញ្ជីអ.ត.ប នៃអនុក្រឹត្យលេខ ១១៤ អនក្រ.បក ស្តីពីអាករលើតម្លៃបន្ថែម ចុះថ្ងៃទី ២៤ ធ្នូ ១៩៩៩

[120] មាត្រា ៦៤: អាត្រាអាករ ផ្នែកទី៣ អាត្រាអាករ និង ការកំណត់ប្រាក់អាករ ជំពូកទី៣ នៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

[121] មាត្រា ៥៤ ជំពូកទី ១៥ អាត្រាសូន្យភាគរយនៃការនាំចេញនូវទំនិញឬសេវា នៃនៃអនុក្រឹត្យលេខ ១១៤ អនក្រ.បក ស្តីពីអាករលើតម្លៃបន្ថែម ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩

ឆ្លងកាត់ដែនដីកម្ពុជា។[122]

### ក.៦.២. មូលដ្ឋានគិតអាករ ឬ តម្លៃជាប់អាករ

តម្លៃជាប់អាករ ត្រូវបានបានកំណត់ដូចតទៅ៖[123]

១. តម្លៃជាប់អាករនៃការផ្គត់ផ្គង់ គឺជាថ្លៃទំនិញ ឬសេវាដែលអ្នកលក់យកពីអ្នកទិញ ។ តម្លៃជាប់អាកររួមមានបន្ទុកដឹកជញ្ជូន ហើយនិងខ្ទង់ដទៃទៀតដែលត្រូវទូទាត់ឲ្យអ្នកលក់ចំពោះការផ្គត់ផ្គង់នោះ រួមបញ្ចូលទាំងអាករពិសេសលើទំនិញ និងសេវាមួយចំនួន លើកលែងតែអាករកលតម្លៃបន្ថែម។

២. ក្នុងករណីដែលការទូទាត់ចំពោះការផ្គត់ផ្គង់ជាប់អាករនោះ ជាសំណងអ្វីមួយ ក្រៅពីប្រាក់កាក់ដើម្បីជាប្រយោជន៍ផ្ទាល់ ឬប្រយោជន៍ដល់អ្នកលក់ សំណងនោះត្រូវគិតបញ្ចូលក្នុងតម្លៃជាប់អាករតាមតម្លៃទីផ្សារ។

៣. តម្លៃជាប់អាកររបស់ទំនិញនាំចុះឡ គឺជាតម្លៃគយ រួមបញ្ចូលទាំងតម្លៃធានារ៉ាប់រង និងដឹកជញ្ជូន ដោយបូកបន្ថែមនូវពន្ធគយ និងអាករពិសេសលើទំនិញ និងសេវាមួយចំនួន។ បើសិនជាគ្មានតម្លៃគយកែតម្រូវនេះទេ ត្រូវកំណត់យកតាមតម្លៃទីផ្សារ។

៤. បើសិនជាតម្លៃជាប់អាកររបស់ទំនិញ ឬសេវាដែលបានផ្គត់ផ្គង់មិនតំណាងឲ្យតម្លៃពិតទេនោះ រដ្ឋបាលសារពើពន្ធ អាចកំណត់ចេញនូវតម្លៃមួយសម្រាប់ទំនិញ ឬសេវា ហើយតម្លៃនោះត្រូវចាត់ទុកជាតម្លៃត្រឹមត្រូវរហូតដល់ពេលមានភស្តុតាងបញ្ជាក់ផ្សេងដែលរដ្ឋបាលសារពើពន្ធបានយល់ព្រមផង។

### ក.៧. ទីកន្លែងផ្គត់ផ្គង់អ.ត.ប

ទីកន្លែងផ្គត់ផ្គង់អ.ត.ប ត្រូវបានកំណត់ដូចតទៅ៖

- ការផ្គត់ផ្គង់ទំនិញត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា បើសិនជាទំនិញនោះត្រូវបានប្រគល់ឲ្យ ទោះមានលក្ខណៈជាការផ្ទេរសិទ្ធិប្រើប្រាស់ ឬសិទ្ធិចាត់ចែងក្តីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ចំពោះការផ្គត់ផ្គង់ត្រូវមានការដឹកជញ្ជូន ការផ្គត់ផ្គង់ត្រូវចាត់ទុកថា បានធ្វើឡើងនៅព្រះរាជាណាចក្រកម្ពុជា គឺបើសិនទំនិញស្ថិតនៅក្នុងកម្ពុជា នៅពេលដែលការដឹកជញ្ជូនបានចាប់ផ្តើម។
- ការផ្គត់ផ្គង់សេវាជាត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា បើសិន

[122] មាត្រា ៥៤ កថាខណ្ឌ ២ ជំពូកទី ១៥ នៃនៃអនុក្រឹត្យលេខ ១១៤ អនក្រ.បក ស្តីពីអាករលើតម្លៃបន្ថែម ចុះថ្ងៃទី ២៤ ធ្នូ ១៩៩៩

[123] មាត្រា ៦១ តម្លៃជាប់អាករ ផ្នែកទី៣ អាត្រាអាករ និង កា៖កំណត់ប្រាក់អាករ ជំពូកទី៣ នៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

សេវាជានោះបានបំពេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយឡែកតែះ

ក. ការផ្គត់ផ្គង់សេវាជាប់ទាក់ទងនឹងអចនទ្រព្យ ត្រូវកំណត់ថាសេវានោះបានធ្វើឡើងនៅទីកន្លែងនៃការដឹកជញ្ជូននោះ

ខ. ការផ្គត់ផ្គង់សេវាជាប់ទាក់ទងនឹងការដឹកជញ្ជូន ត្រូវកំណត់ថាសេវានោះបានធ្វើឡើងនៅទីកន្លែងនៃការដឹកជញ្ជូននោះ

- ទំនិញត្រូវចាត់ទុកថាបាននាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា បើសិនជាទំនិញនោះត្រូវបាននាំចូលក្នុងតំបន់ត្រួតពិនិត្យគយនៃព្រះរាជាណាចក្រកម្ពុជា។[124]

**ក.៨. ពេលផ្គត់ផ្គង់**

ពេលផ្គត់ផ្គង់ចំពោះអ.ត.ប ត្រូវកំណត់ដូចតទៅះ[125]

១. អាករលើតម្លៃបន្ថែមត្រូវដល់កំណត់ និង ត្រូវបង់នៅពេលផ្គត់ផ្គង់

២. ពេលផ្គត់ផ្គង់ទំនិញ និងសេវា គឺជាពេលដែលអ្នកលក់ត្រូវចេញវិក្កយបត្រ ឬជាពេលដែលអ្នកលក់បានចេញវិក្កយបត្រ ប្រសិនបើវិក្កយបត្រនោះត្រូវបានចេញមុនពេលដែលអ្នកលក់ត្រូវចេញវិក័យបត្រ

៣. វិក្កយបត្រអាករលើតម្លៃបន្ថែមត្រូវចេញយ៉ាងយឺតបំផុត ៧ថ្ងៃ ក្រោយការបញ្ជូនទំនិញ ឬការបំពេញសេវា ឬក្រោយការទូទាត់ក្នុងករណីដែលការទូទាត់នោះធ្វើឡើងមុនការបញ្ជូនទំនិញ ឬបំពេញសេវា។ ប្រសិនបើការបញ្ជូនទំនិញពុំមានវិក្កយបត្រភ្ជាប់ជាមួយទេ ត្រូវមានភ្ជាប់ឯកសារបញ្ជូនទំនិញដែលបានកត់ត្រាត្រឹមត្រូវក្នុងទិនានុប្បវត្តិបញ្ជូនទំនិញ។

៤. ចំពោះការផ្គត់ផ្គង់ទំនិញ ឬសេវាដែលធ្វើឡើងជាបន្ត ឬដែលមានការទូទាត់ច្រើនលើកពេលផ្គត់ផ្គង់ត្រូវកំណត់ដោយប្រកាសក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។

៥. ចំពោះការនាំចូលទំនិញ ពេលផ្គត់ផ្គង់ គឺជាពេលដែលអ្នកនាំចូលដាក់លិខិតប្រកាសជូនអាជ្ញាធរគយ(ប្រតិវេទគយន៍) ទៅតាមគោលការណ៍ជាធរមាន។

**ក.៩. អាករលើធាតុចូលដែលអ្នកជាប់អាករមានសិទ្ធិស្នើសុំឥណទាន**

**ក.៩.១ លក្ខខណ្ឌក្នុងការស្នើសុំឥណទានអតបះ**

បន្ទាប់ពីបានចុះបញ្ជី បុគ្គលជាប់អាករ គឺត្រូវបានអនុញ្ញាតអោយនូវឥណទានសម្រាប់

[124] មាត្រា៦៣ ទីកន្លែងផ្គត់ផ្គង់ ផ្នែកទី៣: អាត្រាអាករ និងការកំណត់ប្រាក់អាករ ជំពូកទី៣ នៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

[125] មាត្រា៦២ ពេលផ្គត់ផ្គង់ ផ្នែកទី៣: អាត្រាអាករ និង ការកំណត់ប្រាក់អាករ ជំពូកទី៣ នៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

អ.ត.ប លើធាតុចូលដែលបានបង់ ឬត្រូវបង់ចំពោះ ដែលលក្ខខណ្ឌក្នុងការស្នើសុំឥណទាន អ.ត.ប នោះត្រូវ៖

☞ ទំនិញ និងសេវា ត្រូវទិញដើម្បីធ្វើការលើជាប់អាករ ឬសម្រាប់ប្រើប្រាស់ដើម្បីធ្វើការផ្គត់ផ្គង់ជាប់អ.ត.ប

☞ ទំនិញដែលបានចុះក្នុងបញ្ជីសារពើភ័ណ្ឌ ត្រូវនៅក្នុងដែនាកាលបរិច្ឆេទមានប្រសិទ្ធិភាពនៃការចុះបញ្ជី

☞ប្រតិវេទន៍គយសម្រាប់ការនាំចូលដែលបានបញ្ជាក់ត្រឹមត្រូវ

☞ វិក្កយបត្រអាករសម្រាប់ការទិញក្នុងស្រុក ពីអ្នកផ្គត់ផ្គង់ចុះបញ្ជីអ.ត.ប

☞ ពាក្យស្នើសុំត្រូវធ្វើឡើងតាមទម្រង់កំនត់ដោយអគ្គនាយកដ្ឋានពន្ធដារបានកំនត់

☞ ត្រូវមានឯកសារភស្តុតាងត្រឹមត្រូវច្បាស់លាស់ បញ្ជាក់ថាបុគ្គលបានបង់អ.ត.ប ពិតមែន ដែលអាចអនុញ្ញាតជាឥណទាន។[126]

**ក.៩.២. ឥណទានអាករលើធាតុចូលប្រចាំខែ៖**

នៅពេលបុគ្គលជាប់អ.ត.ប ធ្វើការគណនាប្រាក់អ.ត.បដែលត្រូវបង់ក្នុងខែ គឺនៅពេលដែលទំនិញឬសេវា ត្រូវបានផ្គត់ផ្គង់ឲ្យបុគ្គលជាប់អ.ត.ប ឬធ្វើការនាំចូល។[127] ហើយត្រូវបានអនុញ្ញាតជាឥណទានអាករលើធាតុចូលសម្រាប់អ.ត.ប បង់លើ៖

☞ រាល់ការផ្គត់ផ្គង់ដែលបានទទួលក្នុងខែ

☞ រាល់ការនាំចូលទំនិញដោយបុគ្គលជាប់អាករនៅក្នុងខែ ដែលការផ្តល់នេះឲ្យបានតែការផ្គត់ផ្គង់ ឬទំនិញនាំចូលជាប់អ.ត.ប នោះទាក់ទិនទៅនឹងសកម្មភាពនៃអាជីវកម្មជាប់ អ.ត.បតែប៉ុណ្ណោះ។[128]

**ក.៩.៣. អាករលើធាតុចូលដែលមិនអាចស្នើសុំឥណទានអាករ**

[126] មាត្រា ២៨ ជំពូកទី៦ ឥណទានអ.ត.បលើធាតុចូល នៃអនុក្រឹត្យលេខ ១១៤ អនក្រ.បក ស្តីពីអាករលើតម្លៃបន្ថែម ចុះថ្ងៃទី ២៤ ធ្នូ ១៩៩៩

[127]មាត្រា ៣០ ជំពូកទី៦ ឥណទានអ.ត.បលើធាតុចូល នៃអនុក្រឹត្យលេខ ១១៤ អនក្រ.បក ស្តីពីអាករលើតម្លៃបន្ថែម ចុះថ្ងៃទី ២៤ ធ្នូ ១៩៩៩

[128] មាត្រា ២៩ ជំពូកទី៦ ឥណទានអ.ត.បលើធាតុចូល នៃអនុក្រឹត្យលេខ ១១៤ អនក្រ.បក ស្តីពីអាករលើតម្លៃបន្ថែម ចុះថ្ងៃទី ២៤ ធ្នូ ១៩៩៩

អាករលើធាតុចូលមិនអាចស្នើសុំឥណទានលើធាតុចូល ចំពោះប្រាក់អ.ត.ប ដែលបានបង់លើ៖

- ការទិញ ឬនាំចូលផលិតផលតេលសិលា[129]មួយចំនួន លើកលែងតែបុគ្គលជាប់ អ.ត.ប ប្រកបអាជីវកម្មជាអ្នកផ្គត់ផ្គង់លិតផលតេលសិលាទាំងនោះ។
- អ.ត.ប បង់លើទំនិញ ឬសេវាផ្គត់ផ្គង់ដោយបុគ្គលមិនមែនចុះបញ្ជី អ.ត.ប
- អ.ត.ប បង់លើការទិញ ឬនាំចូលរថយន្ត[130] លើកលែងតែបុគ្គលជាប់អ.ត.ប ប្រកបនូវអាជីវកម្មលក់ ឬជួលរថយន្ត។
- អ.ត.ប បង់លើការចំណាយទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ លើកលែងតែបុគ្គលជាប់ អ.ត.ប មានអាជីវកម្មជាអ្នកផ្គត់ផ្គង់(ការទទួលភ្ញៀវ)[131] ការកំសាន្ត ឬការសំរាកលំហែ។
- អ.ត.ប បង់លើសេវាទូរស័ព្ទចល័ត

ជារួមសម្រាប់បុគ្គលជាប់អាករ ដែលមានទ្រង់ទ្រាយសហគ្រាសជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មានកាតព្វកិច្ចដូចបានរៀបរាប់ខាងលើ និង កិច្ចមួយចំនួនទៀតដូចជា៖

- ដាក់តាំងវិញ្ញាបនបត្រចុះបញ្ជីអតបនៅទីកន្លែងអាជីវកម្ម[132]
- គិតអតបលើអតិថិជនទាំងអស់ចាប់ពីកាលបរិច្ឆេទមានប្រសិទ្ធភាព
- ចេញវិកយប័ត្រអតបដល់អតិថិជនដែលជាបុគ្គលជាប់អាករដូចគ្នា
- ចេញវិក្កយប័ត្រធម្មតា ឬវិក័យបត្រពាណិជ្ជកម្មដល់អតិថិជនដែលជាបុគ្គលមិនជាប់អាករ
- ត្រូវចុះបញ្ជីអតបត្រូវធ្វើមុនពេលអ្នកជាប់ពន្ធអាចនាំចូល ឬការនាំចេញសម្រាប់គោលដៅអាជីវកម្ម

[129] ផលិតផលតេលសិលា សំដៅដល់ប្រេងសាំងធម្មតា ប្រេងសាំងស៊ុបពែ ប្រេងម៉ាស៊ូត និង ប្រេងរំអិល

[130] រថយន្ត សំដៅដល់រថយន្តសម្រាប់តែដឹកមនុស្សដែលមានកន្លែងអង្គុយមិនលើសពី ១០ កៅអី

[131] ការទទួលភ្ញៀវ សំដៅដល់ការផ្គត់ផ្គង់អាហារ ភេសជ្ជៈ ថ្នាំជក់ កន្លែងស្នាក់អាស្រ័យ ឬបដិសណ្ឋាកិច្ចណាមួយ

[132] មាត្រា ៧ ជំពូកទី៣ ការតម្រូវចំពោះការចុះបញ្ជី នៃអនុក្រឹត្យលេខ ១១៤ អនក្រ.បក ស្តីពីអាករលើតម្លៃបន្ថែម ចុះថ្ងៃទី ២៤ ធ្នូ ១៩៩៩

- រក្សាកំណត់ត្រា និងគណនីទាក់ទិននឹងអតបសម្រាប់រយៈពេល១០ឆ្នាំ
- ដាក់លិខិតប្រកាសអ.ត.ប និងបង់ប្រាក់ពន្ធដែលប្រកាសប្រចាំខែត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែជាប់ពន្ធ[133]
- ជូនដំណឹងដល់អគ្គនាយកដ្ឋានពន្ធដារ អំពីការប្រែប្រួលស្ថានភាពអាជីវកម្មរួមមានការផ្ទេរ អាជីវកម្ម ឬ ការស្នើសុំលុបចោលការចុះបញ្ជីអតប.ល.។[134]
- អនុញ្ញាតអោយមន្ត្រីអគ្គនាយកដ្ឋានពន្ធដារពិនិត្យមើលកំណត់ត្រាឯកសារ និងទីតាំងអាជីវកម្មសហគ្រាស។[135]

**ខ. អាករពិសេសលើទំនិញ និងសេវាមួយចំនួន (អាករពិសេស)**

អាករពិសេស ជាប្រភេទអាករមួយ ដែលធ្វើការប្រមូលទៅលើការផ្គត់ផ្គង់ជាប់អាករទាំងឡាយណានៃទំនិញ ឬសេវាមួយចំនួន វៀលែងអាករតម្លៃបន្ថែម និងអាករពិសេសខ្លួនឯង។ អាករពិសេសត្រូវបានដាក់ឲ្យអនុវត្ត ក្នុងវិស័យពន្ធ និង អាករកម្ពុជា តាំងពីឆ្នាំ ១៩៨៥ ក្រោមក្រឹត្យច្បាប់លេខ ២៨ក្រច ១៤ មិថុនា ១៩៨៥ ដែលពេលនោះ អាករពិសេស ត្រូវបានហៅថា ពន្ធលើទំនិញក្នុងប្រទេស។ ក្រោយមកទៀត នៅឆ្នាំ ១៩៩៥ ពន្ធលើទំនិញ ក្នុងប្រទេស ត្រូវបានផ្លាស់ប្តូរ ទៅជា អាករពិសេសលើទំនិញមួយចំនួនវិញតាមរយៈ ច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការ គ្រប់គ្រងឆ្នាំ ១៩៩៥។ ហើយការប្រើ ប្រាស់ពាក្យ "អាករពិសេសលើទំនិញ និង សេវាមួយចំនួន" រហូតដល់បច្ចុប្បន្ន គឺធ្វើឡើង នៅឆ្នាំ ១៩៩៧ ដែលអនុឡោមតាមច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧។[136]

ប្រភេទនៃទំនិញ ឬសេវា ដែលត្រូវជាប់អាករពិសេស គឺមិនខុសពីប្រភេទទំនិញ ឬសេវាដែលជាប់អាករបំភ្លឺសាធារណៈនោះទេ គ្រាន់អាករពិសេស មានដែនអនុវត្តទៅលើប្រភេទទំនិញ ឬសេវាច្រើនប្រភេទ។ ដោយអនុឡោមតាមច្បាប់ស្តីពីការកែតំរូវនៃច្បាប់ ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី ១ កញ្ញា ១៩៩៥ ប្រភេទទំនិញ ដែលត្រូវធ្វើការប្រមូលអាករ ពិសេសមានដូចជា៖

1. ផលិតផលតេលសិលា ប្រេងសាំងស៊ុបពែរ ឬធម្មតា សម្រាប់យានយន្ត ប្រេងរំអិល)

[133] ប្រការ ៨ ការកែសម្រួលកាលបរិច្ឆេទដាក់លិខិតប្រកាស នៃប្រកាសស្តីពីការកែសម្រួលកាលបរិច្ឆេទដាក់លិខិតប្រកាសពន្ធប្រចាំខែ លេខ ១៥៣៩ សហវ.ប្រក ចុះថ្ងៃទី ២៣ ធ្នូ ២០១៦

[134] មាត្រា ១២ ជំពូកទី៣ ការតម្រូវចំពោះការចុះបញ្ជី នៃអនុក្រឹត្យលេខ ១១៤ អនក្រ.បក ស្តីពីអាករលើតម្លៃបន្ថែម ចុះថ្ងៃទី ២៤ ធ្នូ ១៩៩៩

[135] ឯកសារស្តីពី អាករលើតម្លៃបន្ថែម នៃសាលាជាតិពន្ធដារ បោះពុម្ពថ្ងៃទី៩ កញ្ញា ២០១៨

[136] មាត្រា ៨៥ កថាខណ្ឌ ០១ ជំពូកទី០៤ ផ្នែកទី ០១ ស្តីពីបទបញ្ញត្តិកែប្រែអាករពិសេសលើទំនិញមួយចំនួនមកជាអាករពិសេសលើទំនិញ និង សេវាមួយចំនួន នៃច្បាប់សារពើពន្ធ ១៩៩៧ ចុះថ្ងៃទី ២៤ កុម្ភៈ ១៩៩៧

2. ភេសជ្ជៈ[137]
3. បារី បារីស៊ីហ្គា គ្រប់ប្រភេទ។

ប៉ុន្តែក្រោយមកទៀត អាករពិសេសមិនត្រឹមតែត្រូវបានអនុវត្តទៅលើប្រភេទទំនិញ ដែលបានរៀបរាប់ខាងលើនោះទេ ដោយត្រូវអនុវត្តទៅលើទំនិញ និង បញ្ចូលផងដែរនូវសេវាផ្សេងៗមួយចំនួន ដូចជា៖[138]

- រថយន្តដែលមានមានបញ្ជាក់ក្នុងតារាងពន្ធគយលេខសំគាល់ ៨៧.០៣ ដែលមានស៊ីឡាំងជ្រេធំជាង ២០០០ CC ព្រមទាំងគ្រឿងបន្លាស់សំរាប់ប្រភេទរថយន្តទាំងនេះ
- រថយន្តដែលមានមានបញ្ជាក់ក្នុងតារាងពន្ធគយលេខសំគាល់ ៨៧.០៣ ដែលមាន ស៊ីឡាំងជ្រេពី២០០០ CC ចុះក្រោម ព្រមទាំងគ្រឿងបន្លាស់សម្រាប់ប្រភេទរថយន្ត ទាំងនេះ
- យានយន្តគ្រប់ប្រភេទ និងគ្រឿងបន្ទាស់ ដែលមានមានបញ្ជាក់ក្នុងតារាងពន្ធគយលេខសំគាល់ ៨៧.០២ ៨៧០៤-២១ ដល់៨៧០៤-៩០ ៨៧០៦ ៨៧០៨ ៨៧១៤ និង ៨៧១១ ដែលមានស៊ីឡាំងជ្រេចាប់ពី ១២៥CC ឡើងទៅ
- សេវាស្នាក់នៅ ដូចជា សណ្ឋាគារ ផ្ទះសំណាក់
- សេវាលំហែកំសាន្តផ្សេងៗ
- សេវាលក់សំបុត្រដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសពីក្នុងកម្ពុជា ទៅបរទេស
- សេវាទូរគមនាគមន៍ពីក្នុងកម្ពុជា ទៅបរទេស។

ចំពោះសេវាលំហែកំសាន្ត រាល់ការផ្គត់ផ្គង់សេវាលំហែកំសាន្តដែលមានសកម្មភាពដូចជា ការប្រគុំតន្ត្រី, ចាក់ភ្លេង, សំដែងឈុតឆាក ឬកាយវិការមានលក្ខណៈជាសកម្មភាព អាជីវកម្ម

[137] ភេសជ្ជៈ រួមមានដូចជា៖

- ទឹកមានជាតិឧស្ម័ន មានដាក់ជាតិស្ករ ឬក៏សារជាតិផ្អែមដទៃទៀត ឬគ្រឿងក្រអូប និងភេសជ្ជៈដទៃទៀត ដែលគ្មានជាតិ សុរា លើកលែងតែទឹក និង ទឹកមីណេរ៉ាល់ ហើយនិង ទឹកដមផ្លែឈើ ឬ ទឹកដមបន្លែ។
- ស្រាបៀរ
- ស្រាទំពាំងបាយជូរស្រស់ រួមទាំងស្រាទំពាំងបាយជូរដែលមានបន្ថែមជាតិសុរា
- ស្រាវែមុត និងស្រាទំពាំងបាយជូរស្រស់ផ្សេងទៀត ផ្សំពីរុក្ខជាតិ និងសារជាតិក្រអូប
- ភេសជ្ជៈមេរ៉ៃផ្សេងទៀត
- អាល់កុលអេទីលិកសុទ្ធ ដែលមានកម្រិតជាតិសុរាក្នុងឯកតាចំណុះពី ៨០% នៃចំនុះ ឬលើសពីនេះ និង-
- អាល់កុលអេទីលិក ហើយនឹងភេសជ្ជៈមានជាតិសុរា ដែលបាត់បង់កំរិតសុរាដើមរបស់វា
- អាល់កុលអេទីលិកបាត់បង់ធាតុសុទ្ធ ដែលមានកំរិតជាតិសុរាក្នុងឯករាចំណុះ ៨០% នៃចំនុះ និង ភេសជ្ជៈមានជាតិសុរា ភេសជ្ជៈ ស្រវឹងផ្សេងៗទៀត ការរៀបចំកែច្នៃសុរាផ្សំក្នុងប្រភេទ ដែលសម្រាប់ផលិតភេសជ្ជៈ។

[138] មាត្រា ៨៥ កថាខណ្ឌ ០២ ជំពូកទី០៤ ផ្នែកទី ០១ ស្តីពីបទបញ្ញត្តិកែប្រែអាករពិសេសលើទំនិញមួយចំនួនមកជាអាករពិសេសលើទំនិញ និង សេវាមួយចំនួន នៃច្បាប់សារពើពន្ធ ១៩៩៧ ចុះថ្ងៃទី ២៤ កុម្ភៈ ១៩៩៧

នៅក្នុងរង្គសាល, ខារ៉ាអូខេ, ឌីស្កូថែក, ទីកន្លែងសាធារណៈ ឬ ទីកន្លែងណាមួយ បុគ្គលជាប់អាករ ឬ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវជាប់លើអាករពិសេសទៅតាមអាត្រាដែលមានកំណត់ដោយច្បាប់សារពើពន្ធជាធរមាន ។ ផងដែរនោះចំពោះសកម្មភាព អាជីវកម្មមួយចំនួនផ្សេងទៀត ដូចជា ម៉ាស្សា, ប្រណាំងរថយន្ត karting ប្រណាំងម៉ូតូ, ស្នូកឃ័រ, BOWLING, ហ្គេមគ្រប់ប្រភេទ និង កូនគោល ក៏ត្រូវជាប់ អាករពិសេសដូចគ្នា នៅគ្រប់ពេល នៃការផ្គត់ផ្គង់ជាប់អាករ។[139]

**▶▷ អាត្រាអាករ និងមូលដ្ឋានគិតអាករពិសេសលើទំនិញ និងសេវាមួយចំនួន**

**▷អត្រាអាករ**

អាត្រាអាករពិសេស មានការប្រែប្រួលជារឿយៗ ក្នុងគោលដៅដើម្បីធានាបាននូវប្រសិទ្ធភាព ក៏ដូចជារួមចំណែកក្នុងការបំពេញនូវកញ្ចប់ថវិកាជាតិសម្រាប់ការអភិវឌ្ឍន៍។ អាត្រាអាករពិសេសនាពេលបច្ចុប្បន្ន ត្រូវបានបែងចែកទៅតាមប្រភេទនៃទំនិញនិងសេវា ជាមួយគ្នានេះ ទៅលើប្រភេទទំនិញ ឬសេវា ក្នុងស្រុក និងក្រៅស្រុក។

អាករពិសេសលើទំនិញមួយចំនួនដែលផលិតក្នុងស្រុកត្រូវអនុវត្តតាមអាត្រាដូចជា៖

- ➩ ៣៥% ទៅលើសុរា (ស្រា) គ្រប់ប្រភេទ[140]
- ➩ ៣០% ទៅលើស្រាបៀរគ្រប់ប្រភេទ[141]
- ➩ ២០% ទៅលើបារីគ្រប់ប្រភេទ[142]
- ➩ ២៥% ទៅលើបារីស៊ីហ្គា
- ➩ ១០% ភេសជ្ជៈគ្រប់ប្រភេទ
- ➩ ៥% ទៅលើស៊ីម៉ង់គ្រប់ប្រភេទ

អាករពិសេសលើសេវា ត្រូវអនុវត្តតាមអាត្រាដូចជា៖

- ☞ ១០% សម្រាប់ថ្លៃលក់សំបុត្រលើសេវាដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសក្នុង និង ក្រៅប្រទេស។

[139] ប្រការ ២ នៃប្រកាសលេខ ១៥៣ ប្រក.សហវ.ពដ ស្តីពីអាករពិសេសលើសេវាលំហែកំសាន្តផ្សេង ចុះថ្ងៃទី១៥ កុម្ភៈ ២០០១

[140] ចំនុចទី ១ កថាខណ្ឌ ១ នៃសេចក្តីជូនដំណឹង ស្តីពីការអនុវត្តការកែសម្រួលអាត្រាអាករពិសេសលើមុខទំនិញមួយចំនួនដែល ផលិតក្នុងស្រុក លេខ ២៧២៧ អពដ ចុះថ្ងៃទី ២២ មីនា ឆ្នាំ ២០១៦

[141] ចំនុចទី ២ កថាខណ្ឌ ១ នៃសេចក្តីជូនដំណឹង ស្តីពីការអនុវត្តការកែសម្រួលអាត្រាអាករពិសេសលើមុខទំនិញមួយចំនួនដែល ផលិតក្នុងស្រុក លេខ ២៧២៧ អពដ ចុះថ្ងៃទី ២២ មីនា ឆ្នាំ ២០១៦

[142] ចំនុចទី ៣ កថាខណ្ឌ ១ នៃសេចក្តីជូនដំណឹង ស្តីពីការអនុវត្តការកែសម្រួលអាត្រាអាករពិសេសលើមុខទំនិញមួយចំនួនដែល ផលិតក្នុងស្រុក លេខ ២៧២៧ អពដ ចុះថ្ងៃទី ២២ មីនា ឆ្នាំ ២០១៦

☞ ១០% សម្រាប់សេវាលំហែកំសាន្ត។[143]

☞ ៣% សម្រាប់សេវាទូរគមនាគមន៍ និង ក្រៅប្រទេស។

**▶មូលដ្ឋានគិតអាករអាករពិសេសលើទំនិញ**

**ទំនិញផលិតក្នុងស្រុក**

មូលដ្ឋានគិតអាករសម្រាប់គិតអាករពិសេសលើមុខទំនិញផលិតក្នុងស្រុក ត្រូវកំណត់ស្មើនឹង ៩០% នៃថ្លៃផ្គត់ផ្គង់កត់ត្រាក្នុងវិក្កយបត្រឲ្យទៅអតិថិជន ដោយមិនរួមបញ្ចូលនូវ អ.ត.ប និងអាករពិសេសខ្លួនឯង។[144]

រូបមន្តសង្ខេប: មូលដ្ឋានគិតអាករសម្រាប់គិតអាករពិសេសលើមុខទំនិញក្នុងស្រុក = 90% X (ថ្លៃលក់ - អាករលើតម្លៃបន្ថែម - អាករពិសេស) ឬ = 90%(ថ្លៃលក់/110%/130%) (ករណីអាត្រា ៣០%)

**ទំនិញនាំចូល**

មូលដ្ឋានសម្រាប់គិតអាករពិសេសចំពោះទំនិញនាំចូល គឺតម្លៃគិតពន្ធគយដែលកំណត់តាមបទបញ្ញត្តិនៃច្បាប់ស្តីពីគយ ដោយរួមបញ្ចូលនូវពន្ធនាំចូល។

រូបមន្តសង្ខេប: អាករពិសេស = (តម្លៃគិតពន្ធគយ + ពន្ធនាំចូល) X អត្រាអាករពិសេស

ពន្ធនាំចូល = តម្លៃគិតពន្ធគយ + អត្រាពន្ធនាំចូល[145]

**▶មូលដ្ឋានគិតអាករអាករពិសេសលើសេវាមួយចំនួន**

មូលដ្ឋានគិតអាករសម្រាប់គិតអាករពិសេសលើសេវាមួយចំនួន ត្រូវកំណត់ស្មើនឹង ថ្លៃផ្គត់ផ្គង់របស់អ្នកជាប់ពន្ធកត់ត្រាក្នុងវិក្កយបត្រឲ្យទៅអតិថិជន ដោយមិនរួមបញ្ចូលនូវ អ.ត.ប និងអាករពិសេសខ្លួនឯង។

---

[143] ប្រការ ១ នៃប្រកាសលេខ ១៥៣ ប្រក.សហវ.ពដ ស្តីពីអាករពិសេសលើសេវាលំហែកំសាន្តផ្សេង ចុះថ្ងៃទី១៥ កុម្ភៈ ២០០១

[144] សេចក្តីជូនដំណឹង ស្តីពីការកែសម្រួលមូលដ្ឋានគិតអាករពិសេសលើមុខទំនិញមួយចំនួនលផលិតក្នុងស្រុកក្រៅពីបារី និងស្រា លេខ ០០៥ សហវ ចុះថ្ងៃទី១៩ មករា ២០១៥

[145] វេបសាយអគ្គនាយកដ្ឋានគយ និង អាករ បរិយាយពី ទើពន្ធនិងអាករនាំចូល និងនាំចេញ ត្រូវគណនាដូចម្តេច? ថ្ងៃទី ៧ ធ្នូ ២០១៥. ចូលមើលថ្ងៃទី ២០ កក្កដា ២០១៩ http://www.customs.gov.kh/faq/%E1%9E%91%E1%9E%B7%E1%9E%93%E1%9F%92%E1%9E%93%E1%9E%93%E1%9F%90%E1%9E%99%E1%9E%93%E1%9F%81%E1%9F%87%E1%9E%94%E1%9E%B6%E1%9E%93%E1%9E%91%E1%9E%BC%E1%9E%9B%E1%9F%86%E1%9E%91%E1%9E%BC%E1%9E%9B%E1%9E%B6/

រូបមន្តសង្ខេប: មូលដ្ឋានគិតអាករសម្រាប់គិតអាករពិសេសលើសេវាមួយចំនួន = ថ្លៃផ្គត់ផ្គង់ក្នុងវិក្កយបត្រ - អាករលើតម្លៃបន្ថែម - អាករពិសេសខ្លួនឯង។ ឬ = ថ្លៃផ្គត់ផ្គង់/110%/110% (ករណីសេវា លំហែកំសាន្ត។

**▶ការប្រកាសពន្ធ និង ការបង់ពន្ធ**

តើបុគ្គលជាប់អាករប្រភេទណា ជាមុខសញ្ញានៃការប្រមូលប្រាក់អាករពិសេសនេះ?

បុគ្គលជាប់អាករដែលជាមុខសញ្ញាក្នុងការប្រមូលប្រាក់អាករពិសេស មានដូចជា៖

☛អ្នកប្រើប្រាស់ទំនិញ ឬសេវា ដែលជាអ្នកបង់អាករពិសេសជូនរដ្ឋ ព្រោះវាជាប្រភេទពន្ធប្រយោល ដែលអ្នកជាប់ពន្ធភាគច្រើនមិនបានដឹង

☛សហគ្រាស ឬ អាជីវករ (ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត)

➩ម្ចាស់សហគ្រាស ឬអាជីវករ គ្រាន់តែជាភ្នាក់ងារកាត់ប្រាក់អាករពីការលក់ទំនិញ ឬពីការបំពេញសេវាឲ្យអ្នកប្រើប្រាស់ និងមានកាតព្វកិច្ចយកប្រាក់អាករទាំងនោះមកបង់ ជូនរដ្ឋបាលពន្ធដារ ឬរដ្ឋបាលសារពើពន្ធ

➩ម្ចាស់សហគ្រាស ឬអាជីវករ មិនមែនជាអ្នកបង់ប្រាក់អាករទេ។

➩អាករពិសេសត្រូវបង់**តែមួយដងគត់**ដោយបុគ្គលជាប់អាករពិសេស។

➩អាករពិសេសត្រូវដល់កំណត់ត្រូវបង់នៅពេលផ្គត់ផ្គង់

➧ចំពោះទំនិញនាំចូល ត្រូវបានចាត់ទុកថាបានផ្គត់ផ្គង់នៅពេលបាននាំចូលមកក្នុងតំបន់ត្រួតពិនិត្យគយ ក្នុងព្រះរាជាណាចក្រកម្ពុជា។

➧ ចំពោះទំនិញផលិត និងសេវាដែលបានផ្គត់ផ្គង់ក្នុងស្រុក គឺពេលដែលអ្នកផ្គត់ផ្គង់ចេញ

បានចេញវិក្កយបត្រ។[146]

➧ កាលបរិច្ឆេទបង់អាករយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ២០ នៃខែបន្ទាប់។[147]

ជារួមសម្រាប់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត កាលបើមានកម្មវត្ថុអាជីវកម្មរបស់ខ្លួនចម្បង ឬបន្ទាប់បន្សំ ស្ថិតក្នុងសកម្មភាព ឬការប្រតិបត្តិដូចមានរៀបរាប់ខាងលើ នោះក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មានកាតព្វកិច្ចត្រូវអនុវត្តទៅតាមការកំណត់នៃច្បាប់ជាធរមាននេះ។

---

[146] ឯកសារសាលាជាតិពន្ធដារ បង្ហាត់បង្ហាញពីអាករពិសេសលើទំនិញ និងសេវាមួយចំនួន បោះពុម្ពថ្ងៃទី ៩ កញ្ញា ២០១៩

[147] ប្រការ ៤ ការសម្រួលកាលបរិច្ឆេទដាក់លិខិតប្រកាស នៃប្រកាសស្តីពីការកែសម្រួលកាលបរិច្ឆេទដាក់លិខិតប្រកាសពន្ធប្រចាំខែ លេខ ១៥៣៩ សហវ.ប្រក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ ២០១៦

**គ. អាករលើការស្នាក់នៅ**

អាករលើការស្នាក់នៅ សំដៅដល់ប្រភេទអាករមួយដែលត្រូវបានដាក់អោយប្រើប្រាស់ នៅឆ្នាំ ២០០៥ តាមរយៈច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៤ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៤ ដើម្បីជាគុណប្រយោជន៍ដល់ថវិកាថ្នាក់ខេត្ត ក្រុង ចំពោះអាជីវកម្មទាំងឡាយណា ដែលធ្វើការផ្គត់ផ្គត់ទៅលើសេវាការស្នាក់នៅបែបលំហែកំសាន្តជាមួយអាត្រា ២ ភាគរយ។[148] អាករលើការស្នាក់នៅត្រូវដល់កំណត់ និងត្រូវបង់នៅពេលផ្គត់ផ្គង់នៅពេលផ្តល់សេវាស្នាក់នៅ ។ ការផ្គត់ផ្គង់សេវាស្នាក់នៅគឺជាពេលដែលម្ចាស់សណ្ឋាគារ ឬអ្នកតំណាងត្រូវចេញវិក្ក័យបត្រ ឬជាពេលម្ចាសសណ្ឋាគារ ឬអ្នកតំណាងបានចេញវិក្ក័យបត្រ ប្រសិនបើវិក្ក័បត្រនោះត្រូវបានចេញមុនពេលដែលម្ចាស់សណ្ឋាគារ ឬអ្នកតំណាងត្រូវចេញវិក្ក័យបត្រ ។ ម្ចាស់សណ្ឋាគារ ឬអ្នកតំណាងត្រូវចេញវិក្ក័យបត្រអាករលើការស្នាក់នៅយ៉ាងយឺតបំផុត ៧ថ្ងៃ ក្រោយពីការបំពេញសេវា ស្នាក់នៅត្រូវបញ្ចប់ ឬក្រោយការទូទាត់ក្នុងករណីដែលការទូទាត់ត្រូវបានធ្វើឡើងមុនការបំពេញសេវា លើការស្នាក់នៅបានកើតឡើង ។ ក្នុងករណីសេវាលើការស្នាក់នៅត្រូវបានផ្គត់ផ្គង់ក្នុងលក្ខណៈជាអំណោយ ពេលផ្គត់ផ្គង់គឺពេលដែលសេវាផ្គត់ផ្គង់ត្រូវបានបំពេញរួចរាល់ ។[149]

សម្រាប់គោលដៅសំខាន់នៃអាករនេះ គឺសណ្ឋាគារ ដែលពាក្យ ″សណ្ឋាគារ″ សំដៅដល់មូលដ្ឋានផ្គត់ផ្គង់សេវាស្នាក់នៅមានលក្ខណៈជាបន្ទប់ គ្រែ និងមានផ្តល់នូវសម្បទាន និងសេវាផ្សេងទៀត ទៅតាមប្រភេទនៃមូលដ្ឋានសេវាស្នាក់នៅនីមួយៗដូចជា៖[150]

☞សណ្ឋាគារ (Hotel) ៖ ជាអាគារមានច្រើនជាន់ ដែលមានទីតាំងស្ថិតនៅក្នុងទីប្រជុំជនជាយក្រុង ឬតំបន់រមណីយដ្ឋានទេសចរណ៍ និងអាចផ្គត់ផ្គង់នូវសេវាពេញលេញដល់ភ្ញៀវដូច ជា៖ សេវាស្នាក់នៅ ភោជនីយដ្ឋាន សេវាបំរើអាហារភ្ញៀវដល់បន្ទប់ សេវាបោកគក់ ហាងលក់ ទំនិញ និងកន្លែងរៀបចំពិធីជប់លៀង សាលប្រជុំ និងចំណតរថយន្ត។

☞សណ្ឋាគារអាផាតមិន (Hotel Apartment) ៖ ជាសណ្ឋាគារមានបន្ទប់ស្នាក់នៅ និងបន្ទប់ស្វីត (Suite) ដែលបំពាក់គ្រឿងសង្ហារឹម សំភារៈបរិក្ខារ និងផ្គត់ផ្គង់នូវសេវាដូចសណ្ឋាគារដែរ។ បន្ទប់ស្វីតមានបំពាក់គ្រឿងសំភារៈ ផ្ទះបាយនិងមានបន្ទប់សម្រាប់ភ្ញៀវ។

☞សណ្ឋាគារស្វីត (Suite Hotel) ៖ ជាសណ្ឋាគារដែលមានបន្ទប់ស្នាក់នៅទាំងអស់សុទ្ធតែបន្ទប់ស្វីត។

---

[148] មាត្រា ៨ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០៤

[149] ប្រការ ៤ កថាខណ្ឌ២ នៃប្រកាសស្តីពីការអនុវត្តអាករលើការស្នាក់នៅ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៥

[150] ប្រការ ២ នៃប្រកាសស្តីពីការអនុវត្តអាករលើការស្នាក់នៅ លេខ ៣៨០ សហវ.ប្រក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៥

☞សណ្ឋាគាររីសត (Resort Hotel) ៖ ជាប្រភេទសណ្ឋាគារ ដែលសង់ក្នុងតំបន់រមណីយដ្ឋានទេសចរណ៍ ស្ថិតនៅឆ្ងាយពីទីប្រជុំជន មានកន្លែងសម្រាប់លំហែកំសាន្ត លំហែកាយសំរាកយកខ្យល់អាកាស មានផ្តល់នូវម្ហូបអាហារ ឬភេសជ្ជៈចំពោះភ្ញៀវដែលមកស្នាក់នៅកំសាន្ត ដូចជា៖ វាយកូនគោល វាយតេននីយ ស្នូចត្រី ជិះសេះ ។ល។ តំលើបន្ទប់អាចគិតរួមបញ្ចូលទាំង អាហារ។

☞ ម៉ូតែល ៖ ជាអាគារមានមួយ ឬពីរជាន់ ស្ថិតក្នុងតំបន់ជាយក្រុង ឬតាមបណ្តោយផ្លូវសំខាន់ៗ ផ្តល់នូវសម្បទាន និងសេវាមានកំរិតសំរាប់ភ្ញៀវដែលចូលមកស្នាក់នៅ។ មានភោជនីយដ្ឋានសាមញ្ញតូចមួយ (Snake Bar) សំរាប់ទទួលភ្ញៀវ មានចំណតរថយន្តធំទូលាយ និងអាចមាន ផ្គត់ផ្គង់នូវសេវាសំរាប់កំសាន្តមួយចំនួន។

▶ **មូលដ្ឋានគិតអាករ**

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែលមានកម្មវត្ថុអាជីវកម្ម ដូចដែលមានរៀបរាប់ខាងលើ នីតិបុគ្គលនេះត្រូវជាប់កាតព្វកិច្ចបង់ប្រាក់អាករលើការស្នាក់នៅក្នុងអាត្រា ២% ។ អាករលើការស្នាក់នៅត្រូវបានកំណត់យកតាមអត្រា ២% លើថ្លៃបន្ទប់ស្នាក់នៅក្នុងសណ្ឋាគា ដោយរួមបញ្ចូលទាំងពន្ធ អាករ និងបន្ទុកសេវាផ្សេងៗ (service charge) លើកលែងតែអាករលើការស្នាក់នៅខ្លួយនឯក និងអាករលើតម្លៃបន្ថែម ។[151]

<u>រូបមន្តសង្ខេប</u>

មូលដ្ឋានគិតអាករ = ថ្លៃបន្ទប់ + ពន្ធអាករ + បន្ទុកផ្សេងៗ

ឬ

មូលដ្ឋានគិតអាករ = ថ្លៃផ្គត់ផ្គង់កត់ត្រាលើវិក្កបត្រឲ្យអតិថិជន - អ.ត.ប - អាករលើការស្នាក់នៅ

<u>យើងបាន</u>

អាករលើការស្នាក់នៅ = មូលដ្ឋានគិតអាករ x ២%

ក្រុមហ៊ុនត្រូវធ្វើការដាក់លិខិតប្រកាស និងបងប្រាក់អាករប្រចាំឆ្នាំខែ យ៉ាងយឺតបមផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែ ដែលសេវាស្នាក់នៅត្រូវបានផ្គត់ផ្គង់ ។ ក្នុងករណីអ្នកជាប់ពន្ធមិនបានប្រមូល និងមិនបានដាក់លិខិតប្រកាសបង់អាករលើការស្នាក់នៅ អ្នកជាប់ពន្ធនោះត្រូវរងទទួលទោសទណ្ឌតាមបទប្បញ្ញត្តិស្តីពីវិធាន និងនីតិវិធីសារពើពន្ធ ដូចមានចែងក្នុងផ្នែកទី៩-១០ និង១១ ជំពូកទី៥ នៃច្បាប់ស្តីពីសារពើពន្ធ ។[152]

[151] កថាខណ្ឌ ២ នៃសេចក្តីជូនដំណឹងស្តីពីការប្រមូលអាករលើការស្នាក់នៅ លេខ៧១២៧ សហវ.ពដ ចុះថ្ងៃទី២៧ ខែវិច្ឆកា ឆ្នាំ២០០៦

[152] កថាខណ្ឌ ៣ នៃសេចក្តីជូនដំណឹងស្តីពីការប្រមូលអាករលើការស្នាក់នៅ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦

### ឃ. អាករបំភ្លឺសាធារណៈ

អាករបំភ្លឺសាធារណៈ គឺជាអាករមួយក្នុងចំណោមអាករផ្សេងទៀត ដែលអនុវត្តទៅលើការផ្គត់ផ្គង់ទំនិញ ឬផលិតផល ដែលមានទ្រង់ទ្រាយជា សុរាមេរ័យ[153] ឬ បារី [154] គ្រប់ប្រភេទ បន្ទាប់ពីត្រូវបាន ធ្វើការនាំចូល ឬ ផលិតក្នុងស្រុក។[155] អាករនេះ ត្រូវបានដាក់ អោយអនុវត្តប្រើប្រាស់ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ អនុឡោមតាមព្រះរាជក្រមលេខ នស/រកម/១០៩៦/០១ នៃច្បាប់ស្តីពីហិរញ្ញវត្ថុគ្រប់គ្រងឆ្នាំ ១៩៩៩ ដើម្បីជាប្រយោជន៍ដល់ រដ្ឋបាលគ្រប់គ្រង់ថ្នាក់ក្រោមជាតិ ធ្វើការប្រមូរប្រាក់អាករពីរាល់ប្រតិបត្តិ ឬសកម្មភាពផ្គត់ផ្គង់នៃទំនិញ ជាសុរាមេរ័យ ឬ បារី ទុកជាការចំណាយអោយការបំភ្លឺសាធារណៈ។

អាករបំភ្លឺសាធារណៈ ត្រូវកំណត់នៅគ្រប់ដំណាក់កាលនៃការផ្គត់ផ្គង់ និង ត្រូវអនុវត្តលើការផ្គត់ផ្គង់ផលិតផលជាប់អាករ រួមបញ្ចូលទាំងពន្ធអាករនានា វៀលែងតែអាករ បំភ្លឺសាធារណៈខ្លួនឯង និងអាករលើតំលៃបន្ថែម ចំពោះបុគ្គលជាប់ពន្ធតាមរបបស្វ័យ ប្រកាស ។ អាករនេះ ត្រូវដល់កំណត់ និងត្រូវបង់នៅពេលមានការផ្គត់ផ្គង់ សំដៅដល់ រាល់ការផ្គត់ផ្គង់ទាំងឡាយណាដល់អ្នកប្រើប្រាស់ ឬ ការនាំចូលទំនិញដើម្បីធ្វើការផ្គត់ផ្គង់ ក្នុងស្រុក បុគ្គលជាប់ពន្ធ ត្រូវធ្វើការបង់ប្រាក់អាករ ឬប្រមូលអាករ ពីការផ្គង់ផ្គង់នោះ លើទំនិញមានលក្ខណៈជាសុរាមេរ័យ ឬ បារី ។ ហើយវិធាននៃការផ្គត់ផ្គង់ ត្រូវបាន

[153] សុរាមេរ័យ សំដៅលើ ស្រាបៀរ ស្រាទំពាំងបាយជូរស្រស់ រួមទាំងស្រាទំពាំងបាយជូរបន្ថែមជាតិសុរា ស្រាវ៉ែមុត និង ស្រាទំពាំងបាយជូរស្រស់ផ្សេងទៀត ផ្សំពីរុក្ខជាតិ និងសារជាតិក្រអូប ភេសជ្ជៈមេរ័យផ្សេង ទៀត លើកកលែងតែទឹកត្នោត ជូរ និង ស្រាស។

អាល់កុលអេទីលិកសុទ្ធ ដែលមានកម្រិតជាតិសុរាក្នុងឯកតាចំណុះពី ៨០% នៃចំនុះ ឬលើសពីនេះ និងអាល់កុលអេទីលិក ហើយនឹងភេសជ្ជៈមានជាតិសុរា ដែលបាត់បង់កំរិតសុរាដើមរបស់វា

អាល់កុលអេទីលិកបាត់បង់ធាតុសុទ្ធ ដែលមានកំរិតជាតិសុរាក្នុងឯករាចំណុះ ៨០% នៃចំនុះ និង ភេសជ្ជៈ មានជាតិសុរា ភេសជ្ជៈ ស្រវឹងផ្សេងៗទៀត ការរៀបចំកែច្នៃសុរាផ្សំក្នុងប្រភេទ ដែលសម្រាប់ផលិតភេសជ្ជៈ។

[154] បារី សំដៅដល់ផលិតផលសម្រាប់ជក់គ្រប់ប្រភេទដែលផលិតឡើងពីថ្នាំជក់ ហើយបារីក៏រួមបញ្ចូលផងដែរ នូវបារី អគ្គិសនី គ្រប់ប្រភេទ។ ប្រការ ៤ និយមន័យនៃ សុរាមេរ័យ និង បារី នៃប្រកាសលេខ ៩៧៦ ស្តីពីមូលដ្ឋានគិតអាករសម្រាប់ បំភ្លឺសាធារណៈ ចុះថ្ងៃទី ០៩ តុលា ២០១៧

[155] ប្រការ ២ វិសាលភាពនៃអាករបំភ្លឺសាធារណៈ នៃប្រកាសលេខ ៩៧៦ សហវ. ប្រក ស្តីពីការមូលដ្ឋានគិតអាករ សម្រាប់បំភ្លឺសាធារណៈ ចុះថ្ងៃទី ០៩ តុលា ២០១៧

អនុវត្តដូចគ្នា ទៅនឹងវិធាននៃការផ្គត់ផ្គង់សម្រាប់អាករលើតំលើបន្ថែម ដូចមានចែងក្នុងមាត្រា៦២ នៃច្បាប់ស្តីពីសារពើពន្ធ។[156]

**▷▶ អាត្រា និងមូលដ្ឋានអាករសម្រាប់បំភ្លឺសាធារណៈ:**

▷ តាមរយៈប្រកាសលេខ១៧៥ សហវ/ពដ/ប្រក អន្តរក្រសួង ស្តីពីការគ្រប់គ្រង់និងប្រមូលអាករ សម្រាប់បំភ្លឺសាធារណៈ ចុះថ្ងៃទី២២ មករា ឆ្នាំ ២០០២ ប្រការ១ អាករបំភ្លឺសាធារណៈ ត្រូវប្រមូលជាមួយ**អាត្រាគិតអាករ**ត្រឹម **៣%** លើតំលៃសុរាមេរ័យ និង បារីគ្រប់ប្រភេទ ប៉ុន្តែក្រោយមកនីតិវិធី នៃការប្រមូលប្រាក់អាករសម្រាប់បំភ្លឺសាធារណៈ ត្រូវបានកែប្រែ តាមរយៈប្រកាសលេខ ៩៧៦ សហវ. ប្រក ស្តីពីមូលដ្ឋានគិតអាករសម្រាប់ បំភ្លឺសាធារណៈ ចុះថ្ងៃទី ០៩ តុលា ២០១៧ ក្នុងបំនងបំពេញ បន្ថែមនូវវិធាននិងនីតិវិធី សម្រាប់អនុវត្តអាករសម្រាប់បំភ្លឺសាធារណៈ និងក្នុងគោលបំណងកំនត់អោយ ច្បាស់លាស់ នូវមូលដ្ឋានគិតអាករសម្រាប់បំភ្លឺសារធារណៈ លើការផ្គត់ផ្គង់គ្រប់ដំណាក់កាលនូវផលិតផលសុរាមេរ័យ និង បារី។

**▶ មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈ** បែកចែកជា ២ ផ្នែកធំៗ ដូចជា៖[157]

១.ចំពោះអ្នកផលិតនិងអ្នកនាំចូល[158]៖ មូលដ្ឋានគិតអាករ សំដៅដល់ថ្លៃផ្គត់ផ្គង់ ដែលបានកត់ត្រាលើវិក័យបត្រ រូមបញ្ចូលទាំងពន្ធ និងអាករនានា លើកលែងតែអាករបំភ្លឺ សាធារណៈខ្លួនឯង និងអាករលើតំលៃបន្ថែម។

២. ចំពោះអ្នកផ្គត់ផ្គង់បន្ត[159]៖ មូលដ្ឋានគិតអាករស្មើនឹង ២០% នៃថ្លៃផ្គត់ផ្គង់ ដែលបានកត់ត្រាលើវិក័យបត្រ រូមបញ្ចូលទាំងពន្ធ និងអាករនានា វៀរលែងតែអាករបំភ្លឺសាធារណៈ ខ្លួនឯង និងអាករលើតំលៃបន្ថែម។

---

[156] ប្រការ ៦ ពេលផ្គត់ផ្គង់ នៃប្រកាសលេខ ៩៧៦ សហវ. ប្រក ស្តីពីការមូលដ្ឋានគិតអាករ សម្រាប់បំភ្លឺសាធារណៈ ចុះថ្ងៃទី ០៩ តុលា ២០១៧

[157] ប្រការ ៥ មូលដ្ឋានគិតអាករ នៃប្រកាសលេខ ៩៧៦ សហវ. ប្រក ស្តីពីការមូលដ្ឋានគិតអាករ សម្រាប់បំភ្លឺសាធារណៈ ចុះថ្ងៃទី ០៩ តុលា ២០១៧

[158] អ្នកផលិតសំដៅដល់ បុគ្គលណាមួយដែលធ្វើសកម្មភាព បំប្លែងវត្ថុធាតុដើម ផ្គុំ ដំឡើង វេចខ្ចប់ ច្រកបំពេញអោយទៅជាផលិតផលសម្រេច។ អ្នកនាំចូល សំដៅដល់បុគ្គលណាមួយដែលធ្វើការនាំចូលដោយខ្លួនឯង ឬ ដោយបុគ្គដទៃមកក្នុងដែនគយនៃព្រះរាជណាចក្រកម្ពុជា។ ប្រការ ៤ និយមន័យនៃប្រកាសលេខ ៩៧៦ សហវ. ប្រក ស្តីពីការមូលដ្ឋានគិតអាករ សម្រាប់បំភ្លឺសាធារណៈ ចុះថ្ងៃទី ០៩ តុលា ២០១៧

រូបមន្តសង្ខេប:

មូលដ្ឋានគិតអាករ (សម្រាប់អ្នកលក់ដំបូង)= ថ្លៃផ្គត់ផ្គង់ជាប់អាករ + អាករផ្សេងៗ ឬ = ថ្លៃលក់ - អាករលើតម្លៃបន្ថែម - អាករបំភ្លឺសាធារណៈ ឬ =ថ្លៃលក់កត់ត្រាលើវិក្កយបត្រ/110%/103%

មូលដ្ឋានគិតអាករ (សម្រាប់អ្នកលក់បន្ត) = (ថ្លៃលក់ -អាករលើតម្លៃបន្ថែម - អាករបំភ្លឺសាធារណៈ)x 20 ឬ [(ថ្លៃលក់/110%/103%)]x 20%។

សម្រាប់ក្រុមហ៊ុនដែលមានទ្រង់ទ្រាយជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែលមានសកម្មភាពធ្វើការផលិត ឬ នាំចូល ឬធ្វើការចែកចាយបន្ត នូវផលិតផលជា ស្រាបៀរ ស្រាទំពាំង-បាយជូរ បារី បារីអគ្គសនី នឹងត្រូវមានកាតព្វកិច្ច ធ្វើការប្រមូល ប្រកាស និងបង់ប្រាក់អាករ រួមជាមួយអាករផ្សេងទៀត អាចជា អាករពិសេស និង អាករលើតំលើបន្ថែម។

## កថាខណ្ឌទី ០២ ៖ ការប្រើប្រាស់ឯកសារវិក្កយបត្រ អ.ត.ប ក្នុងការប្រមូលអាករ

យោងតាមមាត្រា ៩៨ នៃច្បាប់ស្តីពីសារពើពន្ធដែលបានចែងថា វិក្កយបត្រត្រូវតែចេញឲ្យលើរាល់កិច្ចការជំនួញរវាងអ្នកជាប់ពន្ធ និងបុគ្គលដទៃទៀត ។ អ្នជាប់ពន្ធត្រូវកត់ត្រាសេចក្តីរាយការណ៍លំអិត នៃវិក្កយបយត្រឲ្យបានត្រឹមត្រូវចូលក្នុងទិនានប្បវត្តិ ។ មាត្រា ៧៧ នៃច្បាប់សារពើពន្ធបានកំនត់ អំពីនិទ្ទេសដែលត្រូវកត់ត្រាក្នុងវិក្កយបត្រនីមួយៗជាអាទិ៍ត្រូវមាន ឈ្មោះសហគ្រាស អាស័យដ្ឋាន លេខអត្តសញ្ញាណកម្មសារពើពន្ធរបស់អ្នកលក់ លេខវិក្កយបត្រ ថ្ងៃខែឆ្នាំចេញវិក្កយបត្រ រាយមុខទំនិញ ឬសេវា បរិមាណ ថ្លៃឯកតាតម្លៃសរុបប្រាក់ ឈ្មោះ និង លេខអត្តសញ្ញាណកម្មអាករលើតំលៃបន្ថែម (អតប) របស់ អ្នកទិញ ករណីអ្នកទិញជាបុគ្គល ជាប់អាករលើតម្លៃបន្ថែម (អតប)។[160] អ្នកជាប់ពន្ធត្រូវ ចេញវិក្កយបត្រប្រើប្រាស់តាមលំដាប់លេខ រៀងឲ្យបានត្រឹមត្រូវ និងត្រូវរក្សាក្នុងរយះពេល១០ឆ្នាំ។ វិក្កយបត្រមួយលេខៗត្រូវមានពីរសន្លឹក មួយសន្លឹកសម្រាប់រក្សាទុក និងមួយសន្លឹកទៀតប្រគល់ជូន អ្នកទិញ។

ម៉្យាងទៀតមាត្រា៤២ នៃអនុក្រឹត្យលេ ១១៤ អនក្រ. បក ស្តីពីអាករលើតំលើបន្ថែម ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ ១៩៩៩ ស្តីពីអាករតម្លៃបន្ថែម (អតប) ត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិ ដូចតទៅ៖

ក. នៅពេលធ្វើការផ្គត់ផ្គង់ ទៅឲ្យបុគ្គលជាប់អាករលើតម្លៃបន្ថែម (អតប) ម្នាក់ទៀតបុគ្គលជាប់អាករលើតម្លៃបន្ថែម(អតប) ត្រូវចេញវិក្កយបត្រអាករលើតំលៃបន្ថែម(អតប) ដល់បុគ្គលជាប់អាករលើតម្លៃបន្ថែម (អតប) ម្នាក់ទៀតនោះ។

[159]អ្នកផ្គត់ផ្គង់បន្ត សំដៅដល់បុគ្គលដទៃទៀត ក្រៅពីអ្នកផលិត ឬអ្នកនាំចូលដំបូង ដែលផ្គត់ផ្គង់បន្តនូវផលិតផលជាប់ អាករ។

[160] មាត្រា ៧៧ កថាខណ្ឌ ០១ វិក្កយបត្រអាករលើតំលៃបន្ថែម នៃច្បាប់ស្តីសារពើពន្ធ នស/រកម/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

ខ. វិក្កយបត្រអាករលើតម្លៃបន្ថែម(អតប) ត្រូវមានចុះលេខអត្តសញ្ញាណកម្មនៃការចុះបញ្ជីអាករលើតម្លៃបន្ថែម (អតប) នៃអ្នកទិញ។

គ. បុគ្គលជាប់អាករលើតម្លៃបន្ថែម (អតប) អាចទាមទារឲ្យបុគ្គលជាប់អាករលើតម្លៃ បន្ថែម (អតប) នៃការផ្គត់ផ្គង់នោះ។

ឃ. បុគ្គលជាប់អាករលើតម្លៃបន្ថែម (អតប) ដែលមិនបានផ្តល់វិក្កយបត្រអាករលើតម្លៃបន្ថែម (អតប) ឲ្យទៅបុគ្គលជាប់អាករលើតម្លៃបន្ថែម (អតប) ផ្សេងទៀតត្រូវទទួលទោសទណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ ១៩៩៧។

ង. បុគ្គលជាប់អាករលើតម្លៃបន្ថែម (អតប) មិនត្រូវចេញវិក្កយបត្រអាករលើតម្លៃ បន្ថែម (អតប) ទៅឲ្យអតិថិជន ដែលមិនមែនជាបុគ្គលជាប់អាករលើតម្លៃបន្ថែម (អតប) ទេ ប៉ុន្តែត្រូវចេញវិក្កយបត្រធម្មតា ឬឯកសារផ្សេងទៀត ទៅឲ្យអតិថិជនដែលមិនមែនជាបុគ្គល ជាប់អាករលើតម្លៃបន្ថែម (អតប)។

ច. នៅពេលធ្វើការផ្គត់ផ្គង់ បុគ្គលជាប់អាករលើតម្លៃបន្ថែម (អតប) ត្រូវរក្សាសំណៅដើមនៃវិក្កយបត្រអាករលើតម្លៃបន្ថែម (អតប) វិក្កយបត្រធម្មតា ឬឯកសារផ្សេងទៀត ដែលបានចេញអោយអតិថិជនរបស់ខ្លួន។

កន្លងមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានចេញសេចក្តីជូនដំណឹងលេខ ០២៤ សហវ.ពដ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៦ ស្តីពីការប្រើប្រាស់វិក្កយបត្រ សម្រាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស (របបពិត) ដើម្បីណែនាំសហគ្រាសដែលជាអ្នកជាប់ពន្ធ ត្រូវមានកាតព្វកិច្ចចេញវិក្កយបត្រឲ្យអតិថិជន។

ទោះបីជាមានសេចក្តីណែនាំ ជាបន្តបន្ទាប់ហើយក៏ដោយ សហគ្រាសទាំងនោះនៅ តែពុំទាន់បានអនុវត្តឲ្យបានត្រឹមត្រូវនៅឡើយ។ ការសង្កេត និងតាមដានជាបន្តបន្ទាប់ឃើញថា សហគ្រាសមួយចំនួន មានកាតព្វកិច្ចចេញវិក្កយបត្រអាករលើតំលើបន្ថែម (អតប) ក៏មិនបាន ចេញវិក្កយបត្រត្រឹមត្រូវជូនដល់អតិថិជនដែរ ដោយគ្រាន់តែប្រើប្រាស់លិខិតធម្មតា ដែលមានបញ្ជាក់តែចំនួនប្រាក់ គ្មានឈ្មោះសហគ្រាស គ្មានអាសយដ្ឋាន ឈ្មោះអ្នកលក់ គ្មានរាយមុខ ទំនិញ ឬសេវាដែលបានផ្តល់ជូនអតិថិជន។

ជាថ្មីម្តងទៀត ក្នុងគោលបំណងពង្រឹងការគ្រប់គ្រងអោយបានត្រឹមត្រូវ និងក្នុងទិសដៅធានាការប្រមូលពន្ធឲ្យមានប្រសិទ្ធភាព អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានធ្វើការការណែនាំដល់គ្រប់សហគ្រាសទាំងអស់ថា នៅពេលផ្គត់ផ្គង់ទំនិញ ឬសេវា អ្នកជាប់ពន្ធត្រូវចេញវិក្កយបត្រជូនអតិថិជន។ ការមិនចេញវិក្កយបត្រ ឬបានចេញវិក្កយបត្រមិនត្រឹមត្រូវ ត្រូវចាត់

ទុកជាអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ តាមមាត្រា ១២៨ នៃច្បាប់ស្តីពីសារពើពន្ធ[161] នឹងត្រូវ រងនូវទោសទណ្ឌដូចមានចែងក្នុងមាត្រា១៣៣ និង មាត្រា ១៣៦ នៃច្បាប់ស្តីពីសារពើពន្ធ ក្នុងនោះមាន ដូចជា ការកំណត់ពន្ធបន្ថែម ការផាកពិន័យប្រាក់ពី៥លានរៀល (៥,០០០,០០០រៀល) រហូតដល់ ១០ លានរៀល (១០,០០០,០០០រៀល) ឬ ជាប់ពន្ធនាគារពី០១ខែ រហូតដល់ ០១ ឆ្នាំ ឬទោសទាំង ពីរ(មូលទោស) នេះ។

ជារឿយៗ អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំណូមពរ ចំពោះ លោក លោកស្រី ដែលជាអ្នកទិញ អ្នកប្រើប្រាស់ មេត្តាទាមទារវិក្កយបត្រពី អ្នកលក់ រាល់ពេលទិញ ទំនិញ ឬសេវា និងសូមស្វាគមន៍ផងដែរដល់លោក លោកស្រី ជាអ្នកទិញ អ្នកប្រើប្រាស មេត្តាទាមទារ វិក្កយបត្រពីអ្នកលក់ រាល់ពេលទិញទំនិញ ឬសេវា និងសូម ស្វាគមន៍ផងដែរដល់លោក លោកស្រី ជាអ្នកទិញ ពីពត៌មាននានា នៃការមិនផ្តល់វិក្កយបត្រ។ ដើម្បីធានាពីការអនុវត្តលើការប្រើប្រាស់នូវវិធានវិក័យបត្រសមស្របតាមការតំរូវនៃច្បាប់កំនត់ អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងធ្វើការចុះអង្កេតដល់កន្លែងនៃ សហគ្រាសដែលធ្វើការផ្គត់ផ្គង់ទំនិញ ឬសេវាផ្សេងៗ ត្រួតពិនិត្យអំពីការប្រើប្រាស់វិក្កយបត្រ ព្រមទាំងអនុវត្តវិធានការដាក់ទោសទណ្ឌយ៉ាងមឹងម៉ាត់ ចំពោះ ការមិនចេញវិក្កយបត្រ ឬបាន ចេញវិក្កយបត្រមិនត្រឹមត្រូវ ដូចតាមការជំរាបជូន និង ការផ្សព្វផ្សាយ។

សម្គាល់៖ ចំពោះវិក្កយបត្រ ម្ចាស់សហគ្រាសអាចរៀបចំរចនា និង បោះពុម្ព តម្រូវតាមចាំបាច់ នៃការធ្វើពាណិជ្ជកម្មរបស់ខ្លួន ប៉ុន្តែត្រូវមាននិទ្ទេសទាំងឡាយដូចមានបញ្ជាក់តាមគំរូខាងក្រោម នេះ។[162]

## ១. ទម្រង់នៃវិធានប្រើប្រាស់វិក័យបត្រ

---

[161] មាត្រា ១២៨ ចំណុច ០១ ករណីបុគ្គល អន្តន័យនៃអំពើរាំងស្ទះ រួមមាន៖

ក. មិនបានរក្សាបញ្ជីកាគណនេយ្យ និងឯកសារផ្សេងទៀត ឬមិនបានចេញវិក្កយបត្រលើកិច្ចការជំនួញ

ខ. មិនអនុញ្ញាតឲ្យរដ្ឋបាលសារពើពន្ធធ្វើការពិនិត្យបញ្ជីកាគណនេយ្យ ឬឯកសារផ្សេងៗ។

គ. មិនបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ

ឃ. មិនបានជូនដំណឹងទៅរដ្ឋបាលសារពើពន្ធអំពីការផ្លាស់ប្តូរក្នុងការចុះបញ្ជីដូចមានចែងក្នុងច្បាប់សារពើពន្ធ ១៩៩៧ នេះ

ង. កសាង ឬផ្តល់នូវកំណត់ត្រា ឯកសារ របាយការណ៍ ឬពត៌មានក្លែងបន្លំផ្សេងៗ

ច. លាក់ទុក ឬបំផ្លាញចោលដោយចេតនានូវបញ្ជីគណនេយ្យ កំណត់ត្រា ឯកសារ របាយការណ៍ ឬពត៌មានផ្សេងៗទៀត

ឆ. ព្យាយាមធ្វើឲ្យរាំងស្ទះដល់ការកំណត់ និង ការប្រមូលពន្ធ...

[162] សៀវភៅអេឡិចត្រូនិច ស្តីពី ការប្រើប្រាស់វិក្កយបត្ររបស់សហគ្រាសទាំងអស់ ឆ្នាំ ២០១១ រៀបចំ និងបោះផ្សាយដោយ អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**១.១. និទ្ទេសសំខាន់ៗ៖**[163]

**១.ពត៌មានរបស់អ្នកលក់៖**

- ឈ្មោះសហគ្រាសអាសយដ្ឋាន
- លេខអត្តសញ្ញាណកម្មអាករលើតម្លៃបន្ថែម (អតប)
- លេខរៀងវិក្កយបត្រតាមលំដាប់
- កាលបរិច្ឆេទចេញវិក្កយបត្រឲ្យបានច្បាស់លាស់

**២. ពត៌មានអ្នកទិញ៖**

- ឈ្មោះ
- អាសយដ្ឋាន
- លេខអត្តសញ្ញាណកម្មអាករលើតម្លៃបន្ថែម (បើមាន)
- សេចក្តីបរិយាយទំនិញ ឬសេវា
- ថ្លៃលក់ទំនិញ ឬសេវា
- តំលៃសរុបដែលមិនទាន់រួមបញ្ចូលអាករ និង ប្រាក់អាករដាច់ដោយឡែក
- ទឹកថ្នាំ និងសន្លឹកក្រដាសវិក្កយបត្រ ត្រូវមានគុណភាព និងរក្សាទុកបានយូរ

**ការប្រើប្រាស់ភាសា៖**[164]

- រាល់វិក្កយបត្រត្រូវសរសេរ ឬបោះពុម្ពជា ភាសាខ្មែរ
- អាចជាពីរភាសា គឺ ភាសាខ្មែរ និង ភាសាអង់គ្លេស
- ភាសាអង់គ្លេស ត្រូវនៅពីក្រោម ភាសាខ្មែរ

**គំរូវិក្កយបត្រ៖** គំរូវិក្កយបត្រអាករលើតម្លៃបន្ថែម (Tax invoice) ត្រូវរចនាស្របតាមគំរូវិក្កយបត្រទាំងបួនប្រភេទ ដូចដែរបានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃសេចក្តីណែនាំស្តីពីការប្រើប្រាស់វិក្កយបត្រសំរាប់អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារតាមរបបស្វ័យប្រកាស។ យោងតាមសេចក្តីណែនាំនេះ គំរូនៃវិក្កយបត្រទី១ និងទី២ ប្រើសំរាប់ការសរសេរវិក្កយបត្រដោយដៃ ឬបោះពុម្ពដោយប្រព័ន្ធកុំព្យូទ័រ។

[163] កថាខណ្ឌ ក និទ្ទេសសំខាន់ៗមួយចំនួននៃវិក្កយបត្រ នៃសេចក្តីណែនាំ លេខ១១២៧ អពដ ស្តីពីការប្រើប្រាស់វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារតាមរបបស្វ័យប្រកាស ចុះថ្ងៃទី ២៦ មករា ២០១៦ ឬគេហទំព័រ Facebook, Page នៃវិទ្យាស្ថានហិរញ្ញវត្ថុ និង គណនី ឬ Institute of Finance and Accounting-IFA https://www.facebook.com/Boreiaccounting/photos/a.787016824780510/1178375535644635/?type=3&theater បោះពុម្ពផ្សាយថ្ងៃទី ២១ វិច្ឆិកា ២០១៨ និង ចូលមើលថ្ងៃទី ០៥ មិថុនា ២០១៩

[164] កថាខណ្ឌ ខ នៃសេចក្តីណែនាំ លេខ១១២៧ អពដ ស្តីពីការប្រើប្រាស់វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារតាមរបបស្វ័យប្រកាស ចុះថ្ងៃទី ២៦ មករា ២០១៦

គំរូវិក្កយបត្រទី៣ និងទី៤ គឺប្រើសម្រាប់ការចេញវិក្កយបត្រដោយម៉ាស៊ីនគិតលុយ (POS) ឬម៉ាស៊ីនគិតលុយតាមប្រព័ន្ធកុំព្យូទ័រ។ ហើយគំរូវិក្កយបត្រទី១ និងទី៣ ប្រើសម្រាប់បុគ្គលជាប់អាករលើតម្លៃបន្ថែម (អ.ត.ប) ចេញឲ្យអតិថិជនរបស់ខ្លួនដែលជាបុគ្គលជាប់អាករលើតម្លៃបន្ថែម និងសម្រាប់ជាកម្មវត្ថុនៃការកាត់កង ចំណាយសម្រាប់គណនាពន្ធលើប្រាក់ចំណូល។ ផងដែរនោះគំរូវិក្កយបត្រទី២ និងទី៤ ប្រើសម្រាប់ អតិថិនជនដែលមិនមែនជាបុគ្គលជាប់ (អ.ត.ប) ពោលគឺសម្រាប់អ្នកប្រើប្រាស់ចុងក្រោយ។ គំរូនៃវិក្កយបត្រនេះ គឺមិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់សម្រាប់ស្នើសុំនូវឥណទានអាករលើតម្លៃបន្ថែមឡើយ។ [165]

គំរូវិក្កយបត្រទី ០១ ៖

- សម្រាប់ចេញអោយអតិថិជនជាបុគ្គលជាប់អាករលើតំលើបន្ថែម
- សម្រាប់សរសេរដោយដៃ ឬបោះពុម្ពដោយប្រព័ន្ធកុំព្យូទ័រ
- សម្រាប់ជាកម្មវត្ថុនៃការកាត់កងចំណាយសម្រាប់គណនាពន្ធលើប្រាក់ចំណូល

គំរូវិក្កយបត្រទី ០២៖

- សម្រាប់ចេញអោយអតិថិជនមិនមែនជាបុគ្គលជាប់អាករ ដែលជាអ្នកប្រើប្រាស់ចុងក្រោយ
- សម្រាប់សរសេរដោយដៃ ឬបោះពុម្ពដោយប្រព័ន្ធកុំព្យូទ័រ
- មិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់សម្រាប់ស្នើសុំឥណទានអាករលើតំលើបន្ថែម

គំរូវិក្កយបត្រទី៣

- ចេញដោយម៉ាស៊ីនគិតលុយ ឬម៉ាស៊ីនគិតលុយតាមប្រព័ន្ធកុំព្យូទ័រ
- សម្រាប់ចេញអោយអតិថិជនជាបុគ្គលជាប់អាករលើតំលៃបន្ថែម
- សម្រាប់ជាកម្មវត្ថុនៃការកាត់កងចំណាចសម្រាប់គណនាពន្ធលើប្រាក់ចំណេញ

គំរូវិក្កបយបត្រទី ៤

- ចេញដោយម៉ាស៊ីនគិតលុយ ឬម៉ាស៊ីនគិតលុយតាមប្រព័ន្ធកុំព្យូទ័រ
- មិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់សម្រាប់ស្នើសុំឥណទានអាករលើតំលើបន្ថែម

[165] កថាខណ្ឌ ច. អំពីគំរូវិក្កយបត្រ នៃសេចក្តីណែនាំ អពដ ស្តីពីការប្រើប្រាស់វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារតាមរបបស្វ័យប្រកាស លេខ១១២៧ ចុះថ្ងៃទី ២៦ មករា ២០១៦

- សម្រាប់ចេញអោយអតិថិជនមិនមែនជាបុគ្គលជាប់អាករ ដែលជាអ្នកប្រើប្រាស់ចុងក្រោយ។។។។។។[166]

គំរូវិក្កយបត្រទី ០១



រូបសញ្ញាលក់ក្រុមហ៊ុន LOGO

ឈ្មោះក្រុមហ៊ុនជាភាសាខ្មែរ
COMPANY NAME

លេខអត្តសញ្ញាណកម្ម អតប (VATTIN) □□□□-□□□□□□□□□
អាសយដ្ឋាន៖ ផ្ទះលេខ Address Nº | ផ្លូវ Street | ឃុំ/សង្កាត់ Commune/Sangkat
ក្រុង/ស្រុក/ខណ្ឌ Town/District/Khan | ខេត្ត/រាជធានី Province/City | ទូរស័ព្ទលេខ Telephone Nº

វិក្កយបត្រអាករ
TAX INVOICE

អតិថិជន / Customer :
ឈ្មោះក្រុមហ៊ុន ឬអតិថិជន Company name / Customer
ទូរស័ព្ទលេខ Telephone Nº
លេខអត្តសញ្ញាណកម្ម អតប (VATTIN) □□□□-□□□□□□□□□ (ប្រសិនជាមាន / If any)

លេខរៀងវិក្កយបត្រ៖ Invoice Nº
កាលបរិច្ឆេទ៖ Date □□ □□ □□□□

| ល.រ Nº | បរិយាយមុខទំនិញ Description | បរិមាណ Quantity | ថ្លៃឯកតា Unit Price | ថ្លៃទំនិញ Amount |
|---|---|---|---|---|
| 1 | | | | |
| 2 | | | | |
| 3 | | | | |
| 4 | | | | |
| 5 | | | | |
| 6 | | | | |
| 7 | | | | |
| 8 | | | | |
| 9 | | | | |
| 10 | | | | |
| 11 | | | | |
| 12 | | | | |
| 13 | | | | |
| 14 | | | | |
| 15 | | | | |
| | | | សរុប Sub Total | |
| | | | អាករលើតម្លៃបន្ថែម ១០% VAT (10%) | |
| | | | សរុបរួម Grand Total | |

Sample only

ហត្ថលេខា និងឈ្មោះអ្នកទិញ
Customer's Signature & Name

ហត្ថលេខា និងឈ្មោះអ្នកលក់
Seller's Signature & Name

សម្គាល់៖ ច្បាប់ដើមសម្រាប់អ្នកទិញ ច្បាប់ចម្លងសម្រាប់អ្នកលក់
Note: Original invoice for customer, copied invoice for seller

[166] គេហទំព័រ Facebook, Page នៃវិទ្យាស្ថានហិរញ្ញវត្ថុ និង គណនី ឬ Institute of Finance and Accounting-IFA https://www.facebook.com/Boreiaccounting/photos/a.787016824780510/1178375535644635/?type=3&theater បោះពុម្ពផ្សាយថ្ងៃទី ២១ វិច្ឆិកា ២០១៨ និង ចូលមើលថ្ងៃទី ០៥ មិថុនា ២០១៩

# គំរូវិក្កយបត្រទី ០២



ប្រសញ្ញាសម្គាល់ក្រុមហ៊ុន LOGO

**ឈ្មោះក្រុមហ៊ុនជាភាសាខ្មែរ**
**COMPANY NAME**

លេខអត្តសញ្ញាណកម្ម អតប (VATTIN) □□□□-□□□□□□□□□

អាសយដ្ឋាន៖ ផ្ទះលេខ Address N° ផ្លូវ Street ឃុំ/សង្កាត់ Commune/Sangkat

ក្រុង/ស្រុក/ខណ្ឌ Town/District/Khan ខេត្ត/រាជធានី Province/City ទូរស័ព្ទលេខ Telephone N°

(1)

**វិក្កយបត្រ**
**INVOICE**

(3)

**អតិថិជន / Customer :**
ឈ្មោះក្រុមហ៊ុន ឬអតិថិជន Company name / Customer
ទូរស័ព្ទលេខ Telephone N°

(2)

លេខរៀងវិក្កយបត្រ៖ Invoice N°
កាលបរិច្ឆេទ៖ Date □□ □□ □□□□

(4)

| ល.រ N° | បរិយាយមុខទំនិញ Description | បរិមាណ Quantity | ថ្លៃឯកតា Unit Price | ថ្លៃទំនិញ Amount |
|---|---|---|---|---|
| 1 | | | | |
| 2 | | | | |
| 3 | | | | |
| 4 | | | | |
| 5 | | | | |
| 6 | | | | |
| 7 | | | | |
| 8 | | | | |
| 9 | | | | |
| 10 | | | | |
| 11 | | | | |
| 12 | | | | |
| 13 | | | | |
| 14 | | | | |
| 15 | | | | |
| | | សរុប (បូកបញ្ចូលទាំងអាករ) Total (VAT included) | | |

(5)

Sample only

ហត្ថលេខា និងឈ្មោះអ្នកទិញ
Customer's Signature & Name

ហត្ថលេខា និងឈ្មោះអ្នកលក់
Seller's Signature & Name

សម្គាល់៖ ច្បាប់ដើមសម្រាប់អ្នកទិញ ច្បាប់ចម្លងសម្រាប់អ្នកលក់
Note: Original invoice for customer, copied invoice for seller

## គំរូវិក្កយបត្រទី ០៣



(ត្រាក្រុមហ៊ុន) LOGO

**ឈ្មោះក្រុមហ៊ុនជាភាសាខ្មែរ**

**COMPANY NAME**

លេខអត្តសញ្ញាណកម្ម អតប (VATTIN) ☐☐☐☐-☐☐☐☐☐☐☐☐☐ (1)

អាសយដ្ឋាន៖ ផ្ទះលេខ Address N° | ផ្លូវ Street | ឃុំ/សង្កាត់ Commune/Sangkat | ក្រុង/ស្រុក/ខណ្ឌ Town/District/Khan | ខេត្ត/រាជធានី Province/City | ទូរស័ព្ទលេខ Telephone N°

**វិក្កយបត្រអាករ**

**TAX INVOICE**

(3) **អតិថិជន / Customer :**

ឈ្មោះក្រុមហ៊ុន ឬអតិថិជន
Company name / Customer

ទូរស័ព្ទលេខ
Tel N°

លេខអត្តសញ្ញាណកម្ម អតប (VATTIN) ☐☐☐☐-☐☐☐☐☐☐☐☐☐ (ប្រសិនបើមាន / if any)

(2) លេខរៀងវិក្កយបត្រ៖
Invoice N°

កាលបរិច្ឆេទ៖ ☐☐ ☐☐ ☐☐☐☐
Date

(4)

| ល.រ N° | បរិយាយមុខទំនិញ Description | បរិមាណ Quantity | ថ្លៃឯកតា Unit Price | ថ្លៃទំនិញ Amount |
|---|---|---|---|---|
| | | | | |

(5)

សរុប **Sub Total**

អាករលើតម្លៃបន្ថែម ១០% **VAT (10%)**

សរុបរួម **Grand Total**

ហត្ថលេខា និងឈ្មោះអ្នកទិញ
**Customer's Signature & Name**

ហត្ថលេខា និងឈ្មោះអ្នកលក់
**Seller's Signature & Name**

**សម្គាល់៖** ច្បាប់ដើមសម្រាប់អ្នកទិញ ច្បាប់ចម្លងសម្រាប់អ្នកលក់
**Note:** Original invoice for customer , copied invoice for seller

## គំរូវិក្កយបត្រទី ០៤


ឈ្មោះក្រុមហ៊ុនជាភាសាខ្មែរ

COMPANY NAME

(VATTIN)

Address N° Street Commune/Sangkat Town/District/Khan Province/City Telephone N°

វិក្កយបត្រ

INVOICE

អតិថិជន / Customer :

Company name / Customer

Tel N°

Invoice N°

Date

| N° | Description | Quantity | Unit Price | Amount |
| --- | --- | --- | --- | --- |

សរុប (រួមបញ្ចូលទាំងអាករ)

Total (VAT included)

ហត្ថលេខា និងឈ្មោះអ្នកទិញ

Customer's Signature & Name

ហត្ថលេខា និងឈ្មោះអ្នកលក់

Seller's Signature & Name

សម្គាល់៖ ច្បាប់ដើមសម្រាប់អ្នកទិញ ច្បាប់ចម្លងសម្រាប់អ្នកលក់

Note: Original invoice for customer , copied invoice for seller



[167]

[167] ឧបសម្ព័ន្ធ ០៤ នៃនៃសេចក្តីណែនាំស្តីពីការប្រើប្រាស់វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធ ដែល បានចុះបញ្ជីពន្ធដារតាមរបប ស្វ័យប្រកាស លេខ ១១២៧ អពដ ចុះថ្ងៃទី ២៦ មករា ២០១៦

ជារួមសម្រាប់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសអនុលោមតាមច្បាប់ជាធរមាន ត្រូវមានកាតព្វកិច្ចសំខាន់ចំពោះវិក្កយបត្រដូចជា៖[168]

- ត្រូវចេញវិក្កយបត្ររាល់ការផ្គត់ផ្គង់ទំនិញ ឬសេវាទាំងអស់ ដល់អតិថិជន ទៅតាមគំរូវិក្កយបត្រ និងនិទ្ទេសដូចបានរៀបរាប់ខាងលើ ដោយ៖
  - ⇒ ត្រូវចេញវិក្កយបត្រអាករ (Tax Invoice) ដល់អតិថិជនជាបុគ្គលជាប់អាករ
  - ⇒ ត្រូវចេញវិក្កយបត្រធម្មតា (Commercial Invoice) ដល់អតិថិជនមិនមែនជាបុគ្គលជាប់អាករ
- ត្រូវប្រើវិក្កយបត្រតាមលំដាប់លេខរៀងពេញ ១ ឆ្នាំ នឹងត្រូវរក្សាទុកជាឯកសារសម្រាប់គោលដៅពន្ធដាររយៈពេល ១០ឆ្នាំ
- ត្រូវភ្ជាប់មកជាមួយនូវវិក្កយបត្រអាករត្រឹមត្រូវ ឬជាឯកសារស្កែន (Scan) ចេញពីច្បាប់ដើម (Soft Copy) ចំពោះរាល់ការស្នើសុំឥណទានអាករលើធាតុចូល (VAT Credit) ប្រចាំខែ
- ត្រូវមានវិក្កយបត្រត្រឹមត្រូវតាមទម្រង់ដូចមានកំណត់ក្នុងសេចក្ដីណែនាំនេះ ចំពោះរាល់ការស្នើសុំកាត់កងចំណាយនៃឥណទានលើអាករធាតុចូល (VAT Credit) សម្រាប់គណនាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ
- រាល់វិក្កយបត្រត្រូវសរសេរ ឬបោះពុម្ពជាភាសាខ្មែរអាចជាពីរភាសា គឺ ភាសាខ្មែរ និងភាសាអង់គ្លេស ហើយភាសាអង់គ្លេសត្រូវនៅពីក្រោមភាសាខ្មែរ។

## ផ្នែកទី ០២៖ ការទទួលបានការអនុគ្រោះ និងការអនុវត្តពិសេសចំពោះអាករ

### កថាខណ្ឌទី ០១ ៖ ការលើកលែងប្រាក់អាករចំពោះក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

#### ក. ការទទួលបានការអនុវត្តពិសេសចំពោះអាជីវកម្មមានកម្មវត្ថុជាការដាំដុះស្រូវការប្រមូលទិញស្រូវ និងការផលិតអង្ករនាំចេញ

នៅពេលដែលកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត គឺជាការដាំដុះ ការប្រមូលទិញស្រូវ ឬការផលិតអង្ករនាំចេញ នីតិបុគ្គលនេះនឹងទទួលបានការលើកលែងផ្នែកពន្ធដារចំពោះអាករលើតម្លៃបន្ថែម ក្នុងលក្ខណ្ឌដូចខាងក្រោម ៖[169]

[168] សេចក្ដីណែនាំស្ដីពីការប្រើប្រាស់វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធ ដែល បានចុះបញ្ជីពន្ធដារតាមរបប ស្វ័យប្រកាស លេខ ១១២៧ អពដ ចុះថ្ងៃទី ២៦ មករា ២០១៦

- ចំពោះការផ្គត់ផ្គង់ស្រូវក្នុងស្រុក នីតិបុគ្គលនេះត្រូវជាប់អាករលើតម្លៃបន្ថែមតាមអាត្រា 0%
- ការផ្គត់ផ្គង់អង្ករក្នុងស្រុក ត្រូវជាប់អាករលើតម្លៃបន្ថែមតាមអាត្រាធម្មតា ១0%
- ការនាំចេញអង្ករ ត្រូវជាប់អាករលើតម្លៃបន្ថែមតាមអត្រា 0%
- អាករលើធាតុចូលដែលទាក់ទិននឹងការដាំដុះស្រូវ ប្រូលទិញស្រូវ និងផលិតអង្ករនាំចេញត្រូវបានអនុញ្ញាតជាឥណទាន ឬបង្វិលសង ។

សហគ្រាសដាំដុះស្រូវ ប្រមូលទិញស្រូវ និងផលិតអង្ករនាំចេញ ដែលបានទទួលការលើកទឹក-ចិត្តដូចមានចែងក្នុងសរសេរខាងលើ ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ ប្រចាំឆ្នាំ និងបង់ប្រាក់ពន្ធអាករដទៃទៀតតាមបទប្បញ្ញត្តិស្តីពីសារពើពន្ធជាធរមាន ។ ក្នុងករណីមិនអនុវត្តតាមកាតព្វកិច្ចខាងលើនេះ ក្រុមហ៊ុននឹងត្រូវប្រឈមនឹងការដកហូតមកវិញដោយខាងអគ្គនាយកដ្ឋានពន្ធដារនូវការលើកទឹកចិត្តខាងលើ ។[170]

### ខ. ការទទួលបានការអនុវត្តពិសេសចំពោះអាករលើតម្លៃបន្ថែមសម្រាប់ការនាំចូល និងផ្គត់ផ្គង់ទំនិញមួយចំនួន

ដើម្បីលើកម្ពស់សកម្មភាពកសិកម្មដែលជាអាទិភាពរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់រាជាណាចក្រកម្ពុជា ។អាករលើតម្លៃបន្ថែមលើការនាំចូល និងការផ្គត់ផ្គង់ទំនិញមួយចំនួន ដូចខាងក្រោមនេះ ត្រូវបាន រដ្ឋទទួលបន្ទុកៈ [171]

- ជីគ្រប់ប្រភេទ រួមមាន ជីសម្រាប់ប្រើក្នុងវិស័យកសិកម្មលើគ្រប់មុខដំណាំដែលផ្សំដោយជាតិគីមី ជាតិសរីរាង្គ និង រ៉ែធម្មជាតិ។
- ពូជដំណាំគ្រប់ប្រភេទ រួមមាន ៖
  - ក. គ្រាប់ពូជដំណាំគ្រប់ប្រភេទ
  - ខ. បំណែកពូដំណាំគ្រប់ប្រភេទប្រើសម្រាប់ដាំដុះជា ដើម មើម ខ្នែង មែកសាក មែកផ្សាំ វល្លិ ។ល។
- បសុឱសថ រួមមានឱសថគ្រប់ប្រភេទប្រើប្រាស់តែលើសត្វគ្រប់ប្រភេទ សម្រាប់ទ្រទ្រង់សុខភាព ព្យាបាលការពារ និង បង្កើនផលិតភាពរបស់សត្វ។

[169] ប្រការ១ នៃប្រកាសស្តីពីការលើកទឹកចិត្តពន្ថែមចំពោះការដាំដុះស្រូវ ការប្រមូលទិញស្រូវ និងការផលិតអង្ករនាំចេញ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១

[170] ប្រការ២ នៃប្រកាសស្តីពីការលើកទឹកចិត្តពន្ថែមចំពោះការដាំដុះស្រូវ ការប្រមូលទិញស្រូវ និងការផលិតអង្ករនាំចេញ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១

[171] ប្រការ២ នៃប្រកាសស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមលើការនាំចូល និងការផ្គត់ផ្គង់ទំនិញមួយចំនួនចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤

- ចំណីសត្វ និងចំណីបន្ថែម រួមមាន៖
  - ក. ចំណីសត្វគ្រប់ប្រភេទសម្រាប់ការទ្រទ្រង់ការលូតលាស់របស់សរីរាង្គសត្វ
  - ខ.ចំណីបន្ថែមគ្រប់ប្រភេទ វីតាមីន ឬអង្គធាតុរ៉ែផ្សេងៗទៀត សម្រាប់ប្រើប្រាស់បន្ថែម លើចំណីសត្វ
  - គ. អង្កាម កន្ទក់ និងកម្ទេចចុងអង្ករ សម្រាប់ធ្វើចំណីសត្វ។
- ពូជសត្វគ្រប់ប្រភេទ រួមមាន៖
  - ក. ពូជសត្វស្រុកគ្រប់ប្រភេទ
  - ខ. ពូជសត្វព្រៃគ្រប់ប្រភេទ។
- គ្រឿងយន្ត និង ឧបករណ៍កសិកម្មប្រភេទ៖
  - ក. គោយន្តភ្ជួរ រាស់ និងបន្លាស់សម្រាប់គ្រួសារ
  - ខ. ម៉ាស៊ីនកិចចំណីសត្វ
  - គ. ឧបករណ៍បណ្តុះគ្រាប់ពូជ ឬ ភ្ញាស់ស៊ុតសត្វ
  - ឃ. តួបូមទឹកនៃម៉ាស៊ីនបូមទឹក។

**គ. ការលើកលែងអាករលើតម្លៃបន្ថែមលើមុចទំនិញដែលជាអាហារជាមូលដ្ឋាន សម្រាប់ការរស់នៅ**

អាហារជាមូលដ្ឋាន គឺសំដៅដល់បណ្តាមុខទំនិញមួយចំនួនដែលចាំបាច់សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ ។ នៅពេលដែលក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដែលជាអ្នកជាប់ពន្ធ តាមរបបស្វ័យប្រកាស នីតិបុគ្គលនេះនឹងទទួលបានការលើកលែងនូវអាករ លើតម្លៃបន្ថែមចំពោះការផ្គត់ផ្គង់ក្នុងស្រុកលើមុខទំនិញដែលជាអាហារជាមូលដ្ឋាន ដើម្បីជួយសម្រួលជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ។ សម្រាប់អាករលើតម្លៃបន្ថែមចំពោះមុខទំនិញទាំង នោះត្រូវបានកំណត់ថាបន្ទុករបស់រដ្ឋ ។[172] មុខទំនិញទាំងនោះមានដូចជា ៖[173]

- សាច់សត្វចិញ្ចឹម មានជាអាទិ៍ សាច់គោ ក្របី ពពែ ចៀម ជ្រូក មាន់ ទា ទោះបីមានលក្ខណៈជាសាច់ស្រស់ ឬកែច្នៃតាមវិធីប្រឡាក់ ឬឆ្អើរ
- ស៊ុតសត្វចិញ្ចឹមគ្រប់ប្រភេទ ទោះបីមានលក្ខណៈជាស៊ុតស្រស់ ឬកែច្នៃតាមវិធីផ្អាប់ឬឆ្អើរ

[172]ប្រការ២ នៃប្រកាសស្តីពី ការចាត់ជាបន្ទុករបស់រដ្ឋនូវអាករលើតម្លៃបន្ថែមលើមុខទំនិញដែលជាអាហារជាមូលដ្ឋានសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ចុះថ្ងៃទី០៣ ខែមេសារ ឆ្នាំ២០១៨

[173] ប្រការ៤ នៃប្រកាសស្តីពី ការចាត់ជាបន្ទុករបស់រដ្ឋនូវអាករលើតម្លៃបន្ថែមលើមុខទំនិញដែលជាអាហារជាមូលដ្ឋានសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ចុះថ្ងៃទី០៣ ខែមេសារ ឆ្នាំ២០១៨

- ត្រីទឹកសាប ឬត្រីទឹកប្រៃគ្រប់ប្រភេទ រួមទាំង បង្កង បង្គា កំពឹស ក្តាម និងសិប្បីជាតិគ្រប់ប្រភេទ ទោះបីមានលក្ខណៈជាសាច់ស្រស់ ឬកែឆ្នៃតាមវិធីប្រឡាក់ ឬឆ្អើរ
- ស្ករគ្រប់ប្រភេទ ដែលមិនមានលក្ខណៈជាស្ករគ្រាប់
- អំបិលគ្រប់ប្រភេទ
- ទឹកត្រី និងទឹកស៊ីអ៊ីវគ្រប់ប្រភេទ ។

ចំពោះចំណីអាហារខាងលើត្រូវបានកំណត់ថាជាបន្ទុករបស់រដ្ឋសម្រាប់តែរយៈពេល ២ឆ្នាំតែប៉ុណ្ណោះ ដោយគិតចាប់ពីឆ្នាំ ២០១៨ ដល់ឆ្នាំ ២០១៩ ។ តែការលើលលែងនេះ មិនបានគិតបញ្ចូលចំពោះការផ្គត់ផ្គង់ម្ហូបអាហារដោយភោជនីយដ្ឋានឡើយ ។[174]

**កថាខណ្ឌទី០២៖ការទទួលបានការអនុគ្រោះពិសេសចំពោះសកម្មភាពវិនិយោគដែលមានគម្រោង វិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់**

អនុលោមតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា មានតែគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទេ ដែលមានសិទ្ធិទទួលបាននូវផលប្រយោជន៍ដែលស្ថិតក្នុងក្របខ័ណ្ឌនៃច្បាប់នេះ ។ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ហៅកាត់ថា គ. ល. គ មានន័យថា គម្រោងវិនិយោគ ដែលទទួលបានវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ ។ ដើម្បីទទួលស្គាល់ជា គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អ្នកវិនិយោគត្រូវដាក់សំណើវិនិយោគនៅក្រុមប្រឹក្សា អភិវឌ្ឍន៍កម្ពុជា(ក.អ.ក) ឬ អនុគណៈកម្មាធិការវិនិយោគ ខេត្ត-រាជធានី និង ទទួលបានវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ ។ ក្រៅពីទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារចំពោះពន្ធលើប្រាក់ចំណូលហើយបន្ទាប់ពីក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ទទួលបាននូវនីតិបុគ្គលិកលក្ខណៈជា គ.ល.គ នីតិបុគ្គលនេះនឹងនូវទទួលបានការលើទឹកចិត្តទៅលើកាតព្វកិច្ចចំពោះអាករទៀត ។ ដែលការលើទឹកចិត្តនេះត្រូវប្រព្រឹត្តដូចតទៅ ៖[175]

**ក. ការលើកទឹកចិត្តសម្រាប់ការនាំចូល**

- **វិស័យកាត់ដេរបម្រើឲ្យការនាំចេញ**

- **អាករលើតម្លៃបន្ថែម** លើធាតុចូលផលិតកម្មនាំចូល ត្រូវបានដាក់ជាបន្ទុករបស់រដ្ឋ (លិខិតលេខ ១១០ សជណ.ផស របស់ទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៩

[174] ប្រការ៥ នៃប្រកាសស្តីពី ការចាត់ជាបន្ទុករបស់រដ្ឋនូវអាករលើតម្លៃបន្ថែមលើមុខទំនិញដែលជាអាហារជាមូលដ្ឋានសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ចុះថ្ងៃទី០៣ ខែមេសារ ឆ្នាំ២០១៨

[175] វេបសាយរបស់ អគ្គនាយកដ្ឋានពន្ធគយ និងរដ្ឋាករកម្ពុជា ចូលមើលនៅថ្ងៃទី ១៧ ខែ៧ ឆ្នាំ២០១៩ ម៉ោង ៣:៣៧ នាទី http://www.customs.gov.kh/%E1%9E%93%E1%9E%B8%E1%9E%8F%E1%9E%B7%E1%9E%9C%E1%9E%B7%E1%9E%92%E1%9E%B8%E1%9E%96%E1%9E%B7%E1%9E%9F%E1%9F%81%E1%9E%9F/%E1%9E%82%E1%9E%98%E1%9F%92%E1%9E%9A%E1%9F%84%E1%9E%84%E1%9E%9C%E1%9E%B7%E1%9E%93%E1%9E%B7%E1%9E%99%E1%9F%84%E1%9E%82/

ស្តីពីករណីអនុវត្ត អាករលើតម្លៃបន្ថែម VAT លើធាតុចូលដែលនាំចូល ដោយរោងចក្រផលិតសំលៀកបំពាក់សម្រាប់នាំចេញ)

- **អាករពិសេស** លើទំនិញដែលនាំចូលជាធាតុចូលផលិតកម្មសម្រាប់ឧស្សាហកម្មផលិតសំលៀកបំពាក់ ត្រូវបានដាក់ជាបន្ទុករបស់រដ្ឋ (លិខិតលេខ ៣៩៣ អគរ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥)។

➢ **ឧស្សាហកម្មបម្រើឲ្យការនាំចេញ**

- **អាករពិសេស** លើទំនិញដែលបាននាំចូលគឺជាធាតុចូលផលិតកម្មសម្រាប់ឧស្សាហកម្មគាំទ្រដល់ឧស្សាហកម្មបម្រើឲ្យការនាំចេញត្រូវបានដាក់ជាបន្ទុករបស់រដ្ឋ ។ (លិខិតលេខ ៧៥៨ អគរ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ របស់ អគរ )។

➢ **ឧស្សាហកម្មគាំទ្រដល់ឧស្សាហកម្មបម្រើឲ្យការនាំចេញ**

- **អាករលើតម្លៃបន្ថែម** លើទំនិញនាំចូលដែលជាធាតុចូលផលិតកម្មនិងសម្ភារបរិក្ខារផលិតកម្មសម្រាប់បម្រើឲ្យការផ្គត់ផ្គង់ដោយផ្ទាល់ដល់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិត ស្បែកជើង ឧស្សាហកម្មផលិតកាបូបយួរ និងកាបូបដៃ និងឧស្សាហកម្មផលិតមួក ត្រូវបានចាត់ទុកជាបន្ទុករបស់រដ្ឋ។[176]
- **អាករពិសេស** លើទំនិញដែលនាំចូលជាធាតុចូលផលិតកម្មសម្រាប់ឧស្សាហកម្មគាំទ្រដល់ឧស្សាហកម្ម បម្រើឲ្យការនាំចេញត្រូវបានដាក់ជាបន្ទុករបស់រដ្ឋ (លិខិតលេខ ៣៩៣ អគរ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ និងលិខិតលេខ ៧៥៨ អគរ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥)។

**ខ. នីតិវិធីនាំចូលសម្រាប់ គ.ល.គ**

ដើម្បីនាំចូលនូវសម្ភារបរិក្ខារផលិតកម្ម សម្ភារសាងសង់ ឬ ធាតុចូលផលិតកម្មសម្រាប់បម្រើដល់ផលិតកម្ម របស់ខ្លួនដោយទទួលបាននូវការលើកលែងពន្ធ ឬ អាករ គ.ល.គ ត្រូវអនុវត្តតាមល័ក្ខខ័ណ្ឌដូចខាងក្រោមៈ

- អ្នកវិនិយោគ ឬ តំណាងត្រូវស្នើសុំបញ្ជីមេនៃមុខទំនិញនាំចូលបម្រើឲ្យ គ.ល.គ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា "គណៈកម្មាធិការវិនិយោគកម្ពុជា " (ក.អ.ក"គ.វ.ក")។
- បន្ទាប់ពីទទួលបានការអនុញ្ញាតពី ក.អ.ក"គ.វ.ក" បញ្ជីមេខាងលើ ត្រូវយកមកតម្កល់ទុកនៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (នាយកដ្ឋានរបបគយ)។
- នៅពេលនាំចូល ទំនិញដែលមាននៅក្នុងបញ្ជីមេ អ្នកវិនិយោគ ឬ តំណាងត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតគយ មកអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (នាយកដ្ឋានរបបគយ)

[176] ប្រការ ៤ នៃប្រកាសស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះឧស្សាហកម្មគាំទ្រ ឬអ្នកចុះកិច្ចសន្យាដែលធ្វើការផ្គត់ផ្គង់ទំនិញ ឬសេវាសម្រាប់បម្រើឲ្យការនាំចេញរបស់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតការបូបយួរ និងការបូបដៃ និងឧស្សាហកម្មផលិតមួក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤

ដោយភ្ជាប់មកជាមួយនូវឯកសារចាំបាច់នានារួមមាន វិក្កយបត្រទំនិញ បញ្ជីវេចខ្ចប់ ឯកសារដឹកជញ្ជូន លិខិតផ្ទេរសិទ្ធិសម្រាប់បុគ្គលតំណាង និងឯកសារពាក់ព័ន្ធផ្សេងទៀតក្នុងករណីចាំបាច់។

- បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតគយ អ្នកវិនិយោគ ឬតំណាងត្រូវអនុវត្តនីតិវិធីនៃការបំពេញប្រតិវេទន៍គយដូចមានក្នុងនីតិវិធីប្រតិវេទន៍គយ។

# ជំពូកទី ០៣
# ទោសទណ្ឌរដ្ឋបាលនៃបទបញ្ញត្តិពន្ធដារ

# ជំពូកទី ០៣ ៖ ទោសទណ្ឌរដ្ឋបាលនៃបទបញ្ញត្តិពន្ធដារ

## ផ្នែកទី ០១ ៖ ប្រភេទនៃកំហុសរដ្ឋបាល និង ការទទួលខុសត្រូវ ស្តីពីបទប្បញ្ញត្តពន្ធដារ

### កថាខណ្ឌទី ០១៖ ប្រភេទនៃកំហុសរដ្ឋបាល នៃបញ្ញាត្តពន្ធដារ

ដើម្បីជាការធានារនូវសុក្រឹតភាព និង បញ្ហាសនូវការគេចវេសក្នុងការបងប្រាក់ពន្ធរបស់អ្នកជាប់ពន្ធ អគ្គនាយកដ្ឋានពន្ធដារបានធ្វើការកំណត់ចេញនូវទោសប្បញ្ញត្តិផ្សេងៗ ដើម្បីជាការទប់-ស្កាត់ និង ជាការពិន័យទៅដល់អ្នកជាប់ពន្ធដែលបានគេចវេសនូវកាតព្វកិច្ចរបស់ខ្លួនក្នុងការ បង់ប្រាក់ពន្ធអាករ ។ អ្នកជាប់ពន្ធ ក៏ដូចជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត អាចនឹង ត្រូវប្រឈមក្នុងការទទួលនូវការពិន័យ ឬ ក៏ទោសទណ្ឌផ្សេងៗកាលបើបានប្រព្រឹត្តនូវកំហុសដូចដែលមានកំណត់នៅក្នុងច្បាប់ស្តីពីសារពើពន្ធ ។ កំហុសទាំងនោះត្រូវបានធ្វើការ បែងចែកចេញជាបីប្រភេទផ្សេងៗគ្នាដោយកំហុសទាំងអស់នោះមានដូចជា ៖

**ក. ការធ្វេសប្រហែស**

ការធ្វេសប្រហែសត្រូវបានចែកចេញជាពីរប្រភេទគឺ ការធ្វេសប្រហែស និងការធ្វេសប្រហែសធ្ងន់ធ្ងរ ។ **ការធ្វេសប្រហែស** គឺជាកាលដែលប្រាក់ពន្ធដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារ កាត់ទុកនោះបានបង់មានចំនួនតិចជាងប្រាក់ពន្ធដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារ មិនលើសពី ១០% ។ ឬជាការដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកមិនបានធ្វើការដាក់លិខិតប្រកាសសារពើពន្ធ ឬមិនបានធ្វើការបង់ពន្ធតាមកាលបរិច្ឆេតដែលច្បាប់បានកំណត់ ។[177] **ការធ្វេសបរហែសធ្ងន់ធ្ងរ** គឺជាការដែលប្រាក់ពន្ធដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកបានបង់ មានចំនួនតិចជាងប្រាក់ពន្ធ ដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារលើសពី ១០% ។[178]

អាចចាត់ទុកបានថាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតបានប្រព្រឹត្តិនូវការធ្វេសប្រហែសលុះត្រាតែអំពើទាំងនោះបានបំពេញលក្ខខណ្ឌណាមួយនូវខាងលើ ។

**ខ. ការគេចវេសពន្ធ**

[177] មាត្រា ១២៥ នៃនៃច្បាប់ស្តីពីសារពើពន្ធ និង ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសារពើពន្ធ

[178] មាត្រា ១២៦ នៃនៃច្បាប់ស្តីពីសារពើពន្ធ និង ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសារពើពន្ធ

ការគេចវេសពន្ធ គឺបទល្មើសដោយចេតនាដោយដឹងជាមុន មានការរៀបចំទុក និង ច្រើនដង ទៅលើបទប្បញ្ញត្តិស្តីពីពន្ធដារ ក្នុងបំណងបន្ថយ ឬ បំបាត់ប្រាក់ពន្ធដែលប្បញ្ញត្តិស្តីពីពន្ធដារតម្រូវឲ្យបង់ ។ ត្រូវបានចាត់ទុកថាជាការគេចផងដែរ ក្នុងករណីដែលការធ្វេសប្រហែសធ្ងន់ធ្ងរដូចដែលបានរៀបរាប់ខាងលើនោះបានប្រព្រឹត្តឡើង ៖[179]

- ✓ ពីរលើកដាច់ពីគ្នាក្នុងរយៈពេល ៣ឆ្នាំនៃឆ្នាំប្រតិទិន ។
- ✓ បីលើក ឬច្រើនជាងនេះដាច់ពីគ្នាក្នុងរយៈពេលណាមួយក៏ដោយ ។

កាលបើក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតបានប្រព្រឹត្តិនូវអំពើដូចដែលបានរៀបរាប់ខាងលើនោះនីតិបុគ្គលនេះនឹងត្រូវទទួលនូវទោសទណ្ឌ ។

**គ. អំពើរាំងស្ទះការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារ**

អាចចាត់ទុកបានថាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត បានប្រព្រឹត្តនូវអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារបាន លុះត្រាតែសកម្មភាពមានលេចឡើងនូវសកម្មភាពណាមួយ ដែលជា លក្ខខណ្ឌនៃអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ។ អំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ រួមមាន ៖[180]

- ➢ មិនបានរក្សាបញ្ជីការគណនេយ្យ និង ឯកសារផ្សេងៗ ឬ មិនបានចេញវិក្កយបត្រលើកិច្ចការជំនួញ ។
- ➢ មិនអនុញ្ញាតឲ្យរដ្ឋបាលសារពើពន្ធធ្វើការពិនិត្យបញ្ជីកាគណនេយ្យ ឬ ឯកសារផ្សេងៗ ។
- ➢ មិនបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ។
- ➢ មិនបានជូនដំណឹងទៅរដ្ឋបាលសារពើពន្ធអំពីការផ្លាស់ប្តូរក្នុងការចុះបញ្ជីដូចមានចែងក្នុងច្បាប់នេះ ។
- ➢ កសាង ឬផ្តល់នូវកំណត់ត្រា ឯកសារ របាយការណ៍ ឬពត៌មានក្លែងបន្លំផ្សេងៗ ។
- ➢ លាក់ទុក ឬ បំផ្លាញចោលដោយចេតនានូវបញ្ជីគណនេយ្យ កំណត់ត្រា ឯកសារ របាយការណ៍ ឬពត៌មានផ្សេងៗ ទៀត ។
- ➢ ព្យាយាមធ្វើឲ្យរាំងស្ទះដល់ការកំណត់ និង ការប្រមូលពន្ធ។

[179] មាត្រា ១២៧ នៃនៃច្បាប់ស្តីពីសារពើពន្ធ និង ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសារពើពន្ធ

[180] មាត្រា ១២៨ នៃនៃច្បាប់ស្តីពីសារពើពន្ធ និង ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសារពើពន្ធ

- មិនបានដាក់លិខិតប្រកាសសារពើពន្ធដែលគ្មានប្រាក់ពន្ធត្រូវបង់ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយកាលបរិច្ឆេទដែលច្បាប់បានកំណត់ ។
- ជួយជ្រោមជ្រែងដោយចេតនាដល់អំពើទាំងឡាយខាងលើ ។

## កថាខណ្ឌទី ០២ ៖ ទំនួលខុសត្រូវរបស់អ្នកជាប់ពន្ធ

### ក. ការទទួលខុសត្រូវផ្នែករដ្ឋបាល

#### ១. ការកំណត់ពន្ធឡើងវិញ

ការកំណត់ប្រាក់ពន្ធគឺជាការដែល ក្នុងករណីប្រាក់ពន្ធដែលក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតបានធ្វើការបង់ពន្ធតាមរបៀបកាត់ទុកហើយ នីតិបុគ្គលនេះគ្មានកាតព្វកិច្ចធ្វើការប្រកាសសារពើពន្ធទេនោះ ការកំណត់ពន្ធរបស់អ្នកជាប់ពន្ធ គឺជាការកំណត់ចំនួនប្រាក់ពន្ធ ដែលបានកាត់ទុកនៅក្នុងឆ្នាំប្រតិទិន ។ ឬក៏ក្នុងករណីដែលក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត (អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក) មានកាតពេះកិច្ចត្រូវដាក់លិខិតប្រកាសសារពើពន្ធ ការកំណត់ពន្ធរបស់អ្នកជាប់ពន្ធ ឬ ភ្នាក់ងារកាត់ទុក គឺជាការកំណត់ពន្ធដែល អ្នកជាប់ពន្ធ ឬ ភ្នាក់ងារកាត់ទុកបានគណនានៅលើលិខិតប្រកាសសារពើពន្ធ ដែលដាក់ ជូនរដ្ឋបាលសារពើពន្ធ ។ ប៉ុន្តែចំពោះការកំណត់ពន្ធនេះដែលកាលបើរដ្ឋបាលសារពើពន្ធ រកឃើញនូវមូលដ្ឋានបញ្ជាក់ថា ការប្រមូលពន្ធអាចមានឧបសគ្គ រដ្ឋបាល-សារពើពន្ធអាចធ្វើ ការកំណត់ពន្ធលើអ្នកជាប់ពន្ធពេលណាក៏បាន ។[181] ហេតុនេះហើយប្រសិនបើការកំណត់ពន្ធ របស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត បានផ្តល់នូវភាពសង្ស័យដល់ខាងរដ្ឋបាលសារពើពន្ធនោះ នីតិបុគ្គលនេះអាចនឹងត្រូវប្រឈមនឹងការកំណត់ពន្ធឡើងវិញជាថ្មីម្តងទៀតពីសំណាក់រដ្ឋបាលសារពើពន្ធ ។

ផ្អែកតាមប្រកាសលេខ ០៧៣ ប្រក.សហវ.ពដ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការកំណត់ពន្ធ ការកំណត់ពន្ធឡើងវិញ និងការប្រមូលពន្ធរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងច្បាប់ស្តីពីពន្ធដារ ការកំណត់ពន្ធឡើងវិញត្រូវបានចែកចេញជាពីរប្រភេទ ៖

- **ការកំណត់ពន្ធជាឯកតោភាគី**

181 មាត្រា ១១៦ នៃនៃច្បាប់ស្តីពីសារពើពន្ធ និង ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសារពើពន្ធ

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតនឹងត្រូវប្រឈមមុខក្នុងការកំណត់ពន្ធ ជាឯកតោភាគី ដោយខាងរដ្ឋបាលសារពើពន្ធប្រសិនបើមានការប្រទះឃើញថា ក្នុងដំណើរការប្រព្រឹត្តទៅនៃនីតិបុគ្គលនេះមានបង្ហាញអោយឃើញនូវសកម្មភាពដូច[182]ជា ៖

- ✓ មិនបាដាក់លិខិតប្រកាសសារពើពន្ធតាមការតម្រូវនៃច្បាប់
- ✓ មិនបានធ្វើការចុះបញ្ជី
- ✓ មិនបានកាន់កាប់កត់ត្រារក្សារទុកបានត្រឹមត្រូវនូវបញ្ជីគណនេយ្យ ឬឯកសារផ្សេងៗ តាមការតម្រូវ
- ✓ មិនបានផ្តល់ពតិមានចាំបាច់ជូនរដ្ឋបាលសារពើពន្ធដើម្បីកំណត់ពន្ធឲ្យបានត្រឹមត្រូវ ក្នុងរយៈពេល៣០ថ្ងៃក្រោយកាលបរិច្ឆេទប្រគលលិខិតរបស់រដ្ឋបាលសារពើពន្ធស្នើសុំ ឲ្យនីតិបុគ្គលនេះឆ្លើយតប ឬ ផ្តល់លិខិតយុត្តិការបញ្ជាក់លើចំណុចណាមួយនៃលិខិតប្រកាសសារពើពន្ធ ។
- ✓ បានប្រព្រឹត្តអំពើណាមួយផ្សេងទៀត ដែលត្រូវបានចាត់ទុកថាជាការរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីសារពើពន្ធ ។

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត អាចត្រូវបានកំណត់ពន្ធជាឯកតោភាគី ដោយខាងរដ្ឋបាលសារពើពន្ធក្នុងរយៈពេល ១០ឆ្នាំ ក្រោយកាលបរិច្ឆេទដែលតម្រូវឲ្យលិខិត ប្រកាសសារពើពន្ធ ប្រសិនបើមានភស្តុតាងបញ្ជាក់ថាមានអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីសារពើពន្ធ ។ ក្នុងករណីនីតិបុគ្គលនេះ មិនបានបំពេញកាតព្វកិច្ចតាមការតម្រូវ នៃច្បាប់ដែលជាហេតុបណ្តាលឲ្យមានការកំណត់ពន្ធជាឯកតោភាគី ការមិនបានបំពេញកាតព្វនេះត្រូវបានចាត់ទុកថាមានលក្ខណៈធ្ងន់ធ្ងរធ្វើឲ្យការប្រមូលពន្ធអាចជួបឧបសគ្គ ។ ក្នុងករណីនេះ ប្រាក់ពន្ធត្រូវដល់កំណត់ និង ត្រូវបង់ក្នុងរយៈពេល ៣ថ្ងៃ ក្រោយកាលបិច្ឆេទ ប្រគល់លិខិតជូនដំណឹងទារបំនុលពន្ធ ។

➢ **ការកំណត់ពន្ធឡើងវិញ**

ការកំណត់ពន្ធឡើងវិញ អាចត្រូវធ្វើឡើងទៅលើក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតបាននៅក្នុងពេលដែលនីតិបុគ្គលនេះបានធ្វើឲ្យរដ្ឋបាលសារពើពន្ធយល់ថាពតិមាន សម្រាប់កំណត់ឲ្យបានត្រឹមត្រូវនូវប្រាក់ពន្ធ ដូចដែលមានចែងក្នុងបទប្បញ្ញត្តិស្តីពីសារពើពន្ធ មានលក្ខណៈមិនគ្រប់គ្រាន់

[182] មាត្រា ១១៦ នៃនៃច្បាប់ស្តីពីសារពើពន្ធ និង ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសារពើពន្ធ

មិនត្រឹមត្រូវ ឬ មានការភ្លាំងភ្លាត់ ដែលនាំឲ្យប្រាក់ពន្ធបានបង់មានចំនួនតិចជាងប្រាក់ពន្ធដែលបានកំណត់ ដោយបទប្បញ្ញត្តិស្តីពីសារពើពន្ធ ។

នៅពេលក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដឹងថាលិខិតប្រកាសពន្ធរបស់ខ្លួនមានបញ្ហា នីតិបុគ្គលនេះអាចធ្វើការស្នើសធ្វើការស្នើសុំកែតម្រូវ លិខិតប្រកាសសារពើពន្ធក្នុងរយៈពេល ៣ឆ្នាំ ក្រោយកាលបរិច្ឆេទៃការដាក់លិខិតប្រកាសសារពើពន្ធ ដោយផ្អែកលើមូលដ្ឋាននៃការភ័ន្តច្រឡំ ឬការភ្លាំងភ្លាត់ដែលនីតិបុគ្គលនេះបានធ្វើនៅក្នុងលិខិតប្រកាសពីមុន ។ ប្រសិនបើលទ្ធផលប្រកាសសារពើពន្ធកែតម្រូវនោះបណ្តាលឲ្យមានការបង្វិលសង ប្រាក់ពន្ធ ឬ ឥនទានពន្ធ រដ្ឋបាលសារពើពន្ធអាចធ្វើការពិនិត្យបញ្ជាក់តាមនីតិវិធីត្រួតពិនិត្យ សារពើពន្ធ ។[183]

ប៉ុន្តែប្រសិនបើនៅក្នុងការណីដែលរដ្ឋបាលសារពើពន្ធជាអ្នករកឃើញនូវកំហុស លើលិខិតប្រកាសពន្ធ រដ្ឋបាលសារពើពន្ធអាចធ្វើការកំណត់ពន្ធឡើងវិញក្នុងរយៈពេល ដូចខាងក្រោម ៖[184]

- ✓ រដ្ឋបាលសារពើពន្ធអាចធ្វើការកំណត់ពន្ធឡើងវិញក្នុងរយៈពេល ៣ឆ្នាំ បន្ទាប់ពីឆ្នាំប្រតិទិនដែលការកាត់ទុកបនាកើតឡើង ។
- ✓ ក្នុងរយៈពេល ៣ឆ្នាំក្រោយថ្ងៃដាក់លិខិតប្រកាសសារពើពន្ធ
- ✓ ក្នុងរយៈពេល ១០ឆ្នាំ ក្រោយកាលបរិច្ឆេទដែលតម្រូវឲ្យដាក់លិខិតប្រកាស សារពើពន្ធប្រសិនបើមានភស្តុតាងបញ្ជាក់ថាមានអំពើរាំងស្ទះដល់ការអនុវត្ត បទប្បញ្ញត្តិស្តីពីពន្ធដារ ។
- ✓ ក្នុងរយៈពេលណាមួយក៏បានតាមយល់ព្រមជាលាយល័ក្ខអក្សររបស់អ្នកជាប់ពន្ធ ។

**២. ពន្ធបន្ថែម**

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់ពន្ធបន្ថែម ចំពោះបទល្មើសបទបញ្ញត្តិស្តីពីពន្ធដារ ។ ពន្ធបន្ថែមត្រូវយកសម្រាប់ការបង់ពន្ធខ្វះ ឬ ការបង់យឺតត្រូវគណនាដាច់ដោយឡែកពីពន្ធបន្ថែម សម្រាប់ការរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ។[185] ក្នុងករណីមានការបងពន្ធខ្វះ ពន្ធបន្ថែម និងការប្រាក់ត្រូវដល់កំណត់ និងត្រូវបង់ តាមបែបបទដូច

[183] មាត្រា ១១៧ កថាខ័ណ្ឌ ៣ នៃនៃច្បាប់ស្តីពីសារពើពន្ធ និង ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសារពើពន្ធ

[184] មាត្រា ១១៧ កថាខ័ណ្ឌ ៣ នៃនៃច្បាប់ស្តីពីសារពើពន្ធ និង ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសារពើពន្ធ

[185] មាត្រា ១៣០ នៃនៃច្បាប់ស្តីពីសារពើពន្ធ និង ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសារពើពន្ធ

ប្រាក់ពន្ធដែលបានបងខ្វះនោះ ។ ទោះជាក្នុងករណីណាក៏ដោយ ការអនុវត្តពន្ធបន្ថែមរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មិនមានផលប៉ះពាល់ដល់ការអនុវត្តន៍ទោសទណ្ឌចំពោះបទល្មើសផ្នែក ព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារឡើយ ។

**២.១. ពន្ធបន្ថែមចំពោះការបង់ពន្ធខ្វះ**

- <u>ករណីធ្វេសប្រហែស</u> ៖ ចំពោះការធ្វេសប្រហែស ប្រាក់ពន្ធបន្ថែមត្រូវស្មើនឹង ១០% នៃប្រាក់ពន្ធដែលបង់ខ្វះបូកបន្ថែមការប្រាក់ ២% នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួនប្រាក់ពន្ធខ្វះមិនទាន់បានបង់ ។
- <u>ករណីធ្វេសប្រហែសធ្ងន់ធ្ងរ</u> ៖ ប្រាក់ពន្ធបន្ថែមត្រូវស្មើនឹង ២៥% នៃចំនួនប្រាក់ពន្ធដែល បង់ខ្វះបូកបន្ថែមការប្រាក់ ២% នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬ ចំណែកនៃខែដែលចំនួនប្រាក់ពន្ធខ្វះមិនទាន់បានបង់ ។
- <u>ករណីកំណត់ពន្ធជាឯកតោភាគី</u> ៖ ប្រាក់ពន្ធបន្ថែមត្រូវស្មើ ៤០%នៃចំនួនប្រាក់ពន្ធដែល បង់ខ្វះបូកបន្ថែមការប្រាក់ ២% នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬ ចំណែកនៃខែដែលចំនួនប្រាក់ពន្ធខ្វះមិនទាន់បានបង់ ។

ការប្រាក់មិនត្រូវបានអនុវត្តទេ ក្នុងរយៈពេលកំណត់ពន្ធឡើងវិញតាមមាត្រា១១៨ នៃច្បាប់ស្តីពីសារពើពន្ធ ឬក្នុង ៣០ថ្ងៃក្រោយប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធ ។[186]

**២.២. ពន្ធបន្ថែមចំពោះការយឺតយ៉ាវក្នុងការបង់ពន្ធ**

- <u>ករណីមិនបានបង់ពន្ធតាមកាលកំណត់</u> ៖ នៅពេលនីតិបុគ្គលនេះមិនបានបង់ពន្ធតាមកាលកំណត់ពន្ធបន្ថែមត្រូវកំណត់តាមអត្រាពន្ធ ១០% នៃទឹកប្រាក់ពន្ធបង់យឺត បូកនឹង ការប្រាក់ ២%នៃទឹកប្រាក់ពន្ធបង់យឺតសម្រាប់ខែនីមួយៗ ឬ ចំណែកនៃខែដែលចំនួនប្រាក់ពន្ធនោះនៅមិនទាន់បានបង់ ។ ពន្ធបន្ថែមចំពោះការយឺតយ៉ាវក្នុងការបង់ពន្ធលើមធ្យោបាយដឹក ជញ្ជូនត្រូវស្មើនឹង ១០០%នៃប្រាក់ពន្ធត្រូវបង់ ។
- <u>ករណីមិនបានបង់ពន្ធក្នុងរយៈពេល ១៥ថ្ងៃក្រោយបានទទួលលិខិតរំលឹកទារបំណុលពន្ធ</u> ៖ ត្រូវអនុវត្តប្រាក់ពន្ធបន្ថែម ២៥%នៃទឹកប្រាក់ពន្ធបង់យឺត បូកនឹងការប្រាក់២% នៃទឹកប្រាក់ពន្ធបង់យឺតសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួនប្រាក់ពន្ធនោះនៅមិនទាន់បានបង់ ។

[186] មាត្រា ១៣១ នៃនៃច្បាប់ស្តីពីសារពើពន្ធ និង ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសារពើពន្ធ

➢ <u>ករណីកំណត់ពន្ធជាឯកតោភាគីសម្រាប់ការមិនដាក់លិខិតប្រកាស</u> ៖ ត្រូវអនុវត្តពន្ធបន្ថែមត្រូវស្មើ៤០%នៃចំនួនប្រាក់ពន្ធដែលបានកំណត់ បូកបន្ថែមការប្រាក់ ២% នៃចំនួនប្រាក់ពន្ធដែលបានកំណត់សម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធមិនទាន់ បានបង់ ។

ការប្រាក់យឺតយ៉ាវត្រូវគិតចាប់ពីថ្ងៃទី ០១ នៃខែបន្ទាប់ពីខែដែលបង់ពន្ធ ។ ចំពោះពន្ធ លើប្រាក់-ចំណូល ការប្រាក់យឺតយ៉ាវត្រូវគិតចាប់ពីថ្ងៃទី០១ នៃខែបន្ទាប់ដែលជាខែផុតរយៈ ពេលកំណត់សម្រាប់ការដាក់លិខិតប្រកាសលទ្ធផលប្រចាំឆ្នាំ ។[187]

### ២.៣. ពន្ធបន្ថែមចំពោះការប្រព្រឹត្តអំពើរាំងស្ទះការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារ

នៅពេលដែលក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត បានប្រព្រឹត្តនូវអំពើរាំងស្ទះ នីតិបុគ្គលនេះ ត្រូវបង់នូវប្រាក់ពន្ធបន្ថែមចំពោះការប្រព្រឹត្តនូវអំពើរាំងស្ទះ ។ ចំពោះការប្រព្រឹត្ត អំពើរាំងស្ទះការអនុវត្តន៍ប្បញ្ញត្តិស្តីពីពន្ធដារ ពន្ធបន្ថែមត្រូវកំណត់ដូចខាងក្រោម ៖

- ២.០០០.០០០ រៀល ចំពោះបុគ្គលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកក្រោមរបបពិត
- ៥០០.០០០រៀល ចំពោះអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកក្រោមរបបបំព្រួញ ឬរបបមៅការ។

### ៣. បន្ទុកភស្តុតាង

នៅក្នុងពេលដែលក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មិនបានរក្សាទុកឯកសារគ្រប់គ្រាន់ ឬក៏មិនបានផ្តល់ពត៌មានគ្រប់គ្រាន់ រដ្ឋបាលសារពើពន្ធមានសិទ្ធិកំណត់ពន្ធលើអ្នកជាប់ពន្ធដោយផ្អែកលើមូលដ្ឋាននៃពត៌មានជាក់លាក់ ដែលរដ្ឋបាលសារពើពន្ធមាន ។ បន្ទុកភស្តុតាង ដើម្បីបញ្ជាក់ថាប្រាក់ពន្ធដែលរដ្ឋបាលសារពើពន្ធកំណត់មិនត្រឹមត្រូវ គឺស្ថិតនៅលើ អ្នកជាប់ពន្ធ ។

នៅពេលណាដែលប្រាក់ចំណូលជាប់ពន្ធ ឬ ប្រាក់ចំណូលដែលនីតិបុគ្គលនេះបានប្រកាសមានភាពខុសគ្នាច្រើនធៀបទៅនឹងការទិញទ្រព្យសកម្ម ឬ វត្ថុនានាដែលធ្វើឲ្យឃើញចំណាយរបស់អ្នកជប៉ាពន្ធលេចធ្លោឡើងនោះ រដ្ឋបាលសារពើពន្ធមានសិទ្ធិកំណត់ពន្ធដោយ ផ្អែកលើមូលដ្ឋាននៃប្រាក់ចំណូលប៉ាន់ស្មានសមស្របទៅនឹងទំហំនៃសំណាយដើម្បីទិញទ្រព្យសកម្ម ឬ វត្ថុនានាដែលលេចធ្លោនោះ ។ បន្ទុកភស្តុតាងដើម្បីបញ្ជាក់ថាប្រាក់ពន្ធដែលរដ្ឋបាល សារពើពន្ធកំណត់មិនត្រឹមត្រូវគឺស្ថិតនៅលើអ្នកជាប់ពន្ធ ។[188] ឬនៅក្នុងករណីដែលរដ្ឋបាលសារពើពន្ធបដិសេធចំណាយ ឬការកាត់-កងណាមួយដែលក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតបានអនុវត្ត នីតិមុគ្គលនេះគឺជាអ្នកទទួលខុសត្រូវក្នុងការផ្តល់ភស្តុតាងបញ្ជាក់ថាការ បដិសេធចំណាយនោះមិនត្រឹមត្រូវ ។

[187] មាត្រា ១៣២ នៃនៃច្បាប់ស្តីពីសារពើពន្ធ និង ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសារពើពន្ធ

[188] មាត្រា ១១៩ នៃនៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

នៅក្នុងករណីដែលការកំណត់ពន្ធជាឯកតោភាគី ឬ ការកំណត់ពន្ធឡើងវិញមានជាប់ទាក់ទងនឹងចំណូលដែលផ្អែកទៅលើពត៌មានជាកលាក់ ដែលរដ្ឋបាលសារពើពន្ធត្រូវបញ្ជាក់ឲ្យបានច្បាស់-លាស់នូវពត៌មានដែលតម្រូវឲ្យបានយកមកប្រើប្រាស់ ដើម្បីកំណត់ឡើងវិញនូវចំណូលនោះ ។ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត គឺជាអ្នកទទួលខុសត្រូវក្នុងការផ្តល់ ភស្តុតាងបញ្ជាក់ថា ការកណាត់ពន្ធជាឯកតោភាគី ឬការកំណត់ពន្ធឡើងវិញនេះមិនត្រឹមត្រូវ ។

**ខ. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនៃបទប្បញ្ញត្តិពន្ធដារ**

នៅពេលមានការប្រព្រឹត្តនូវកំហុស ឬ បទល្មើស បើទោះបីជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតបានទទួលខុត្រូវផ្នែករដ្ឋបាលហើយក៏ពិតមែន ក៏នីតិបុគ្គលនេះនៅតែមានកាតព្វកិច្ចក្នុងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដ៏ដែល ។ ការប្តឹងចោទប្រកាន់ និងទាមទារការដាក់ទោសចំពោះបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ត្រូវធ្វើឡើងដោយអគ្គនាយកនៃនាយកដ្ឋានពន្ធដារដោយមានការយល់ព្រមពីមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។[189] ទោសទណ្ឌផ្នែកព្រហ្មទណ្ឌនៃបទប្បញ្ញត្តិពន្ធដារ ដែលក្នុងហ៊ុនឯកជនទទួលខុសត្រូវ មានកម្រិតអាចនឹងត្រូវទទួលមានដូចជា ៖

**១. ការគេចវេសពន្ធ**

ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀត អភិបាល បណ្ណាធិការ កម្មសិទ្ធិករ របស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដែលបានប្រព្រឹត្តិអំពើគេចវេសពន្ធដូចមានរៀបរាប់ ខាងលើត្រូវរងការផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០រៀល ដល់ ២០.០០០.០០០ រៀល ឬជាប់ពន្ធនាគារពី១ឆ្នាំ ដល់៥ឆ្នាំ ឬទោសទាំងពីរនេះ ។[190]

**២. អំពើរាំងស្ទះដល់ការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារ**

ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀត របស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវ-មានកម្រិតដែលបានប្រព្រឹត្តិអំពើរាំងស្ទះដល់ការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារ ដូចបាន រៀបរាប់ខាងលើត្រូវរងការផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០រៀល ដល់ ១០.០០០.០០០ រៀល ឬជាប់ពន្ធនាគារពី១ខែ ដល់១ឆ្នាំ ឬទោសទាំងពីរនេះ ។[191]

**៣. អំពើជ្រោមជ្រែង នឹងអូសទាញ**

[189] មាត្រា ១៣៤ នៃនៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

[190] មាត្រា ១៣៥ នៃនៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

[191] មាត្រា ១៣៦ នៃនៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

ប្រសិនបើមានចេតនាជួយជ្រោមជ្រែង ឬ អូសទាញបុគ្គលម្នាក់ទៀតឲ្យប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌដូចបានរៀបរាប់ ឬ ក៏ដោយចេតនាបានផ្តល់គំនិត ឬ ជំរុញបុគ្គលម្នាក់ទៀតឲ្យប្រព្រឹត្តិបទល្មើសបែបនេះត្រូវជាប់ពិរុទ្ធ ហើយត្រូវទទួលរងការផ្តន្ទាទោស ដូចគ្នានឹង ការប្រព្រឹត្តិបទល្មើសផ្ទាល់ខ្លួនផងដែរ ។[192]

## ផ្នែកទី ០២ ៖ សិទ្ធិប្តឹងតវ៉ាទៅនឹងនីតិវិធីរបស់រដ្ឋបាលសារពើពន្ធ

### កថាខណ្ឌទី ០១៖ នីតិវិធីបណ្តឹងតវ៉ាទៅរដ្ឋបាលសារពើពន្ធ

#### ក. នីតិវិធីដាក់ពាក្យបណ្តឹងតវ៉ា

នៅពេលដែលក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មានការមិនពេញចិត្តនឹងការកំណត់ពន្ធការកំណត់ពន្ធឡើងវិញ ការទារបំណុលពន្ធ សេចក្តីសម្រេច ឬវិធានការផ្សេងៗ របស់អគ្គនាយកដ្ឋានពន្ធដារ នីតិបុគ្គលនេះមានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ា ទៅកាន់អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធ ដារក្នុងរយៈពេល ៣០ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទនៃការទទួល បានលិខិតជូនដំណឹងស្តីពីសេចក្តីសម្រេច ឬវិធានការផ្សេងៗរបស់អគ្គនាយកដ្ឋានពន្ធដារ។[193]

សិទ្ធិតវ៉ានេះត្រូវកម្រិតព្រំដែនត្រឹមដើមហេតុឬព័ត៌មានផ្សេងទៀតដែលមាននៅក្នុងការកំណត់ពន្ធការកំណត់ពន្ធឡើងវិញសេចក្តីសម្រេចឬវិធានការផ្សេងឬនីតិវិធីប្រមូលពន្ធរបស់រដ្ឋបាលពន្ធដារប៉ុណ្ណោះ។ អ្នកតវ៉ាមិនអាចដាក់ពាក្យបណ្តឹងតវ៉ាជាសមូហភាពបានទេ លើកលែងតែអ្នកតវ៉ានោះត្រូវបានកំណត់ពន្ធជារួម។ បន្ថែមពីនេះក្នុងករណីដែលអ្នកតវ៉ាបានដាក់ពាក្យបណ្តឹងតវ៉ាហួសរយៈពេលកំណត់ដូចមានសរសេរក្នុងអត្ថបទខាងលើអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អាចចេញសេចក្តីបដិសេធពាក្យបណ្តឹងតវ៉ា ដោយត្រូវបញ្ជាក់ហេតុផលឲ្យបានច្បាស់លាស់។[194]

ការតវ៉ាចខាងរដ្ឋបាលពុំធ្វើឲ្យអ្នកជាប់ពន្ធរួចផុតពីកាតព្វកិច្ចបង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗដែលបញ្ជាក់នៅក្នុងលិខិតជូនដំណឹងទារបំណុលពន្ធឡើយ ។[195]

---

[192] មាត្រា ១៣៧ នៃនៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

[193] ប្រការ ៥ នៃប្រកាសស្តីពី វិធាន និងនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ាពន្ធដារ នៅអគ្គនាយកដ្ឋានពនធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី ០៦ ខែវិច្ឆិការ ឆ្នាំ២០១៥

[194] ប្រការ ៥ នៃប្រកាសស្តីពី វិធាន និងនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ាពន្ធដារ នៅអគ្គនាយកដ្ឋានពនធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី ០៦ ខែវិច្ឆិការ ឆ្នាំ២០១៥

[195] មាត្រា ១២០ កថាខណ្ឌ ៣ នៃនៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

## ខ. ខ្លឹមសារនៃបណ្តឹង និង បន្ទុកភស្តុតាង

### ១. ខ្លឹមសារនៃបណ្តឹង

ពាក្យបណ្តឹងតវ៉ាត្រូវចុះហត្ថលេខាដោយផ្ទាល់ពីរនាក់តវ៉ា ឬអ្នកតំណាងស្របច្បាប់។ អ្នកតវ៉ាអាចចាត់តាំងតំណាងស្របច្បាប់ ដែលមានសិទ្ធិសម្រេចចូលរួមក្នុងនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ាជំនួសដោយមានភ្ជាប់មកជាមួយពាក្យបណ្តឹងតវ៉ា និងលិខិតផ្ទេរសិទ្ធ ដែលមានចុះហត្ថលេខារបស់សាម៉ីអ្នកតវ៉ា។

ពាក្យបណ្តឹងតវ៉ាត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយត្រូវមានខ្លឹមសា និង ព័ត៌មានដូចខាងក្រោមៈ[196]

- កាលបរិច្ឆេទនៃបណ្តឹងតវ៉ា
- អត្តសញ្ញាណរបស់អ្នកជាប់ពាក់ព័ន្ធជាអាទ៍VAT TIN និង/ឬ PIN ប្រសិនបើមាន
- អាស័យដ្ឋានលេខទូរស័ព្ទនិងឬសារអេឡិចត្រូនិចរបស់អ្នកតវ៉ាឬតំណាងស្របច្បាប់របស់អ្នកតវ៉ា
- កាយោងលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធការកំណត់ពន្ធឡើងវិញការ ប្រមូលពន្ធសេចក្តីសម្រេចផ្សេងទៀតពាក់ព័ន្ធវិធានការពន្ធដារដែលជាកម្មវត្ថុនៃ បណ្តឹងតវ៉ា
- អង្គហេតុឬវិធានការដាក់ចេញដោយគដ្ឋានពន្ធដារឬអង្គភាពកំណត់ពន្ធដែលជាកម្មវត្ថុនៃបណ្តឹងតវ៉ា
- សំអាងហេតុនិងមូលដ្ឋានគតិយុត្តនៃបណ្តឹងតវ៉ាដែលសម័យអ្នកតវ៉ាលើកជាសំអាងក្នុងការតវ៉ាទៅនឹងវិធានការពាក់ព័ន្ធពន្ធដារដែលសម្រេចដោយអគ្គនាយកដ្ឋានពន្ធដារឬអង្គភាពកំណត់ពន្ធ
- ព័ត៌មានចាំបាច់ផ្សេងទៀតដែលពាក់ព័ន្ធនឹងបណ្តឹងតវ៉ា។

### ២. បន្ទុកភស្តុតាងសម្រាប់បណ្តឹងតវ៉ា

នៅពេលធ្វើការដាក់ពាក្យបណ្តឹងតវ៉ា ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវភ្ជាប់មកនូវឯកសារដែលជាភស្តុតាងមកជាមួយនឹងពាក្យបណ្តឹងនៅពេលមកដាក់ពាក្យបណ្តឹង ។

[196] ប្រការ ៦ នៃប្រកាសស្តីពី វិធាន និងនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ាពន្ធដារ នៅអគ្គនាយកដ្ឋានពនធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី ០៦ ខែវិច្ឆិការ ឆ្នាំ២០១៥

ពាក្យបណ្តឹងតវ៉ាត្រូវភ្ជាប់មកជាមួយនូវភស្តុតាងជាអាទិ៍ដូចខាងក្រោម៖

- ✓ លិខិតជូនដំណឹងស្តីពីការកំណត់ពន្ធ ការកំណត់ពន្ធឡើងវិញ ការទារបំណុលពន្ធ ឬសេចក្តីសម្រេចផ្សេងទៀតពាក់ព័ន្ធវិធានការពន្ធដារ ដែលជាកម្មវត្ថុនៃបណ្តឹង-តវ៉ា
- ✓ ឯកសារដែលបញ្ជាក់ពីការទូទាត់ប្រាក់ពន្ធ ជាអាទិ៍ប្រកាសឥណទានធនាគារ ឬ បង្កាន់ដៃ ឬលិខិតបញ្ជាក់ការបង់ពន្ធ ក្នុងករណីដែលបានបង់ពន្ធរួច
- ✓ ភស្តុតាងផ្សេងទៀតពាក់ព័ន្ធអង្គហេតុ ឬសំអាងហេតុនៃបណ្តឹងតវ៉ារបស់អ្នកតវ៉ា ជាអាទិ៍ ទិនានុប្បវត្តិ វិក័យបត្រ កិច្ចសន្យា លិខិតយុត្តិការ ឬឯកសារផ្សេងៗ ។

ក្នុងករណីលក្ខខណ្ឌនៃការដាក់ពាក្យបណ្តឹងតវ៉ា ដូចមានកំណត់ខាងលើនៅពេលដែល អ្នកតវ៉ា ឬ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតមិនបានបំពេញគ្រប់គ្រាន់ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារអាចចេញសេចក្តីសម្រេចបដិសេធពាក្យបណ្តឹងតវ៉ាដោយបញ្ជាក់ មូលហេតុដែលបានច្បាស់លាស់។

**គ. នីតិវិធីដោះស្រាយបណ្តឹងតវ៉ា**

ពាក្យបណ្តឹងតវ៉ារបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវដំណើរការទៅតាមនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ាដែលមានដំណាក់កាលដូចខាងក្រោម៖[197]

- ចុះបញ្ជីនិងគ្រប់គ្រងបណ្តឹងតវ៉ា
- របាយការណ៍បំភ្លឺដែលធ្វើឡើងដោយអង្គភាពកំណត់ពន្ធឬអង្គភាពប្រមូលពន្ធ
- អង្កេតដើមហេតុនៃបណ្តឹងតវ៉ា
- សេចក្តីសំរេចលើបន្តឹងតវ៉ា
- ជូនដំណឹងអំពីសេចក្តីសម្រេចដោះស្រាយបណ្តឹងតវ៉ា។

ក្រុមហ៊ុនឯកជនទទួលខុសត្រូមមានកម្រិតនឹងទទួលបានលិខិតជូនដំណឹងស្តីពីសេចក្តីសម្រេចដោះស្រាយបណ្តឹងតវ៉ា ។ សេចក្តីសម្រេចដោះស្រាយបណ្តឹងតវ៉ានឹងចេញនូវដោយ អគ្គនាយកនៃអគ្គនាយកដ្ឋានពនញធដារក្នុងរយៈ ពេល៦០ថ្ងៃ[198] នៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទទទួលពាក្យ

[197] ប្រការ ៩ នៃប្រកាសស្តីពី វិធាន និងនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ាពន្ធដារ នៅអគ្គនាយកដ្ឋានពនធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី ០៦ ខែវិច្ឆិការ ឆ្នាំ២០១៥

[198] ប្រការ ១៣ នៃប្រកាសស្តីពី វិធាន និងនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ាពន្ធដារ នៅអគ្គនាយកដ្ឋានពនធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី ០៦ ខែវិច្ឆិការ ឆ្នាំ២០១៥

បណ្តឹងតវ៉ា ។ នៅក្នុងសេចក្តីសម្រេចដោះស្រាយបណ្តឹងតវ៉ា ត្រូវមានបញ្ជាក់អំពីអង្គហេតុ អង្គច្បាប់ និងសំអាងហេតុដែលជាមូលដ្ឋាននៃសេចក្តីសម្រេចច្បាស់លាស់ ។

ប្រសិនបើក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មិនពេញចិត្តនឹងសេចក្តីសម្រេចដោះ-ស្រាយ ឬសេចក្តីសម្រេចបដិសេធបណ្តឹងតវ៉ា របស់អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារអាចដាក់ពាក្យតវ៉ាទៅគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ ក្នុងរយៈពេល ៣០ថ្ងៃ នៃថ្ងៃ ធ្វើការគិតចាប់ពីកាលបរិច្ឆេទ នៃការទទួលបានលិខិតជូនដំណឹងស្តីពីសេចក្តីសម្រេច ដោះស្រាយបណ្តឹងតវ៉ា ឬសេចក្តីសម្រេចបដិសេធរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយចម្លងជូនអគ្គនាយកដ្ឋានពន្ធដារមួយច្បាប់ ។

ហួសរយៈពេលកំណត់ដូចមានកំណត់នៅខាងលើ នៃប្រការនេះសេចក្តីសម្រេចដោះស្រាយបណ្តឹងតវ៉ា ឬ សេចក្តីសម្រេចបដិសេធរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ត្រូវមានអានុភាពអនុវត្តដោយពុំអាចធ្វើជាកម្មវត្ថុនៃការដាក់ពាក្យបណ្តឹងតវ៉ា ទៅគណៈកម្មាធិការដោះស្រាយវិវាទសារ-ពើពន្ធឡើយ។

ការទទួលដោះស្រាយបណ្តឹងវិវាទដោយគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធត្រូវមានអានុភាពអនុវត្តសេចក្តីសម្រេចដោះស្រាយបណ្តឹងរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ។[199]

## កថាខណ្ឌទី ០២ ៖ ការដាក់ពាក្យបណ្តឹងទៅតុលាការ

### ក. នីតិវិធីប្តឹងទៅតុលាការ

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតមានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ច ជំទាស់នឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការសម្រុះសម្រួលសារពើពន្ធក្នុងរយៈពេល៣០ថ្ងៃ ក្រោយពីបានទទួលដំណឹងស្តីពីសេចក្តីសម្រេចនោះ ។ មុននឹងដាក់ពាក្យបណ្តឹងទៅតុលាការ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវធ្វើការតម្កល់ទុកនៅរតនាគារជាតិនូវប្រាក់ចំនួនស្មើនឹងប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗដែលទាក់ទិននឹងវិវាទតាមការកំណត់របស់រដ្ឋបាលសារពើពន្ធ ។[200]

### ខ. ខ្លឹមសារនៃបណ្តឹង

---

[199] ប្រការ ១៥ នៃប្រកាសស្តីពី វិធាន និងនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ាពន្ធដារ នៅអគ្គនាយកដ្ឋានពនធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី ០៦ ខែវិច្ឆិការ ឆ្នាំ២០១៥

[200] មាត្រា ១២៤ នៃនៃច្បាប់ស្តីពីសារពើពន្ធ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

- ពាក្រុបណ្តឹងត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ
- នៅក្នុងលិខិតនៃពាក្យបណ្ដឹង ត្រូវសរសេចំណុចបញ្ជាក់ដូចខាងក្រោមនេះ ៖ [201]
    - ឈ្មោះ ឬនាមករណ៍
    - អាស័យដ្ឋានរបស់ភាគី
    - ឈ្មោះនិងអាស័យដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់
    - ខ្លឹមសារនៃសាលក្រមដែលក្រុមហ៊ុនទាមទារឲ្យតុលាការចេញ និង អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ពីការទាមទារ។

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត គប្បីសរសេរបញ្ជាក់ឱ្យច្បាស់លាស់អំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ និងចំណុចដែលត្រូវការបញ្ជាក់ភស្តុតាងគប្បីសរសេរបញ្ជាក់នូវអង្គហេតុសំខាន់ៗក្នុងចំណោមអស់ហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារនិងភស្តុតាង។ ពាក្យបណ្ដឹងដែលមានសរសេរអំពីការតទល់ ឬការការពារខ្លួនត្រូវចាត់ទុកជាឯកសារត្រៀមផងដែរ។

[201] មាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាទៅលើ ការទទួលខុសត្រូវរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតចំពោះពន្ធ និងអាករនៅកម្ពុជា ។ យើងឃើញថាក្រុមហ៊ុនប្រភេទនេះបានរួមចំណែក ធ្វើឲ្យកំណើនថវិការជាតិកើនឡើង ចំណូលសារពើពន្ធ គឺផ្នែកមួយដ៏សំខាន់ក្នុងការគាងគរប្រមូលថវិការចូលឃ្លាំងជាតិ។ ចំណូលសារពើពន្ធ ត្រូវបានរួមបញ្ចូលគ្នា ពីចំណូលពន្ធ និងអាករផ្សេងៗដែលប្រមូលបានពីប្រជាពលរដ្ឋតាមរយៈទំនិញ និងសេវាសារធារណៈ។ ចំណូលសារពើពន្ធ ត្រូវបានប្រមូលពីប្រជាពលរដ្ឋតាមរយៈទំនិញនិងការប្រើប្រាសសេវាសាធារណៈ និងប្រមូលពីនីតិបុគ្គលតាមរយៈការបង់ប្រាក់ពន្ធនិងអាករចំពោះសកម្មភាពសេដ្ឋកិច្ចរបស់ពួកគេ។

ក្នុងនាមជានីតិបុគ្គលស្វែងរកប្រាក់ចំណេញ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតត្រូវមានកាតព្វកិច្ចចុះបញ្ជីនៅរដ្ឋាបាលសារពើពន្ធក្នុងរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬ ក្រោយពីពេលទទួលបានការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ឬ ក្រសួងស្ថាប័ណពាក់ព័ន្ធ។ បន្ទាប់ពីបានសម្រេចក្នុងការចុះបញ្ជី ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតនឹងទទួលបាននូវសិទ្ធិ ផ្សេងៗដែលបានផ្តល់ឥឲ្យដោយច្បាប់ ក៏ដូចជាកាតព្វកិច្ចចំពោះអគ្គនាយកដ្ឋានពន្ធដារក្នុងការបង់ប្រាក់ពន្ធ និងអាករដែលបានកំណត់ដោយច្បាប់។ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតត្រូវមាន កាតព្វកិច្ចដាក់លិខិតប្រកាសបង់ពន្ធ និងអាករជាប្រចាំខែ និងជាប្រចាំឆ្នាំ ។ រៀងរាល់ខែ នីតិបុគ្គលនេះត្រូវដាក់លិខិតប្រកាសបង់ប្រាក់ពន្ធ និងប្រាក់អាករយ៉ាងយូបំផុតត្រឹមថ្ងៃទី ២០ នៅខែបន្ទាប់ចំពោះប្រភេទពន្ធ និងអាករដូចជា ៖ ប្រាក់រំដោះពន្ធលើប្រាក់ចំណូល, ពន្ធលើប្រាក់បៀវត្ស, ពន្ធកាត់ទុក, អាករលើតម្លៃបន្ថែម, អាករពិសេសលើទំនិញ និងសេវាមួយចំនួន, អាករលើការស្នាក់នៅ និង អាករ សម្រាប់បំភ្លឺសាធារណៈ។ បន្ទាប់ពីកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធប្រចាំខែ ជារៀងរាល់ឆ្នាំនីតិបុគ្គលនេះត្រូវធ្វើការដាក់លិខិតប្រកាសបង់ពន្ធ និងអាករយ៉ាងយូបំផុតត្រឹមថ្ងៃទី ៣១ ខែមីនា នៃឆ្នាំសារពើពន្ធ ។ ក្រុហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតត្រូវធ្វើការដាក់លិខិតប្រកាសបង់ពន្ធ និងអាករប្រចាំឆ្នាំចំពោះពន្ធអាករដូចជា ៖ ពន្ធលើប្រាក់ចំណូល, ពន្ធអប្បបរមា, ពន្ធប៉ាតង, ពន្ធលើមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ និង ពន្ធលើតែមប្រើសារពើពន្ធ ។ ស្របគ្នានឹងការទទួលបាននូវកាតព្វកិច្ចជាច្រើន ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតក៏នឹងទទួលបាននូវសិទ្ធិក្នុងនាមជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលមានកំណត់ដោយច្បាប់ជាធរមានដូចជា ៖ ទទួលបានការរក្សាទុកជាការសម្ងាត់នូវរាល់ព័ត៌មាន, ការទទួលបានការពន្យល់ណែនាំ,ទទួលបានការពន្យលរាល់សេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធចំពោះកិច្ចការសារពើពន្ធ, សិទ្ធិក្នុងការប្តឹងតវ៉ាចំពោះរាល់សេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធ, មានការទទួលស្គាល់តំណាងស្របច្បាប់របស់អ្នកជាប់ពន្ធ, ទទួលបានការអនុវត្តដោយមានតម្លាភាព និង មិនលម្អៀងពីសំណាក់រដ្ឋបាល សារពើពន្ធ,

និង ទទួលបានការទទួលស្គាល់អំពីភាពស្មោះត្រង់ក្នុងការអនុវត្តកាតព្វកិច្ចសារពើពន្ធ ។ លើសពីសិទ្ធិដែលទទួលបានដូចដែលមានរៀបរាប់ខាងលើ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ក៏នៅនឹងទទួលបានសិទ្ធិក្នុងការប្តឹងទៅតុលាការមានសមត្ថកិច្ច ជំទាស់នឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការសម្រុះសម្រួលសារពើពន្ធក្នុងរយៈពេល៣០ថ្ងៃ ក្រោយពីបានទទួលដំណឹងស្តីពីសេចក្តីសម្រេចនោះ ។ មុននឹងដាក់ពាក្យបណ្តឹងទៅតុលាការ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវធ្វើការតម្កល់ទុកនៅរតនាគារជាតិនូវប្រាក់ចំនួនស្មើនឹងប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗដែលទាក់ទិននឹងវិវាទតាមការកំណត់របស់រដ្ឋបាលសារពើពន្ធ ។

បន្ទាប់ពីបានធ្វើការបងស្រាយអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតក្រុមយើងខ្ញុំបានយល់ឃើញថា ការសិក្សាទៅលើប្រធានបទខាងលើដែលស្តី **"អំពីការទទួលខុសត្រូវរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតចំពោះពន្ធ និងអាករនៅកម្ពុជា"** ពិជាមានសារៈប្រយោជន៍ណាស់ក្នុងជួយផ្តល់ពុទ្ធិដល់សិស្សនិស្សិតក្នុងការយក់ទៅសិក្សារ ដ៏ដូចជានីតិបុគ្គលស្វែងរកប្រាក់ចំណេញ ក្នុងនាមជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ឬចំពោះអ្នកដែលមានបំណងធ្វើការបើកអាជីវកម្មក្នុងទ្រង់ទ្រាយក្រុមហ៊ុននេះ យក់ទៅស្វែងយល់ អំពីសិទ្ធិ និងកាតឬកិច្ចរបស់ខ្លួនព្រមទាំងការទទួលខុសត្រូវរបស់ពួកគេតាមរយៈសៀវភៅមួយនេះ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីយើងខ្ញុំទាំងពីរបានធ្វើការសិក្សាស្រាវជ្រាវ យ៉ាងស្វះស្វែងក្នុងរយះប៉ុន្មានខែនេះស្តីការទទួលខុសត្រូវរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតចំពោះពន្ធ និងអាករនៅកម្ពុជាយើងសង្កេតឃើញថាសិទ្ធិ និងកាតព្វកិច្ចដែលបទបញ្ញាត្តិសារពើពន្ធមានជាធរមានគឺគ្រប់គ្រាន់ក្នុងការគ្រប់គ្រង់ និងការប្រមូលចំណូលអាករយ៉ាងមានប្រសិទ្ធិរួចទៅហើយបូករួមការវិវិត្តការផ្លាស់ប្តូរ ការកែទម្រង់យ៉ាងច្រើនទៅលើប្រព័ន្ធគោលនយោបាយសារពើពន្ធ ប្រព័ន្ធគ្រប់គ្រង់នៃអ្នកជាប់ពន្ធទូទាំងប្រទេសការផ្តល់សេវាជូនចំពោះអ្នកជាប់ពន្ធតាម របបស្វ័យប្រកាសកាន់តែប្រសើរឡើង ភាពងាយស្រួល និងទំនើបជឿនលឿនដល់អ្នកជាប់ពន្ធទៀតនោះញ៉ាំងអោយប្រសិទ្ធិភាពនៃការ ប្រមូលប្រាក់ពន្ធការបង់ប្រាក់បង់និងការដាក់លិខិតប្រកាសកាន់តែមានភាពងាយស្រួល។ ជាពិសេស ទៅទៀតនោះគឺការដាក់ចេញ នូវលិខិតបទដ្ឋានគតិយុត្តជាបន្តបន្ទាប់ដើម្បីសម្រួលដល់ការអនុវត្តនា ពេលបច្ចុប្បន្នអោយស្របទៅនឹងស្ថានការណ៍នៃប្រទេសជាតិជាក់ស្តែង។

ថ្វីបើអ្វីដែលអគ្គនាយកដ្ឋានមាននិងកំពុងអនុវត្តដូចរៀបរាប់ខាងលើក៏ដោយ ក៏យើងសង្កេតឃើញថាការអនុវត្តជាក់ស្តែងរបស់រដ្ឋបាលសារពើពន្ធគ្រប់ជាន់ថ្នាក់នៅទូទាំងប្រទេសនៅមាន កម្រិតនៅឡើងតួយ៉ាងគឺផ្នែកការអនុវត្តច្បាប់សារពើពន្ធនិងផ្នែកបច្ចេកទេសតែម្តង។ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញអោយមាននូវការចុះបញ្ជីតាមប្រព័ន្ធអេឡិតត្រូនិច(E-Registration) ដែលប្រកាសដាក់អោយអនុវត្តតាមរយះប្រកាស៨៩៦សហវស្តីពីការចុះបញ្ជីពន្ធដារ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦ ប៉ុន្តែរហូតមកទល់ពេលនេះការចុះបញ្ជីតាមរយះប្រព័ន្ធអេឡិចត្រូនិចនៅពុំទាន់ដាក់អោយ ដំណើរការត្រឹមត្រូវនៅឡើយដោយហេតុកត្តាបច្ចេកទេសឬកត្តាផ្សេងៗ។

ដោយបានពិភាក្សានិងសិក្សាស្វែងយល់បន្ថែមពីយើងខ្ញុំទាំងពីរពួកយើងខ្ញុំមាន នូវអនុសាសន៍មួយចំនួន ដើម្បីជាការរួមចំណែកក្នុងការផ្តល់យោបល់ដល់អគ្គនាយកដ្ឋានដូចជា៖

- ចំពោះអាករពិសេសអាត្រាអាករដែលកំណត់យកទៅលើការផ្គត់ផ្គង់ទំនិញ និងសេវាមួយចំនួននៅមានអាត្រាទាបនៅឡើយដែលមន្ត្រីមានសមត្ថភាពគួរតែពិចារណា និងពន្លឿនការកែប្រែអាត្រាអាករទៅលើប្រភេទមុខទំនិញ ដែលជាមុខសញ្ញានៃអាករពិសេសព្រោះយើងដឹងហើយថាមុខសញ្ញាទំនិញ នៃអាករពិសេសជាប្រភេទទំនិញដែលអាចប៉ះពាល់ដល់សុខភាព និងបរិស្ថានដូចជាបារីហ៊ីហ្គាស្រាស្រាបៀរភេសជ្ជៈនិងទំនិញដទៃទៀត។ ព្រោះការអនុញ្ញាតអោយអាត្រាអាករនៅទាបស្របពេលការវិនិយោគនិងការធ្វើពាណិជ្ជកម្មជាប់អាករនេះកាន់តែមានច្រើនឡើងៗ ធ្វើអោយផលចំណូលជាតិពីអាករពិសេសនៅមានចំនួនតិចជាងប្រទេសជិតខាង បើប្រៀបធៀប

ទៅនឹងប្រទេសឡាវពន្ធលើបារីមានចំនួនដល់ទៅ៦០% ខណៈប្រទេសកម្ពុជាកំណត់យកត្រឹមតែ២០%មិនត្រឹមតែប៉ុណ្ណោះ នាំអោយអាគ្រាសុខភាពជាតិក៏អាចមានផលប៉ះពាល់ផងដែរដែលរដ្ឋាភិបាលនិងមន្ត្រីពាក់ព័ន្ធគួរតែធ្វើការពិនិត្យឡើងវិញ។

- ធ្វើការចុះត្រួតពិនិត្យនៅតាមក្រុមហ៊ុន ឬសហគ្រាសដោយផ្ទាល់យ៉ាងហោចម្តងព្រោះអ្នកជាប់ពន្ធខ្លះមានត្រឹមតែឈ្មោះតែពុំមានសកម្មភាព។ ហើយអ្នកជាប់ពន្ធខ្លះទៀតចុះបញ្ជីពន្ធដារត្រឹមមួយកម្មវត្ថុតែដល់ពិនិត្យ លើការអនុវត្តជាក់ស្តែងអ្នកជាប់ពន្ធខ្លះអនុវត្តរហូតដល់២ទៅ៣កម្មវត្ថុ។ នេះជាហេតុដែលនាំអោយបាត់បង់ចំណូលពីពន្ធនិងអាករផ្សេងៗទៅតាមស្ថានភាពជាក់ស្តែង។
- ពន្លឿននូវរយៈពេលចុះបញ្ជីពន្ធដារអោយបានឆាប់រហ័ស ព្រោះថាការចុះបញ្ជីដែលប្រព្រឹត្តទៅនាពេលបច្ចុប្បន្ន ចំណាយរយៈពេលច្រើន ដែលខុសពីការ កំណត់ក្នុងច្បាប់ថាការចុះបញ្ជីពន្ធដារ ទទួលបាននូវលិខិតអះអាងពីការចុះ បញ្ជី គឺចន្លោះពី ៧ ទៅ ១៥ថ្ងៃ ប៉ុន្តែជាក់ស្តែងអាចទៅ ១ខែ ទៅ ២ខែ។
- ផងដែរនោះស្របពេលស្ថានភាពកម្ពុជានាពេលឥលូវគឺមានលំហូរ នៃការវិនិយោគពីវិនិយោគិនបរទេសមកប្រកបពាណិជ្ជកម្ម នៅកម្ពុជាមានការកើតឡើង ជាលំដាប់ជាពិសេសគឺពាណិជ្ជករពីប្រទេសចិន តែម្តងនៅពាសពេញផ្ទៃប្រទេសនៃ ព្រះរាជាណាចក្រកម្ពុជា។ ដែលខេត្តព្រះសីហនុ គឺជាខេត្តអទិភាពនៃក្រុមពាណិជ្ជករចិនមកបណ្តាក់ទុកបើកក្រុមហ៊ុនឬសហគ្រាសគ្រប់រូបភាពសកម្មភាព។ ដូចនេះគួរតែមានបង្កើតនូវគណៈកម្មការដែលធ្វើការគ្រប់គ្រងទៅការ គ្រប់គ្រងអ្នកជាប់ពន្ធជាពិសេសគឺក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែលជាទ្រង់ទ្រាយ ក្រុមហ៊ុនវិនិយោគិនចិនចូលចិត្តកំនត់យកបង្កើតក្រុមហ៊ុន។ ព្រោះការបង្កើតអោយមានគណៈកម្មការ នេះឡើងងាយស្រួលក្នុងការផ្តល់សេវាដ៏ច្រើនគំហុកពីសំណាក់ពាណិជ្ជករចិន និងធ្វើការគ្រប់គ្រងតាមដានការអនុវត្តនូវកាតព្វកិច្ចដែលនីតិបុគ្គលទាំងនោះមាន បានប្រសិទ្ធិភាពនិងត្រឹមត្រូវ។

ជារួមពួកយើងទាំងពីរសង្ឃឹមថា ការគ្រប់គ្រងរបស់រដ្ឋបាលសារពើពន្ធក្នុងការគ្រប់គ្រងទៅលើអ្នកជាប់ពន្ធទូទាំងប្រទេសកាន់តែមានប្រសើរឡើង ជាពិសេសនូវអ្វើ ដែលខាងស្ថាប័នអគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញប្រកបដោយប្រសិទ្ធិភាពនិងតម្លាភាពគណនេយ្យភាព។

# គន្លងិខ្មេស

# ឯកសារយោង

❖ **លិខិតបទដ្ឋានគតិយុត្ត**

## ច្បាប់

- រដ្ឋធម្មនុញ ឆ្នាំ១៩៩៣
- ក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី៦ ខែកក្កដារ ឆ្នាំ ២០០៦
- ច្បាប់ស្តីពី "សារពើពន្ធ" ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧
- ច្បាប់ស្តីពី "វិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ" ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣
- ច្បាប់ស្តីពី "វិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃកម្ពុជា" ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០៤
- ច្បាប់ស្តីពី "ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ" ២០១៨ ចុះថ្ងៃទី ០៩ ធ្នូ ២០១៧
- ច្បាប់ស្តីពី "ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ" ២០១៧

## អនុក្រឹត្យ

- អនុក្រឹត្យលេខ ០៣ អនក្រ.បក ស្តីពី" ការរៀបចំ និងការប្រព្រឹត្ត ទៅនៃគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ "ចុះថ្ងៃទី ០៦ ខែមករា ឆ្នាំ២០១៦
- អនុក្រឹត្យលេខ ១២៤ អនក្រ.បក ស្តីពី " ការលើកទឹកចិត្តផ្នែក ពន្ធដារ សម្រាប់សហគ្រាសធុនតូច និងមធ្យម ក្នុងវិស័យអគ្គិភាព " ចុះថ្ងៃទី ០២ ខែតុលា ឆ្នាំ២១០៨
- អនុក្រឹត្យលេខ ១៧ អមក្រ.បក ស្តីពី" ការលើកទឹកចិត្ត ផ្នែកពន្ធដារចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្តរបស់សហគ្រាសធុនតូច និង សហគ្រាស ធុនមធ្យម " ចុះថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១៧
- អនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥
- អនុក្រឹត្យស្តីពីអាករលើតំលៃ បន្ថែមលេខ ១១៤ អនក្រ.ប្រក ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៩

## ប្រកាស

- ប្រកាសស្ដីពីការលើកទឹកចិត្តពន្ធបន្ថែមចំពោះការដាំដុះស្រូវ ការប្រមូលទិញស្រូវ និងការផលិតអង្ករនាំចេញ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១
- ប្រកាសស្ដីពី ពន្ធលើប្រាក់បៀវត្ស
- សេចក្ដីណែនាំ ស្ដីពីការអនុវត្តអាត្រាពន្ធលើប្រាក់បៀវត្សថ្មី
- ប្រកាសស្ដីពី "ពន្ធលើប្រាក់ចំណេញ" ចុះថ្ងៃទ១២ ខែធ្នូ ឆ្នាំ២០០៣
- ប្រកាសស្ដីពីការអនុវត្តអាករលើការស្នាក់នៅ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៥
- ប្រកាសស្ដីពី "ការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបប ស្វ័យប្រកាស" ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ២០១៨
- ប្រកាសស្ដីពី ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទប្រចាំឆ្នាំ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧
- ប្រកាសស្ដីពី "ការចុះបញ្ជីពន្ធដារ" ចុះថ្ងៃទី ០៦ ខែសីហាឆ្នាំ ២០១៦
- ប្រកាសស្ដីពី " វិធាន និងនីតិវិធីនៃការដោះស្រាយបណ្ដឹងតវ៉ាពន្ធដារ នៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ" ចុះថ្ងៃទី០៦ ខែវិច្ឆកា ឆ្នាំ២០១៥
- ប្រកាសលេខ ៥៣៦ សហវ.ប្រក ស្ដីពី " ការណែនាំអនុវត្ត បទប្បញ្ញត្តិស្ដីពីពន្ធលើប្រតិបត្តិការប្រេងកាត " ចុះថ្ងៃពី ០៤ ខែមិថុនា ឆ្នាំ២០១៨
- ប្រកាសលេខ ៩៧៦ សហវ. ប្រក ស្ដីពីការមូលដ្ឋានគិតអាករ សម្រាប់បំភ្លឺសាធារណៈ ចុះថ្ងៃទី ០៩ តុលា ២០១៧
- ប្រកាសស្ដីពីវិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ ២៥ ធ្នូ ២០១៥
- ប្រកាសលេខ ១៥៣៩ សហវ.ប្រក ស្ដីពី " ការកែសម្រួល ការបរិច្ឆេទដាក់លិខិតប្រកាសពន្ធប្រចាំខែ" ចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០១៦
- ប្រកាសស្ដីពី ការអនុវត្តអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួល តារាងពន្ធតែមប្រ៏សារពើពន្ធ ចុះថ្ងៃទី ១៨ សីហា ឆ្នាំ២០១៥

- ប្រកាសស្តីពីការណែនាំអនុវត្តអាករលើតម្លៃបន្ថែម ចំពោះការផ្គត់ផ្គង់មិនជាប់អាករ លេខ៥៥៩ សហវ.ប្រក ចុះថ្ងៃទី ២៥ ឧសភា ១៩៩៧
- ប្រកាស ស្តីពីអាករពិសេសលើសេវាលំហែកំសាន្តផ្សេង លេខ ១៥៣ ប្រក.សហវ.ពដ ចុះថ្ងៃទី១៥ កុម្ភៈ ២០០១
- ប្រកាសស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមលើការនាំចូល និងការផ្គត់ផ្គង់ទំនិញមួយចំនួនចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤
- ប្រកាសស្តីពី ការចាត់ជាបន្ទុករបស់រដ្ឋនូវអាករលើតម្លៃបន្ថែមលើមុខទំនិញដែលជាអាហារជាមូលដ្ឋានសម្រាប់ ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ចុះថ្ងៃទី០៣ ខែមេសារ ឆ្នាំ២០១៨
- ប្រកាសស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះឧស្សាហកម្មគាំទ្រ ឬអ្នកចុះកិច្ចសន្យាដែលធ្វើការផ្គត់ផ្គង់ ទំនិញ ឬសេវាសម្រាប់បម្រើឲ្យការនាំចេញរបស់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតការបូបយួរ និងការបូបដៃ និងឧស្សាហកម្មផលិតមួក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤

## សេចក្តីណែនាំ

- សារាចរលេខ ០១១ សហវ ស្តីពីការអនុវត្តកាតព្វកិច្ច កាត់ទុកលើប្រាក់ពន្ធលើអត្ថប្រយោជន៍បន្ថែមចុះថ្ងៃទី ០៦ ខេតុលា ឆ្នាំ ២០១៦
- សេចក្តីណែនាំ អពដ ស្តីពីការប្រើប្រាស់វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធ ដែលបានចុះបញ្ជីពន្ធដារតាមរបបស្វ័យប្រកាស លេខ១១២៧ ចុះថ្ងៃទី ២៦ មករា ២០១៦
- សេចក្តីណែនាំ លេខ ១៧៧៥៤ អពដ ស្តីពី « ការអនុវត្តការលើក ទឹកចិត្តផ្នែកពន្ធដារចំពោះសហគ្រាសធុនតូច និង សហគ្រាសធុនមធ្យមដែលបានចុះបញ្ជី ដោយស្ម័គ្រចិត្ត » ចុះថ្ងៃទី ១០ ខែតុលា ឆ្នាំ២០១៧
- សេចក្តីណែនាំ ស្តីពីការអនុវត្តប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទប្រចាំឆ្នាំ ចុះថ្ងៃទី២២ មិថុនា ២០១៨

- សេចក្ដីជូនដំណឹងស្ដីពីការប្រមូលអាករលើការស្នាក់នៅ ចុះថ្ងៃទី២៧ ខែវិច្ឆកា ឆ្នាំ២០០៦

## សេចក្ដីជូនដំណឹង

- សេចក្ដីជូនដំណឹង ស្ដីពីការអនុវត្តការកែសម្រួលអាត្រាអាករពិសេសលើមុខទំនិញមួយចំនួន ដែលផលិតក្នុងស្រុក លេខ ២៧២៧ អពដ ចុះថ្ងៃទី ២២ មីនា ឆ្នាំ ២០១៦
- សេចក្ដីជូនដំណឹង ស្ដីពីការកែសម្រួលមូលដ្ឋានគិតអាករពិសេសលើមុខទំនិញមួយចំនួនៃលផលិតក្នុងស្រុក ក្រៅពីបារី និង ស្រា លេខ ០០៥ សហវ ចុះថ្ងៃទី១៩ មករា ២០១៥

## ❖ ឯកសារដែលចងក្រងជាសៀវភៅ និងឯកសារផ្សេងៗ

- អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សៀវភៅណែនាំស្ដីពី "ពន្ធលើប្រាក់ចំណេញ" ឆ្នាំ២០០៣
- អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច សៀវភៅណែនាំស្ដីពី "ពន្ធកាត់ទុកលើនិវាសនជន និង អនិវាសនជន" ឆ្នាំ២០១៣
- បទបង្ហាញស្ដីពីអាករលើតម្លៃបន្ថែម រៀបរៀងដោយអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ឯកសារស្ដីពី អាករលើតម្លៃបន្ថែម នៃសាលាជាតិពន្ធដារ បោះពុម្ពថ្ងៃទី៩ កញ្ញា ២០១៨
- ឯកសារសាលាជាតិពន្ធដារ បង្ហាត់បង្ហាញពីអាករពិសេសលើទំនិញ និងសេវាមួយចំនួន បោះពុម្ពថ្ងៃទី ៩ កញ្ញា ២០១៩

## ❖ ប្រព័ន្ធផ្សព្វផ្សាយ និងគេហទំព័រផ្សេងៗ

- www.tax.gov.kh
- អគ្គនាយកដ្ឋានពន្ធគយ និងរដ្ឋាករកម្ពុជា ចូលមើលនៅថ្ងៃទី ១៧ ខែ៧ ឆ្នាំ២០១៩ ម៉ោង ៣:៣៧ នាទី
  http://www.customs.gov.kh/%E1%9E%93%E1%9E%B8%E1%9E%8F%E1%9E%B7%E1%9E%9C%E1%9E%B7%E1%9E%92%E1%9E%B8%E1%9E%96%E1%9E%B7

%E1%9E%9F%E1%9F%81%E1%9E%9F/%E1%9E%82%E1%9E%98%E1%9F%92%E1%9E%9A%E1%9F%84%E1%9E%84%E1%9E%9C%E1%9E%B7%E1%9E%93%E1%9E%B7%E1%9E%99%E1%9F%84%E1%9E%82/

- គេហទំព័រ Facebook, Page នៃវិទ្យាស្ថានហិរញ្ញវត្ថុ និង គណនី ឬ Institute of Finance and Accounting-IFA https://www.facebook.com/Boreiaccounting/photos/a.787016824780510/1178375535644635/?type=3&theater បោះពុម្ពផ្សាយថ្ងៃទី ២១ វិច្ឆិកា ២០១៨ និង ចូលមើលថ្ងៃទី ០៥ មិថុនា ២០១៩
- វេបសាយអគ្គនាយកដ្ឋានគយ និង អាករ បរិយាយពី ទើពន្ធនិងអាករនាំចូល និងនាំចេញត្រូវគណនាដូចម្តេច? ថ្ងៃទី ៧ ធ្នូ ២០១៥. ចូលមើលថ្ងៃទី ២០ កក្កដា ២០១៩ http://www.customs.gov.kh/faq/%E1%9E%91%E1%9E%B7%E1%9E%93%E1%9F%92%E1%9E%93%E1%9E%93%E1%9F%90%E1%9E%99%E1%9E%93%E1%9F%81%E1%9F%87%E1%9E%94%E1%9E%B6%E1%9E%93%E1%9E%91%E1%9E%BC%E1%9E%9B%E1%9F%86%E1%9E%91%E1%9E%BC%E1%9E%9B%E1%9E%B6/
- គេហទំព័រ Facebook, Page នៃវិទ្យាស្ថានហិរញ្ញវត្ថុ និង គណនី ឬ Institute of Finance and Accounting-IFA បោះពុម្ពផ្សាយថ្ងៃទី ២១ វិច្ឆិកា ២០១៨ និង ចូលមើលថ្ងៃទី ០៥ មិថុនា ២០១៩https://www.facebook.com/Boreiaccounting/photos/a.787016824780510/1178375535644635/?type=3&theater

# ឧបសម្ព័ន្ធ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ទម្រង់ FORM TPP 01

Reset a Form

# ទម្រង់ស្នើសុំចុះបញ្ជីព័ត៌មានបុគ្គល
# TAXPAYER REGISTER FORM

## ១. ព័ត៌មានផ្ទាល់ខ្លួន / PERSONAL DETAIL

ឈ្មោះ Name: ______ ឈ្មោះជាឡាតាំង Name in Latin: ______

ភេទ Sex: ☐ ប្រុស Male ☐ ស្រី Female ថ្ងៃខែឆ្នាំកំណើត Date of birth: ថ្ងៃ ___ ខែ ___ ឆ្នាំ ___ ជនជាតិ National: ______

សញ្ជាតិ Nationality: ______ ▶ ☐ លេខអត្តសញ្ញាណប័ណ្ណ Identification card number ☐ លេខលិខិតឆ្លងដែន Passport number: ______

មុខរបរបច្ចុប្បន្ន Current job: ______

សារអេឡិចត្រូនិក Email: ______ លេខទូរស័ព្ទ Phone number: ______




### ទីកន្លែងកំណើត

ភូមិ Village: ______ ឃុំ/សង្កាត់ Commune: ______

ក្រុង/ស្រុក/ខណ្ឌ District: ______ ខេត្ត/រាជធានី Province/City: ______

### អាសយដ្ឋានទីស្នាក់ការសហគ្រាសបច្ចុប្បន្ន / Current registered office Address

ផ្ទះលេខ House No.: ______ ផ្លូវ Street: ______ ភូមិ Village: ______

ឃុំ/សង្កាត់ Commune: ______ ក្រុង/ស្រុក/ខណ្ឌ District: ______ ខេត្ត/រាជធានី Province/City: ______

សារអេឡិចត្រូនិក Email: ______ ទូរស័ព្ទចល័ត /ទូរស័ព្ទលើតុ Mobile phone / Office telephone: ______

## ២. ព័ត៌មានគ្រួសារ / INFORMATION

តើលោក-លោកស្រី មានប្តី ឬប្រពន្ធ ទេ? Do you have spouse? ☐ គ្មាន No ☐ មាន Yes ☐ ប្តី Husband ☐ ប្រពន្ធ Wife ▶ បើមាន សូមបំពេញព័ត៌មានខាងក្រោម If Yes, Please fill information below

ឈ្មោះ Name: ______ ឈ្មោះជាឡាតាំង Name in Latin: ______

ភេទ Sex: ☐ ប្រុស Male ☐ ស្រី Female ថ្ងៃខែឆ្នាំកំណើត Date of birth: ថ្ងៃ ___ ខែ ___ ឆ្នាំ ___ ជនជាតិ National: ______

សញ្ជាតិ Nationality: ______ ▶ ☐ លេខអត្តសញ្ញាណប័ណ្ណ Identification card number ☐ លេខលិខិតឆ្លងដែន Passport number: ______

មុខរបរបច្ចុប្បន្ន Current job: ______

សារអេឡិចត្រូនិច Email: ______ លេខទូរស័ព្ទ Phone number: ______




### ទីកន្លែងកំណើត

ភូមិ Village: ______ ឃុំ/សង្កាត់ Commune: ______

ក្រុង/ស្រុក/ខណ្ឌ District: ______ ខេត្ត/រាជធានី Province/City: ______

### អាសយដ្ឋានទីស្នាក់ការសហគ្រាសបច្ចុប្បន្ន Current registered office Address

តើអាសយដ្ឋានលោក-លោកស្រី ដូចអាសយដ្ឋាន ប្តី ឬប្រពន្ធ? Do you have the same address as your spouse? ☐ មិនដូច No ☐ ដូច Yes បើដូចមិនបាច់បំពេញអាសយដ្ឋានខាងក្រោម If No, please fill information below

ផ្ទះលេខ House No.: ______ ផ្លូវ Street: ______ ភូមិ Village: ______

ឃុំ/សង្កាត់ Commune: ______ ក្រុង/ស្រុក/ខណ្ឌ District: ______ ខេត្ត/រាជធានី Province/City: ______

សារអេឡិចត្រូនិក Email: ______ ទូរស័ព្ទចល័ត /ទូរស័ព្ទលើតុ Mobile phone / Office telephone: ______

## ៣. ព័ត៌មានកូន / INFORMATION

ឈ្មោះ Name: ________ ឈ្មោះជាឡាតាំង Name in Latin: ________
ភេទ Sex: ☐ ប្រុស Male ☐ ស្រី Female ថ្ងៃខែឆ្នាំកំណើត Date of birth: ថ្ងៃ ខែ ឆ្នាំ ជនជាតិ National: ________ សញ្ជាតិ Nationality: ________
☐ លេខអត្តសញ្ញាណប័ណ្ណ Identification card number ☐ លេខលិខិតឆ្លងដែន Passport number: ________ មុខរបរបច្ចុប្បន្ន Current job: ________

ឈ្មោះ Name: ________ ឈ្មោះជាឡាតាំង Name in Latin: ________
ភេទ Sex: ☐ ប្រុស Male ☐ ស្រី Female ថ្ងៃខែឆ្នាំកំណើត Date of birth: ថ្ងៃ ខែ ឆ្នាំ ជនជាតិ National: ________ សញ្ជាតិ Nationality: ________
☐ លេខអត្តសញ្ញាណប័ណ្ណ Identification card number ☐ លេខលិខិតឆ្លងដែន Passport number: ________ មុខរបរបច្ចុប្បន្ន Current job: ________

ឈ្មោះ Name: ________ ឈ្មោះជាឡាតាំង Name in Latin: ________
ភេទ Sex: ☐ ប្រុស Male ☐ ស្រី Female ថ្ងៃខែឆ្នាំកំណើត Date of birth: ថ្ងៃ ខែ ឆ្នាំ ជនជាតិ National: ________ សញ្ជាតិ Nationality: ________
☐ លេខអត្តសញ្ញាណប័ណ្ណ Identification card number ☐ លេខលិខិតឆ្លងដែន Passport number: ________ មុខរបរបច្ចុប្បន្ន Current job: ________

ឈ្មោះ Name: ________ ឈ្មោះជាឡាតាំង Name in Latin: ________
ភេទ Sex: ☐ ប្រុស Male ☐ ស្រី Female ថ្ងៃខែឆ្នាំកំណើត Date of birth: ថ្ងៃ ខែ ឆ្នាំ ជនជាតិ National: ________ សញ្ជាតិ Nationality: ________
☐ លេខអត្តសញ្ញាណប័ណ្ណ Identification card number ☐ លេខលិខិតឆ្លងដែន Passport number: ________ មុខរបរបច្ចុប្បន្ន Current job: ________

## ៤. ព័ត៌មានធនាគារ / BANK'S INFORMATION

ឈ្មោះធនាគារ Bank's Name: ________ ឈ្មោះជាឡាតាំង Name in Latin: ________
ប្រភេទកាត Type of card: ________ លេខគណនី Acc number: ________ ឈ្មោះគណនី Acc name: ________
កាលបរិច្ឆេទបង្កើត Date start: ថ្ងៃ ខែ ឆ្នាំ កាលបរិច្ឆេទផុតកំណត់ Date End: ថ្ងៃ ខែ ឆ្នាំ
ប្រភេទឯកសារ Type of document: ________ លេខឯកសារ Document number: ________
ឯកសារភ្ជាប់ Document attach: ________

## ៥. សំណុំឯកសារភ្ជាប់ / Attachment Check-list

| | |
|---|---|
| ☐ ទម្រង់ស្នើសុំចុះបញ្ជីព័ត៌មានបុគ្គល / FORM TPP01 | ច្បាប់ដើម / Original |
| ☐ អត្តសញ្ញាណប័ណ្ណ / ID CARD | ច្បាប់ថតចម្លង / Certified copy |
| ☐ លិខិតឆ្លងដែន / PASSPORT | ច្បាប់ថតចម្លង / Certified copy |
| ☐ សៀវភៅគ្រួសារ / FAMILY BOOK | ច្បាប់ថតចម្លង / Certified copy |
| ☐ សៀវភៅស្នាក់នៅ / ACCOMEDATION BOOK | ច្បាប់ថតចម្លង / Certified copy |
| ☐ លិខិតផ្សេងៗ / OTHER LETTER ________ | ច្បាប់ថតចម្លង / Certified copy |

ខ្ញុំបាទ/នាងខ្ញុំ សូមធានាទទួលខុសត្រូវចំពោះមុខច្បាប់ថា ព័ត៌មានបំពេញខាងលើនេះ ពិតជាត្រឹមត្រូវប្រាកដមែន។
I declare that information provided in this application including all attachment is true and correct.

**អ្នកស្នើសុំ / Applicant**

កាលបរិច្ឆេទ Date: ថ្ងៃ ខែ ឆ្នាំ
ហត្ថលេខា Signature: ហត្ថលេខា
និងឈ្មោះ and Name: ឈ្មោះ
លេខទូរស័ព្ទ Telephone Nº: ________

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

**ទម្រង់ ១០១ / FORM 101**

Reset Your Form

# ពាក្យស្នើសុំចុះបញ្ជីពន្ធដារ
# (របបស្វ័យប្រកាស)
## APPLICATION FORM FOR TAX REGISTRATION
*(SELF ASSESSMENT)*

**សម្រាប់មន្ត្រីពន្ធដារ / Tax official use only**

លេខអត្តសញ្ញាណកម្មសារពើពន្ធ
Tax Identification Number ( TIN )

សម្រាប់បិទបាកូដ/Stick bar code here!

## I. ព័ត៌មានសហគ្រាស / ENTERPRISE INFORMATION

### 1. ព័ត៌មាននៃការស្នើសុំចុះបញ្ជីពន្ធដារ / INFORMATION FOR TAX REGISTRATION

ឈ្មោះសហគ្រាស
Name of enterprise

ឈ្មោះសហគ្រាសជាអក្សរឡាតាំង
Name of enterprise in Latin

ចុះបញ្ជីនៅ
Registered at ☐ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
Department of Large Taxpayers ☐ សាខាពន្ធដារ
Tax Branch

ឆ្នាំជាប់ពន្ធរបស់សហគ្រាស
Tax year for enterprise ចាប់ពី
Start date D D M M ដល់
End date D D M M

### 2. អាសយដ្ឋានទីចាត់ការសហគ្រាស / HEAD OFFICE ADDRESS

ផ្ទះលេខ/អគារ
House Nº/Building | ផ្លូវ
Street | ភូមិ
Village

ឃុំ/សង្កាត់
Commune | ក្រុង/ស្រុក/ខណ្ឌ
District | ខេត្ត/រាជធានី
Province/City

សារអេឡិចត្រូនិក
Email | ប្រអប់សំបុត្រ/ប្រអប់សំបុត្រអេឡិចត្រូនិក
P.O. Box / Electronic mail box

ទូរស័ព្ទចល័ត
Mobile phone | ទូរស័ព្ទលើតុ
Office telephone | ទូរសារ
Fax

តើអចលនទ្រព្យដែលមានអាសយដ្ឋានខាងលើនេះជាកម្មសិទ្ធិរបស់សហគ្រាសផ្ទាល់ ឬជួល? / Is the property of this above address owned by enterprise or rented?

☐ កម្មសិទ្ធិ
Owned តើទីចាត់ការសហគ្រាសនេះមានលេខអត្តសញ្ញាណកម្មអចលនទ្រព្យដែរឬទេ?
Does this head office address have property identification number (PIN) ? ☐ គ្មាន
No ☐ មាន
Yes

បើមាន សូមបំពេញលេខអត្តសញ្ញាណកម្មអចលនទ្រព្យ
If Yes, please fill property identification number (PIN) ▶

☐ ជួល
Rent សូមបញ្ជាក់ថ្លៃឈ្នួល/១ខែ
please state rental fee/month ៛ តើទីចាត់ការសហគ្រាសដែលជួលនេះមានលេខអត្តសញ្ញាណកម្មអចលនទ្រព្យដែរឬទេ?
Does this rental head office have property identification number (PIN) ?

☐ គ្មាន
No ☐ មាន
Yes បើមានសូមបំពេញលេខអត្តសញ្ញាណកម្មអចលនទ្រព្យ
please fill property identification number (PIN) ▶

### 3. អាសយដ្ឋានអាជីវកម្មគោលដើម / MAIN BUSINESS ADDRESS

តើអាសយដ្ឋានអាជីវកម្មគោលដើមដូចអាសយដ្ឋានទីចាត់ការសហគ្រាសខាងលើដែរឬទេ?
Is your main business address same as your head office address?

☐ ដូច
Yes ▶ បើដូច ពុំចាំបាច់បំពេញព័ត៌មានខាងក្រោមទេ
If Yes, no need to fill any information below

☐ មិនដូច
No ▶ បើមិនដូច សូមបំពេញបន្ថែមខាងក្រោម
If No, please fill information below

ផ្ទះលេខ/អគារ
House Nº/Building | ផ្លូវ
Street | ភូមិ
Village

ឃុំ/សង្កាត់
Commune | ក្រុង/ស្រុក/ខណ្ឌ
District | ខេត្ត/រាជធានី
Province/City

សារអេឡិចត្រូនិក
Email | ប្រអប់សំបុត្រ/ប្រអប់សំបុត្រអេឡិចត្រូនិក
P.O. Box / Electronic mail box

ទូរស័ព្ទចល័ត
Mobile phone | ទូរស័ព្ទលើតុ
Office telephone | ទូរសារ
Fax

តើអចលនទ្រព្យដែលមានអាសយដ្ឋានខាងលើនេះជាកម្មសិទ្ធិរបស់សហគ្រាសផ្ទាល់ ឬជួល? / Is the property of this above address owned by entreprise or rented?

☐ កម្មសិទ្ធិ
Owned តើអាសយដ្ឋានអាជីវកម្មគោលដើមនេះមានលេខអត្តសញ្ញាណកម្មអចលនទ្រព្យដែរឬទេ?
Does your main business address have property identification number (PIN) ? ☐ គ្មាន
No ☐ មាន
Yes

បើមាន សូមបំពេញលេខអត្តសញ្ញាណកម្មអចលនទ្រព្យ
If Yes, please fill property identification number (PIN) ▶

☐ ជួល
Rent សូមបញ្ជាក់ថ្លៃឈ្នួល/១ខែ
please state rental fee/month ៛ តើអាសយដ្ឋានអាជីវកម្មគោលដើមដែលជួលនេះមានលេខអត្តសញ្ញាណកម្មអចលនទ្រព្យដែរឬទេ?
Does this rental main business address have property identification number (PIN) ?

☐ គ្មាន
No ☐ មាន
Yes បើមានសូមបំពេញលេខអត្តសញ្ញាណកម្មអចលនទ្រព្យ
If Yes, please fill property identification number (PIN) ▶

## 4. ឯកសារចុះបញ្ជីចេញដោយក្រសួងពាណិជ្ជកម្ម ឬក្រសួង ស្ថាប័នពាក់ព័ន្ធ / DOCUMENTS ISSUED BY MINISTRY OF COMMERCE OR OTHER MINISTRIES/ INSTITUTIONS

ឈ្មោះស្ថាប័ន
Name of institution

លេខចុះបញ្ជី
Registration N°

កាលបរិច្ឆេទ
Date of registration D D M M Y Y Y Y

## 5. ទ្រង់ទ្រាយសហគ្រាស / FORMS OF BUSINESS

- ☐ សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត / Single member private limited company
- ☐ សាខាក្រុមហ៊ុនបរទេស / Foreign company's branch
- ☐ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ / Partnership
- ☐ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត / Private limited company
- ☐ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត / Public limited company
- ☐ ក្រុមហ៊ុនសហកម្មសិទ្ធិទទួលខុសត្រូវមានកម្រិត / Limited partnership
- ☐ សហគ្រាសឯកបុគ្គល / Sole proprietorship
- ☐ ការិយាល័យតំណាង / Representative office
- ☐ សហគ្រាសរដ្ឋ / State owned company
- ☐ អង្គការក្រៅរដ្ឋាភិបាល / Non governmental organization
- ☐ ក្រុមហ៊ុនចម្រុះ / Joint venture company
- ☐ សហគ្រាសសាធារណៈ / Public company
- ☐ ទ្រង់ទ្រាយដទៃទៀត សូមបញ្ជាក់ / Other forms of business Please specify

## 6. សកម្មភាពអាជីវកម្ម / BUSINESS ACTIVITIES

សកម្មភាពអាជីវកម្មចម្បង
Main business activities

សកម្មភាពអាជីវកម្មចម្បងជាភាសាអង់គ្លេស
Main business activities in English

សកម្មភាពអាជីវកម្មបន្ទាប់បន្សំ
Additional business activities

សកម្មភាពអាជីវកម្មបន្ទាប់បន្សំជាភាសាអង់គ្លេស
Additional business activities in English

## 7. ព័ត៌មានស្តីពីនិយោជិត / EMPLOYEE INFORMATION

ចំនួននិយោជិត
Number of employees

ប្រាក់ខែសរុប
Total salary

## 8. ព័ត៌មានអំពីគណនីធនាគារ / BANK ACCOUNT INFORMATION

ឈ្មោះធនាគារ
Name of bank

ឈ្មោះគណនី
Account name

លេខគណនី
Account number

តើលោកអ្នកមានព័ត៌មានស្តីពីគណនីធនាគារលើសពីមួយឬទេ?
Do you have other bank account information?

☐ គ្មាន / No ☐ មាន / Yes ▶ បើមាន សូមបំពេញព័ត៌មានបន្ថែមនៅ ទម្រង់ ១០១-A
If Yes, please fill additional information in form 101-A

## 9. ពន្ធប៉ាតង់ / PATENT TAX

ខ្ញុំបាទ / នាងខ្ញុំស្នើសុំប្រកាសបង់ពន្ធប៉ាតង់ប្រចាំឆ្នាំ Y Y Y Y
I apply for patent tax payment for the year of

ចំនួនសកម្មភាពអាជីវកម្ម
Numbers of business activities

ប្រាក់ពន្ធប៉ាតង់ក្នុង១សកម្មភាព ៛
Amount of patent tax per business activity

ទឹកប្រាក់ពន្ធប៉ាតង់សរុបចំនួន 0.00 ៛
Total amount of patent tax

## 10. ពន្ធប្រថាប់ត្រា / REGISTRATION TAX

ខ្ញុំបាទ / នាងខ្ញុំស្នើសុំប្រកាសបង់ពន្ធប្រថាប់ត្រាលើលក្ខន្តិកៈក្រុមហ៊ុន ៛
I apply for paying registration tax with amount of

## 11. ផ្លាកយីហោ / ផ្លាកផ្សាយពាណិជ្ជកម្ម / COMPANY SIGNS / BUSINESS BILLBOARDS

តើសហគ្រាសលោកអ្នកបានលើកផ្លាកយីហោឬនៅ?
Does your enterprise tag with business sign/billboard?

☐ គ្មាន / No ☐ មាន / Yes ▶ បើមាន សូមបំពេញឈ្មោះផ្លាកយីហោខាងក្រោម
If Yes, Please fill business sign/billboard below

## II. ព័ត៌មានម្ចាស់ភាគហ៊ុន / SHAREHOLDER'S INFORMATION

### 1. ព័ត៌មានស្ដីពីម្ចាស់ភាគហ៊ុន /SHAREHOLDER'S INFORMATION

☐ សម្រាប់រូបវន្តបុគ្គល / PHYSICAL PERSON




ឈ្មោះ
Name

ឈ្មោះជាអក្សរឡាតាំង
Name in Latin

សញ្ជាតិ
Nationality

តួនាទី
Position

ភាគរយនៃហ៊ុន
Percentage of share %

ថ្ងៃខែឆ្នាំកំណើត
Date of birth D D M M Y Y Y Y

☐ លេខអត្តសញ្ញាណប័ណ្ណ
Identification card number

☐ លេខលិខិតឆ្លងដែន
Passport number

☐ សម្រាប់នីតិបុគ្គល / LEGAL PERSON

ឈ្មោះក្រុមហ៊ុន
Name of company

ឈ្មោះក្រុមហ៊ុនជាអក្សរឡាតាំង
Name of company in Latin

លេខអត្តសញ្ញាណកម្មសារពើពន្ធ
Tax identification number (TIN)

ភាគរយនៃហ៊ុន
Percentage of share %

### 2. អាសយដ្ឋានម្ចាស់ភាគហ៊ុន / SHAREHOLDER'S ADDRESS

សូមជ្រើសរើស Please choose ☐ រូបវន្តបុគ្គល / PHYSICAL PERSON ☐ នីតិបុគ្គល / LEGAL PERSON

ផ្ទះលេខ/អគារ
House Nº/Building

ផ្លូវ
Street

ភូមិ
Village

ឃុំ/សង្កាត់
Commune

ក្រុង/ស្រុក/ខណ្ឌ
District

ខេត្ត/រាជធានី
Province/City

សារអេឡិកត្រូនិក
Email

ប្រអប់សំបុត្រ/ប្រអប់សំបុត្រអេឡិកត្រូនិក
P.O. Box / Electronic mail box

ទូរស័ព្ទចល័ត
Mobile phone

ទូរស័ព្ទលើតុ
Office telephone

ទូរសារ
Fax

តើអចលនទ្រព្យដែលមានអាសយដ្ឋានខាងលើនេះជាកម្មសិទ្ធិរបស់ម្ចាស់ភាគហ៊ុនផ្ទាល់ ឬជួល? / Is the property of this above address owned by shareholder or rented?

☐ កម្មសិទ្ធិ
Owned

តើអាសយដ្ឋានខាងលើនេះមានលេខអត្តសញ្ញាណកម្មអចលនទ្រព្យដែរឬទេ?
Does this above address have property identification number (PIN) ?

☐ គ្មាន
No

☐ មាន
Yes

បើមាន សូមបំពេញលេខអត្តសញ្ញាណកម្មអចលនទ្រព្យ
If Yes, please fill property identification number (PIN)

☐ ជួល
Rent

សូមបញ្ជាក់ថ្លៃឈ្នួល/១ខែ ៛
please state rental fee/month

តើអាសយដ្ឋានដែលជួលនេះមានលេខអត្តសញ្ញាណកម្មអចលនទ្រព្យដែរឬទេ?
Does this rental address have property identification number (PIN)?

☐ គ្មាន
No

☐ មាន បើមានសូមបំពេញលេខអត្តសញ្ញាណកម្មអចលនទ្រព្យ
Yes If Yes, please fill property identification number (PIN)

តើសហគ្រាសរបស់លោកអ្នកមានម្ចាស់ភាគហ៊ុនលើសពីមួយឬទេ?
Does your enterprise have more than one shareholder ?

☐ គ្មាន
No

☐ មាន
Yes

បើមាន សូមបំពេញព័ត៌មានបន្ថែមនៅ ទម្រង់ ១០១-B
If Yes, please fill additional information in form 101-B

### 3. ព័ត៌មានស្ដីពីអ្នកតំណាងនីតិបុគ្គល / COMPANY REPRESENTATIVE INFORMATION FOR LEGAL PERSON

ឈ្មោះ
Name

ឈ្មោះជាអក្សរឡាតាំង
Name in Latin

តួនាទី
Position

ប្រាក់បៀវត្សរ៍ ឬ កម្រៃ
Salary/Fee ៛/ ខែ

សញ្ជាតិ
Nationality

ថ្ងៃខែឆ្នាំកំណើត
Date of birth D D M M Y Y Y Y

☐ លេខអត្តសញ្ញាណប័ណ្ណ
Identification card number

☐ លេខលិខិតឆ្លងដែន
Passport number

| លរ<br>No. | ឈ្មោះអ្នកទទួលប្រាក់<br>Name of Recipients | កម្មវត្ថុនៃការទូទាត់ប្រាក់<br>Object of Payment | លេខវិក្កយបត្រ<br>Invoice/Payment Note | ទឹកប្រាក់ត្រូវបើកមុនការកាត់ទុក<br>Amount Before Tax Withheld | អត្រាពន្ធ<br>Tax Rate | ពន្ធកាត់ទុក<br>Withholding Tax |
|---|---|---|---|---|---|---|
| A | B | c | D | E | F | G = E x F |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

## តារាងលម្អិតអំពីពន្ធកាត់ទុកចំពោះអ្នកជាប់ពន្ធអនិវាសនជន Details on the Withholding Tax on Non-Resident Taxpayers :

| លរ<br>No. | ឈ្មោះអ្នកទទួលប្រាក់<br>Name of Recipients | កម្មវត្ថុនៃការទូទាត់ប្រាក់<br>Object of Payment | លេខវិក្កយបត្រ<br>Invoice/Payment Note | ទឹកប្រាក់ត្រូវបើកមុនការកាត់ទុក<br>Amount Before Tax Withheld | អត្រាពន្ធ ១៤%<br>Tax Rate 14% | ពន្ធកាត់ទុក<br>Withholding Tax |
|---|---|---|---|---|---|---|
| A | B | c | D | E | F | G = E x F |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

កំណត់សម្គាល់ : ប្រសិនបើសរសេរមិនអស់ សូមភ្ជាប់ជាមួយក្នុងក្រដាសដោយឡែក ។

**Notes** : Use separate sheets if the space is insufficient.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទម្រង់ ពកទ ០៣
Form WT 03

អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# លិខិតប្រកាសពន្ធកាត់ទុក
# Return for Withholding Tax

( មាត្រា២៥ថ្មី មាត្រា២៦ថ្មី និងមាត្រា៣១ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ )
(Article 25 "New", 26 "New" and 31 "New" of the Law on Taxation)

សម្រាប់មន្ត្រីពន្ធដារ For Tax Official
ថ្ងៃទី ☐☐ DD ខែ ☐☐ MM ឆ្នាំ ☐☐ YY
លេខចូល Nº ……………………..………
ហត្ថលេខា
Signature
ឈ្មោះមន្ត្រីពន្ធដារ ……………………….
Tax official Name

| 01 | ការិយបរិច្ឆេទសារពើពន្ធសម្រាប់លិខិតប្រកាសនេះ Period covered by this return | |
|---|---|---|
| | ពីថ្ងៃទី………… ខែ………… ឆ្នាំ………… From (DD) Month (MM) Year (YYYY) | ដល់ថ្ងៃទី………… ខែ………… ឆ្នាំ………… From (DD) Month (MM) Year (YYYY) |

| 02 | លេខអត្តសញ្ញាណកម្មសារពើពន្ធ TIN | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | |

**03**

ឈ្មោះសហគ្រាស Name of Enterprise : ……………………………………………………

សកម្មភាពអាជីវកម្ម Business Activities : ……………………………………………………

អាសយដ្ឋាន Address: No……………… វិថី Street……………… ក្រុម Group……………… ភូមិ Village ………………

ឃុំ/សង្កាត់ Sangkat……………… ក្រុង/ស្រុក/ខណ្ឌ District ……………… ខេត្ត/រាជធានី Municipality ………………

ទូរស័ព្ទ/ទូរសារ Fax/Phone ……………… សារអេឡិចត្រូនិក E-mail ………………

## I. ពន្ធកាត់ទុកលើនិវាសនជន ( មាត្រា ២៥ "ថ្មី" ) Withholding Tax on Resident (Article 25 "New") :

| 04 | កម្មវត្ថុនៃការទូទាត់ប្រាក់ Object of Payment | ទឹកប្រាក់ត្រូវបើក Amount to be Paid | អត្រាពន្ធ Tax Rate | ពន្ធកាត់ទុក Withholding Tax | កំណត់សម្គាល់ Remarks |
|---|---|---|---|---|---|
| | A | B | C | D = B x C | |
| 1 | ការបំពេញសេវានានា សួយសារចំពោះទ្រព្យអរូបី ភាគកម្មក្នុងធនធានរ៉ែ Performance of Services, Royalty for Intangibles, Interests in Minerals | ………… | **15%** | ………… | ………… |
| 2 | ការបង់ការប្រាក់ឱ្យទៅអ្នកជាប់ពន្ធមិនមែនជាធនាគារឬស្ថាប័នសន្សំប្រាក់ Payment of Interest to Non-Bank or Saving Institution Taxpayers | ………… | **15%** | ………… | ………… |
| 3 | ការបង់ការប្រាក់ឱ្យអ្នកជាប់ពន្ធដែលមានគណនីសន្សំមានកាលកំណត់ * Payment of Interest to Taxpayers who have Fixed Term Deposit Accounts | ………… | **6%** | ………… | ………… |
| 4 | ការបង់ការប្រាក់ឱ្យអ្នកជាប់ពន្ធដែលមានគណនីសន្សំគ្មានកាលកំណត់ * Payment of Interest to Taxpayers who have Non-Fixed Term Saving | ………… | **4%** | ………… | ………… |
| 5 | ការបង់ថ្លៃឈ្នួលចលនទ្រព្យនិងអចលនទ្រព្យ Payment of Rental/Lease of Movable and Immovable Property | ………… | **10%** | ………… | ………… |
| | សរុប **Total** | ………… | | ………… | ………… |

## II. ពន្ធកាត់ទុកលើអនិវាសនជន ( មាត្រា ២៦ "ថ្មី" ) Withholding Tax on Non-Resident (Article 26 "New") :

| 05 | កម្មវត្ថុនៃការទូទាត់ប្រាក់ Object of Payment | ទឹកប្រាក់ត្រូវបើក Amount to be Paid | អត្រាពន្ធ Tax Rate | ពន្ធកាត់ទុក Withholding Tax | កំណត់សម្គាល់ Remarks |
|---|---|---|---|---|---|
| | A | B | C | D = B x C | |
| 1 | ការបង់ការប្រាក់ Payment of Interest | ………… | **14%** | ………… | ………… |
| 2 | ការបង់សួយសារ ថ្លៃឈ្នួល ចំណូលផ្សេងៗទាក់ទិននឹងការប្រើប្រាស់ទ្រព្យសម្បត្តិ Payment of Royalty, Rental/Leasing, and Income related to the use of Property | ………… | **14%** | ………… | ………… |
| 3 | ការទូទាត់ថ្លៃសេវាគ្រប់គ្រង និងសេវាបច្ចេកទេសនានា Payment of Management Fee and Technical Services | ………… | **14%** | ………… | ………… |
| 4 | ការបង់ភាគលាភ Payment of Dividend | ………… | **14%** | ………… | ………… |
| | សរុប **Total** | ………… | | ………… | ………… |

យើងខ្ញុំបានពិនិត្យគ្រប់ចំណុចទាំងអស់នៅលើលិខិតប្រកាសនេះ និងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយ ។ យើងខ្ញុំមានសក្ខីបត្របញ្ជាក់ច្បាស់លាស់ ត្រឹមត្រូវ ពេញលេញ ដែលធានាបានថាព័ត៌មានទាំងអស់នៅលើលិខិតប្រកាសនេះ ពិតជាត្រឹមត្រូវប្រាកដមែន ហើយគ្មានប្រតិបត្តិការណាមួយមិនបានប្រកាសនោះទេ ។ យើងខ្ញុំសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ទាំងឡាយជាធរមាន ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ ។ We have examined all items on this return and the annexes attached here with. We have clear, correct, and full supporting documents to ensure that all information on this return is true and accurate and there is no business operation undeclared. We are fully responsible due to the existing Laws for any falsified information.

ធ្វើនៅ ………………… ថ្ងៃទី ☐☐ ខែ ☐☐ ឆ្នាំ ☐☐☐☐
Filed in DD MM YYYY

**អភិបាល/បណ្ណាធិការ/កម្មសិទ្ធិករ សហគ្រាស**
Director/Manager/Owner of Enterprise
(ហត្ថលេខា និងត្រា Signature & Seal)

សម្រាប់មន្ត្រីពន្ធដារ For Tax Official
បែបបទនៃការបង់ប្រាក់ : ☐សាច់ប្រាក់ ☐មូលប្បទានបត្រ ☐បង្វែរ
ចំនួនទឹកប្រាក់…………………………………………
បង់តាមបង្កាន់ដៃលេខ………………ចុះថ្ងៃទី……/……/……
លរ.លន គណនេយ្យកម្ម………………ថ្ងៃធ្វើ……/……/……
ឈ្មោះមន្ត្រីពន្ធដារ……………ហត្ថលេខា …………………

* ចំណុច ៣ និង ៤ គឺជាការបង់ការប្រាក់ដោយធនាគារឬស្ថាប័នសន្សំប្រាក់ក្នុងស្រុកឱ្យទៅអតិថិជនជាអ្នកផ្ញើប្រាក់
Point 3 and 4 are the payment of interest by domestic banks and saving institutions to their clients that have deposit or saving accounts.

**តារាងលម្អិតអំពីពន្ធកាត់ទុកចំពោះអ្នកជាប់ពន្ធនិវាសនជន Details on the Withholding Tax on Resident Taxpayers** :

| លរ<br>No. | ឈ្មោះអ្នកទទួលប្រាក់<br>Name of Recipients | កម្មវត្ថុនៃការទូទាត់ប្រាក់<br>Object of Payment | លេខវិក្កយបត្រ<br>Invoice/Payment Note | ទឹកប្រាក់ត្រូវបើកមុនការកាត់ទុក<br>Amount Before Tax Withheld | អត្រាពន្ធ<br>Tax Rate | ពន្ធកាត់ទុក<br>Withholding Tax |
|---|---|---|---|---|---|---|
| A | B | c | D | E | F | G = E x F |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

**តារាងលម្អិតអំពីពន្ធកាត់ទុកចំពោះអ្នកជាប់ពន្ធអនិវាសនជន Details on the Withholding Tax on Non-Resident Taxpayers** :

| លរ<br>No. | ឈ្មោះអ្នកទទួលប្រាក់<br>Name of Recipients | កម្មវត្ថុនៃការទូទាត់ប្រាក់<br>Object of Payment | លេខវិក្កយបត្រ<br>Invoice/Payment Note | ទឹកប្រាក់ត្រូវបើកមុនការកាត់ទុក<br>Amount Before Tax Withheld | អត្រាពន្ធ ១៤%<br>Tax Rate 14% | ពន្ធកាត់ទុក<br>Withholding Tax |
|---|---|---|---|---|---|---|
| A | B | c | D | E | F | G = E x F |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

កំណត់សម្គាល់ : ប្រសិនបើសរសេរមិនអស់ សូមភ្ជាប់ជាមួយក្នុងក្រដាសដោយឡែក ។

**Notes** : Use separate sheets if the space is insufficient.

| | |
|---|---|
| ☐ ទទួល Accepted | ☐ បដិសេធ Rejected |
| លេខចូល Entry Number .......................... | |
| កាលបរិច្ឆេទDate ......... / .......... / ............ | |
| មន្ត្រីទទួល Receiving Officer | |
| .......................................................... | |

ព្រះរាជាណាចក្រកម្ពុជា

Kingdom of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation - Religion - King

# ពាក្យស្នើសុំ

# Application

## អនុវត្តអត្រាសូន្យចំពោះការផ្គត់ផ្គង់ផលិតផលឬសេវាដល់

## For Zero Rating the Supply of Products or Services to

## ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិតស្បែកជើង

## Garment Industry, Textile Industry, Footwear Industry

## ឧស្សាហកម្មផលិតកាបូបយួរ និងកាបូបដៃ និងឧស្សាហកម្មផលិតមួក

## Bag Industry, Handbag Industry and Hat Industry.

រយៈពេលស្នើសុំ ពីថ្ងៃទី........ខែ..........ឆ្នាំ............. ដល់ ថ្ងៃទី........ខែ..........ឆ្នាំ.............

Application Period from DD MM YYYY Until DD MM YYYY

ខ្ញុំបាទ/នាងខ្ញុំ ឈ្មោះ : ....................................................................... សញ្ជាតិ: .....................................................

I am(Mr./Mrs) Nationality

អាយុ : ................. ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែន លេខ : ..............................................................

Ages : Year old Holding Identification Card/Passport No.

ចេញដោយ : ....................................................................................... ជា : ....................................................

Issued by I am (Title)

របស់ក្រុមហ៊ុន : .................................................................. លេខអត្តសញ្ញាណកម្មសារពើពន្ធ : ...............................

of (Company) Tax Identification Number

អាសយដ្ឋានអាជីវកម្ម : ........................................................................................................................................

Business Address

បានចុះកិច្ចសន្យាផ្គត់ផ្គង់ (ផលិតផល/សេវា) : ......................................................................................................

Has contracted to supply (Products/Services)

ដល់ក្រុមហ៊ុន : .................................................................... លេខអត្តសញ្ញាណកម្មសារពើពន្ធ : ...............................

to (Company) Tax Identification Number

អាសយដ្ឋានអាជីវកម្ម : ........................................................................................................................................

Business Address

តាមកិច្ចសន្យាលេខ : ........................................... ចុះថ្ងៃទី................. ខែ ............... ឆ្នាំ ................។

In accordance with the contract No. Date

ខ្ញុំបាទ/នាងខ្ញុំ សូមសន្យាថានឹងអនុវត្តឲ្យបានត្រឹមត្រូវតាម បទប្បញ្ញត្តិ និងល័ក្ខខ័ណ្ឌទាំងអស់ ដូចមានចែងក្នុងប្រកាស

I commit to apply strictly to the provisions and all conditions as stated in the Prakas

លេខ ៣១១ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០១៤ ។ បើផ្ទុយទៅវិញ ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវទាំងស្រុង

Number 311 MEF. Date 19 March 2014. If I fail to do so I will fully responsible for

ក្នុងការបង់អាករលើតម្លៃបន្ថែមរួមទាំងទោសទណ្ឌទាំងអស់ទៅតាមច្បាប់ពន្ធដារជាធរមាន ។

the repayment of Value added Tax and all sanctions according to the existing Tax Laws.

ធ្វើនៅ .............................. ថ្ងៃទី ............. ខែ ................ ឆ្នាំ .................

Made in Date

ហត្ថលេខា

signature

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation - Religion - King

| | |
|---|---|
| ☐ ទទួល Accepted | ☐ បដិសេធ Rejected |

លេខចូល Entry Number ..........................
កាលបរិច្ឆេទDate ......... / .......... / ............
មន្ត្រីទទួល Receiving Officer
..........................................................

# ពាក្យស្នើសុំ
Application

## អនុវត្តអត្រាសូន្យចំពោះការផ្គត់ផ្គង់ផលិតផលឬសេវាដល់
For Zero Rating the Supply of Products or Services to

## ការផ្គត់ផ្គង់អង្ករសម្រាប់ បម្រើឲ្យការនាំចេញអង្ករ
Rice Supply for Rice Export.

រយៈពេលស្នើសុំ ពីថ្ងៃទី........ខែ.........ឆ្នាំ............ ដល់ ថ្ងៃទី........ខែ.........ឆ្នាំ............
Application Period from DD MM YYYY Until DD MM YYYY

ខ្ញុំបាទ/នាងខ្ញុំ ឈ្មោះ : ........................................................................ សញ្ជាតិ: .....................................................
I am(Mr./Mrs) Nationality

អាយុ : ................ ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែន លេខ : ..........................................................
Ages : Year old Holding Identification Card/Passport No.

ចេញដោយ : ........................................................................................ ជា : ....................................................
Issued by I am (Title)

របស់ក្រុមហ៊ុន : ................................................................... លេខអត្តសញ្ញាណកម្មសារពើពន្ធ : ...............................
of (Company) Tax Identification Number

អាសយដ្ឋានអាជីវកម្ម : .........................................................................................................................
Business Address

បានចុះកិច្ចសន្យាផ្គត់ផ្គង់ (ផលិតផល/សេវា) : ..........................................................................................
Has contracted to supply (Products/Services)

ដល់ក្រុមហ៊ុន : ..................................................................... លេខអត្តសញ្ញាណកម្មសារពើពន្ធ : ...............................
to (Company) Tax Identification Number

អាសយដ្ឋានអាជីវកម្ម : .........................................................................................................................
Business Address

តាមកិច្ចសន្យាលេខ : .......................................... ចុះថ្ងៃទី................ ខែ .............. ឆ្នាំ ................។
In accordance with the contract No. Date

ខ្ញុំបាទ/នាងខ្ញុំ សូមសន្យាថានឹងអនុវត្តឲ្យបានត្រឹមត្រូវតាម បទប្បញ្ញត្តិ និងល័ក្ខខ័ណ្ឌទាំងអស់ ដូចមានចែងក្នុងប្រកាស
I commit to apply strictly to the provisions and all conditions as stated in the Prakas
លេខ ៣១៣ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០១៤ ។ បើផ្ទុយទៅវិញ ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវទាំងស្រុង
Number 313 MEF. Date 19 March 2014. If I fail to do so I will fully responsible for
ក្នុងការបង់អាករលើតម្លៃបន្ថែមរួមទាំងទោសទណ្ឌទាំងអស់ទៅតាមច្បាប់ពន្ធដារជាធរមាន ។
the repayment of Value added Tax and all sanctions according to the existing Tax Laws.

ធ្វើនៅ ......................... ថ្ងៃទី ............ ខែ ............... ឆ្នាំ .................
Made in Date

ហត្ថលេខា
signature

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ ១៧៧៥៤ អពដ

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧

# សេចក្ដីណែនាំ
## ស្ដីពី
## ការអនុវត្តការលើកទឹកចិត្តផ្នែកពន្ធដារ
## ចំពោះសហគ្រាសធុនតូចនិងសហគ្រាសធុនមធ្យមដែលបានចុះបញ្ជីដោយស្ម័គ្រចិត្ត

អនុលោមតាមអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការលើកទឹកចិត្តផ្នែកពន្ធដារចំពោះសហគ្រាសធុនតូចនិងសហគ្រាសធុនមធ្យមដែលបានចុះបញ្ជីដោយស្ម័គ្រចិត្ត និងប្រកាសលេខ ៥០២ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧ ស្ដីពីការណែនាំអនុវត្តខ្លឹមសារអនុក្រឹត្យស្ដីពីការលើកទឹកចិត្តផ្នែកពន្ធដារចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្តសហគ្រាសធុនតូចនិងសហគ្រាសធុនមធ្យម អគ្គនាយកដ្ឋានពន្ធដារ សូមធ្វើការណែនាំចំពោះ នាយកដ្ឋានពាក់ព័ន្ធ និងសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ ដូចខាងក្រោម÷

១. ការចុះបញ្ជីពន្ធដារចំពោះសហគ្រាសធុនតូចនិងសហគ្រាសធុនមធ្យម ដែលបានមកចុះបញ្ជីដោយស្ម័គ្រចិត្ត ដូចមានចែងក្នុងប្រការ ៥ នៃប្រកាសលេខ ៥០២ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧ ត្រូវធ្វើឡើងដោយគ្មានការកំណត់ទោសទណ្ឌលើការប្រព្រឹត្តអំពើរំលងស្មុះ ការយឺតយ៉ាវ ក្នុងការបង់ពន្ធប្រថាប់ត្រា និងពន្ធប៉ាតង់ឡើយ។ ចំពោះពន្ធប៉ាតង់ត្រូវអនុវត្ត តែទៅលើឆ្នាំជាប់ពន្ធចរន្តដែលសហគ្រាសមកចុះបញ្ជីប៉ុណ្ណោះ។

២. ការលើកទឹកចិត្តផ្នែកពន្ធដារត្រូវបានផ្ដល់ឱ្យចំពោះតែសហគ្រាសធុនតូចនិងសហគ្រាសធុនមធ្យមទាំងឡាយណា ដែលបានមកដាក់ពាក្យចុះបញ្ជីពន្ធដារក្នុងអំឡុងពេល ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ តែប៉ុណ្ណោះ។ ការលើកទឹកចិត្តផ្នែកពន្ធដារ មានដូចខាងក្រោម÷

ក- លើកលែងពន្ធលើប្រាក់ចំណូលចំនួន ២ ឆ្នាំ ដោយគិតចាប់ពី÷
- ឆ្នាំដែលទទួលបានប្រាក់ចំណូលដំបូងចំពោះសហគ្រាសដែលពុំទាន់មានប្រាក់ចំណូល ឬ
- ឆ្នាំដែលចុះបញ្ជីពន្ធដារចំពោះសហគ្រាសដែលមានប្រាក់ចំណូលរួចហើយ។

ខ- ក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូលនេះ សហគ្រាសធុនតូច និងសហគ្រាសធុនមធ្យម ត្រូវបានលើកលែងពីការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា។

៣. ដើម្បីឱ្យការលើកទឹកចិត្តផ្នែកពន្ធដារនេះអនុវត្តដោយប្រសិទ្ធភាពខ្ពស់ អគ្គនាយកដ្ឋានពន្ធដារនឹងចេញលិខិតបញ្ជាក់អំពីការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត ព្រមទាំងការលើកទឹកចិត្តដែលសហគ្រាសទទួលបាន។ នាយកដ្ឋានពាក់ព័ន្ធ និងសាខាពន្ធដារខេត្ត-ខណ្ឌត្រូវបំពេញព័ត៌មានក្នុងពាក្យស្នើសុំចុះបញ្ជីពន្ធដារ (ទម្រង់១០១ និង S01) ឱ្យបានច្បាស់លាស់ដែលបញ្ជាក់ថាសហគ្រាសបានចុះបញ្ជីដោយស្ម័គ្រចិត្ត។

៤. ចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្តក្នុងឆ្នាំ២០១៧ ដែលបានធ្វើឡើងមុនកាលបរិច្ឆេទនៃការចេញប្រកាសលេខ ៥០២ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧ ក៏ត្រូវទទួលបានការលើកទឹកចិត្តដូចគ្នាដែរ ប៉ុន្តែ ប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំខែ ដែលបានដាក់លិខិតប្រកាសនិងបង់រួចមុនទទួលបានលិខិតបញ្ជាក់ការលើកចិត្តផ្នែកពន្ធដារ មិនត្រូវបានអនុញ្ញាតជាឥណទានទេ។

៥. សាខាពន្ធដារខេត្ត-ខណ្ឌត្រូវផ្ញើបញ្ជីឈ្មោះសហគ្រាសធុនតូចនិងសហគ្រាសធុនមធ្យម ដែលបានចុះបញ្ជីដោយស្ម័គ្រចិត្តក្នុងឆ្នាំ២០១៧មុនកាលបរិច្ឆេទនៃការចេញសេចក្ដីណែនាំនេះ មកអគ្គនាយកដ្ឋានពន្ធដារតាមទម្រង់ដែលបានកំណត់។

ទទួលបានសេចក្ដីណែនាំនេះ សូមលោកប្រធាននាយកដ្ឋានពាក់ព័ន្ធ និងលោកប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ ចាត់ចែងអនុវត្តតាមការណែនាំខាងលើប្រកបដោយប្រសិទ្ធភាព ស័ក្ដិសិទ្ធភាព និងស្មារតីទទួលខុសត្រូវខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

ព្រះរាជាណាចក្រកម្ពុជា
**KINGDOM OF CAMBODIA**
ជាតិ សាសនា ព្រះមហាក្សត្រ
National - Religion - King


ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
**MINISTRY OF ECONOMY AND FINANCE**
**Fax/Phone: (855) 23 427 798**


# ច្បាប់ស្តីពីសារពើពន្ធ

# និង

# ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសារពើពន្ធ

## Law on Taxation
## (Old and New)


*Tax Policy Unit*
*Janaury, 2004*

# ព្រះរាជក្រម

**យើង**

**ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីទេសរដ្ឋមន្ត្រីទទួលបន្ទុកនីតិសម្បទា និង អភិវឌ្ឍន៍ និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីសារពើពន្ធ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៨ ខែមករា ឆ្នាំ១៩៩៧ នាសម័យប្រជុំលើកទី ៧ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ:

# ជំពូកទី ១
# បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណេញ
## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ : បន្ទុកពន្ធ**

បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណេញ ដូចមានចែងក្នុងច្បាប់ស្តីអំពីហិរញ្ញវត្ថុសម្រាប់ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០២/នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៨/នស ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៤ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និង ច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ត្រូវបានធ្វើវិសោធនកម្មដូចតទៅដើម្បីជាគុណប្រយោជន៍ដល់ថវិការដ្ឋ ។

**មាត្រា ២ : កម្មវត្ថុនៃពន្ធ**

ពន្ធលើប្រាក់ចំណេញ គឺជាបំណុលរបស់បុគ្គលនិវាសនជន ចំពោះប្រាក់ចំណូលប្រភពកម្ពុជា និង ប្រាក់ចំណូលប្រភពបរទេស និង របស់បុគ្គលអនិវាសនជន ចំពោះប្រាក់ចំណូលប្រភពកម្ពុជា ។

***មាត្រា ៣ (ថ្មី) : និយមន័យ***

*សម្រាប់គោលដៅនៃបទប្បញ្ញត្តិស្តីពីសារពើពន្ធ :*

*១- ពាក្យ "អ្នកជាប់ពន្ធនិវាសនជន" សំដៅដល់ :*

*ក- រូបវន្តបុគ្គលដែលមាននិវាសនដ្ឋាន ឬមានកន្លែងស្នាក់នៅជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី ១៨២ ថ្ងៃនៅក្នុងរយៈពេល ១២ ខែណាមួយដែលបានបញ្ចប់ក្នុងឆ្នាំសារពើពន្ធចរន្ត*

*ខ- នីតិបុគ្គល ឬក្រុមអាជីវកម្ម ដែលត្រូវបានបង្កើតឬត្រូវបានគ្រប់គ្រងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានកន្លែងប្រកបអាជីវកម្មជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។*

*២- ពាក្យ "អ្នកជាប់ពន្ធអនិវាសនជន" មានន័យថាបុគ្គលណាមួយដែលមិនមែនជាអ្នកជាប់ពន្ធនិវាសនជនតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ និងទទួលប្រាក់ចំណូលប្រភពកម្ពុជា ។*

*៣- ពាក្យ "នីតិបុគ្គល" សំដៅដល់សហគ្រាស ឬអង្គការនានាដែលប្រកបអាជីវកម្ម ទោះបីជាបាន ឬមិនទាន់បានទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលក្តី ។ ពាក្យ "នីតិបុគ្គល" រួមបញ្ចូលផងដែរនូវស្ថាប័នរដ្ឋាភិបាល អង្គការសាសនា អង្គការសប្បុរសធម៌ ឬអង្គការមិនស្វែងរកចំណេញ ។ ចំពោះបុគ្គលអនិវាសនជនពាក្យ "នីតិបុគ្គល" សំដៅដល់គ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ពាក្យ "នីតិបុគ្គល" ពុំរាប់បញ្ចូលទេនូវក្រុមអាជីវកម្ម ឬសហគ្រាសឯកបុគ្គល ។*

*៤- ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" សំដៅដល់ទីកន្លែងប្រកបអាជីវកម្មជាប់លាប់នៅព្រះរាជាណាចក្រកម្ពុជា សាខារបស់ក្រុមហ៊ុនបរទេស ឬភ្នាក់ងារនិវាសនជននៅព្រះរាជាណាចក្រកម្ពុជាដែលតាមរយៈនេះបុគ្គលអនិវាសនជនប្រកបអាជីវកម្មរបស់*

ខ្លួន ។ ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" រួមបញ្ចូលផងដែរនូវសមាគម ឬរូបភាពទំនាក់ទំនងផ្សេងទៀត ដែលតាមរយៈនេះបុគ្គលអនិវាសជនធ្វើសកម្មភាពសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ។

៥- ពាក្យ "ក្រុមអាជីវកម្ម" សំដៅដល់ក្រុមសម្ព័ន្ធនាម ដែលមានម្ចាស់ភាគទុនជារូបវន្តបុគ្គលនិវាសនជនយ៉ាងច្រើន ១០ នាក់ ហើយក្នុងនោះចំណែកសមមាត្ររបស់ម្ចាស់ភាគទុននៅក្នុងខ្ទង់មូលធន ប្រាក់ចំណេញ និងការខាតបង់ ត្រូវស្របតាមលក្ខណៈវិនិច្ឆ័យដែលត្រូវកំណត់ដោយអនុក្រឹត្យ ។ ក្នុងនិយមន័យនេះ "ក្រុមអាជីវកម្ម" មិនអាចជាសមាជិករបស់ក្រុមហ៊ុនបុគ្គលណាមួយ ហើយក៏មិនរាប់បញ្ចូលផងទេនូវក្រុមហ៊ុនដើមទុនគ្រឹះស្ថានអចិន្ត្រៃយ៍ ឬសហគ្រាសឯកបុគ្គល ។

៦- ពាក្យ "សហគ្រាសឯកបុគ្គល" សំដៅដល់សហគ្រាសអាជីវកម្មដែលជាកម្មសិទ្ធិ ១០០ ភាគរយរបស់រូបវន្តបុគ្គលណាម្នាក់ ។ ក្នុងនិយមន័យនេះ ប្តី ប្រពន្ធ និង កូនក្នុងបន្ទុក ត្រូវចាត់ទុកថាជារូបវន្តបុគ្គលតែម្នាក់ ។

៧- ពាក្យ "អាជីវកម្ម" សំដៅដល់សកម្មភាពសេដ្ឋកិច្ចរបស់បុគ្គល ដែលមានគោលដៅទាញយកប្រាក់ចំណូលអំពីការផលិត និងលក់ទំនិញ ការផ្គត់ផ្គង់សេវា ភតិសន្យា ការជួល ឬការលក់ទ្រព្យសម្បត្តិ ឬសកម្មភាពផ្សេងទៀត ។

៨- ពាក្យ "ភាគលាភ" សំដៅដល់ ចំណែកជាសាច់ប្រាក់ ឬជាទ្រព្យដែលនីតិបុគ្គលបានចែកឱ្យអ្នកចូលហ៊ុន ទៅតាមកំរិតនៃភាគកម្មរបស់ខ្លួននៅក្នុងដើមទុនផ្ទាល់របស់នីតិបុគ្គល លើកលែងតែភាគលាភជាប័ណ្ណភាគហ៊ុន និង ការបែងចែកនានាក្នុងពេលជំរះបញ្ជីរំលាយក្រុមហ៊ុនទាំងស្រុង ។ ចំណែកណាមួយដែលចាត់ទុកថាជាភាគលាភ ឬមិនមែនជាភាគលាភ ត្រូវផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះ ដោយពុំគិតថានីតិបុគ្គលមាន ឬគ្មានប្រាក់ចំណូល ឬប្រាក់ចំណេញចរន្ត ឬលទ្ធផលយោងសារជាថ្មីឡើយ ។

៩- ពាក្យ "អ្នកចូលហ៊ុន" សំដៅដល់បុគ្គលដែលមានចំណែកភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់នីតិបុគ្គល ។ សម្រាប់គោលដៅនៃពន្ធនេះ នីតិបុគ្គលណាមួយទោះបីមិនមែនជាក្រុមហ៊ុនដើមទុនក្តី ត្រូវចាត់ទុកដូចជាក្រុមហ៊ុនដើមទុន ហើយបុគ្គលដែលមានចំណែកភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់នីតិបុគ្គល ឬក៏បុគ្គលអាចបានទទួលប្រាក់ចំណូល ឬប្រាក់ចំណេញក្នុងឋានៈជាអ្នកបានចូលរួមក្នុងនីតិបុគ្គលនោះ ត្រូវចាត់ទុកថាជាអ្នកចូលហ៊ុនរបស់នីតិបុគ្គលដែរ ។

១០- ពាក្យ "បុគ្គលទាក់ទិន" សំដៅដល់ :

ក- សមាជិកណាម្នាក់ក្នុងគ្រួសារអ្នកជាប់ពន្ធ

ខ- សហគ្រាសដែលគ្រប់គ្រងលើអ្នកជាប់ពន្ធ ឬសហគ្រាសត្រូវបានអ្នកជាប់ពន្ធគ្រប់គ្រង ឬក៏សហគ្រាសនោះនិងអ្នកជាប់ពន្ធស្ថិតនៅក្រោមការគ្រប់គ្រងរួមគ្នា ។ ពាក្យ "គ្រប់គ្រង" មានន័យថាមានកម្មសិទ្ធិចាប់ពី ៥១ ភាគរយឡើងទៅលើតម្លៃ ឬសិទ្ធិបោះឆ្នោតនៃភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់សហគ្រាស ។ ដើម្បីកំណត់ទំហំនៃការគ្រប់គ្រងរបស់អ្នកជាប់ពន្ធជារូបវន្តបុគ្គលណាម្នាក់ ត្រូវគិតបញ្ចូលទាំងអស់នូវកម្មសិទ្ធិលើភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់រូបវន្តបុគ្គលនោះ និងកម្មសិទ្ធិផ្ទាល់ ឬប្រយោលរបស់សហព័ទ្ធអ្នកជាប់ពន្ធ ។

១១- ពាក្យ "អ្នកវិនិយោគ" មានន័យថាបុគ្គលណាមួយដែលអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

១២- ពាក្យ "គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់" មានន័យថាគម្រោងវិនិយោគដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាទទួលស្គាល់ថាជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

### មាត្រា ៤ : របបកំណត់ពន្ធ

របបកំណត់ពន្ធមានដូចតទៅ :

១- ការកំណត់ពន្ធលើប្រាក់ចំណេញ ត្រូវអនុវត្តតាមរបបពិត របបបំព្រួញ និង របបម៉ៅការ ។

២- វិធាន និងនីតិវិធី ដើម្បីចាត់បញ្ចូលអ្នកជាប់ពន្ធឱ្យស្ថិតក្នុងរបបកំណត់ពន្ធណាមួយនៃរបបទាំង ៣ ខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ដោយផ្អែកលើទ្រង់ទ្រាយអាជីវកម្ម ប្រភេទសកម្មភាពអាជីវកម្ម និង កំរិតផលរបរ ។

## ផ្នែកទី ២
## ប្រាក់ចំណេញជាប់ពន្ធ និង អត្រាពន្ធ

### មាត្រា ៥ : ឆ្នាំជាប់ពន្ធ

ឆ្នាំជាប់ពន្ធត្រូវបានកំណត់ដូចខាងក្រោម :

១- ពន្ធលើប្រាក់ចំណេញអនុវត្តចំពោះរបបពិត ត្រូវគណនាចេញពីលទ្ធផលនៃតុល្យការសម្រេចបានក្នុងឆ្នាំសារពើពន្ធកន្លងទៅ ។

២- ប្រសិនជាពុំមានតុល្យការណាមួយបានបញ្ឈប់ក្នុងកំឡុងនៃឆ្នាំណាមួយទេនោះ ពន្ធដែលត្រូវបង់សម្រាប់ឆ្នាំជាបន្ទាប់ ត្រូវគិតយកលើប្រាក់ចំណេញក្នុងរយៈវេលាដែលកន្លងទៅ ចាប់តាំងពីថ្ងៃផុតរយៈពេលជាប់ពន្ធដែលកន្លងហួសទៅនោះ ។ ចំពោះសហគ្រាសថ្មីត្រូវគិតចាប់តាំងពីថ្ងៃដែលផ្តើមធ្វើប្រតិបត្តិការមកទល់នឹងថ្ងៃទី ៣១ ខែធ្នូ នៃឆ្នាំដែលត្រូវគិតពន្ធ ។

៣- កាលបើមានធ្វើតុល្យការជាច្រើនត១គ្នាក្នុងកំឡុងនៃឆ្នាំមួយដដែលនោះ លទ្ធផលនៃតុល្យការទាំងឡាយនេះ ត្រូវបូករួមគ្នា ធ្វើជាមូលដ្ឋាននៃពន្ធដែលត្រូវបង់ ។

៤- ពន្ធលើប្រាក់ចំណេញអនុវត្តចំពោះរបបបំព្រួញ និង របបម៉ៅការ ត្រូវគណនាតាមវិធីគណនេយ្យមូលដ្ឋានសាច់ប្រាក់ នៅក្នុងឆ្នាំប្រតិទិនកន្លងមក ។

៥- សេចក្តីណែនាំនានាស្តីអំពីការធ្វើរបាយការណ៍ ការដាក់លិខិតប្រកាសចុងក្រោយសម្រាប់សហគ្រាសដែលបញ្ឈប់ អាជីវកម្ម ឬរៀបចំឡើងវិញ ឬត្រូវបានលក់ ឬផ្ទេរក្នុងឆ្នាំប្រតិទិន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

### មាត្រា ៦ : វិធានគណនេយ្យ

វិធានគណនេយ្យត្រូវបានកំណត់ដូចខាងក្រោម :

១- ចំពោះអ្នកជាប់ពន្ធតាមរបបបំព្រួញដែលប្រើវិធីគណនេយ្យមូលដ្ឋានសាច់ប្រាក់ ប្រាក់ចំណូលត្រូវគិតបញ្ចូលនៅក្នុងឆ្នាំ ដែលបានទទួលជាក់ស្តែងនូវសាច់ប្រាក់ ឬទ្រព្យដទៃទៀត ទោះបីជាការទូទាត់បានធ្វើឡើងសម្រាប់ឆ្នាំផ្សេងទៀតក្តី ។ ឯចំណាយ ឬការកាត់កងនានា អាចផាត់ចេញនៅក្នុងឆ្នាំដែលចំណាយ ឬខ្ទង់ផ្សេងទៀតត្រូវបានទូទាត់សងជាក់ស្តែង លើកលែងតែចំណាយ ទូទាត់មុន និងទាយជ្ជទានឱ្យដល់វិលស់ ។

២- ចំពោះអ្នកជាប់ពន្ធតាមរបបពិតដែលប្រើវិធីគណនេយ្យតាមបង្គលគណនេយ្យទូទៅ ប្រាក់ចំណូលត្រូវគិតបញ្ចូលនៅក្នុងឆ្នាំដែលចំណូលនោះបានកើតឡើង ទោះបីប្រាក់ចំណូលនោះបានទូទាត់ ឬមិនទាន់ទូទាត់ក្តី ។ ការកាត់កងចំណាយណាមួយអាចធ្វើទៅបាន លុះណាតែហេតុការណ៍បញ្ជាក់នូវបន្ទុករបស់អ្នកជាប់ពន្ធបានកើតឡើង លទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចដែលជាប់ទាក់ទងដល់ខ្ទង់ចំណាយនោះបានកើតឡើង និងចំនួនទឹកប្រាក់ដែលជាបន្ទុករបស់អ្នកជាប់ពន្ធអាចបង្ហាញច្បាស់លាស់ ។

៣- ចំពោះអ្នកជាប់ពន្ធតាមរបបពិត ចំណាយនានាធ្វើឡើងចំពោះបុគ្គលទាក់ទិនដែលស្ថិតក្រោមរបបបំព្រួញ មិនអនុញ្ញាតឱ្យផាត់ចេញមុនការទូទាត់ជាក់ស្តែងឡើយ ។

៤- ចំពោះធនាគារ និង ស្ថាប័នសញ្ញ័យធនក្នុងស្រុក ត្រូវបានអនុញ្ញាតឱ្យធ្វើសំវិធានធនសម្រាប់ឥណទេយ្យជាប់សង្ស័យ ដើម្បីកំណត់ប្រាក់ចំណេញជាប់ពន្ធ ។ វិធាន និងនីតិវិធីស្តីពីការកាត់កងនានា ត្រូវកំណត់ដោយអនុក្រឹត្យ ។

## មាត្រា ៧ : ប្រាក់ចំណេញជាប់ពន្ធ

ប្រាក់ចំណេញជាប់ពន្ធ គឺជាប្រាក់ចំណេញសុទ្ធបានមកពីលទ្ធផលទាំងអស់នៃប្រតិបត្តិការគ្រប់ប្រភេទ ដែលសហគ្រាសសំរេចបាន រួមបញ្ចូលទាំងតម្លៃលើសបានមកពីការលក់ចំណែកនានានៃទ្រព្យសកម្មក្នុងពេលកំពុងប្រកបអាជីវកម្ម ឬនៅពេលបញ្ចប់អាជីវកម្ម ព្រមទាំងប្រាក់ចំណូលអំពីកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ឬវិនិយោគ ការប្រាក់ ថ្លៃឈ្នួល និង សួយសារផង ។

## មាត្រា ៨ : ការកំណត់ប្រាក់ចំណេញជាប់ពន្ធ

ប្រាក់ចំណេញជាប់ពន្ធ កើតចេញពីចំនួនលើសនៃផលដុលដែលសម្រេចបាន អាស្រ័យដោយមានការចំណាយ ដើម្បីនាំមកវិញ និងរក្សាទុកនូវចំណេញ ។

## *មាត្រា ៩ (ថ្មី) : ប្រាក់ចំណូលលើកលែងពន្ធ*

*ប្រាក់ចំណូលលើកលែងពន្ធត្រូវបានកំណត់ដូចតទៅ :*

*១- វៀរលែងតែមានបទប្បញ្ញត្តិផ្ទុយ និង លើកលែងតែប្រាក់ចំណូលដែលត្រូវជាប់ពន្ធតាមមាត្រា ២២ នៃច្បាប់នេះ ពន្ធលើប្រាក់ចំណេញមិនត្រូវអនុវត្តចំពោះ :*

*ក- ប្រាក់ចំណូលរបស់រាជរដ្ឋាភិបាល ឬប្រាក់ចំណូលស្ថាប័នរាជរដ្ឋាភិបាល*

*ខ- ប្រាក់ចំណូលរបស់អង្គការណាមួយដែល :*

*- ត្រូវបានរៀបចំឡើង និងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រឬអប់រំ*

*- គ្មានចំណែកណាមួយនៃទ្រព្យ ឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជន*

*គ- ប្រាក់ចំណូលរបស់អង្គការពលករ ឬសភាពាណិជ្ជកម្ម ឧស្សាហកម្ម ឬកសិកម្ម ក្នុងករណីដែលប្រាក់ចំណូលរបស់អង្គការទាំងនោះមិនត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជនរបស់អ្នកចូលហ៊ុន ឬរូបវន្តបុគ្គល*

*ឃ- ប្រាក់ចំណេញដែលបានមកពីការលក់ផលិតផលកសិកម្ម ដែលបុគ្គលមិនមែនជាអ្នកជាប់ពន្ធតាមរបបពិតផលិតបានដោយខ្លួនឯងទោះបីផលិតផលនោះមិនទាន់កែច្នៃ ឬកែច្នៃហើយក៏ដោយទៅតាមទម្លាប់នៃការងារកសិកម្ម។*

*ប្រតិបត្តិការតាមមធ្យោបាយឧស្សាហកម្ម រួមទាំងការកែច្នៃការរក្សាគុណភាព ការវេចខ្ចប់សម្រាប់លក់ ពុំត្រូវបានចាត់ទុកជាទម្លាប់នៃការងារកសិកម្មឡើយ*

*ង- ភាគលាភដែលបានទទួលមកពីសហគ្រាសនិវាសនជន ក្នុងករណីដែលប្រាក់ពន្ធត្រូវបង់តាមមាត្រា ២០ថ្មី មាត្រា ២៣ថ្មី និងមាត្រា ២៦ថ្មី នៃច្បាប់នេះត្រូវបានបង់រួចរាល់ ។*

*២- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកំណត់ដោយប្រកាសអំពីនីតិវិធីនៃការស្នើសុំលើកលែងពន្ធ ភាពបាត់បង់លក្ខណៈលើក លែងពន្ធ ការប្រកាសសារពើពន្ធ និង ការចុះបញ្ជី ។*

## មាត្រា ១០ : ការកំណត់ប្រាក់ចំណូលរបស់ក្រុមអាជីវកម្ម

ប្រាក់ចំណូលរបស់ក្រុមអាជីវកម្មត្រូវបានកំណត់ដូចតទៅ :

១- ចំពោះក្រុមអាជីវកម្ម ក្នុងការកំណត់ប្រាក់ចំណូលរបស់ខ្លួនសម្រាប់ឆ្នាំជាប់ពន្ធណាមួយ សមាជិកម្នាក់ៗត្រូវគិតដាច់ដោយឡែកពីគ្នានូវចំណែករៀងៗខ្លួននៅក្នុងខ្ទង់ចំណូល ចំណេញ ខាត ការកាត់កងឥណទាន និង វិភាគទានសប្បុរសធម៌ក្នុងឆ្នាំនោះ ។ សម្រាប់គោលដៅនេះ ខ្ទង់នីមួយៗត្រូវរក្សាចរិតលក្ខណៈនៅដដែល ហើយត្រូវចាត់ទុកថាបានបែងចែកនៅក្នុងឆ្នាំជាប់ពន្ធ ទោះបីជាមាន ឬគ្មានការបែងចែកជាក់ស្តែងក្តី ។ ការខាតបង់ដែលត្រូវយោងទៅឆ្នាំមុខ នឹងត្រូវកំណត់ឡើងក្រោយពីបានបែងចែកខ្ទង់នានាហើយ ។

២- វិធានសម្រាប់កំណត់ចំនួនទឹកប្រាក់ ដែលត្រូវបែងចែកការចាត់ចែងចំពោះវិភាគទានផ្សេងៗ និងការកែតម្រូវទៅលើចំណែកជាមូលដ្ឋានរបស់សមាជិកម្នាក់ៗនៃក្រុមអាជីវកម្មនៅក្នុងឆ្នាំជាប់ពន្ធណាមួយ ត្រូវកំណត់ដោយអនុក្រឹត្យ ។

# ផ្នែកទី ៣

# ការកាត់កង

## មាត្រា ១១ : ការកាត់កងដែលអនុញ្ញាត

ការកាត់កងដែលអនុញ្ញាតត្រូវបានកំណត់ដូចតទៅ :

១- វៀរលែងតែបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា១២ ដល់មាត្រា១៨ នៃច្បាប់នេះ ចំណាយដែលអនុញ្ញាតឱ្យកាត់កងរួមមានបន្ទុកដែលអ្នកជាប់ពន្ធបានទូទាត់ ឬត្រូវសងនៅក្នុងឆ្នាំជាប់ពន្ធដើម្បីប្រកបអាជីវកម្ម ។

២- ថ្លៃឈ្នួល ការប្រាក់ ការប៉ះប៉ូវ ការទូទាត់ ឬកម្រៃនានាដែលបានបើកឱ្យអ្នកទទួលខុសត្រូវ ឬអភិបាលរបស់សហគ្រាស សមាជិកភាគទុន ឬសមាជិករបស់ក្រុមអាជីវកម្ម សមាជិកនៃគ្រួសារអ្នកជាប់ពន្ធ ឬបុគ្គលទាក់ទិនផ្សេងទៀត ក្នុងករណីមានភស្តុតាងបញ្ជាក់ថា ការទូទាត់នោះបានអនុវត្តចំពោះការបំពេញសេវាជាក់ស្តែង ហើយក្នុងកំរិតសមហេតុសមផលផងដែរ ។

៣- ប្រាក់ដែលបានទូទាត់លើអាគារថ្មី ឬទ្រព្យសកម្មដទៃទៀត ការកែលំអជាប់លាប់ ឬការកែលំអនានា ក្នុងនោះមានទាំងការប្រាក់និងប្រាក់ពន្ធអាករដែលបានបង់ក្នុងរយៈពេលសាងសង់ ឬទិញចូលផង ។ ទឹកប្រាក់នេះត្រូវកត់ត្រាចូលក្នុងគណនីទ្រព្យសកម្មដែលពាក់ព័ន្ធ ហើយត្រូវកាត់កងតាមការរំលស់ដូចមានចែងក្នុងមាត្រា ១៣ នៃច្បាប់នេះ ។

## មាត្រា ១២ : ចំណាយការប្រាក់

ត្រូវបានអនុញ្ញាតឱ្យកាត់កងនូវចំណាយលើការប្រាក់ដែលអ្នកជាប់ពន្ធបានទូទាត់ ឬត្រូវសងនៅក្នុងឆ្នាំជាប់ពន្ធដើម្បីប្រកបអាជីវកម្ម ប៉ុន្តែមិនឱ្យលើសពីផលបូកនៃចំណូលការប្រាក់របស់អ្នកជាប់ពន្ធ និង ៥០ ភាគរយនៃប្រាក់ចំណូលសុទ្ធក្រៅពីការប្រាក់របស់អ្នកជាប់ ពន្ធនៅក្នុងឆ្នាំជាប់ពន្ធ ។

ចំណូលសុទ្ធក្រៅពីការប្រាក់ គឺជាប្រាក់ចំណូលដុលក្រៅពីចំណូលការប្រាក់ ដកខ្ទង់ចំណាយនានាដែលអនុញ្ញាតឱ្យផាត់ចេញ លើកលែងតែចំណាយការប្រាក់ ។

ចំណាយការប្រាក់ដែលសល់ពីការកាត់កងខាងលើ ត្រូវចាត់ទុកជាចំណាយការប្រាក់សម្រាប់ឆ្នាំជាប់ពន្ធបន្ទាប់ ហើយការផាត់ចេញត្រូវអនុវត្តតាមខ្លឹមសារនៃមាត្រានេះដូចគ្នា ។

## *មាត្រា ១៣ (ថ្មី) : រំលស់ទ្រព្យរូបី*

*១- លក្ខខ័ណ្ឌនៃរំលស់ធម្មតានៃទ្រព្យរូបីមានដូចតទៅ :*

*ក- ក្នុងការកំណត់ប្រាក់ចំណេញជាប់ពន្ធ ការកាត់កងសម្រាប់រំលស់ ត្រូវបានផ្តល់ឱ្យម្ចាស់ទ្រព្យរូបី ឬអ្នកជួលទ្រព្យរូបី ក្នុងករណីដែលអ្នកជួលទទួលខុសត្រូវលើហានិភ័យចំពោះការបាត់បង់ ឬការខូចខាតនៃទ្រព្យស្របតាមល័ក្ខខ័ណ្ឌដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ*

*ខ- ទ្រព្យរូបីដែលអាចរំលស់បាន គឺទ្រព្យរូបីប្រើប្រាស់ក្នុងអាជីវកម្មដែលតែងតែបាត់បង់តម្លៃដោយការប្រើប្រាស់ ឬភាពហួសសម័យ ។ ដីធ្លីមិនមែនជាទ្រព្យអាចរំលស់បានទេ*

*គ- ទ្រព្យរូបីទាំងអស់ ត្រូវបានបែងចែកជាថ្នាក់ដូចតទៅ :*

*ថ្នាក់ ១: អគារ និងរចនាសម្ព័ន្ធ ព្រមទាំងសមាសភាគរបស់វា ។ អត្រារំលស់ ៥ ភាគរយតាមវិធីរំលស់ស្មើភាគ*

*ថ្នាក់ ២: កុំព្យូទ័រ ប្រព័ន្ធពត៌មានអេឡិចត្រូនិច សហ្វវែរ និងបរិក្ខារទុកដាក់ទិន្នន័យ ។ អត្រារំលស់ ៥០ ភាគរយ តាមវិធីរំលស់ថយជាលំដាប់*

*ថ្នាក់ ៣: រថយន្ត រថយន្តដឹកទំនិញ គ្រឿងសង្ហារឹម និងបរិក្ខារការិយាល័យ ។ អត្រារំលស់ ២៥ ភាគរយ តាមវិធីរំលស់ថយជាលំដាប់*

*ថ្នាក់ ៤: ទ្រព្យរូបីឯទៀតទាំងអស់ អត្រារំលស់ ២០ ភាគរយ តាមវិធីរំលស់ថយជាលំដាប់ ។*

*ឃ- នីតិវិធីក្នុងការបង្កើតថ្នាក់នៃទ្រព្យ ការបញ្ចូលទ្រព្យថ្មីទៅក្នុងថ្នាក់ណាមួយ ការបញ្ចេញទ្រព្យពីថ្នាក់ណាមួយ និង ការចាត់ចែងចំពោះបញ្ហាជួសជុលព្រមទាំងចំណាយផ្សេងៗ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។*

*ង- វិធានអន្តរកាលសម្រាប់អ្នកជាប់ពន្ធក្នុងការប្រើវិធីរំលស់ ដូចមានចែងក្នុងកថាខ័ណ្ឌនេះ សម្រាប់ឆ្នាំសារពើពន្ធ ២០០២ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។*

*ច-	ការកាត់កងសម្រាប់រំលស់នៅក្នុងកថាខ័ណ្ឌនេះត្រូវគណនាដោយផ្អែក លើតម្លៃទ្រព្យក្រោយការកាត់កងទឹកប្រាក់រំលស់ពិសេសក្នុងកថាខ័ណ្ឌ ២ នៃមាត្រានេះ ។*

*២-	លក្ខខ័ណ្ឌនៃរំលស់ពិសេសនៃទ្រព្យរូបីមានដូចតទៅ :*

*ក-	រំលស់ពិសេស គឺជាចំនួនដែលអាចកាត់កងក្នុងឆ្នាំទី១នៃការទិញ ឬនាពេលក្រោយមកទៀតនៅឆ្នាំទី ១ នៃការដាក់ប្រើប្រាស់ទ្រព្យរូបី ដោយគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដូចមានចែងក្នុងវាក្យខណ្ឌ ខ នៃកថាខ័ណ្ឌនេះ ។ ចំនួនដែលអាចកាត់កងបាននេះស្មើនឹង ៤០ ភាគរយនៃតម្លៃមូលធននៃទ្រព្យរូបីថ្មី ឬទ្រព្យរូបីប្រើប្រាស់រួចដែលបានដាក់ប្រើប្រាស់ក្នុងផលិតកម្ម និងការកែច្នៃដែលនឹងកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ រំលស់ពិសេសនឹងកាត់បន្ថយនូវតម្លៃមូលធននៃទ្រព្យរូបីដែលអាចប្រើប្រាស់សម្រាប់ការរំលស់ធម្មតាតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ*

*ខ-	រំលស់ពិសេសនៃទ្រព្យរូបីនឹងត្រូវបានយកមកកាត់កង ដើម្បីកំណត់ប្រាក់ចំណូលជាប់ពន្ធរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ឆ្នាំសារពើពន្ធ ប្រសិនបើអ្នកវិនិយោគមិនជ្រើសយកការប្រើប្រាស់សិទ្ធិទទួលរយៈពេលលើកលែងពន្ធដូចមានចែងក្នុងកថាខ័ណ្ឌ ៤ នៃមាត្រា ២០ ថ្មីនៃច្បាប់នេះ*

*គ-	ទ្រព្យរូបីដែលបានទទួលនូវការកាត់កងរំលស់ពិសេស ត្រូវដាក់ប្រើប្រាស់យ៉ាងតិចបំផុត ៤ ឆ្នាំសារពើពន្ធបន្ទាប់ពីឆ្នាំសារពើពន្ធដែលរំលស់ពិសេសត្រូវបានកាត់កង ។ ប្រសិនបើទ្រព្យរូបីនោះត្រូវបានឈប់ប្រើប្រាស់មុនរយៈពេលនេះ អ្នកវិនិយោគត្រូវកត់ត្រាបញ្ចូលក្នុងប្រាក់ចំណេញជាប់ពន្ធវិញនូវចំនួនមួយស្មើនឹងទឹកប្រាក់រំលស់ពិសេសដែលបានកាត់កងកាត់ បន្ថយដោយចំនួនមួយស្មើនឹង ២ ភាគរយនៃទឹកប្រាក់រំលស់ពិសេសដែលបានកាត់កងសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលទ្រព្យនោះត្រូវបានដាក់ឱ្យប្រើប្រាស់ ។ ចំនួននេះនឹងមិនប៉ះពាល់តម្លៃពិតគណនេយ្យនៃទ្រព្យរូបីសម្រាប់ការកំណត់ផលចំណេញពីមូលធនជាប់ពន្ធតាមមាត្រា ៧ នៃច្បាប់នេះ ។*

## មាត្រា ១៤ : រំលស់ទ្រព្យអរូបី

ចំពោះទ្រព្យអរូបីដែលរួមមានប្រកាសនីយប័ត្រតក្កកម្ម សិទ្ធិចម្លង គំនូរប្លង់ គំរូ និងសិទ្ធិអាជីវកម្ម ដែលមានអាយុកាលមានកំណត់អត្រារំលស់លើទ្រព្យនីមួយៗ ត្រូវគណនាដោយផ្អែកលើអាយុកាលរបស់ទ្រព្យនោះ តាមវិធីរំលស់ស្មើភាគ ។ បើសិនជាអាយុកាលនៃទ្រព្យអរូបីមិនអាចកំណត់បាន រំលស់ប្រចាំឆ្នាំត្រូវអនុវត្តតាមអត្រា ១០ ភាគរយលើតម្លៃទ្រព្យអរូបី ។

## មាត្រា ១៥ : រំលស់ធនធានធម្មជាតិ

ការរំលស់ធនធានធម្មជាតិត្រូវបានកំណត់ដូចតទៅ :

១-	ទាយជ្ជទានឱ្យដល់ការរំលស់លើធនធានធម្មជាតិមានជាអាទិ៍ ប្រេងកាត និងឧស្ម័នធម្មជាតិ ត្រូវបានកំណត់ដូចតទៅ:

ក-	ចំណាយក្នុងការរុករក និងអភិវឌ្ឍន៍ ក្នុងនោះមានទាំងការប្រាក់ ដែលជាប់ទាក់ទងដល់ចំណាយនោះផង ត្រូវបូកបញ្ចូលទៅក្នុងគណនីទ្រព្យសកម្មនៃធនធាននោះ ។

ខ-	ទឹកប្រាក់រំលស់លើធនធានធម្មជាតិនីមួយៗ ដែលត្រូវផាត់ចេញនៅក្នុងឆ្នាំជាប់ពន្ធណាមួយ ត្រូវគណនាដោយយកសមតុល្យនៃគណនីធនធានធម្មជាតិទៅគុណនឹងផលចែករវាងបរិមាណដែលបានផលិតចេញអំពីធនធានធម្មជាតិនៅក្នុងឆ្នាំ និងចំនួនប៉ាន់ស្មាននៃផលិតផលសរុបដែលអាចទាញយកបានពីធនធាននោះ ។

២-	នីតិវិធីសម្រាប់កំណត់ចំនួនប៉ាន់ស្មាននៃផលិតផលសរុប ត្រូវកំណត់ដោយអនុក្រឹត្យ ។

## មាត្រា ១៦ : វិភាគទានសប្បុរសធម៌

ត្រូវបានអនុញ្ញាតឱ្យផាត់ចេញនូវវិភាគទានសប្បុរសធម៌ដែលបានបរិច្ចាគឱ្យអង្គការនានា ដូចមានចែងក្នុងមាត្រា ៩ នៃច្បាប់នេះ ប៉ុន្តែមិនត្រូវឱ្យលើសពី ៥ ភាគរយនៃប្រាក់ចំណេញជាប់ពន្ធមុនពេលកាត់កងវិភាគទានសប្បុរសធម៌ទាំងនោះឡើយ ។

លក្ខណៈវិនិច្ឆ័យនៃវិភាគទានសប្បុរសធម៌ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## មាត្រា ១៧ : ការយោងការខាតបង់ទៅមុខ

ក្នុងករណីដែលមានការខាតបង់នៅក្នុងឆ្នាំជាប់ពន្ធណាមួយ ការខាតបង់នោះត្រូវចាត់ជាបន្ទុកសម្រាប់ឆ្នាំជាប់ពន្ធបន្ទាប់ ហើយត្រូវកាត់ចេញពីប្រាក់ចំណេញសម្រេចបាននៅក្នុងឆ្នាំជាប់ពន្ធបន្ទាប់នោះ ។ បើប្រាក់ចំណេញនេះមិនគ្រប់គ្រាន់សម្រាប់ទូទាត់ជាស្ថាពរទេ ចំណែកនៃការខាតបង់ដែលនៅសេសសល់ ត្រូវយោងទៅឆ្នាំជាប់ពន្ធបន្តបន្ទាប់រហូតដល់ឆ្នាំជាប់ពន្ធទី៥ ។

នៅពេលណាដែលការខាតបង់មានលើសពីមួយឆ្នាំ មាត្រានេះត្រូវអនុវត្តចំពោះការខាតបង់ទាំងឡាយ តាមលំដាប់ដែលការខាតបង់បានកើតឡើង ។

## មាត្រា ១៨ : ការបែងចែកប្រាក់ចំណូល និង ការកាត់កងក្នុងចំណោមអ្នកជាប់ពន្ធ

ក្នុងករណីសហគ្រាសចាប់ពី២ ឡើងទៅ ទោះបីជាបានបង្កើត ឬរៀបចំឡើងនៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា ហើយដែលស្ថិតក្រោមកម្មសិទ្ធិរួមគ្នា ក្នុងករណីចាំបាច់រដ្ឋបាលសារពើពន្ធអាចធ្វើការបែងចែកប្រាក់ចំណូលដុល ប្រាក់ផាត់ចេញ ឬអត្ថប្រយោជន៍ផ្សេងៗក្នុងចំណោមសហគ្រាស និងម្ចាស់កម្មសិទ្ធិទាំងនោះ ដើម្បីទប់ស្កាត់ការចៀសវាង ឬគេចវេសពន្ធ ឬក៏ដើម្បីឆ្លុះបញ្ចាំងឱ្យបានច្បាស់លាស់នូវប្រាក់ចំណូលរបស់សហគ្រាស ឬរបស់ម្ចាស់កម្មសិទ្ធិ ។

សម្រាប់គោលដៅនៃមាត្រានេះ សហគ្រាសចាប់ពី ២ ឡើងទៅ ត្រូវស្ថិតក្រោមកម្មសិទ្ធិរួមគ្នា បើសិនជាមានបុគ្គលណាម្នាក់មានកម្មសិទ្ធិចាប់ពី ២០ ភាគរយឡើងទៅលើតម្លៃ ឬភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់សហគ្រាសនីមួយៗ ។

## មាត្រា ១៩ : ការកាត់កងដែលមិនអនុញ្ញាត

សម្រាប់បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណេញ ចំណាយដែលមិនអនុញ្ញាតឱ្យផាត់ចេញមាន :

១-	ចំណាយលើសកម្មភាពទាំងឡាយដែលជាទូទៅចាត់ទុកជាការកំសាន្ត ការសំរាកលំហែ ការទទួលភ្ញៀវ ឬការប្រើប្រាស់មធ្យោបាយណាមួយដែលជាប់ទាក់ទងនឹងសកម្មភាពទាំងនេះ ។

២-	ចំណាយសម្រាប់ការរស់នៅផ្ទាល់ខ្លួន ឬក្រុមគ្រួសារ លើកលែងតែអត្ថប្រយោជន៍បន្ថែមជាប្រាក់ ឬជាវត្ថុដែលប្រាក់ពន្ធត្រូវបានកាត់ទុកតាមបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស ។

៣-	ប្រាក់ពន្ធដែលបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណេញបានកំណត់ និង ពន្ធកាត់ទុកដែលបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្សបានកំណត់ ។

៤-	ការខាតបង់លើការលក់ ឬដោះដូរទ្រព្យសម្បត្តិ ទោះដោយផ្ទាល់ ឬប្រយោលក្តីរវាងបុគ្គលទាក់ទិន ។

៥-	ចំណាយនានា វៀរលែងតែចំណាយដែលកើតមានហើយ ហើយអ្នកជាប់ពន្ធអាចបញ្ជាក់ច្បាស់លាស់នូវចំនួនទឹកប្រាក់ និង គោលដៅអាជីវកម្ម ស្របទៅតាមបែបបទដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

## ផ្នែកទី ៤
## អត្រាពន្ធ និង ប្រាក់ពន្ធត្រូវបង់

### *មាត្រា ២០ (ថ្មី) : ការកំណត់ប្រាក់ពន្ធត្រូវបង់*

*អត្រាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំមានដូចតទៅ :*

*១-	២០ ភាគរយ ចំពោះប្រាក់ចំណេញដែលសម្រេចបានដោយនីតិបុគ្គល ។*

*២-	៣០ ភាគរយ ចំពោះប្រាក់ចំណេញដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាត និងឧស្ម័នធម្មជាតិ ឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិ រួមទាំងព្រៃឈើ រ៉ែ មាស ឬត្បូងថ្មមានតម្លៃនានា ។*

*៣-	៩ ភាគរយ ចំពោះប្រាក់ចំណេញរបស់គម្រោងវិនិយោគមានលក្ខណ:សម្បត្តិគ្រប់គ្រាន់ ដែលទទួលស្គាល់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាសម្រាប់រយ:ពេលអន្តរកាល ៥ ឆ្នាំ ដោយគិតចាប់ផ្តើមពីថ្ងៃប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។*

*៤-	០ ភាគរយ ចំពោះប្រាក់ចំណេញរបស់គម្រោងវិនិយោគមានលក្ខណ:សម្បត្តិគ្រប់គ្រាន់ដែលស្ថិតនៅក្នុងរយ:ពេលលើកលែងពន្ធដែលកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រោមច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ក្នុងករណីដែលគំរោងវិនិយោគមានលក្ខណ:សម្បត្តិគ្រប់គ្រាន់បានបំពេញតាមការតម្រូវរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង មាត្រា ១០៤ ថ្មីនៃច្បាប់នេះ ។*

*៥-	តាមតារាងអត្រាពន្ធកំណើនតាមថ្នាក់ខាងក្រោម ចំពោះប្រាក់ចំណេញដែលសម្រេចបានដោយរូបវន្តបុគ្គល និងចំណែកដែលត្រូវបែងចែកឱ្យសមាជិកម្នាក់ៗរបស់ក្រុមអាជីវកម្ម ដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គល :*

| ***ភាគនៃប្រាក់ចំណេញប្រចាំឆ្នាំដែលត្រូវជាប់ពន្ធ*** | | | | ***អត្រាពន្ធ*** |
|---|---|---|---|---|
| *ពី* | *០ ៛* | *ដល់* | *៦.០០០.០០០ ៛* | *០%* |
| *ពី* | *៦.០០០.០០១ ៛* | *ដល់* | *១៥.០០០.០០០ ៛* | *៥%* |
| *ពី* | *១៥.០០០.០០១ ៛* | *ដល់* | *១០២.០០០.០០០ ៛* | *១០%* |
| *ពី* | *១០២.០០០.០០១ ៛* | *ដល់* | *១៥០.០០០.០០០ ៛* | *១៥%* |
| *លើសពី* | | | *១៥០.០០០.០០០ ៛* | *២០%* |

*៦-	សិទ្ធិ បុព្វសិទ្ធ និងសិទ្ធិដទៃទៀត ដែលគម្រោងវិនិយោគមានលក្ខណ:សម្បត្តិគ្រប់គ្រាន់បានទទួលក្រោមច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា មិនអាចផ្ទេរឬប្រគល់ជូនទៅតតិយជនណាមួយឡើយ លើកលែងតែក្នុងករណីទិញ ឬរំលាយបញ្ចូលគ្នា ។*

## មាត្រា ២១ ៖ ពន្ធលើសហគ្រាសធានារ៉ាប់រង

ពន្ធលើសហគ្រាសធានារ៉ាប់រងត្រូវបានកំណត់ដូចតទៅ ៖

១- ចំពោះសហគ្រាសដែលមានសកម្មភាពជាសំខាន់ក្នុងការធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើជីវិត ទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗ ពន្ធលើប្រាក់ចំណេញត្រូវបានកំណត់ដូចតទៅ ៖

ក- ៥ ភាគរយនៃបុព្វលាភធានារ៉ាប់រងដុល ដែលទទួលបាននៅក្នុងឆ្នាំជាប់ពន្ធ ចំពោះការធានារ៉ាប់រង ឬធានារ៉ាប់រងបន្តនូវហានិភ័យនៅព្រះរាជាណាចក្រកម្ពុជា

ខ- តាមអត្រាកំណត់ក្នុងមាត្រា ២០ នៃច្បាប់នេះ ចំពោះសកម្មភាពដទៃទៀត ដែលមិនមែនជាការធានារ៉ាប់រង ឬធានារ៉ាប់រងបន្ត ។

២- វិធាន និងនីតិវិធីនៃការបង់ពន្ធលើប្រាក់ចំណេញរបស់សហគ្រាសធានារ៉ាប់រង ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## មាត្រា ២២ ៖ ពន្ធលើប្រាក់ចំណេញចំពោះអាជីវកម្មមិនទាក់ទិន

ចំពោះអាជីវកម្មមិនទាក់ទិន ពន្ធលើប្រាក់ចំណេញត្រូវបានកំណត់ដូចតទៅ ៖

១- ពន្ធលើប្រាក់ចំណេញត្រូវកំណត់ស្មើនឹង ២០ ភាគរយ លើចំនួនប្រាក់ចំណូលជាប់ពន្ធ នៃអាជីវកម្មមិនទាក់ទិនរបស់អង្គការនានា ដូចមានចែងក្នុងមាត្រា ៩ នៃច្បាប់នេះ ។

២- សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណេញ ពាក្យ "ប្រាក់ចំណូលជាប់ពន្ធនៃអាជីវកម្មមិនទាក់ទិន" គឺជាផលដករវាងប្រាក់ចំណូលដុលសម្រេចបានពីអាជីវកម្មមិនទាក់ទិន ដែលអង្គការណាមួយបានធ្វើជាទៀងទាត់ និង ការកាត់កងនានាទាក់ទិនផ្ទាល់ទៅនឹងការធ្វើអាជីវកម្មដែលបទប្បញ្ញត្តិស្ដីពីពន្ធលើប្រាក់ចំណេញបានអនុញ្ញាត ។

៣- ពាក្យ "អាជីវកម្មមិនទាក់ទិន" សំដៅដល់ អាជីវកម្មខាងពាណិជ្ជកម្ម ឬឧស្សាហកម្ម ឬអាជីវកម្មផ្សេងទៀតរបស់អង្គការដើម្បីស្វែងរកប្រាក់ចំណេញ ឬមូលនិធិ ហើយពុំមានទាក់ទិនជាសំខាន់ដល់គោលដៅ ឬមុខងារដែលជាមូលដ្ឋាននៃការលើកលែងពន្ធ ដូចមានចែងក្នុងមាត្រា ៩ នៃច្បាប់នេះ ។

## *មាត្រា ២៣ (ថ្មី) ៖ ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ*

*ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ ត្រូវបានកំណត់ដូចតទៅ ៖*

*១- ពន្ធលើប្រាក់ចំណេញបន្ថែមត្រូវបង់ក្នុងចំនួនស្មើនឹង ២០ ភាគរយនៃទឹកប្រាក់ត្រូវបែងចែកចំពោះ ៖*

*ក- ការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធលើប្រាក់ចំណេញ ប្រសិនបើសហគ្រាសធ្វើការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំដែលបានបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ០ភាគរយ ដូចមានចែងក្នុងកថាខ័ណ្ឌ ៤ នៃមាត្រា ២០ ថ្មីនៃច្បាប់នេះ និង*

*ខ- ការបែងចែកដទៃទៀត វៀរលែងតែការបែងចែកដែលបានកំណត់ក្នុងកថាខ័ណ្ឌ ២ និងកថាខ័ណ្ឌ ៣ នៃមាត្រានេះ និង ការបង់សងវិញនូវមូលធន ។*

*២- ពន្ធលើប្រាក់ចំណេញបន្ថែមត្រូវបង់ក្នុងចំនួនស្មើនឹង ១១ ភាគ ៨១ នៃទឹកប្រាក់ត្រូវបែងចែកចំពោះការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធលើប្រាក់ចំណេញ ប្រសិនបើសហគ្រាសធ្វើការបែងចែកប្រាក់*

ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំដែលបានបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ៩ ភាគរយ តាមកថាខ័ណ្ឌ ៣ នៃមាត្រា២០ ថ្មីនៃច្បាប់នេះ ។

៣- ពន្ធលើប្រាក់ចំណេញបន្ថែមមិនត្រូវអនុវត្តទេ ចំពោះការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធលើប្រាក់ចំណេញ ប្រសិនបើសហគ្រាសធ្វើការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំដែលបានបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ២០ ភាគរយ តាមកថាខ័ណ្ឌ ១ នៃមាត្រា ២០ថ្មី ឬអត្រា ៣០ ភាគរយ តាមកថាខ័ណ្ឌ ២ នៃមាត្រា ២០ថ្មី នៃច្បាប់នេះ ។

៤- ប្រសិនបើសហគ្រាសណាមួយបានទទួលភាគលាភបានបង់ពន្ធតាមកថាខ័ណ្ឌ ១ កថាខ័ណ្ឌ ២ និង កថាខ័ណ្ឌ ៣ នៃមាត្រានេះ ពីសហគ្រាសមួយទៀត ត្រូវកត់ត្រាចំនួនប្រាក់ភាគលាភនោះទៅក្នុងគណនីភាគលាភរបស់ខ្លួន។ ពេលសហគ្រាសនោះបែងចែកភាគលាភជាបន្តទៀតទៅអ្នកចូលហ៊ុនរបស់ខ្លួន ទឹកប្រាក់បែងចែកដែលត្រូវដកចេញពីគណនីភាគលាភ មិនត្រូវជាប់ពន្ធលើប្រាក់ចំណេញបន្ថែមដូចក្នុងកថាខ័ណ្ឌ ១ កថាខ័ណ្ឌ ២ និង កថាខ័ណ្ឌ ៣ នៃមាត្រានេះទេ ។

៥- សម្រាប់គោលដៅនៃមាត្រានេះ ការបែងចែកណាមួយនៃប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធលើប្រាក់ចំណេញ ត្រូវអនុវត្តតាមលំដាប់ដូចខាងក្រោម :

ក- ដំបូង យកចេញពីប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធលើប្រាក់ចំណេញដែលបានបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ២០ ភាគរយ តាមកថាខ័ណ្ឌ ១ នៃ មាត្រា ២០ ថ្មីនៃច្បាប់នេះ ឬអត្រា ៣០ ភាគរយ តាមកថាខ័ណ្ឌ ២ នៃមាត្រា ២០ ថ្មីនៃច្បាប់នេះ

ខ- បន្ទាប់មក យកចេញពីប្រាក់ចំណេញរក្សាទុកឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធលើប្រាក់ចំណេញដែលបានបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ៩ ភាគរយ តាមកថាខ័ណ្ឌ ៣ នៃមាត្រា ២០ ថ្មីនៃច្បាប់នេះ

គ- បន្ទាប់មកទៀត យកចេញពីប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធលើប្រាក់ចំណេញដែលបានបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ០ ភាគរយ តាមកថាខ័ណ្ឌ៤ នៃមាត្រា២០ថ្មី នៃច្បាប់នេះ ។

## ផ្នែកទី ៥
## ពន្ធដទៃទៀត

### មាត្រា ២៤ (ថ្មី) : ពន្ធអប្បបរមា

ពន្ធអប្បបរមាត្រូវបានកំណត់លើអ្នកជាប់ពន្ធតាមរបបពិត ។ ពន្ធអប្បបរមា ជាពន្ធមួយដាច់ដោយឡែក និងផ្សេងពីពន្ធលើប្រាក់ចំណេញ ។ ពន្ធនេះត្រូវបង់ដោយអ្នកជាប់ពន្ធតាមរបបពិត លើកលែងតែគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។ ពន្ធអប្បបរមាត្រូវកំណត់តាមអត្រា ១ ភាគរយលើផលរបរប្រចាំឆ្នាំ រួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម ហើយត្រូវបង់នៅពេលទូទាត់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ។

ពន្ធអប្បបរមាអាចត្រូវបានកាត់បន្ថយដោយពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ដែលបានបង់ជាក់ស្តែងតាមវិធានដែលមានចែងក្នុងមាត្រា ៣៧ថ្មី មាត្រា ៣៨ និង មាត្រា ៣៩ នៃច្បាប់នេះ ។

## ផ្នែកទី ៦
## ពន្ធកាត់ទុក និង ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ

### មាត្រា ២៥ (ថ្មី) : ពន្ធកាត់ទុកទូទៅ

ពន្ធកាត់ទុកទូទៅត្រូវបានកំណត់ដូចតទៅ :

១-	អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ដែលបានធ្វើការទូទាត់ជាសាច់ប្រាក់ ឬជាវត្ថុ ឱ្យដល់អ្នកជាប់ពន្ធនិវាសនជន ត្រូវកាត់ទុក និងបង់ប្រាក់ពន្ធទៅតាមអត្រាកំណត់ដូចខាងក្រោម លើចំនួនទូទាត់មុនការកាត់ទុកប្រាក់ពន្ធ ៖

ក-	អត្រា ១៥ ភាគរយ ចំពោះ ៖

- ប្រាក់ចំណូលដែលរូបវន្តបុគ្គលបានទទួលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ ឬសេវាប្រហាក់ប្រហែល

- សួយសារចំពោះទ្រព្យអរូបី និងភាគកម្មក្នុងធនធានរ៉ែ ហើយនិងការប្រាក់ដែលអ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្មដែលមិនមែនជាធនាគារឬស្ថាប័នសញ្ជ័យធនក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន

ខ-	អត្រា ១០ ភាគរយ ចំពោះប្រាក់ចំណូលពីការឱ្យជួលចលន ឬអចលនទ្រព្យ

គ-	អត្រា ៦ ភាគរយ ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុក បង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជនដែលមានគណនីបញ្ញើមានកាលកំណត់

ឃ-	អត្រា ៤ ភាគរយ ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុក បង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន ដែលមានគណនីសន្សំគ្មានកាលកំណត់ ។

២-	ការកាត់ទុកក្នុងមាត្រានេះ មិនត្រូវអនុវត្តទេចំពោះការប្រាក់ដែលបង់ទៅឱ្យធនាគារ និងស្ថាប័នសញ្ជ័យធនក្នុងស្រុក និង ការទូទាត់ចំពោះប្រាក់ចំណូល លើកលែងពន្ធដូចមានចែងក្នុងមាត្រា ៩ ថ្មី នៃច្បាប់នេះ ។

## មាត្រា ២៦ (ថ្មី) ៖ ពន្ធកាត់ទុកលើការទូទាត់ប្រាក់ឱ្យដល់បុគ្គលអនិវាសនជន

អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ដែលបានទូទាត់ប្រាក់ចំណូលខាងក្រោមនេះ ឱ្យទៅអ្នកជាប់ពន្ធអនិវាសនជន ត្រូវកាត់ទុក និងបង់នូវប្រាក់ពន្ធចំនួន ១៤ ភាគរយ នៃទឹកប្រាក់ត្រូវបើក ៖

ក-	ការប្រាក់

ខ-	សួយសារ ថ្លៃឈ្នួល និង ប្រាក់ចំណូលផ្សេងៗទាក់ទិននឹងការប្រើប្រាស់ទ្រព្យសម្បត្តិ

គ-	ការទូទាត់ចំពោះសេវាគ្រប់គ្រង និងសេវាបច្ចេកទេសនានា ដែលនឹងត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ឃ-	ភាគលាភ ។

## មាត្រា ២៧ (ថ្មី) ៖ ពន្ធកាត់ទុកចុងក្រោយ

ពន្ធកាត់ទុកលើការទូទាត់ឱ្យដល់អ្នកជាប់ពន្ធនិវាសនជនតាមមាត្រា ២៥ ថ្មីនៃច្បាប់នេះ និងពន្ធកាត់ទុកលើការទូទាត់ឱ្យដល់អ្នកជាប់ពន្ធអនិវាសនជនតាមមាត្រា ២៦ ថ្មីនៃច្បាប់នេះ ត្រូវចាត់ទុកថាជាពន្ធចុងក្រោយសម្រាប់អ្នកទទួលការទូទាត់ដែលមានបញ្ជាក់ក្នុងមាត្រាទាំង ២ ខាងលើនេះ ។

## មាត្រា ២៨ (ថ្មី) ៖ ប្រាក់រំដោះនៃពន្ធលើប្រាក់ចំណេញ

សហគ្រាសដែលជាប់ពន្ធលើប្រាក់ចំណេញតាមរបបពិត រួមទាំងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ៩ ភាគរយ មានកាតព្វកិច្ចបង់ប្រាក់រំដោះប្រចាំខែ សម្រាប់ពន្ធលើប្រាក់ចំណេញ តាមអត្រា ១ ភាគរយ នៃផលរបរគិតរួមបញ្ចូលទាំងពន្ធអាករទាំងអស់ វៀរលែងតែអាករលើតម្លៃបន្ថែមដែលសម្រេចបានក្នុងខែ

*មុន។ ផលរបររបស់គម្រោង វិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងរយៈពេលលើកលែងពន្ធដែលកំណត់ដោយច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានលើកលែងពីការបង់ប្រាក់រំដោះនេះ ។ ប្រាក់រំដោះនឹងត្រូវបានយកមកកាត់កងពីពន្ធលើប្រាក់ចំណេញ នៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ ។*

# ផ្នែកទី ៧

# កាតព្វកិច្ចរបស់អ្នកជាប់ពន្ធ

## មាត្រា ២៩ : កាតព្វកិច្ចទូទៅសំរាប់អ្នកជាប់ពន្ធតាមរបបពិត និង របបបំព្រួញ

អ្នកជាប់ពន្ធតាមរបបពិត និង របបបំព្រួញមានកាតព្វកិច្ច :

១- អ្នកជាប់ពន្ធលើប្រាក់ចំណេញ ដែលត្រូវបង់ពន្ធតាមរបបពិត ឬរបបបំព្រួញ ត្រូវផ្ញើជូនជារៀងរាល់ឆ្នាំទៅរដ្ឋបាលសារពើពន្ធនូវលិខិតប្រកាសប្រាក់ចំណេញដែលខ្លួនសម្រេចបានក្នុងឆ្នាំសារពើពន្ធមុន ។ លិខិតប្រកាសនោះត្រូវចុះបញ្ជីជាដាច់ខាតក្នុងរយៈវេលា ៣ ខែ ក្រោយពីដំណាច់ឆ្នាំសារពើពន្ធ ។

២- អ្នកជាប់ពន្ធតាមរបបពិតត្រូវដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធ ដោយភ្ជាប់ជាមួយនូវ :

ក- តារាងតុល្យការ

ខ- គណនីលទ្ធផល

គ- តារាងពត៌មានបន្ថែម ។

៣- អ្នកជាប់ពន្ធតាមរបបបំព្រួញ ត្រូវដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធ ដោយភ្ជាប់ជាមួយនូវឯកសារនានាតាមគំរូដែលរដ្ឋបាលសារពើពន្ធបានផ្តល់ជូន ។

៤- ចំពោះសហគ្រាសដែលមានការខាតបង់ ក៏ត្រូវដាក់លិខិតប្រកាសសារពើពន្ធតាមបែបបទ និងក្នុងរយៈវេលាដូចគ្នាដែរ ។

## មាត្រា ៣០ : កាតព្វកិច្ចសំរាប់អ្នកជាប់ពន្ធតាមរបបម៉ៅការ

អ្នកជាប់ពន្ធតាមរបបម៉ៅការមានកាតព្វកិច្ច :

១- អ្នកជាប់ពន្ធតាមរបបម៉ៅការ ត្រូវដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធជារៀងរាល់ឆ្នាំ យ៉ាងយឺតបំផុតនៅថ្ងៃទី ៣១ តុលា តាមគំរូដែលរដ្ឋបាលសារពើពន្ធបានផ្តល់ជូន ។

២- ចំនួនប្រាក់ចំណេញម៉ៅការត្រូវកំណត់ដោយរដ្ឋបាលសារពើពន្ធ បន្ទាប់ពីបានត្រួតពិនិត្យ និង ពិភាក្សាជាមួយអ្នកជាប់ពន្ធ ឬអ្នកតំណាង ។ ប្រាក់ចំណេញម៉ៅការនេះ ត្រូវគិតតាមអត្រាចំណេញទៅតាមប្រភេទ និង តាមមុខរបរអាជីវកម្មដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

៣- កំរិតពន្ធលើប្រាក់ចំណេញម៉ៅការត្រូវកំណត់ជាស្តេរវត្តសម្រាប់រយៈពេលមួយមានកំណត់ ៣ខែ ៦ខែ ឬ ១ឆ្នាំ ។

៤- អ្នកជាប់ពន្ធលើប្រាក់ចំណេញតាមរបបម៉ៅការត្រូវបង់ពន្ធនេះជារៀងរាល់ខែ តាមពេលវេលាដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ

### *មាត្រា ៣១ (ថ្មី) : កាតព្វកិច្ចរបស់ភ្នាក់ងារកាត់ទុក*

*១- បុគ្គល ឬអ្នកទទួលភារៈបើកប្រាក់ដែលកាត់ទុកប្រាក់ពន្ធតាមមាត្រា ២៥ថ្មី និងមាត្រា ២៦ថ្មី នៃច្បាប់នេះ ត្រូវដាក់លិខិតប្រកាសសារពើពន្ធ និង បង់ប្រាក់ពន្ធដែលបានកាត់ទុកជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃខែបន្ទាប់ពីខែដែលបានធ្វើការទូទាត់ ។*

*២- សហគ្រាសត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភដូចមានចែងក្នុងមាត្រា២៣ថ្មីនៃច្បាប់នេះ និង បង់ពន្ធជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃខែបន្ទាប់ពីខែដែលការបែងចែកត្រូវបានទូទាត់ ។*

### មាត្រា ៣២ : កាតព្វកិច្ចរបស់បុគ្គលដែលត្រូវបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ

បុគ្គលដែលមានកាតព្វកិច្ចបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ត្រូវដាក់លិខិតប្រកាសសារពើពន្ធ និង បង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញជូនរដ្ឋបាលសារពើពន្ធ ទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃខែបន្ទាប់ពីខែ ដែលបំណុលបានកើតឡើង ។

## ផ្នែកទី ៨
## ប្រភពប្រាក់ចំណូល

### *មាត្រា ៣៣ (ថ្មី) : ប្រាក់ចំណូលប្រភពកម្ពុជា*

*ដោយមិនមានការកម្រិតត្រឹមតែប្រាក់ចំណូលដូចខាងក្រោមនេះ ប្រាក់ចំណូលប្រភពកម្ពុជារួមមាន :*

*១- ការប្រាក់ដែលបង់ដោយសហគ្រាសនិវាសនជន ក្រុមអាជីវកម្មនិវាសនជន ឬស្ថាប័នរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។*

*២- ភាគលាភដែលបានបែងចែកដោយសហគ្រាសនិវាសនជន ។*

*៣- ប្រាក់ចំណូលពីសេវាកម្មដែលបានបំពេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។*

*៤- ប្រាក់ចំណូលពីការគ្រប់គ្រង និង សេវាបច្ចេកទេស ដែលបានទូទាត់ដោយបុគ្គលនិវាសនជន ។*

*៥- ប្រាក់ចំណូលដែលបានមកពីចលនៈ ឬអចលនទ្រព្យ ក្នុងករណីដែលទ្រព្យនោះស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។*

*៦- ប្រាក់សួយសារដែលបានមកពីការប្រើប្រាស់ ឬសិទ្ធិប្រើប្រាស់ទ្រព្យអរូបីដែលបានទូទាត់ដោយបុគ្គលនិវាសនជន ឬបុគ្គលអនិវាសនជនតាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ដែលតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។*

*៧- ផលចំណេញពីការលក់អចលនទ្រព្យដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬផលចំណេញពីការផ្ទេរផលប្រយោជន៍ណាមួយនៃអចលនទ្រព្យដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។*

*៨-　　បុព្វលាភធានារ៉ាប់រង ឬធានារ៉ាប់រងបន្ត ចំពោះហានិភ័យនៅព្រះរាជាណាចក្រកម្ពុជា ។*

*៩-　　ផលចំណេញពីការលក់ចលនទ្រព្យ ដែលជាចំណែកនៃទ្រព្យអាជីវកម្មរបស់គ្រឹះស្ថានអចិន្ត្រៃយ៍របស់អ្នកជាប់ពន្ធអនិវាសនជន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។*

*១០-　　ប្រាក់ចំណូលពីសកម្មភាពអាជីវកម្មរបស់បុគ្គលអនិវាសនជន តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។*

### *មាត្រា ៣៤ (ថ្មី) : ប្រាក់ចំណូលបរទេស*

*រាល់ប្រាក់ចំណូលដែលមិនមែនជាប្រាក់ចំណូលប្រភពកម្ពុជាដូចក្នុងមាត្រា៣៣ ថ្មីនៃច្បាប់នេះ ត្រូវចាត់ទុកថាជាប្រាក់ចំណូលប្រភពបរទេស ។*

### មាត្រា ៣៥ : ការកំណត់ប្រភព

ក្នុងករណីដែលគ្មានពត៏មានគ្រប់គ្រាន់ដើម្បីកំណត់ប្រភពចំណូល ឬបើសិនជាវិធាននានាដែលមានរួចមកហើយពុំអាចឆ្លុះបញ្ចាំងឱ្យបានច្បាស់លាស់នូវប្រាក់ចំណូលពីប្រភពណាមួយបានទេនោះ រដ្ឋបាលសារពើពន្ធជាអ្នកកំណត់ប្រភពនៃប្រាក់ចំណូលនោះ ។

## ផ្នែកទី ៩
## គណនាប្រាក់ពន្ធប្រចាំឆ្នាំត្រូវបង់

### មាត្រា ៣៦ : ឥណទានពន្ធបរទេស

អ្នកជាប់ពន្ធនិវាសនជនដែលបានទទួលប្រាក់ចំណូលប្រភពបរទេស និងបានបង់ពន្ធតាមច្បាប់ពន្ធដារបរទេស ត្រូវបានទទួលនូវឥណទានពន្ធសម្រាប់កាត់កងពីប្រាក់ពន្ធលើប្រាក់ចំណេញដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែលុះណាតែមានការបង្ហាញឯកសារបញ្ជាក់អំពីការបង់ពន្ធនៅបរទេសនោះ ។

ដើម្បីគណនាប្រាក់ពន្ធដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជាមុនពេលកាត់ឥណទានពន្ធនេះ ត្រូវយកចំនួនសរុបនៃប្រាក់ចំណូលដែលបានទទួលអំពីប្រភពកម្ពុជា និងប្រភពបរទេសមកគិត ។

ឥណទានពន្ធត្រូវបានកំណត់ដាច់ដោយឡែកពីគ្នា សម្រាប់ប្រាក់ពន្ធដែលបានបង់ដោយនិវាសនជនកម្ពុជានៅប្រទេសក្រៅនីមួយៗ ។ ប៉ុន្តែឥណទានពន្ធដែលអនុញ្ញាតឱ្យកាត់កងសម្រាប់ឆ្នាំជាប់ពន្ធ គឺចំនួនដែលទាបជាងគេក្នុងចំណោមៈ

ក-　　ប្រាក់ពន្ធដែលបានបង់ជាក់ស្តែងនៅប្រទេសក្រៅណាមួយ

ខ-　　ចំនួនដែលបានមកពីការយកប្រាក់ពន្ធលើប្រាក់ចំណេញសរុបពីគ្រប់ប្រភព សម្រាប់រយៈពេលជាមួយគ្នា ដែលគណនាតាមអត្រាពន្ធក្នុងមាត្រា២០ នៃច្បាប់នេះ ទៅគុណនឹងផលចែករវាងប្រាក់ចំណូលដែលបានទទួលនៅប្រទេសក្រៅនោះ និងប្រាក់ចំណូលសរុបពីគ្រប់ប្រភព ។

ឥណទានពន្ធបរទេសអាចផ្តល់ឱ្យបាន លុះណាតែអ្នកជាប់ពន្ធនិវាសនជនបានបំពេញបែបបទ ព្រមទាំងផ្តល់ឯកសារនានាកំណត់ដោយរដ្ឋបាលសារពើពន្ធ ជាពិសេសសេចក្តីបញ្ជាក់របស់អ្នកទូទាត់ប្រាក់ពន្ធនៅបរទេស និងរដ្ឋបាលសារពើពន្ធបរទេសនោះ ។

ក្នុងករណីឥណទានពន្ធមានចំនួនលើសពីបំណុលពន្ធ ចំនួនលើសនោះអាចយោងទៅប្រើនៅឆ្នាំបន្តបន្ទាប់រហូតដល់ឆ្នាំទី៥ គិតពីឆ្នាំបន្ទាប់នៃឆ្នាំដែលឥណទានពន្ធនោះបានកើតឡើង ។ បើសិនជាមានឥណទានពន្ធច្រើនឆ្នាំ ត្រូវយកឥណទានពន្ធទាំងនោះមកប្រើ តាមលំដាប់ឆ្នាំដែលបានកើតឡើង ។

## *មាត្រា ៣៧ (ថ្មី) : ការគណនាបំណុលពន្ធលើប្រាក់ចំណេញ*

*ការគណនាបំណុលពន្ធលើប្រាក់ចំណេញត្រូវបានកំណត់ដូចតទៅ :*

*១- គណនាបំណុលពន្ធសរុបតាមមាត្រា ២០ ថ្មី និង មាត្រា ២៣ ថ្មីនៃច្បាប់នេះ ។*

*២- ដកឥណទានពន្ធបរទេសតាមមាត្រា៣៦ នៃច្បាប់នេះ ប៉ុន្តែមិនឱ្យលើសបំណុលពន្ធក្នុងកថាខ័ណ្ឌ១ នៃមាត្រានេះទេ ។*

## មាត្រា ៣៨ : គណនាប្រាក់ពន្ធត្រូវបង់ ឬឥណទានពន្ធសំរាប់ឆ្នាំជាប់ពន្ធ

ការគណនាប្រាក់ពន្ធត្រូវបង់ ឬឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធត្រូវបានកំណត់ដូចតទៅ :

១- ក្នុងករណីដែលលទ្ធផលគណនាតាមមាត្រា ៣៧ នៃច្បាប់នេះ មានចំនួនច្រើនជាងផលបូកនៃចំនួនប្រាក់ពន្ធដែលបានកាត់ទុកក្នុងនាមអ្នកជាប់ពន្ធ តាមមាត្រា ២៥ នៃច្បាប់នេះ និងចំនួនប្រាក់រំដោះពន្ធលើប្រាក់ចំណេញដែលអ្នកជាប់ពន្ធបានបង់ប្រចាំឆ្នាំ តាមមាត្រា ២៨ នៃច្បាប់នេះ អ្នកជាប់ពន្ធត្រូវបង់បន្ថែមចំនួនដែលលំអៀងនោះជូនរដ្ឋបាលសារពើពន្ធ ។

២- ប្រសិនបើលទ្ធផលគណនាតាមមាត្រា ៣៧ នៃច្បាប់នេះ មានចំនួនតិចជាងផលបូកនៃចំនួនប្រាក់ពន្ធដែលបានកាត់ទុកក្នុងនាមអ្នកជាប់ពន្ធតាមមាត្រា ២៥ នៃច្បាប់នេះ និងចំនួនប្រាក់រំដោះពន្ធលើប្រាក់ចំណេញដែលអ្នកជាប់ពន្ធបានបង់សម្រាប់ឆ្នាំជាប់ពន្ធ តាមមាត្រា ២៨ នៃច្បាប់នេះ ក្រោយពីបានគិតបំណុលពន្ធអប្បបរមារួចហើយ អ្នកជាប់ពន្ធអាចសុំបង្វិលសងវិញនូវចំនួនដែលលំអៀង ឬយោងទៅប្រើជាប្រាក់រំដោះសម្រាប់ឆ្នាំបន្ទាប់ ។

៣- មុននឹងធ្វើការទូទាត់ប្រាក់ពន្ធតាមកថាខ័ណ្ឌ ១ ឬក៏សុំបង្វិលសងតាមកថាខ័ណ្ឌ ២ អ្នកជាប់ពន្ធត្រូវតែកំណត់ជាមុននូវបំណុលពន្ធអប្បបរមា តាមនីតិវិធីដែលមានចែងក្នុងមាត្រា ៣៩ នៃច្បាប់នេះ ។

## មាត្រា ៣៩ : គណនាប្រាក់ពន្ធអប្បបរមា ប្រាក់ពន្ធត្រូវបង់ ឬឥណទានសំរាប់ឆ្នាំជាប់ពន្ធ

ការគណនាប្រាក់ពន្ធអប្បបរមា ប្រាក់ពន្ធត្រូវបង់ ឬឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធត្រូវបានកំណត់ដូចតទៅ:

១- អ្នកជាប់ពន្ធត្រូវបង់ពន្ធអប្បបរមា នៅពេលធ្វើការទូទាត់ប្រាក់ពន្ធលើប្រាក់ចំណេញ ។ ពន្ធអប្បបរមាត្រូវបង់ អាចត្រូវបានកាត់បន្ថយដោយបំណុលពន្ធលើប្រាក់ចំណេញក្នុងឆ្នាំជាប់ពន្ធជាមួយគ្នាតាមមាត្រា ២០ នៃច្បាប់នេះ។

២- ក្នុងករណីបំណុលពន្ធលើប្រាក់ចំណេញលើសពីបំណុលពន្ធអប្បបរមា :

ក- អ្នកជាប់ពន្ធត្រូវទូទាត់ប្រាក់ពន្ធត្រូវបង់តាមមាត្រា៣៧ នៃច្បាប់នេះ នៅពេលដាក់លិខិតប្រកាសសារពើពន្ធ

ខ- ប្រសិនបើចំនួនទឹកប្រាក់ដែលបានកាត់ទុកតាមមាត្រា ២៥ និង មាត្រា ២៨ នៃច្បាប់នេះ មានចំនួនលើសពីបំណុលពន្ធអប្បបរមា អ្នកជាប់ពន្ធអាចស្នើសុំជាឥណទានពន្ធបាន

គ- ក្នុងករណីដូចក្នុងកថាខ័ណ្ឌ ២ នៃមាត្រានេះ អ្នកជាប់ពន្ធមិនជាប់ពន្ធអប្បបរមាទេ ។

៣- ប្រសិនបើបំណុលពន្ធលើប្រាក់ចំណេញ តិចជាងបំណុលពន្ធអប្បបរមា :

ក- ឥណទានពន្ធរបស់អ្នកជាប់ពន្ធតាមកថាខ័ណ្ឌ ២ មាត្រា ៣៨ នៃច្បាប់នេះ ត្រូវបានកាត់បន្ថយដោយទឹកប្រាក់លំអៀងខាងលើ

ខ- ឥណទានពន្ធដែលបានកាត់បន្ថយចុះក្នុងការអនុវត្តតាមវាក្យខ័ណ្ឌ ក នៃកថាខ័ណ្ឌនេះ ត្រូវចាត់ជាការទូទាត់ប្រាក់ពន្ធអប្បបរមាសម្រាប់ឆ្នាំជាប់ពន្ធ ។

# ជំពូកទី ២
# បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស

## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

### មាត្រា ៤០ : បន្ទុកពន្ធ

បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៤ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ដើម្បីជាគុណប្រយោជន៍ដល់ថវិការដ្ឋ ។

### មាត្រា ៤១ : កម្មវត្ថុនៃពន្ធ

ពន្ធលើប្រាក់បៀវត្ស គឺជាពន្ធប្រចាំខែកំណត់លើប្រាក់បៀវត្សដែលបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបំរើការងារ ។

រូបវន្តបុគ្គលនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជា និង ប្រាក់បៀវត្សប្រភពបរទេស ។

រូបវន្តបុគ្គលអនិវាសនជន ត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជា ។

### *មាត្រា ៤២ (ថ្មី) : និយមន័យ*

*សម្រាប់គោលដៅនៃបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស :*

*១- ពាក្យ "និវាសនជន" ក្នុងករណីដែលប្រើចំពោះនិយោជិតអ្នកជាប់ពន្ធ ឬរូបវន្តបុគ្គល មានន័យថាដែលមាននិវាសនដ្ឋាន ឬមានកន្លែងស្នាក់នៅជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី ១៨២ ថ្ងៃនៅក្នុងរយៈពេល ១២ ខែណាមួយដែលបានបញ្ចប់ក្នុងឆ្នាំសារពើពន្ធចរន្ត ។*

២- ពាក្យ "អនិវាសនជន" មានន័យថា បុគ្គលណាមួយដែលមិនមែនជានិវាសនជន តាមកថាខ័ណ្ឌ ១ នៃមាត្រានេះ និង ទទួលប្រាក់បៀវត្សប្រភពកម្ពុជា ។

៣- វៀរលែងតែមានបទប្បញ្ញត្តិផ្ទុយ ការប្រើពាក្យនិយោជិតអ្នកជាប់ពន្ធ និង រូបវន្តបុគ្គល គឺសំដៅដល់ទាំងនិវាសនជន និងអនិវាសនជន ដូចមានចែងក្នុងមាត្រានេះ ។

៤- ពាក្យ "និយោជក" រួមមាន ស្ថាប័នរដ្ឋ នីតិបុគ្គលនិវាសនជន ក្រុមអាជីវកម្មនិវាសនជន គ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា អង្គការមិនស្វែងរកចំណេញ ឬរូបវន្តបុគ្គលនិវាសនជនដែលប្រកបអាជីវកម្ម ។

៥- ពាក្យ "និយោជិត" សំដៅដល់ រូបវន្តបុគ្គលដែលបានទទួលប្រាក់បៀវត្សអំពីសកម្មភាពបំរើការងាររបស់ខ្លួន រួមបញ្ចូលទាំងអ្នកទទួលខុសត្រូវ ឬអភិបាលរបស់សហគ្រាស មន្ត្រីរាជការ មន្ត្រីជ្រើសតាំងដោយការបោះឆ្នោត លើកលែងតែសមាជិករដ្ឋសភា និងព្រឹទ្ធសភា ។

៦- ពាក្យ "ប្រាក់បៀវត្សប្រភពកម្ពុជា" មានន័យថា ប្រាក់បៀវត្សដែលបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបំរើការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដោយឡែកចំពោះប្រាក់បៀវត្សដែលអនិវាសនជនបានទទួលក្នុងការផ្តល់ជំនួយបច្ចេកទេស ត្រូវចាត់ទុកថាមានប្រភពនៅក្នុងប្រទេសដែលអ្នកទូទាត់ប្រាក់បៀវត្សនោះស្នាក់នៅ ។

៧- ពាក្យ "បរទេស" :

ក- ពេលណាប្រើជាមួយរូបវន្តបុគ្គល មានន័យថាដែលជាអនិវាសនជន

ខ- ចំពោះការកំណត់ប្រភពប្រាក់ចំណូល មានន័យថា ក្រៅព្រះរាជាណាចក្រកម្ពុជា ។

៨- ពាក្យ "ប្រាក់បៀវត្ស" ក្នុងច្បាប់នេះ សំដៅដល់ បៀវត្ស លាភការ ប្រាក់បំណាច់ បុព្វលាភ ប្រាក់ម៉ោងបន្ថែម ប្រាក់ប៉ះប៉ូវនានា និងអត្ថប្រយោជន៍បន្ថែមដែលបានទូទាត់ឱ្យដល់និយោជិត ឬដែលបានទូទាត់ដើម្បីជាប្រយោជន៍ផ្ទាល់ ឬប្រយោលដល់និយោជិត ចំពោះការបំពេញសកម្មភាពបំរើការងារ ។

## ផ្នែកទី ២
## ប្រាក់បៀវត្សលើកលែងពន្ធ

### មាត្រា ៤៣ : ប្រាក់បៀវត្សរបស់មន្ត្រីការទូត និង មន្ត្រីបរទេសដទៃទៀត

ការលើកលែងពន្ធលើប្រាក់បៀវត្សរបស់មន្ត្រីការទូត និង មន្ត្រីបរទេសដទៃទៀត ត្រូវបានកំណត់ដូចតទៅ:

១- ត្រូវបានលើកលែងពន្ធលើប្រាក់បៀវត្ស ចំពោះ :

ក- ប្រាក់បៀវត្សដែលមន្ត្រី និងនិយោជិតនៃបេសកកម្មទូត ឬកុងស៊ុលរបស់រដ្ឋាភិបាលបរទេសណាមួយ ដែលកាន់លិខិតឆ្លងដែនការទូត ឬផ្លូវការរបស់ប្រទេសនោះ បានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារជាផ្លូវការនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ខ- ប្រាក់បៀវត្សដែលតំណាងមន្ត្រី និង និយោជិតបរទេសរបស់អង្គការអន្តរជាតិ និង របស់ទីភ្នាក់ងារខាងសហប្រតិបត្តិការបច្ចេកទេសនៃរដ្ឋាភិបាលដទៃទៀត បានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារជាផ្លូវការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- ការលើកលែងពន្ធក្នុងមាត្រានេះ ត្រូវឈរលើគោលការណ៍បដិការរវាងរដ្ឋាភិបាលដែលពាក់ព័ន្ធ។

## មាត្រា ៤៤ : ប្រាក់ចំណូលលើកលែងពន្ធរបស់និយោជិត

ត្រូវបានលើកលែងពន្ធ :

១- ប្រាក់សំណងដោយពិតប្រាកដនូវចំណាយខាងវិជ្ជាជីវៈដែលបានចាយដោយនិយោជិតតាមសេចក្ដីបង្គាប់ និង សម្រាប់ជាប្រយោជន៍នៃនិយោជក ហើយដែលបានបំពេញល័ក្ខខ័ណ្ឌ ៣ ដូចតទៅ :

ក- បានចាយក្នុងផលប្រយោជន៍ផ្ទាល់ និង ដាច់ខាតរបស់សហគ្រាស

ខ- មិនបង្ហាញលក្ខណៈហួសប្រមាណ ឬស្ដុកស្ដម្ភហួសហេតុ

គ- បានបង្ហាញជាភស្ដុតាងដោយវិក្កយបត្ររាយលំអិត និងបានទូទាត់ស្រេចបាច់ ហើយដែលបានធ្វើក្នុងនាមអ្នកបានទទួលប្រាក់សំណងនូវចំណាយពិតប្រាកដ ។

២- ប្រាក់បំណាច់នៃការបញ្ឈប់លែងឱ្យធ្វើការ ក្នុងកំរិតដែលបានបញ្ញត្តិក្នុងច្បាប់ការងារ ។

៣- លាភការបន្ថែមមានលក្ខណៈខាងសង្គមកិច្ច ក្នុងករណីដែលបានបញ្ញត្តិក្នុងច្បាប់ការងារ ។

៤- ការផ្គត់ផ្គង់ឱ្យដោយឥតយកថ្លៃ ឬយកថ្លៃទាបជាងថ្លៃដើមនូវឯកសណ្ឋាន ឬបរិក្ខារសម្រាប់វិជ្ជាជីវៈពិសេស ។

៥- ប្រាក់បំណាច់ម៉ោការសម្រាប់ចំណាយបេសកកម្ម និងការធ្វើដំណើរ ។ ប្រាក់បំណាច់នេះមិនត្រូវត្រួតគ្នាជាមួយប្រាក់សំណង ពិតប្រាកដនូវចំណាយដូចមានចែងក្នុងមាត្រានេះឡើយ ។

# ផ្នែកទី ៣
# មូលដ្ឋានគិតពន្ធប្រចាំខែ ប្រាក់បៀវត្សរ៍ជាប់ពន្ធប្រចាំខែ
# និង ការកំណត់ប្រាក់ពន្ធប្រចាំខែ

## មាត្រា ៤៥ : មូលដ្ឋានគិតពន្ធប្រចាំខែ

វៀរលែងតែអត្ថប្រយោជន៍បន្ថែមដែលត្រូវកំណត់ពន្ធតាមមាត្រា ៤៨ នៃច្បាប់នេះ មូលដ្ឋានគិតពន្ធប្រចាំខែរបស់និវាសនជន គឺជាប្រាក់បៀវត្សរ៍ជាប់ពន្ធ ដោយផាត់ចេញនូវ :

១- ប្រាក់កាត់ទុក ដែលជាកាតព្វកិច្ចក្នុងការប្រតិបត្តិតាមច្បាប់ការងារ ដើម្បីបង្កើតបេឡាសោធន និងធានាសុខុមាលភាពសង្គម ។

២- ការទូទាត់នានាដែលត្រូវបានលើកលែងពន្ធ ដូចមានចែងក្នុងមាត្រា ៤៤ នៃច្បាប់នេះ ។

## មាត្រា ៤៦ : ប្រាក់បៀវត្សរ៍ជាប់ពន្ធប្រចាំខែ

ប្រាក់បៀវត្សរ៍ជាប់ពន្ធប្រចាំខែត្រូវបានកំណត់ដូចតទៅ :

១-	ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែរបស់និយោជិតនិវាសនជន រួមមាន :

ក-	ប្រាក់បៀវត្សដែលបានទទួលពីប្រភពកម្ពុជា

ខ-	ប្រាក់បៀវត្សដែលបានទទួលពីប្រភពបរទេស

គ-	ប្រាក់បុរេប្រទាន ប្រាក់ឱ្យខ្ចី ឬប្រាក់រំដោះដែលនិយោជកបានបើកឱ្យនិយោជិត ។ ប្រាក់បុរេប្រទាន ប្រាក់ឱ្យខ្ចី ឬប្រាក់រំដោះត្រូវបូកបន្ថែមលើបៀវត្សជាប់ពន្ធនៃខែដែលប្រាក់ទាំងនោះបានបើក ហើយត្រូវកាត់បន្ថយពីប្រាក់បៀវត្សក្នុងខែ ដែលនិយោជិតបានបង់សងវិញ ។

២-	ផ្អែកលើការបង្ហាញភស្តុតាងនៃស្ថានភាពគ្រួសារ និយោជិតនិវាសនជនណាមួយដែលមាន :

ក-	កូនស្ថិតក្នុងបន្ទុកនាពេលដែលត្រូវបង់ពន្ធ ត្រូវបានទទួលនូវការបន្ថយមូលដ្ឋានកំណត់ពន្ធចំនួន ៧៥.០០០ រៀល (ប្រាំពីរម៉ឺនប្រាំពាន់រៀល) ក្នុងកូនម្នាក់ៗក្នុងមួយខែ ។

ខ-	សហព័ទ្ធដែលធ្វើតែជាមេផ្ទះ ត្រូវបានទទួលនូវការបន្ថយមូលដ្ឋានកំណត់ពន្ធចំនួន ៧៥.០០០រៀល (ប្រាំពីរម៉ឺនប្រាំពាន់រៀល) សម្រាប់តែម្នាក់ក្នុងមួយខែ ។

៣-	ចំពោះអ្នកជាប់ពន្ធអនិវាសនជន ប្រាក់បៀវត្សជាប់ពន្ធរួមមានប្រាក់បៀវត្សប្រភពកម្ពុជា ដែលត្រូវជាប់ពន្ធតាមបទប្បញ្ញត្តិទាំងឡាយនៃជំពូកនេះ ។

## មាត្រា ៤៧ : ការកំណត់ប្រាក់ពន្ធប្រចាំខែរបស់និយោជិត

សម្រាប់និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវបង់ត្រូវកំណត់លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និង ត្រូវកាត់ទុកដោយនិយោជក តាមអត្រាកំណើនតាមថ្នាក់ ដូចតទៅ :

| ភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | ០ ៛ ០០ | ដល់ | ៥០០.០០០ ៛ ០០ | ០% |
| ពី | ៥០០.០០១ ៛ ០០ | ដល់ | ១.២៥០.០០០ ៛ ០០ | ៥% |
| ពី | ១.២៥០.០០១ ៛ ០០ | ដល់ | ៨.៥០០.០០០ ៛ ០០ | ១០% |
| ពី | ៨.៥០០.០០១ ៛ ០០ | ដល់ | ១២.៥០០.០០០ ៛ ០០ | ១៥% |
| លើសពី | | | ១២.៥០០.០០០ ៛ ០០ | ២០% |

## មាត្រា ៤៨ : ការកំណត់ប្រាក់ពន្ធលើអត្ថប្រយោជន៍បន្ថែម

ចំពោះអត្ថប្រយោជន៍បន្ថែម ជារៀងរាល់ខែនិយោជកត្រូវកាត់ទុក និង បង់ប្រាក់ពន្ធតាមកាលកំណត់តាមអត្រា ២០ ភាគរយនៃតម្លៃសរុបរបស់អត្ថប្រយោជន៍បន្ថែម ដែលបានផ្តល់ឱ្យនិយោជិតទាំងអស់ ។ តម្លៃនៃអត្ថប្រយោជន៍បន្ថែម គឺជាតម្លៃទីផ្សារ រួមទាំងពន្ធអាករទាំងអស់ ។

## *មាត្រា ៤៩ (ថ្មី) : ការកំណត់ប្រាក់ពន្ធលើប្រាក់បៀវត្សរបស់អ្នកជាប់ពន្ធអនិវាសនជន*

*វៀរលែងតែអត្ថប្រយោជន៍បន្ថែមដែលត្រូវកំណត់ពន្ធតាមមាត្រា ៤៨ នៃច្បាប់នេះ សម្រាប់អ្នកជាប់ពន្ធអនិវាសនជន ប្រាក់ពន្ធត្រូវកាត់ទុកដោយអ្នកបើកប្រាក់ឱ្យតាមអត្រា ២០ ភាគរយ លើរាល់ការទូទាត់ប្រាក់បៀវត្សជាប់ពន្ធដែលមានចែងក្នុង*

*កថាខ័ណ្ឌ៣ នៃមាត្រា៤៦ នៃច្បាប់នេះ ។ ពន្ធកាត់ទុកនេះ គឺជាពន្ធចុងក្រោយនៃពនលើប្រាក់បៀវត្សសម្រាប់អនិវាសនជនជាអ្នកទទួលប្រាក់បៀវត្ស ។*

## មាត្រា ៥០ : ឥណទានពន្ធបរទេស

អ្នកជាប់ពន្ធនិវាសនជនដែលបានទទួលប្រាក់បៀវត្សប្រភពបរទេស និងបានបង់ពន្ធតាមច្បាប់ពន្ធដារបរទេស ត្រូវបានទទួលនូវឥណទានពន្ធសម្រាប់កាត់កងពីប្រាក់ពន្ធលើប្រាក់បៀវត្សដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែលុះណាតែមានការបង្ហាញឯកសារបញ្ជាក់អំពីការបង់ពន្ធនៅបរទេសនោះ ។

ក- ដើម្បីគណនាប្រាក់ពន្ធដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា មុនពេលកាត់ឥណទានពន្ធនេះ ត្រូវយកចំនួនសរុបប្រាក់បៀវត្សដែលបានទទួលអំពីប្រភពកម្ពុជា និង ប្រភពបរទេសមកគិត

ខ- ឥណទានពន្ធត្រូវបានកំណត់ដាច់ដោយឡែកពីគ្នាសម្រាប់ប្រាក់ពន្ធដែលបានបង់ដោយ និវាសនជនកម្ពុជានៅប្រទេសក្រៅនីមួយៗ ។ ប៉ុន្តែឥណទានពន្ធផ្តល់ឱ្យសម្រាប់ពន្ធលើប្រាក់បៀវត្សដែលបានបង់នៅប្រទេសក្រៅ គឺជាចំនួនដែលទាបជាងគេក្នុងចំណោម:

- ប្រាក់ពន្ធដែលបានបង់ជាក់ស្តែងនៅប្រទេសក្រៅណាមួយ
- ចំនួនដែលបានមកពីការយកប្រាក់ពន្ធលើប្រាក់បៀវត្សសរុបពីគ្រប់ប្រភពក្នុងរយៈពេលជាមួយគ្នា ដែលគណនាតាមអត្រាកំណើនតាមថ្នាក់ក្នុងមាត្រា ៤៧ នៃច្បាប់នេះ ទៅគុណនឹងផលចែករវាងប្រាក់បៀវត្សដែលបានទទួលនៅប្រទេសក្រៅនោះ និងប្រាក់បៀវត្សសរុបពីគ្រប់ប្រភព ។

ការបង្វិលសងឥណទានពន្ធបរទេសអាចធ្វើទៅបាន លុះណាតែអ្នកជាប់ពន្ធនិវាសនជនបានបំពេញបែបបទ ព្រមទាំងផ្តល់ឯកសារនានាកំណត់ដោយរដ្ឋបាលសារពើពន្ធ ជាពិសេសសេចក្តីបញ្ជាក់របស់និយោជក និង រដ្ឋបាលសារពើពន្ធនៃទីកន្លែងបំរើការងារនៅឯបរទេស ។

# ផ្នែកទី ៤

# ភារកិច្ចរបស់និយោជក និង និយោជិត

## មាត្រា ៥១ : ហេតុបណ្តាលអោយជាប់ពន្ធ

ការបើកបៀវត្ស បង្កើតជាហេតុបណ្តាលឱ្យជាប់ពន្ធ ។

## មាត្រា ៥២ : បំណុលពន្ធ និង ភារកិច្ចកាត់ទុកប្រាក់ពន្ធ

បំណុលពន្ធ និង ភារកិច្ចកាត់ទុកប្រាក់ពន្ធ ត្រូវបានកំណត់ដូចតទៅ :

១- ពន្ធនេះ គឺជាបំណុលរបស់រូបវន្តបុគ្គលដែលបានទទួលប្រាក់បៀវត្ស រួមទាំងរូបវន្តបុគ្គលបរទេសផង វៀរលែងតែមានបទប្បញ្ញត្តិផ្ទុយដែលមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិ ។

២- ពន្ធលើប្រាក់បៀវត្សត្រូវប្រមូលតាមរបៀបកាត់ទុកជាមុនជារៀងរាល់ខែ ដោយនិយោជកនៅរាល់ពេលបើកប្រាក់បៀវត្ស ។

៣- ប្រសិនបើនិយោជកស្នាក់នៅបរទេស តំណាងសារពើពន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលនិយោជកបានចាត់តាំង គឺជាអ្នកទទួលភារៈកាត់ទុកពន្ធលើប្រាក់បៀវត្សមុនពេលបើកប្រាក់បៀវត្សទៅឱ្យនិយោជិត និងបង្វែរប្រាក់ពន្ធទាំងនោះជូនរដ្ឋ ។

៤- និយោជក ឬតំណាងនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់និយោជកបរទេស ហើយនិងនិយោជិតត្រូវទទួលខុសត្រូវរួមគ្នាក្នុងការបង់ពន្ធលើប្រាក់បៀវត្សក្នុងព្រះរាជាណាចក្រកម្ពុជា ដោយពុំកំណត់ថាប្រាក់បៀវត្សបានបើកឱ្យនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេសឡើយ ។ ក្នុងករណីមិនបានកាត់ទុកប្រាក់ពន្ធលើប្រាក់បៀវត្ស និយោជកត្រូវទទួលខុសត្រូវចំពោះច្បាប់នេះ ទោះបីជាប្រាក់ពន្ធត្រូវបានបង់ដោយនិយោជិតរួចហើយក្តី ។

**មាត្រា ៥៣ : ការបង់ប្រាក់ពន្ធដែលបានកាត់ទុក**

ប្រាក់ពន្ធកាត់ទុកដែលទាក់ទងដល់ការបើកប្រាក់បៀវត្សធ្វើឡើងក្នុងខែណាមួយ ត្រូវបង់យ៉ាងយឺតបំផុតនៅថ្ងៃទី ១៥ នៃខែបន្ទាប់ជូនទៅរដ្ឋបាលសារពើពន្ធនៅទីកន្លែងនៃលំនៅដ្ឋានឬគ្រឹះស្ថានជាគោលដើមនៃអ្នកទទួលភារៈកាត់ទុកប្រាក់ពន្ធនេះ។

**មាត្រា ៥៤ : ការកាត់ទុកប្រាក់ពន្ធ ការកាន់បញ្ជិកា និង របាយការណ៍**

គ្រប់និយោជកដែលបើកប្រាក់បៀវត្សត្រូវជាប់ពន្ធ ត្រូវទទួលបំពេញភារកិច្ច :

១- កាត់ទុកប្រាក់ពន្ធមុនពេលបើកបៀវត្ស ។

២- រាយការណ៍ជូនរដ្ឋបាលសារពើពន្ធ និង និយោជិតអំពីស្ថានភាពប្រាក់ពន្ធដែលបានកាត់ទុក ។

៣- កាន់កាប់ និង ថែរក្សាបញ្ជិកាដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

# ជំពូកទី ៣

# បទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែម

## ផ្នែកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ៥៥ : បន្ទុកអាករ**

ចាប់តាំងពីថ្ងៃទី ០១ ខែមករា ឆ្នាំ ១៩៩៨ តទៅ នឹងត្រូវបានបង្កើតអាករលើតម្លៃបន្ថែម ចំពោះការផ្គត់ផ្គង់ជាប់អាករ ដើម្បីជាប្រយោជន៍ដល់ថវិការដ្ឋ ។

**មាត្រា ៥៦ : និយមន័យ**

សម្រាប់គោលដៅនៃបទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែម :

១- ពាក្យ "ទំនិញ" សំដៅដល់ទ្រព្យរូបីក្រៅពីដីធ្លី និង ប្រាក់កាស ។

២-	ពាក្យ "សេវា" សំដៅដល់ការផ្តល់អ្វីមួយដែលមានតម្លៃក្រៅពីទំនិញ ដីធ្លី និង ប្រាក់កាស ។

៣-	ពាក្យ "ការផ្គត់ផ្គង់ទំនិញ" សំដៅដល់ការផ្ទេរសិទ្ធិប្រើប្រាស់ ឬសិទ្ធិចាត់ចែងក្នុងឋានៈជាម្ចាស់កម្មសិទ្ធិទំនិញ ទោះបីមានសំណង ឬគ្មានសំណងក្តី ។ ការផ្គត់ផ្គង់សេវាបន្ទាប់បន្សំដែលទាក់ទិននឹងការផ្គត់ផ្គង់ទំនិញ ត្រូវចាត់ទុកដូចជាការផ្គត់ផ្គង់ទំនិញ។

៤-	ពាក្យ"ការផ្គត់ផ្គង់សេវា" សំដៅដល់ការផ្គត់ផ្គង់ដែលមិនមែនជាការផ្គត់ផ្គង់ទំនិញ ដីធ្លី ឬប្រាក់កាសដែលធ្វើឡើងដើម្បីបានទទួលសំណងអ្វីមួយ ។ ការផ្គត់ផ្គង់ទំនិញបន្ទាប់បន្សំដែលទាក់ទិននឹងការផ្គត់ផ្គង់សេវា ត្រូវចាត់ទុកដូចជាការផ្គត់ផ្គង់សេវា។

៥-	ពាក្យ"បុគ្គល" សំដៅដល់បុគ្គល ឬក្រុមបុគ្គលដែលធ្វើអាជីវកម្ម ហើយនិងបុគ្គលណាមួយទៀតដែលទាក់ទិនជាមួយបុគ្គលនោះ ។

៦-	ពាក្យ "ទាក់ទិន" ចំពោះបុគ្គលណាមួយ មានន័យថា :

ក-	បុគ្គលណាមួយដែលមានកម្មសិទ្ធិចាប់ពី ២០ ភាគរយឡើងទៅលើតម្លៃ ឬសិទ្ធិបោះឆ្នោតនៃភាគកម្មនៅក្នុងដើមទុនផ្ទាល់នៃបុគ្គលដែលលើកយកមកពិចារណា

ខ-	មានការគ្រប់គ្រងរួមគ្នាឬមាននាយករួមគ្នាជាមួយបុគ្គល

គ-	ជាសមាជិកគ្រួសារ ឬជាសហព័ទ្ធឬជាសមាជិកក្រុមគ្រួសារនៃសហព័ទ្ធរបស់បុគ្គល

ឃ-	បានទិញចាប់ពី ៣០ ភាគរយឡើងទៅនៃធាតុចេញសរុបរបស់បុគ្គលក្នុងរយៈពេលបីខែបន្តបន្ទាប់ ។

៧-	ពាក្យ "អាករ" ក្នុងជំពូកនេះសំដៅដល់អាករលើតម្លៃបន្ថែម ។

## មាត្រា ៥៧ : ការផ្គត់ផ្គង់មិនជាប់អាករ

ការផ្គត់ផ្គង់មិនជាប់អាករ មានដូចតទៅ :

១-	សេវាប្រៃសណីយ៍សាធារណៈ ។

២-	សេវារបស់មន្ទីរពេទ្យ និងគ្លីនិក សេវាខាងវេជ្ជសាស្ត្រ និងទន្តសាស្ត្រ និងការលក់ទំនិញបន្ទាប់បន្សំខាងវេជ្ជសាស្ត្រ និង ទន្តសាស្ត្រដែលទាក់ទិននឹងការបំពេញសេវាទាំងនេះ ។

៣-	សេវាដឹកជញ្ជូនអ្នកដំណើរដោយប្រព័ន្ធដឹកជញ្ជូនសាធារណៈ ដែលជាកម្មសិទ្ធិទាំងស្រុងរបស់រដ្ឋ ។

៤-	សេវាធានារ៉ាប់រង ។

៥-	សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុ ដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

៦-	ការនាំចូលសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនដែលរួចពន្ធគយ ក្នុងកម្រិតតម្លៃដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

៧-	សកម្មភាពមិនស្វែងរកចំណេញដើម្បីបំរើផលប្រយោជន៍សាធារណៈ ដែលបានទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## មាត្រា ៥៨ : ការផ្គត់ផ្គង់មិនជាប់អាករចំពោះបេសកកម្មទូត និង អង្គការអន្តរជាតិ

ការផ្គត់ផ្គង់មិនជាប់អាករចំពោះបេសកកម្មទូតនិងអង្គការអន្តរជាតិ ត្រូវបានកំណត់ដូចតទៅ :

១- ការនាំចូលនូវទំនិញសម្រាប់ ឬដោយបេសកកម្មទូត និងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា សម្រាប់យកមកប្រើនៅក្នុងការបំពេញមុខងារជាផ្លូវការរបស់ខ្លួន ត្រូវកំណត់ថាជាការផ្គត់ផ្គង់មិនជាប់អាករ ។ ការផ្គត់ផ្គង់មិនជាប់អាករត្រូវបានផ្តល់ឱ្យតែក្នុងករណីមានការបញ្ជាក់អំពីប្រធានបេសកកម្មជូននាយកដ្ឋានពន្ធដារថាទំនិញទាំងនោះបាននាំចូលមកសម្រាប់គោលដៅនៃការប្រើប្រាស់ខាងលើនេះមែន ។

២- ការនាំចូលទំនិញសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់បុគ្គលិកផ្លូវការនៃបេសកកម្ម ឬអង្គការ ដូចមានចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ ត្រូវកំណត់ថាជាការផ្គត់ផ្គង់មិនជាប់អាករចំពោះតែមុខទំនិញទាំងឡាយ ដែលមានចុះនៅក្នុងបញ្ជីរាយមុខទំនិញដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

៣- ការផ្គត់ផ្គង់មិនជាប់អាករនៅក្នុងមាត្រានេះ ត្រូវឈរលើគោលការណ៍បដិការរវាងរដ្ឋាភិបាលពាក់ព័ន្ធ ។

# ផ្នែកទី ២
# គោលការណ៍ទូទៅនៃអាករលើតម្លៃបន្ថែម

## មាត្រា ៥៩ : បុគ្គលជាប់អាករ

បុគ្គលជាប់អាករ សំដៅដល់បុគ្គលដែលត្រូវជាប់ពន្ធតាមរបបពិត ហើយដែលធ្វើការផ្គត់ផ្គង់ជាប់អាករ ដូចមានចែងក្នុងមាត្រា ៦០ នៃច្បាប់នេះ ។

បុគ្គលដែលជាប់ពន្ធតាមរបបបំព្រួញ អាចស្នើសុំឱ្យចាត់ជាបុគ្គលជាប់អាករបាន ។ លក្ខខ័ណ្ឌ និង នីតិវិធីសម្រាប់ការស្នើសុំនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

សម្រាប់គោលដៅនៃជំពូកនេះ និយោជិតមិនត្រូវបានចាត់ទុកថាជាបុគ្គលជាប់អាករទេ ចំពោះសកម្មភាពដែលបានបំពេញក្នុងឋានៈជានិយោជិត ។

## មាត្រា ៦០ : ការផ្គត់ផ្គង់ជាប់អាករ

លើកលែងតែមានបទប្បញ្ញត្តិផ្ទុយនៅក្នុងជំពូកនេះ ពាក្យ“ការផ្គត់ផ្គង់ជាប់អាករ” សំដៅដល់ :

១- ការផ្គត់ផ្គង់ទំនិញ ឬសេវាដោយបុគ្គលជាប់អាករនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- ការដកយកទំនិញមកប្រើប្រាស់ផ្ទាល់ខ្លួនដោយបុគ្គលជាប់អាករ ។

៣- ការផ្តល់ជាអំណោយ ឬការផ្គត់ផ្គង់ក្រោមតម្លៃពិត នូវទំនិញ ឬសេវាដោយបុគ្គលជាប់អាករ។

៤- ការនាំចូលទំនិញមកក្នុងតំបន់ត្រួតពិនិត្យគយនៃព្រះរាជាណាចក្រកម្ពុជា ។

វិធាន និង នីតិវិធីសម្រាប់ការអនុវត្តមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## មាត្រា ៦១ : តម្លៃជាប់អាករ

តម្លៃជាប់អាករត្រូវបានកំណត់ដូចតទៅ :

១- តម្លៃជាប់អាករនៃការផ្គត់ផ្គង់ គឺជាថ្លៃទំនិញ ឬសេវាដែលអ្នកលក់យកពីអ្នកទិញ ។ តម្លៃជាប់អាកររួមមានបន្ទុកដឹកជញ្ជូន ហើយនិងខ្ទង់ដទៃទៀតដែលត្រូវទូទាត់ឱ្យអ្នកលក់ចំពោះការផ្គត់ផ្គង់នោះ រួមបញ្ចូលទាំងអាករពិសេសលើទំនិញ និងសេវាមួយចំនួន លើកលែងតែអាករលើតម្លៃបន្ថែម ។ នីតិវិធីសម្រាប់ធ្វើការកែតម្រូវតម្លៃជាប់អាករនៅពេលផ្គត់ផ្គង់ ឬក្រោយពេលផ្គត់ផ្គង់ ត្រូវកំណត់ដោយអនុក្រឹត្យ ។

២- ក្នុងករណីដែលការទូទាត់ចំពោះការផ្គត់ផ្គង់ជាប់អាករជាសំណងអ្វីមួយក្រៅពីប្រាក់កាសដើម្បីជាផលប្រយោជន៍ផ្ទាល់ ឬប្រយោលដល់អ្នកលក់ សំណងនោះត្រូវគិតបញ្ចូលក្នុងតម្លៃជាប់អាករតាមតម្លៃទីផ្សារ ។

៣- តម្លៃជាប់អាកររបស់ទំនិញនាំចូល គឺជាតម្លៃគយ រួមបញ្ចូលទាំងតម្លៃធានារ៉ាប់រង និងដឹកជញ្ជូន ដោយបូកបន្ថែមនូវពន្ធគយ និងអាករពិសេសលើទំនិញ និងសេវាមួយចំនួន ។ បើសិនជាគ្មានតម្លៃគយកែតម្រូវនេះទេ ត្រូវកំណត់យកតាមតម្លៃទីផ្សារ ។

៤- បើសិនជាតម្លៃជាប់អាកររបស់ទំនិញ ឬសេវាដែលបានផ្គត់ផ្គង់មិនតំណាងឱ្យតម្លៃពិតទេនោះ រដ្ឋបាលសារពើពន្ធអាចកំណត់ចេញនូវតម្លៃមួយសម្រាប់ទំនិញ ឬសេវា ហើយតម្លៃនោះត្រូវចាត់ទុកជាតម្លៃត្រឹមត្រូវរហូតដល់ពេលមានភស្តុតាងបញ្ជាក់ផ្សេងដែលរដ្ឋបាលសារពើពន្ធបានយល់ព្រមផង ។

៥- តម្លៃជាប់អាករនៃទំនិញប្រើរួចហើយ ដែលបុគ្គលជាប់អាករបានទិញពីអ្នកប្រើប្រាស់ដើម្បីលក់ជាប្រចាំ ឬលក់ជំនួសមុខឱ្យអ្នកប្រើប្រាស់ គឺជាចំនួនលំអៀងរវាងថ្លៃលក់ និង ថ្លៃទិញឬប្រាក់កម្រៃដែលបានមកពីការលក់ទំនិញនោះ។

## មាត្រា ៦២ : ពេលផ្គត់ផ្គង់

ពេលផ្គត់ផ្គង់ត្រូវបានកំណត់ដូចតទៅ :

១- អាករលើតម្លៃបន្ថែមត្រូវដល់កំណត់ និង ត្រូវបង់នៅពេលផ្គត់ផ្គង់ ។

២- ពេលផ្គត់ផ្គង់ទំនិញ និងសេវា គឺជាពេលដែលអ្នកលក់ត្រូវចេញវិក្កយបត្រ ឬជាពេលដែលអ្នកលក់បានចេញវិក្កយបត្រ ប្រសិនបើវិក្កយបត្រនោះត្រូវបានចេញមុនពេលដែលអ្នកលក់ត្រូវចេញវិក្កយបត្រ ។

៣- វិក្កយបត្រអាករលើតម្លៃបន្ថែមត្រូវចេញយ៉ាងយឺតបំផុត ៧ ថ្ងៃក្រោយការបញ្ជូនទំនិញ ឬការបំពេញសេវា ឬក្រោយការទូទាត់ក្នុងករណីដែលការទូទាត់ធ្វើឡើងមុនការបញ្ជូនទំនិញ ឬការបំពេញសេវា ។ ប្រសិនបើការបញ្ជូនទំនិញពុំមានវិក្កយបត្រភ្ជាប់ជាមួយទេ ត្រូវមានភ្ជាប់ឯកសារបញ្ជូនទំនិញដែលបានកត់ត្រាត្រឹមត្រូវក្នុងទិនានុប្បវត្តិបញ្ជូនទំនិញ ។

៤- ចំពោះការផ្គត់ផ្គង់ទំនិញ ឬសេវាដែលធ្វើឡើងជាបន្ត ឬដែលមានការទូទាត់ច្រើនលើក ពេលផ្គត់ផ្គង់ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

៥- ចំពោះការនាំចូលទំនិញ ពេលផ្គត់ផ្គង់ គឺជាពេលដែលអ្នកនាំចូលដាក់លិខិតប្រកាសជូនអាជ្ញាធរគយទៅតាមគោលការណ៍ជាធរមាន ។

### មាត្រា ៦៣ : ទីកន្លែងផ្គត់ផ្គង់

ទីកន្លែងផ្គត់ផ្គង់ត្រូវបានកំណត់ដូចតទៅ :

១- ការផ្គត់ផ្គង់ទំនិញត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា បើសិនជាទំនិញនោះត្រូវបានប្រគល់ឱ្យទោះមានលក្ខណៈជាការផ្ទេរសិទ្ធិប្រើប្រាស់ ឬសិទ្ធិចាត់ចែងក្តីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ចំពោះករណីដែលការផ្គត់ផ្គង់ត្រូវមានការដឹកជញ្ជូន ការផ្គត់ផ្គង់ត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺបើសិនជាទំនិញស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅពេលដែលការដឹកជញ្ជូនត្រូវបានចាប់ផ្តើម ។

២- ការផ្គត់ផ្គង់សេវាត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា បើសិនជាសេវានោះបានបំពេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយឡែកតែ :

ក- ការផ្គត់ផ្គង់សេវាជាប់ទាក់ទងនឹងអចលនទ្រព្យ ត្រូវកំណត់ថាសេវានោះបានធ្វើឡើងនៅទីកន្លែងដែលទ្រព្យនោះស្ថិត នៅ ។

ខ- ការផ្គត់ផ្គង់សេវាជាប់ទាក់ទងនឹងការដឹកជញ្ជូន ត្រូវកំណត់ថាសេវានោះបានធ្វើឡើងនៅទីកន្លែងនៃការដឹកជញ្ជូននោះ

៣- ទំនិញត្រូវចាត់ទុកថាបាននាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា បើសិនជាទំនិញនោះត្រូវបាននាំចូលមកក្នុងតំបន់ត្រួតពិនិត្យគយនៃព្រះរាជាណាចក្រកម្ពុជា ។

## ផ្នែកទី ៣
## អត្រាអាករ និង ការកំណត់ប្រាក់អាករ

### មាត្រា ៦៤ : អត្រាអាករ

អត្រាអាករត្រូវបានកំណត់ដូចតទៅ :

១- អាករលើតម្លៃបន្ថែមត្រូវកំណត់តាមអត្រា ១០ ភាគរយ លើតម្លៃជាប់អាករនៃការផ្គត់ផ្គង់ជាប់អាករនីមួយៗ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- អាករលើតម្លៃបន្ថែមត្រូវកំណត់តាមអត្រា ០ ភាគរយ លើតម្លៃជាប់អាករនៃការផ្គត់ផ្គង់ជាប់អាករនីមួយៗ ចំពោះទំនិញនាំចេញពីព្រះរាជាណាចក្រកម្ពុជា ហើយនិងការផ្គត់ផ្គង់សេវាជាប់អាករ ដែលបានបំពេញនៅក្រៅព្រះរាជាណាចក្រកម្ពុជាដូចមានចែងក្នុងមាត្រា ៦៣ នៃច្បាប់នេះ ។

៣- រដ្ឋបាលសារពើពន្ធអាចប្រើប្រាស់ឯកសារមួយចំនួន ដើម្បីបញ្ជាក់ថាមានការនាំចេញជាក់ស្តែងមែន ក្នុងនោះមានជាអាទិ៍ សេចក្តីបញ្ជាក់ការនាំចេញរបស់ទីចាត់ការគយនិងរដ្ឋាករ ឯកសារនាំចូលរបស់ប្រទេសនាំចូលលិខិតឥណទានបានប្រើប្រាស់និងការទូទាត់ដែលធនាគារក្នុងស្រុកបានទទួល ។

## មាត្រា ៦៥ : ឥណទានអាករលើធាតុចូល និង ការផ្គត់ផ្គង់មិនជាប់អាករ

ឥណទានអាករលើធាតុចូលនិងការផ្គត់ផ្គង់មិនជាប់អាករត្រូវបានកំណត់ដូចតទៅ :

១- ប្រាក់អាករដែលបុគ្គលជាប់អាករបានបង់លើទំនិញ និងសេវាសម្រាប់ប្រើប្រាស់ក្នុងអាជីវកម្ម ដែលបុគ្គលជាប់អាករម្នាក់ទៀតបានផ្គត់ផ្គង់ឱ្យ ឬប្រាក់អាករដែលបានបង់ដោយបុគ្គលជាប់អាករក្នុងឋានៈជាអ្នកនាំចូលលើទំនិញ ឬសេវានាំចូលសម្រាប់ប្រើប្រាស់នៅក្នុងអាជីវកម្មរបស់ខ្លួន ត្រូវក្លាយជាឥណទានអាករលើធាតុចូលសម្រាប់កាត់កងចេញពីអាករលើធាតុចេញ។ ធាតុចូលមានន័យថា ទំនិញ ឬសេវាដែលបានទិញចូល ហើយធាតុចេញមានន័យថា ទំនិញ ឬសេវាដែលបានលក់ចេញ ។

២- ក្នុងករណីទំនិញ និងសេវាទិញចូល ត្រូវបានប្រើប្រាស់មួយចំណែកជាការផ្គត់ផ្គង់ជាប់អាករ និង មួយចំណែកទៀតជាការផ្គត់ផ្គង់មិនជាប់អាករ ឥណទានអាករត្រូវបានអនុញ្ញាតឱ្យតែចំពោះចំណែកដែលបានប្រើប្រាស់ជាការផ្គត់ផ្គង់ជាប់អាករ ។

## មាត្រា ៦៦ : ការកំណត់ប្រាក់អាករ

ប្រាក់អាករត្រូវបានកំណត់ដូចតទៅ :

១- អាករដែលបានកំណត់ក្នុងមាត្រា ៦៤ នៃច្បាប់នេះ ត្រូវចាត់ទុកជាបំណុលចំពោះរដ្ឋនៅពេលផ្គត់ផ្គង់ ។

២- ប្រាក់អាករត្រូវបង់ជូនរដ្ឋ ស្មើនឹងប្រាក់អាករលើធាតុចេញសរុប តាមអត្រាក្នុងមាត្រា៦៤ នៃច្បាប់នេះ ដកឥណទានអាករលើធាតុចូលដែលបានអនុញ្ញាតសរុបក្នុងខែជាមួយគ្នា ។

## មាត្រា ៦៧ : អចលកម្មរូបីដែលឈប់ប្រើប្រាស់ក្នុងអាជីវកម្ម

ក្នុងករណីអចលកម្មរូបីនៃអាជីវកម្មណាមួយដែលបានទទួលឥណទានអាករដូចក្នុងមាត្រា ៦៥ នៃច្បាប់នេះ ត្រូវឈប់ប្រើប្រាស់នៅក្នុងអាជីវកម្មរបស់បុគ្គលជាប់អាករ ទ្រព្យនោះត្រូវចាត់ទុកថាបានលក់ និងត្រូវជាប់អាករតាមតម្លៃទីផ្សារ នៅពេលឈប់ប្រើការនោះ ។

## មាត្រា ៦៨ : ឯកសារចាំបាច់សំរាប់សុំឥណទានអាករលើធាតុចូល

សំណើសុំឥណទានអាករលើធាតុចូល ត្រូវភ្ជាប់មកជាមួយនូវ :

១- វិក្កយបត្រអាករលើតម្លៃបន្ថែម ដែលបានធ្វើឡើងស្របតាមមាត្រា ៧៨ នៃច្បាប់នេះ ។

២- ប្រតិវេទន៍គយសម្រាប់ការនាំចូលដែលអាជ្ញាធរគយបានបញ្ជាក់ត្រឹមត្រូវ ។ ប្រតិវេទន៍នោះត្រូវមានចុះឈ្មោះបុគ្គលជាប់អាករដែលជាអ្នកទទួលទំនិញ ឬជាអ្នកនាំចូល និងចំនួនប្រាក់ពន្ធអាករដែលបានបង់នៅពេលនាំចូល។

## មាត្រា ៦៩ : អាករលើធាតុចូលដែលមិនអនុញ្ញាតអោយប្រើជាឥណទាន

អាករលើធាតុចូលដែលមិនអនុញ្ញាតឱ្យប្រើជាឥណទាន រួមមានប្រាក់អាករដែលបុគ្គលជាប់អាករបានបង់លើការចំណាយទទួលភ្ញៀវ កំសាន្ត ឬសំរាកលំហែ ការទិញរថយន្ត ឬការទិញផលិតផលគេលសិលាមួយចំនួន ។

## ផ្នែកទី ៤
## ការបង់ប្រាក់អាករ

### មាត្រា ៧០ : ការដាក់លិខិតប្រកាសអាករលើតំលៃបន្ថែមប្រចាំខែ

លិខិតប្រកាសអាករលើតម្លៃបន្ថែមសម្រាប់ខែណាមួយ ត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតត្រឹមថ្ងៃទី ២០ នៃខែបន្ទាប់ ហើយត្រូវបង់ប្រាក់អាករទៅតាមចំនួនដែលបានប្រកាសនៅពេលដាក់លិខិតប្រកាសនោះ ។

### មាត្រា ៧១ : ការចាត់ចែងចំពោះចំនួនឥណទានលើស

បើសិនជាអាករលើធាតុចូលដែលបុគ្គលជាប់អាករបានបង់តាមមាត្រា ៦៤ នៃច្បាប់នេះ មានចំនួនខ្ពស់ជាងអាករលើធាតុចេញដែលបុគ្គលនោះប្រមូលសម្រាប់ខែណាមួយ :

១- ចំនួនលើសត្រូវប្រើជាឥណទានអាករចំពោះប្រាក់អាករលើតម្លៃបន្ថែមដែលបុគ្គលនៅជំពាក់ខែកន្លងទៅ

២- ចំនួនលើសដែលនៅសល់ទៀតនោះ ត្រូវចាត់ទុកជាឥណទានអាករលើធាតុចូលនៃមាត្រា៦៥ នៃច្បាប់នេះសម្រាប់ខែបន្ទាប់ ។

### មាត្រា ៧២ : ការបង្វិលសងប្រាក់អាករឱ្យអ្នកនាំចេញ

រដ្ឋបាលសារពើពន្ធអាចបង្វិលសងនូវឥណទានអាករលើធាតុចូលលើសប្រចាំខែ តាមការស្នើសុំរបស់បុគ្គលជាប់អាករដែលមានសកម្មភាពនាំចេញជាសំខាន់ ប្រសិនបើបុគ្គលនោះបានបង្ហាញឯកសារបញ្ជាក់ច្បាស់លាស់ក្នុងការនាំចេញ ហើយនិងបានប្រតិបត្តិត្រឹមត្រូវនូវកាតព្វកិច្ចកាន់បញ្ជិកា និងឯកសារផ្សេងទៀត ។

### មាត្រា ៧៣: ការបង្វិលសងប្រាក់អាករក្នុងករណីមានឥណទានអាករលើសចាប់ពី ៣ ខែឡើងទៅ

បើសិនជាបុគ្គលជាប់អាករមានឥណទានអាករលើធាតុចូលលើសចាប់ពី ៣ ខែឡើងទៅ បុគ្គលនោះអាចដាក់ពាក្យសុំបង្វិលសងប្រាក់អាករនៅដំណាច់ខែទី៣ ឬនៅក្នុងខែណាមួយជាបន្តមកទៀត ។ ដើម្បីឱ្យមានតម្លៃអនុវត្តសម្រាប់ខែណាមួយ ពាក្យសុំត្រូវដាក់ស្នើក្នុងរយៈពេល ២០ ថ្ងៃក្រោយដំណាច់ខែទាំងនោះ ។

### មាត្រា ៧៤ : ការបង្វិលសងប្រាក់អាករអោយបេសកកម្មទូត និង អង្គការអន្តរជាតិ

បេសកកម្មទូត ឬកុងស៊ុលបរទេស អង្គការអន្តជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា អាចដាក់ពាក្យសុំបង្វិលសងប្រាក់អាករលើទំនិញដែលបានទិញនៅក្នុងស្រុក ដែលនឹងមានចុះនៅក្នុងបញ្ជីរាយមុខទំនិញ កំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ការបង្វិលសងប្រាក់អាករអាចអនុវត្តទៅបានតែក្នុងករណីមានការបញ្ជាក់អំពី

ប្រធានបេសកកម្មជូនទៅរដ្ឋបាលសារពើពន្ធថា ទំនិញត្រូវបានទិញមកសម្រាប់យកទៅប្រើប្រាស់នៅក្នុងការបំពេញមុខងារជាផ្លូវការរបស់អង្គភាពសាមី ។

**មាត្រា ៧៥ : ការទទួលខុសត្រូវចំពោះការប្រមូល និង ការបង់អាករ**

ការទទួលខុសត្រូវចំពោះការប្រមូល និងការបង់អាករ ត្រូវបានកំណត់ដូចតទៅ :

១- បុគ្គលជាប់អាករ ឬអ្នកនាំចូលមានកាតព្វកិច្ចត្រូវបង់អាករដែលកំណត់ដោយមាត្រា ៦៤ នៃច្បាប់នេះ លើរាល់ការផ្គត់ផ្គង់ជាប់អាករដែលបុគ្គលជាប់អាករ ឬអ្នកនាំចូលបានអនុវត្ត ។

២- ល័ក្ខខ័ណ្ឌពិសេសបញ្ជាក់អំពីការទទួលខុសត្រូវរបស់អ្នកទិញចំពោះប្រាក់អាករ ក្នុងករណីដែលអ្នកផ្គត់ផ្គង់គ្មានធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្នុងករណីដែលមានឧបសគ្គផ្សេងទៀតដល់ការប្រមូលប្រាក់អាករអំពីអ្នកផ្គត់ផ្គង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

៣- បុគ្គលណាមួយដែលបានធ្វើការផ្គត់ផ្គង់ទំនិញ និង សេវាក្នុងនាមម្ចាស់កម្មសិទ្ធិ និង មិនមែនក្នុងឋានៈជានិយោជិតរបស់គេទេនោះ ហើយដែលមានការគ្រប់គ្រងលើការផ្គត់ផ្គង់ត្រូវចាត់ទុកថា ជាបុគ្គលជាប់អាករសម្រាប់ការផ្គត់ផ្គង់នោះ ។

## ផ្នែកទី ៥

## បទប្បញ្ញត្តិខាងរដ្ឋបាល

**មាត្រា ៧៦ : ការចុះបញ្ជី**

គោលការណ៍ស្តីពីការចុះបញ្ជី ត្រូវបានកំណត់ដូចតទៅ :

១- បុគ្គលជាប់អាករដូចមានចែងក្នុងមាត្រា ៥៩ នៃច្បាប់នេះ ត្រូវធ្វើការចុះបញ្ជីសម្រាប់អាករលើតម្លៃបន្ថែមឱ្យបានស្រេចបាច់ក្នុងរយៈពេល ៣០ ថ្ងៃក្រោយថ្ងៃដែលបុគ្គលនោះក្លាយជាបុគ្គលជាប់អាករ ។ វិធាន និង នីតិវិធីសម្រាប់ការចុះបញ្ជីនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

២- ចំពោះបុគ្គលដែលមានការតម្រូវឱ្យធ្វើការចុះបញ្ជី ហើយដែលមិនបានធ្វើការចុះបញ្ជីនោះ រដ្ឋបាលសារពើពន្ធអាចធ្វើការចុះបញ្ជីបុគ្គលនោះចាប់តាំងពីពេលដែលបុគ្គលនោះត្រូវមកធ្វើការចុះបញ្ជី ។ បុគ្គលដែលត្រូវបានចុះបញ្ជីតាមបែបនេះត្រូវមានការទទួលខុសត្រូវចំពោះប្រាក់អាករទាំងអស់ក្នុងមាត្រា ៦៤ នៃច្បាប់នេះ ចាប់តាំងពីកាលបរិច្ឆេទដែលបុគ្គលនោះត្រូវមកធ្វើការចុះបញ្ជី ។

៣- បើសិនជាបុគ្គលជាប់អាករណាមួយដែលបានចុះបញ្ជីតាមមាត្រានេះយល់ឃើញថា ខ្លួនមិនត្រូវជាបុគ្គលជាប់អាករសម្រាប់ឆ្នាំចរន្ត និងឆ្នាំបន្ទាប់ទេ បុគ្គលនោះអាចដាក់ពាក្យសុំលុបការចុះបញ្ជីវិញ ។

៤- សម្រាប់ក្រុមបុគ្គលទាក់ទិន ២ នាក់ ឬច្រើននាក់ ដែលក្នុងនោះបុគ្គលម្នាក់ ឬច្រើននាក់ មិនមែនជាបុគ្គលជាប់អាករទេនោះ រដ្ឋបាលសារពើពន្ធអាចចាត់ទុកបុគ្គលជាប់អាករណាមួយថាបានចុះបញ្ជីសម្រាប់សកម្មភាពសេដ្ឋកិច្ចទាក់ទិនទាំងមូល ឬភាគណាមួយ ។ បើសិនជាគ្មានបុគ្គលទាក់ទិនណាម្នាក់ជាបុគ្គលជាប់អាករទេនោះ រដ្ឋបាលសារពើពន្ធអាចចុះបញ្ជីនូវបុគ្គលក្នុងក្រុមម្នាក់ ឬច្រើននាក់សម្រាប់ សកម្មភាពសេដ្ឋកិច្ចទាក់ទិនទាំងមូល ឬភាគណាមួយ ។

៥- សម្រាប់គោលដៅនៃការចុះបញ្ជី និងដោយមានការយល់ព្រមពីរដ្ឋបាលសារពើពន្ធផង ចំពោះបុគ្គលជាប់អាករមួយក្រុមដែលជាប់ទាក់ទិនគ្នាដូចមានចែងក្នុងមាត្រា ៥៦ នៃច្បាប់នេះ សកម្មភាពរបស់សមាជិកនានានៅក្នុងក្រុម អាចចាត់ទុកជា

សកម្មភាពរបស់សមាជិកជ្រើសតាំងតែម្នាក់ប៉ុណ្ណោះ ។ ក្នុងករណីនេះ សមាជិកម្នាក់ៗនៅក្នុងក្រុម ត្រូវមានការទទួលខុសត្រូវរួមគ្នា និង យ៉ាងពេញលេញចំពោះការប្រតិបត្តិតាមបទប្បញ្ញត្តិនៃជំពូកនេះ ។

## មាត្រា ៧៧ : វិក្កយបត្រអាករលើតំលៃបន្ថែម

គោលការណ៍ស្តីពីវិក្កយបត្រអាករលើតម្លៃបន្ថែម ត្រូវបានកំណត់ដូចតទៅ :

១- បុគ្គលជាប់អាករដែលធ្វើការផ្គត់ផ្គង់ ត្រូវចេញវិក្កយបត្រអាករលើតម្លៃបន្ថែមដែលមានចុះលេខរៀងត្រឹមត្រូវឱ្យទៅអ្នកទិញ ។

២- វិក្កយបត្រដែលកថាខ័ណ្ឌ ១ នៃមាត្រានេះ បានតម្រូវឡើងសម្រាប់ការផ្គត់ផ្គង់ណាមួយ ត្រូវដាក់ចំណងជើងថា "វិក្កយបត្រអាករលើតម្លៃបន្ថែម" ហើយត្រូវមានចុះនិទ្ទេសដូចតទៅ :

ក- ឈ្មោះ និង លេខចុះបញ្ជីរបស់អ្នកលក់

ខ- កាលបរិច្ឆេទចេញវិក្កយបត្រ

គ- ឈ្មោះរបស់អ្នកទិញ ឬរបស់និយោជិត ឬភ្នាក់ងាររបស់អ្នកទិញ

ឃ- បរិមាណ សេចក្តីបរិយាយ និង ថ្លៃលក់ទំនិញ ឬសេវា

ង- តម្លៃសរុបដែលមិនទាន់គិតអាករពិសេសលើទំនិញ និង សេវាមួយចំនួន ហើយនិងអាករលើតម្លៃបន្ថែម

ច- តម្លៃជាប់អាករសរុប បើសិនជាខុសគ្នាពីចំនួនទឹកប្រាក់នៅក្នុងវាក្យខ័ណ្ឌ ង នៃកថាខ័ណ្ឌនេះ

ឆ- ប្រាក់អាករត្រូវបង់

ជ- កាលបរិច្ឆេទនៃការផ្គត់ផ្គង់ទំនិញ ឬសេវា បើសិនជាខុសគ្នាពីកាលបរិច្ឆេទចេញវិក្កយបត្រ។

៣- បុគ្គលទាំងឡាយមិនអាចចេញវិក្កយបត្រ ឬឯកសារផ្សេងទៀតបញ្ជាក់នូវទឹកប្រាក់ណាមួយថា ជាប្រាក់អាករលើការផ្គត់ផ្គង់ទំនិញ ឬសេវាបានទេ លើកលែងតែបុគ្គលនោះជាបុគ្គលជាប់អាករបានចុះបញ្ជីស្របតាមមាត្រា ៧៧ នៃច្បាប់នេះ ហើយទំនិញ ឬសេវាផ្គត់ផ្គង់ គឺជាទំនិញ ឬសេវាជាប់អាករ ។

៤- ក្រៅអំពីទោសទណ្ឌដទៃទៀត បើសិនជាវិក្កយបត្រណាមួយត្រូវបានប្រកាសអះអាងដោយក្លែងបន្លំថា ជាវិក្កយបត្រអាករលើតម្លៃបន្ថែម ហើយវិក្កយបត្រនោះបានបង្ហាញថា មានទឹកប្រាក់អាករមួយចំនួនត្រូវបង់ បុគ្គលអ្នកចេញវិក្កយបត្រត្រូវបង់ជូនរដ្ឋបាលសារពើពន្ធក្នុងរយៈពេលប្រាំពីរថ្ងៃក្រោយកាលបរិច្ឆេទចេញវិក្កយបត្រនូវទឹកប្រាក់ដែលបានចុះលើវិក្កយបត្រនោះ ទោះបីជាទឹកប្រាក់អាករត្រូវបង់មែន ឬមិនមែនក្តី ។

៥- ក្នុងករណីមានការលក់រាយដែលក្នុងនោះការលក់ភាគច្រើនមិនបានធ្វើជាមួយបុគ្គលជាប់អាករ វិក្កយបត្រដែលតម្រូវដោយកថាខ័ណ្ឌ១ នៃមាត្រានេះ ត្រូវចាត់ទុកថាបានបំពេញគ្រប់គ្រាន់ បើសិនជាអ្នកលក់បានផ្តល់បង្កាន់ ដៃទទួលប្រាក់លំអិតសម្រាប់បញ្ជី បេឡា ឬក៏ឯកសារផ្សេងទៀតដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៦-	ចំពោះការនាំចូល ប្រតិវេទន៍គយដែលបានបំពេញត្រឹមត្រូវ និង ដែលមានសេចក្ដីបញ្ជាក់អំពីការបង់ប្រាក់អាករ ត្រូវប្រើប្រាស់ជាឯកសារត្រួតពិនិត្យ ដើម្បីកំណត់លក្ខណៈអាចទទួលបាននូវឥណទានអាករ ។

## មាត្រា ៧៨ : ការមិនបានចេញវិក្កយបត្រអាករលើតំលៃបន្ថែម

ការមិនបានចេញវិក្កយបត្រអាករលើតម្លៃបន្ថែម ត្រូវរងទោសទណ្ឌដូចតទៅ :

១-	ក្រៅអំពីទោសទណ្ឌដទៃទៀត បើសិនជារដ្ឋបាលសារពើពន្ធរកឃើញជាលើកទី២ ថា គ្រឹះស្ថានណាមួយរបស់បុគ្គលជាប់អាករមិនបានចេញវិក្កយបត្រតាមការតម្រូវនោះ រដ្ឋបាលសារពើពន្ធអាចបិទគ្រឹះស្ថាននោះក្នុងរយៈពេលមានកំណត់មួយដែលមិនលើសពីប្រាំពីរថ្ងៃ ។

២-	បើសិនជាគ្រឹះស្ថានណាមួយ ដែលធ្លាប់ត្រូវបានបិទដូចក្នុងកថាខ័ណ្ឌ១ នៃមាត្រានេះ នៅតែប្រព្រឹត្តបទល្មើសបែបនោះជាថ្មីទៀត គ្រឹះស្ថាននោះអាចត្រូវបានបិទជាថ្មីទៀតក្នុងរយៈពេលមានកំណត់មួយដែលមិនលើសពីប្រាំពីរថ្ងៃ ។

## មាត្រា ៧៩ : បញ្ជី កំណត់ត្រា និង ពត៌មាន

គោលការណ៍ស្ដីពីបញ្ជីកំណត់ត្រាពត៏មាន សម្រាប់អាករលើតម្លៃបន្ថែមត្រូវបានកំណត់ដូចតទៅ :

១-	សម្រាប់គោលដៅបទប្បញ្ញត្តិទាំងឡាយក្នុងជំពូកនេះ បុគ្គលជាប់អាករត្រូវរក្សាទុកនូវច្បាប់ចម្លងវិក្កយបត្រទាំងអស់ដែលបានធ្វើចេញ និង វិក្កយបត្រទាំងអស់ដែលបានទទួល ។

២-	បុគ្គលជាប់អាករត្រូវកត់ត្រា និងរក្សាទុកឱ្យបានត្រឹមត្រូវនូវបញ្ជី កំណត់ត្រានៃរាល់កិច្ចការជំនួញដែលបានធ្វើ ហើយត្រូវមានគណនីតាមដានទឹកប្រាក់អាករដែលបានប្រមូលលើការលក់ និង ទឹកប្រាក់អាករដែលបានបង់លើការទិញនានារបស់ខ្លួនព្រមទាំងសេចក្ដីកែតម្រូវផ្សេងៗលើតម្លៃលក់ ឬទឹកប្រាក់អាករទៅតាមបែបបទដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ ។

៣-	កិច្ចការដូចមានចែងក្នុងកថាខ័ណ្ឌ ២ នៃមាត្រានេះ ត្រូវធ្វើប្រចាំថ្ងៃ ហើយត្រូវធ្វើការបូកសរុប និងគណនាសមតុល្យនៅដំណាច់ខែនីមួយៗ ។ បុគ្គលជាប់អាករត្រូវធ្វើជារៀងរាល់ខែនូវសម្រង់អាករលើតម្លៃបន្ថែម ទៅតាមបែបបទកំណត់ដោយរដ្ឋបាលសារពើពន្ធ ។

៤-	វិក្កយបត្រ កំណត់ត្រា និងឯកសារផ្សេងទៀតដែលជាប់ទាក់ទងនឹងអាករនេះ ត្រូវរក្សាទុកតាមលំដាប់ថ្ងៃខែតាមបែបបទ និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់ក្នុងរយៈពេល ១០ឆ្នាំយ៉ាងតិច ក្រោយការបញ្ចប់កិច្ចការជំនួញចុងក្រោយបំផុត ដែលជាប់ទាក់ទងនឹងឯកសារទាំងនេះ ។

៥-	ឯកសារ និងកំណត់ត្រាទាំងអស់ដែលត្រូវរក្សាទុកតាមមាត្រានេះ ហើយនិងឯកសារ និងកំណត់ត្រាឯទៀតដែលទាក់ទងនឹងអាជីវកម្មរបស់បុគ្គល ត្រូវផ្ដល់ឱ្យរដ្ឋបាលសារពើពន្ធត្រួតពិនិត្យនៅពេលមានសំណើ ។

## មាត្រា ៨០ : វិធានពិសេសសំរាប់ការនាំចូល

បទប្បញ្ញត្តិនានានៃជំពូកនេះ ដែលទាក់ទងនឹងការនាំចូល ត្រូវគ្រប់គ្រងដោយទីចាត់ការគយ និងរដ្ឋាករ ទៅតាមបែបបទដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

## មាត្រា ៨១ : ការបញ្ឈប់អាជីវកម្ម

វិធាននៃការបញ្ឈប់អាជីវកម្ម ត្រូវបានកំណត់ដូចតទៅ :

១- ក្នុងរយៈពេល ១០ ថ្ងៃ ក្រោយការបញ្ឈប់អាជីវកម្មដែលបុគ្គលជាប់អាករបានធ្វើការចុះបញ្ជី បុគ្គលនោះត្រូវដាក់លិខិតប្រកាសមួយ ទៅតាមទម្រង់ដែលបានកំណត់ជូនរដ្ឋបាលសារពើពន្ធ ដោយភ្ជាប់មកជាមួយនូវពត៌មានលំអិតអំពីការលក់ និងការទិញនានា ក្រោយពីការធ្វើប្រកាសសារពើពន្ធចុងក្រោយបំផុត និងពត៌មានលំអិតអំពីទំនិញទាំងអស់នៅក្នុងស្តុកដែលមិនទាន់បង់អាករ ឬដែលបានទទួលឥណទានអាកររួចហើយ ព្រមទាំងបង់ប្រាក់អាករដល់កំណត់ទាំងនោះ ។

២- វិធាន និងនីតិវិធីសម្រាប់ការបញ្ឈប់អាជីវកម្ម ការលុបឈ្មោះពីបញ្ជី ហើយនិងការទទួលខុសត្រូវរបស់អ្នកតំណាងតាមផ្លូវការ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## មាត្រា ៨២ : ការផ្ទេរអាជីវកម្ម

ការផ្ទេរអាជីវកម្មពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត ស្របតាមលក្ខខ័ណ្ឌដែលត្រូវកំណត់ដោយអនុក្រឹត្យ មិនត្រូវជាប់អាករលើតម្លៃបន្ថែមទេ។ វិធាន និងនីតិវិធីនៃការជូនដំណឹងអំពីការផ្ទេរ ការចុះបញ្ជីរបស់បុគ្គលអ្នកទទួលអាជីវកម្ម ការទទួលខុសត្រូវរបស់បុគ្គលអ្នកផ្ទេរអាជីវកម្ម ការទទួលខុសត្រូវរបស់បុគ្គលអ្នកទទួលអាជីវកម្ម និង កិច្ចរក្សាកំណត់ត្រាផ្សេង១ ត្រូវកំណត់ដោយអនុក្រឹត្យ។

## មាត្រា ៨៣ : កិច្ចសន្យាដែលបានធ្វើមុនកាលបរិច្ឆេទចូលជាធរមាននៃអាករ

គោលការណ៍អនុវត្តចំពោះកិច្ចសន្យាដែលបានធ្វើមុនកាលបរិច្ឆេទចូលជាធរមាននៃអាករ ត្រូវបានកំណត់ ដូចតទៅ :

១- ត្រូវដាក់ឱ្យអនុវត្តនូវអាករតាមមាត្រា ៩៥ នៃច្បាប់នេះ លើការផ្គត់ផ្គង់ជាប់អាករនានាក្រោមកិច្ចសន្យាដែលបានធ្វើឡើងមុនកាលបរិច្ឆេទចូលជាធរមាននៃអាករនេះ បើសិនជាការផ្គត់ផ្គង់ត្រូវបានធ្វើឡើងនៅចំ ឬនៅក្រោយកាលបរិច្ឆេទចូលជាធរមាននៃអាករ ។

២- ចំពោះការផ្គត់ផ្គង់ជាប់អាករដូចមានចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ ប្រាក់អាករលើតម្លៃបន្ថែមដែលបានកត់ត្រាក្រៅពីកិច្ចសន្យា ត្រូវចាត់ទុកជាសំណងបន្ថែមចំពោះមុខទំនិញ ឬសេវាដែលបានទិញ និងជាកាតព្វកិច្ចតាមផ្លូវច្បាប់របស់អ្នកទិញចំពោះអ្នកលក់ ។

## មាត្រា ៨៤ : ឥណទានអាករចំពោះទំនិញស្តុក

ឥណទានអាករចំពោះទំនិញស្តុកត្រូវបានកំណត់ដូចតទៅ :

១- ចំពោះបុគ្គលទើបបានចុះបញ្ជី ហើយនៅថ្ងៃចុះបញ្ជីនោះមានស្តុកទំនិញដែលបានបង់អាករលើតម្លៃបន្ថែម ឬអាករលើផលរបរ រួចហើយបុគ្គលនោះអាចដាក់ពាក្យសុំឱ្យរដ្ឋបាលសារពើពន្ធអនុញ្ញាតនូវឥណទានអាករចំពោះប្រាក់អាករដែលបានបង់លើស្តុកទាំងនោះ បន្ទាប់ពីរដ្ឋបាលសារពើពន្ធបានត្រួតពិនិត្យឃើញថាវិក្កយបត្រ ឬច្បាប់ចម្លងនៃប្រតិវេទន៍គយរបស់ទំនិញទាំងនោះមានលក្ខណៈត្រឹមត្រូវ។

២- បើមានការឯកភាពចំពោះលក្ខណៈត្រឹមត្រូវនៃឯកសារទាំងនោះហើយ រដ្ឋបាលសារពើពន្ធអាចអនុញ្ញាតនូវឥណទានអាករចំពោះការផ្គត់ផ្គង់ដែលបានធ្វើក្នុងអំឡុង ៦០ ថ្ងៃ មុនថ្ងៃចុះបញ្ជី ឬមុនថ្ងៃដែលច្បាប់នេះចូលជាធរមាន ។ ឥណទានអាករនេះអាចយកទៅប្រើក្នុងប្រកាសសារពើពន្ធទាំងឡាយសម្រាប់អាករនេះ ទៅតាមលក្ខខ័ណ្ឌដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ។

# ជំពូកទី ៤
# វិសោធនកម្មលើច្បាប់ស្តីអំពីហិរញ្ញវត្ថុសម្រាប់ឆ្នាំ១៩៩៤ និង លើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥

## ផ្នែកទី១
## បទប្បញ្ញត្តិស្តីពីការកែប្រែអាករពិសេសលើទំនិញមួយចំនួន មកជាអាករពិសេសលើទំនិញនិងសេវាមួយចំនួន

**មាត្រា ៨៥ :**

ចាប់ពីថ្ងៃប្រកាសឱ្យប្រើច្បាប់នេះ អាករពិសេសលើទំនិញមួយចំនួននៃច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ត្រូវហៅថា"អាករពិសេសលើទំនិញ និងសេវាមួយចំនួន" វិញ ហើយមាត្រាមួយចំនួនត្រូវបានធ្វើវិសោធនកម្មដូចមានចែងក្នុងជំពូកនេះ ។

មាត្រា ១៨ នៃច្បាប់ដូចយោងខាងលើ ត្រូវបានកែប្រែដូចតទៅ :

- ៣០ ភាគរយ សម្រាប់រថយន្តដែលមានបញ្ជាក់ក្នុងតារាងពន្ធគយលេខសំគាល់៨៧.០៣ ដែលមានស៊ីឡាំងជ្រេធំជាង ២.០០០ CC ព្រមទាំងគ្រឿងបន្លាស់សម្រាប់ប្រភេទរថយន្តទាំងនេះ ។
- ២០ ភាគរយ សម្រាប់ផលិតផលតេលសិលា និងរថយន្ត ដែលមានបញ្ជាក់ក្នុងតារាងពន្ធគយលេខសំគាល់ ៨៧.០៣ ដែលមានស៊ីឡាំងជ្រេពី ២.០០០ CC ចុះក្រោម ព្រមទាំងគ្រឿងបន្លាស់សម្រាប់ប្រភេទរថយន្តទាំងនេះ ។
- ១០ ភាគរយ សម្រាប់ភេសជ្ជៈ បារីគ្រប់ប្រភេទ សណ្ឋាគារ និង សេវាលំហែកំសាន្តផ្សេងៗ ព្រមទាំងយានយន្តគ្រប់ប្រភេទ និង គ្រឿងបន្លាស់ដែលមានបញ្ជាក់ក្នុងតារាងពន្ធគយលេខសំគាល់ ៨៧.០២ ៨៧០៤-២១ ដល់ ៨៧០៤-៩០ ៨៧០៦ ៨៧០៨, ៨៧១៤ និង ៨៧១១ ដែលមានស៊ីឡាំងជ្រេចាប់ពី ១២៥ CC ឡើងទៅ ។
- ២ ភាគរយ សម្រាប់ថ្លៃលក់សំបុត្រក្នុងស្រុក លើការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសពីក្នុងព្រះរាជាណាចក្រកម្ពុជាទៅបរទេស សេវាទូរគមនាគមន៍ពីក្នុងព្រះរាជាណាចក្រកម្ពុជាទៅបរទេស ។

ពាក្យ "ថ្លៃលក់កត់ត្រាក្នុងវិក្កយបត្រ" ក្នុងកថាខ័ណ្ឌ ២ នៃមាត្រា ២១ នៃច្បាប់ដូចយោងខាងលើ ត្រូវបានកែប្រែជា "ថ្លៃ លក់ចេញពីរោងចក្រកត់ត្រាក្នុងវិក្កយបត្រ" ។

បន្ថែមកថាខ័ណ្ឌខាងក្រោមក្នុងមាត្រា ២១ នៃច្បាប់ដូចយោងខាងលើ :

"៣- សេវាផ្គត់ផ្គង់នៅព្រះរាជាណាចក្រកម្ពុជា គឺថ្លៃក្នុងវិក្កយបត្រនៃសេវាដែលបានផ្គត់ផ្គង់" ។

ពាក្យ"ចំពោះទំនិញផលិត" ក្នុងកថាខ័ណ្ឌ២ ក្នុងមាត្រា២២ នៃច្បាប់ដូចយោងខាងលើ ត្រូវបានកែប្រែជា "ចំពោះទំនិញផលិត និង សេវាផ្គត់ផ្គង់" ។

បន្ថែមកថាខ័ណ្ឌខាងក្រោមក្នុងមាត្រា ២៣ នៃច្បាប់ដូចយោងខាងលើ :

"៣- អ្នកផ្គត់ផ្គង់ ចំពោះសេវាផ្គត់ផ្គង់នៅព្រះរាជាណាចក្រកម្ពុជា" ។

បន្ថែមកថាខ័ណ្ឌខាងក្រោមក្នុងមាត្រា ២៤ នៃច្បាប់ដូចយោងខាងលើ :

"៣- ចំពោះសេវាទូរគមនាគមន៍ និងដឹកជញ្ជូននៅព្រះរាជាណាចក្រកម្ពុជា ត្រូវមានបញ្ជីដោយឡែកដែលមានចុះកាលបរិច្ឆេទ និងតម្លៃនៃសេវាដែលបានផ្គត់ផ្គង់ពីចំណុចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទៅចំណុចនៅក្រៅព្រះរាជាណាចក្រកម្ពុជា" ។

## ផ្នែកទី ២

## បទប្បញ្ញត្តិស្តីពីការកែប្រែអាករលើផលរបរ

**មាត្រា ៨៦ :**

អាករលើផលរបរដែលមានចែងក្នុងច្បាប់ស្តីអំពីហិរញ្ញវត្ថុសម្រាប់ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០២/នស ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ១៩៩៣ ត្រូវបានកែប្រែដូចតទៅ :

១- លុបកថាខ័ណ្ឌ ២ ក្នុងមាត្រា ៣៩ នៃច្បាប់ដូចយោងខាងលើ ។

២- ពាក្យ "តម្លៃក្រៅគយ" ក្នុងមាត្រា៤៦ នៃច្បាប់ដូចយោងខាងលើ ត្រូវបានកែប្រែជា "តម្លៃមានពន្ធគយ និងអាករពិសេសលើទំនិញ និងសេវាមួយចំនួន" ។

៣- បន្ថែមកថាខ័ណ្ឌខាងក្រោម ក្នុងមាត្រា ៤៧ នៃច្បាប់ដូចយោងខាងលើ :

"នាយកដ្ឋានពន្ធដារអាចប្រមូលអាករលើការប្រើប្រាស់ និង អនុវត្តទោសទណ្ឌលើរាល់ទំនិញដែលដាក់លក់នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលអ្នកលក់ពុំមានឯកសារបញ្ជាក់គ្រប់គ្រាន់ថាបានបង់អាករលើការប្រើប្រាស់នៅពេលនាំចូល" ។

៤- បន្ថែមកថាខ័ណ្ឌ ង ដូចខាងក្រោម ក្នុងមាត្រា ៤៩ នៃច្បាប់ដូចយោងខាងលើ :

"ង- ចាប់ពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ១៩៩៧ តទៅ អ្នកជាប់ពន្ធទាំងអស់ត្រូវ :

- ប្រើវិធាននៃពេលផ្គត់ផ្គង់ ដូចមានចែងក្នុងមាត្រា ៦២ នៃច្បាប់នេះដែលចែងអំពីអាករលើតម្លៃបន្ថែម ដើម្បីកំណត់កាលបរិច្ឆេទដែលអាករត្រូវក្លាយជាបំណុលរបស់អ្នកជាប់ពន្ធចំពោះរដ្ឋ ។
- ចេញវិក្កយបត្រស្របតាមវិធាន និងនីតិវិធីដូចមានចែងក្នុងមាត្រា៦២ នៃច្បាប់នេះដែលចែងអំពីអាករលើតម្លៃបន្ថែម ។
- ចាត់ទុកថាបានរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ និងទទួលរងទោសទណ្ឌតាមមាត្រា ១៣៣ នៃច្បាប់នេះក្នុងករណីមិនប្រតិបត្តិតាមមាត្រា ៤៩ កថាខ័ណ្ឌ ង នេះ" ។

៥-	ក្នុងច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ត្រូវបន្ថែមមួយកថាខ័ណ្ឌក្នុងមាត្រា ៣៣ ថា: ចាប់ពី ថ្ងៃទី ០១ ខែមករា ឆ្នាំ ១៩៩៨ តទៅ :

- អ្នកជាប់ពន្ធតាមរបបពិតប្រាកដ មិនត្រូវជាប់អាករលើផលរបរទេ
- អ្នកជាប់ពន្ធតាមរបបផ្សេងទៀត ត្រូវជាប់អាករលើផលរបរតាមអត្រា ២ ភាគរយ
- មាត្រា ៤៤ មាត្រ ា៤៥ មាត្រា ៤៦ មាត្រា ៤៧ និង មាត្រា ៤៨ នៃច្បាប់ស្តីអំពីហិរញ្ញវត្ថុសម្រាប់ឆ្នាំ ១៩៩៤ និង មាត្រា ៣៧ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ត្រូវទុកជានិរាករណ៍ ។

# ជំពូកទី ៥
# បទប្បញ្ញត្តិស្តីពីវិធាន និង នីតិវិធីសារពើពន្ធ
## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ៨៧ : កម្មវត្ថុ**

ត្រូវបានបង្កើតដោយបទប្បញ្ញត្តិទាំងឡាយនៃជំពូកនេះនូវសិទ្ធិ និង កាតព្វកិច្ចរបស់អ្នកជាប់ពន្ធ និង របស់រដ្ឋបាលសារពើពន្ធ នីតិវិធីនៃការពិនិត្យឡើងវិញនូវប្រាក់ពន្ធបានបង់ នីតិវិធីដោះស្រាយវិវាទបទល្មើស និង ទោសទណ្ឌសារពើពន្ធ ។

បទប្បញ្ញត្តិទាំងឡាយនៃជំពូកនេះត្រូវអនុវត្តចំពោះពន្ធគ្រប់ប្រភេទ វៀរលែងតែពន្ធដោយឡែកណាមួយដែលមានចែងផ្សេង ។

**មាត្រា ៨៨ : និយមន័យ**

សម្រាប់គោលដៅនៃជំពូកនេះ :

១-	ពាក្យ "ពន្ធ" មានន័យថា ពន្ធ និង អាករទាំងឡាយ ។

២-	ពាក្យ "បុគ្គល" មានន័យថា រូបវន្តបុគ្គល ឬនីតិបុគ្គល ។

៣-	ពាក្យ "អ្នកជាប់ពន្ធ" មានន័យថាជាបុគ្គលដែលមានកាតព្វកិច្ចត្រូវបង់ពន្ធ ។

៤-	ពាក្យ "រដ្ឋបាលសារពើពន្ធ" មានន័យថាជាអង្គការចាត់តាំងនៃនាយកដ្ឋានពន្ធដារ ។

៥-	ពាក្យ "លិខិតប្រកាសសារពើពន្ធ" មានន័យថាជាឯកសារដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានតម្រូវឱ្យអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក បំពេញទៅតាមល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងច្បាប់នេះ ។

៦-	ពាក្យ "ភ្នាក់ងារកាត់ទុក" មានន័យថាជាបុគ្គលដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវឱ្យធ្វើការកាត់ទុក និងបង់ប្រាក់ពន្ធចូលថវិកា ក្នុងនាមនៃតតិយជន ។

៧- ពាក្យ "សកម្មភាពសេដ្ឋកិច្ច" មានន័យថាជាសកម្មភាពរបស់បុគ្គលដែលធ្វើជានិច្ចកាលជាប់បន្ត ឬមួយដងមួយគ្រា ដើម្បីរកមិនរកចំណេញក្នុងការផ្គត់ផ្គង់ ឬមានបំណងផ្គត់ផ្គង់ទំនិញ ឬសេវាឱ្យដល់បុគ្គលដទៃក្នុងគោលដៅដើម្បីបាន អត្ថប្រយោជន៍អ្វីមួយ ។

## មាត្រា ៨៩ : កិច្ចព្រមព្រៀងអន្តរជាតិ

បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងអន្តរជាតិទាក់ទិននឹងបញ្ហាពន្ធ ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយ ត្រូវមានវិសាលភាពគ្របដណ្តប់លើបទប្បញ្ញត្តិនៃច្បាប់នេះ ។

## មាត្រា ៩០ : ភាសាប្រើនៅក្នុងលិខិតប្រកាស និង ឯកសារសារពើពន្ធ

លិខិតប្រកាសសារពើពន្ធទាំងអស់ ក៏ដូចជាឯកសារ និងលិខិតទាក់ទងផ្សេងៗដែលចាំបាច់សម្រាប់ការកំណត់ពន្ធ ការប្រមូលពន្ធ និងការបង្ខំឱ្យប្រតិបត្តិតាមច្បាប់ពន្ធ ឬដែលជាប់ទាក់ទងនឹងបែបបទផ្សេងទៀតក្នុងការកំណត់ពន្ធ ត្រូវធ្វើជាភាសាខ្មែរ ។

# ផ្នែកទី ២
# សិទ្ធិ និង ភាតព្វកិច្ច

## មាត្រា ៩១ : សិទ្ធិ និង ភាតព្វកិច្ចរបស់អ្នកជាប់ពន្ធ

សិទ្ធិ និង ភាតព្វកិច្ចរបស់អ្នកជាប់ពន្ធ ត្រូវបានកំណត់ដូចតទៅ :

១- អ្នកជាប់ពន្ធមានសិទ្ធិដូចតទៅ :

ក- ត្រូវបានទុកជាការសម្ងាត ហើយត្រូវបានយកមកប្រើប្រាស់តែក្នុងគោលដៅ ដែលមានបញ្ជាក់នៅក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារនូវពត៌មាននានាទាក់ទិននឹងកិច្ចការរកស៊ីរកម្មរបស់ខ្លួនដែលបានផ្តល់ឱ្យរដ្ឋបាលសារពើពន្ធ ដូចមានចែងក្នុងមាត្រា ៩៤ នៃច្បាប់នេះ ។

ខ- ទទួលពត៌មានជាប្រចាំអំពីកិច្ចដំណើរការនៃប្រព័ន្ធពន្ធដារ ហើយនិងនីតិវិធីនៃការកំណត់ពន្ធ ដូចមានចែងក្នុងមាត្រា ៩៦ និង មាត្រា ១១៨ នៃច្បាប់នេះ ។

គ- ទទួលពត៌មានអំពីសិទ្ធិរបស់ខ្លួនរួមទាំងសិទ្ធិក្នុងការប្តឹងតវ៉ាដូចមានចែងក្នុងមាត្រា ១១៨ និងមាត្រា ១២២ នៃច្បាប់នេះ។

ឃ- ប្តឹងតវ៉ាដូចមានចែងនៅក្នុងច្បាប់នេះ ចំពោះរាល់សេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធ ដូចមានចែងក្នុងមាត្រា ១១៨ និង មាត្រា ១២២ នៃច្បាប់នេះ ។

ង- បង់ពន្ធមិនឱ្យលើសពីបទប្បញ្ញត្តិស្តីពីពន្ធដារកំណត់ ដូចមានចែងក្នុងមាត្រា ១០៧ នៃច្បាប់នេះ។

២- អ្នកជាប់ពន្ធមានកាតព្វកិច្ចដូចតទៅ :

ក- ចុះឈ្មោះក្នុងបញ្ជីរបស់រដ្ឋបាលសារពើពន្ធ ដូចមានចែងនៅក្នុងមាត្រា ១០១ នៃច្បាប់នេះ ។

ខ- ដាក់លិខិតប្រកាសសារពើពន្ធ និង ផ្តល់ពត៌មានតាមការតម្រូវនៃបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចមានចែងក្នុងមាត្រា ៩៨ និង មាត្រា ១០៤ នៃច្បាប់នេះ ។

គ- បង់ពន្ធតាមកាលបរិច្ឆេទកំណត់ ដូចមានចែងនៅក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ។

ឃ- កាន់កាប់ ថែរក្សា និងត្រូវបង្ហាញបញ្ជី លិខិតយុត្តិកា និងឯកសារផ្សេងៗដល់រដ្ឋបាលសារពើពន្ធ ដូចមានចែងនៅក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ និងមាត្រា ៩៨ នៃច្បាប់នេះ ។

ង- បង្ហាញខ្លួនចំពោះរដ្ឋបាលសារពើពន្ធតាមកាលបរិច្ឆេទ ដែលមានចុះនៅក្នុងលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ ដូចមានចែងក្នុងមាត្រា ៩៩ នៃច្បាប់នេះ ។

ច- បង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗ ដែលរដ្ឋបាលសារពើពន្ធបានកំណត់ទៅតាមកាលបរិច្ឆេទ ដូចមានចែងនៅក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ឬដែលរដ្ឋបាលសារពើពន្ធបានជូនដំណឹងជាលាយលក្ខណ៍អក្សរ ដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ និងមាត្រា១០៧ មាត្រា១៣០ មាត្រា១៣១ និងមាត្រា១៣២ នៃច្បាប់នេះ ។

## មាត្រា ៩២ : អំណាច និង ភារកិច្ចរបស់រដ្ឋបាលសារពើពន្ធ

អំណាចរបស់រដ្ឋបាលសារពើពន្ធមានដូចខាងក្រោមនេះ

១- កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ដូចមានចែងក្នុងមាត្រា ១១៦ និងមាត្រា ១១៧ នៃច្បាប់នេះ ។

២- តម្រូវឱ្យអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកបង្ហាញខ្លួន ដូចមានចែងក្នុងមាត្រា ៩៩ នៃច្បាប់នេះ។

៣- កំណត់បញ្ជី ឯកសារចាំបាច់នានា និងលិខិតយុត្តិការដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវកាន់រក្សាទុក និងផ្តល់ជូនរដ្ឋបាលសារពើពន្ធ ដូចមានចែងក្នុងមាត្រា ៩៨ និងមាត្រា ១០០ នៃច្បាប់នេះ ។

៤- ទាមទារឱ្យអ្នកជាប់ពន្ធ ឬតតិយជនផ្តល់ពត៌មានទាក់ទិននឹងអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ដូចមានចែងក្នុងមាត្រា ៩៩ នៃច្បាប់នេះ ។

៥- ចូលលំនៅដ្ឋាន ឬគ្រឹះស្ថានអាជីវកម្មរបស់អ្នកជាប់ពន្ធ ភ្នាក់ងារកាត់ទុក ឬតតិយជន ដើម្បីទទួលបាននូវពត៌មានទាក់ទិននឹងអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ដូចមានចែងក្នុងមាត្រា ១០០ នៃច្បាប់នេះ

៦- ទទួលពីស្ថាប័នរដ្ឋទាំងឡាយនូវពត៌មានស្តីពី ឬដែលទាក់ទិននឹងអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ដូចមានចែងក្នុងមាត្រា ១១៦ នៃច្បាប់នេះ ។

៧- អនុវត្តវិធានការតឹងទារចំពោះអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកនៅពេលដែលបុគ្គលនោះមិនបានបង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗតាមការតម្រូវនៃច្បាប់នេះ ដូចមានចែងក្នុងមាត្រា ១០៩ ដល់មាត្រា ១១៥ នៃច្បាប់នេះ ។

៨- កំណត់ឡើងវិញនូវកិច្ចការជំនួញរវាងអ្នកជាប់ពន្ធទាំងឡាយដែលមានជាប់ទាក់ទង ដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ។

រដ្ឋបាលសារពើពន្ធមានភារកិច្ចដូចតទៅ :

១-	ប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗ ដូចមានចែងក្នុងមាត្រា ៩៣ នៃ ច្បាប់នេះ ។

២-	រក្សាការសម្ងាត់នូវពត៌មានដែលអ្នកជាប់ពន្ធ ឬតតិយជនបានផ្តល់ឱ្យ ហើយផ្តល់ពត៌មានទាំងនេះអោយដល់តែបុគ្គលណាដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានកំណត់ប៉ុណ្ណោះ ដូចមានចែងក្នុងមាត្រា៩៤ មាត្រា ១២៨ និងមាត្រា ១៣៨ នៃច្បាប់នេះ។

៣-	ផ្តល់ពត៌មានដល់អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក សំដៅធានាឱ្យការអនុវត្តបានសមស្របទៅតាមបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចមានចែងក្នុងមាត្រា ៩៦ នៃច្បាប់នេះ ។

៤-	បង្វិលសងវិញ ឬចាត់ជាឥណទានពន្ធនូវប្រាក់ពន្ធដែលបង់លើស ដូចដែលមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ។

៥-	ផ្តល់លិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឱ្យអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ដូចមានចែងនៅក្នុងមាត្រា ១១៦ ដល់មាត្រា ១១៨ នៃច្បាប់នេះ ។

# ផ្នែកទី ៣
# រដ្ឋបាលសារពើពន្ធ

## មាត្រា ៩៣ : ការទទួលខុសត្រូវក្នុងការអនុវត្តន៍ច្បាប់ពន្ធដារ

ស្ថាប័នទាំងឡាយ ដែលទទួលខុសត្រូវគ្រប់គ្រងការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារមានដូចខាងក្រោម:

- នាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ស្ថាប័នដទៃទៀតរបស់រាជរដ្ឋាភិបាលដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានផ្តល់អំណាចឱ្យ ។

រដ្ឋបាលសារពើពន្ធមានកាតព្វកិច្ចប្រមូលពន្ធ អនុវត្តទោសទណ្ឌតាមការកំណត់នៃបទប្បញ្ញត្តិស្តីពីពន្ធដារ និងប្តឹងទៅតុលាការ ក្នុងករណីមានការរំលោភច្បាប់ ។

## មាត្រា ៩៤ : ភាពសម្ងាត់នៃពត៌មានពន្ធដារ

រដ្ឋបាលសារពើពន្ធ ហើយនិងបុគ្គលគ្រប់រូបដែលជា ឬធ្លាប់ជាមន្ត្រី និងភ្នាក់ងារនៃរដ្ឋបាលសារពើពន្ធ ត្រូវរក្សាសម្ងាត់នូវពត៌មានទាក់ទងនឹងអ្នកជាប់ពន្ធដែលបានទទួលនៅក្នុងពេលបំពេញភារកិច្ចជាផ្លូវការ ហើយអាចផ្តល់ពត៌មានទៅឱ្យតែបុគ្គលដែលមាត្រានេះបានអនុញ្ញាតប៉ុណ្ណោះ ។

មន្ត្រី និង ភ្នាក់ងារនៃរដ្ឋបាលសារពើពន្ធអាចផ្តល់ពត៌មានទាក់ទិននឹងអ្នកជាប់ពន្ធឱ្យចំពោះតែ :

១-	មន្ត្រី និងភ្នាក់ងារផ្សេងទៀតរបស់រដ្ឋបាលសារពើពន្ធនៅក្នុងពេល និងក្នុងគោលដៅបំពេញភារកិច្ចតាមបទប្បញ្ញត្តិស្តីពីពន្ធដារ។

២-	អាជ្ញាធរព្រហ្មទណ្ឌ សម្រាប់គោលដៅប្តឹងចោទប្រកាន់អំពីបទល្មើសពន្ធដារ ។

៣-	តុលាការនៅក្នុងដំណាក់ការជំរះក្តី ដើម្បីកំណត់ពន្ធត្រូវបង់របស់អ្នកជាប់ពន្ធ ឬក៏ការទទួលខុសត្រូវចំពោះការរំលោភបទប្បញ្ញត្តិស្តីពីពន្ធដារ ។

៤- អាជ្ញាធរពន្ធដាររបស់ប្រទេសណាមួយទៀត ស្របតាមកិច្ចព្រមព្រៀងអន្តរជាតិ ។

បុគ្គលដែលបានទទួលពត៌មានពីបុគ្គលម្នាក់ទៀតដែលបានការអនុញ្ញាតឱ្យផ្តល់ពត៌មាន ដូចមានចែងក្នុងកថាខ័ណ្ឌ ២ នៃមាត្រានេះ ត្រូវរក្សាសម្ងាត់លើពត៌មាននោះទៅតាមការកំណត់នៃមាត្រានេះ លើកលែងតែកិរិតអប្បបរមាណាមួយដែលចាំបាច់ត្រូវអនុញ្ញាតឱ្យផ្តល់ពត៌មាននេះ ។

ពត៌មានទាក់ទិននឹងអ្នកជាប់ពន្ធ អាចផ្តល់ទៅឱ្យបុគ្គលម្នាក់ទៀតបាន បើសិនមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអ្នកជាប់ពន្ធ ។

## *មាត្រា ៩៥ (ថ្មី) : ការផ្តល់ពត៌មានដល់អ្នកជាប់ពន្ធ*

*១- លិខិតស្នាម ឬលិខិតជូនដំណឹងដែលរដ្ឋបាលសារពើពន្ធផ្តល់ទៅឱ្យអ្នកជាប់ពន្ធ មានលក្ខណៈជាការដាក់ឱ្យអ្នកជាប់ពន្ធនោះ មានកាតព្វកិច្ចចំពោះរដ្ឋបាលសារពើពន្ធ លុះណាតែលិខិតស្នាម ឬលិខិតជូនដំណឹងនោះត្រូវបានធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវបានប្រគល់ឱ្យដល់អ្នកជាប់ពន្ធ ។*

*២- ក្នុងករណីដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវឱ្យរដ្ឋបាលសារពើពន្ធផ្តល់លិខិតស្នាម ឬដំណឹងជាលាយលក្ខណ៍អក្សរទៅឱ្យបុគ្គល លិខិតស្នាម ឬលិខិតជូនដំណឹងនោះត្រូវបានចាត់ទុកថាបានប្រគល់យ៉ាងត្រឹមត្រូវ លុះណាតែបានប្រគល់ឱ្យបុគ្គលនោះ ឬក៏បានផ្ញើតាមប្រៃសណីយ៍ជាលិខិតអនុសិដ្ឋទៅអាស័យដ្ឋានតាមផ្លូវច្បាប់របស់បុគ្គលនោះ ។*

*៣- កាលបរិច្ឆេទនៃលិខិតស្នាម ឬលិខិតជូនដំណឹងផ្សេងៗ គឺជាកាលបរិច្ឆេទនៃការប្រគល់ឱ្យបុគ្គល ។ ក្នុងករណីលិខិតស្នាម ឬលិខិតជូនដំណឹងត្រូវបានផ្ញើតាមលិខិតអនុសិដ្ឋ កាលបរិច្ឆេទនៃការជូនដំណឹងគឺជាកាលបរិច្ឆេទនៃការបោះត្រាលើលិខិតអនុសិដ្ឋរបស់ការិយាល័យប្រៃសណីយ៍ ។*

*៤- លិខិតស្នាម ឬលិខិតជូនដំណឹងត្រូវចាត់ទុកថាបានប្រគល់ទទួលត្រឹមត្រូវកាលបើល័ក្ខខ័ណ្ឌក្នុងកថាខ័ណ្ឌ ២ នៃមាត្រានេះត្រូវបានបំពេញរួចហើយ ទោះបីជាបុគ្គលដែលត្រូវបានជូនដំណឹងនោះបដិសេធការប្រគល់ ឬការទទួលលិខិតអនុសិដ្ឋក្តី ។*

*៥- ក្នុងករណីដែលអាសយដ្ឋានរបស់បុគ្គលត្រូវបានផ្លាស់ប្តូរ ហើយបុគ្គលមិនបានជូនដំណឹងដល់រដ្ឋបាលសារពើពន្ធអំពីការផ្លាស់ប្តូរនោះទេ លិខិតស្នាម ឬលិខិតជូនដំណឹងដែលបានបញ្ជូនទៅអាស័យដ្ឋានដែលបានស្គាល់ចុងក្រោយបង្អស់ ត្រូវចាត់ទុកថាបានប្រគល់ទទួលត្រឹមត្រូវ ។*

*៦- ក្នុងករណីដោយមូលហេតុណាមួយដែលលិខិតស្នាម ឬលិខិតជូនដំណឹងមិនអាចផ្តល់ដល់អ្នកជាប់ពន្ធ ដូចមានចែងក្នុងកថាខ័ណ្ឌ១ កថាខ័ណ្ឌ២ កថាខ័ណ្ឌ៣ កថាខ័ណ្ឌ៤ និង កថាខ័ណ្ឌ៥ នៃមាត្រានេះ លិខិតស្នាម ឬលិខិតជូនដំណឹងត្រូវបានចាត់ទុកថាបានប្រគល់យ៉ាងត្រឹមត្រូវ ប្រសិនបើរដ្ឋបាលសារពើពន្ធបាន :*

*ក- បិទលិខិតស្នាម ឬលិខិតជូនដំណឹងភ្ជាប់ទៅនឹងទ្វារនិវាសនដ្ឋាន ឬទីកន្លែងប្រកបអាជីវកម្មរបស់អ្នកជាប់ពន្ធ ឬ*

*ខ- ផ្សព្វផ្សាយតាមសារពត៌មាន ដោយតម្រូវឱ្យអ្នកជាប់ពន្ធចូលមករដ្ឋបាលសារពើពន្ធមិនឱ្យលើសពី ១៥ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទផ្សព្វផ្សាយ ។*

## មាត្រា ៩៦ : ការផ្សព្វផ្សាយ និង ការពន្យល់ណែនាំច្បាប់ពន្ធដារ

រដ្ឋបាលសារពើពន្ធត្រូវរៀបចំសៀវភៅពន្យល់ខ្លីៗ ស្តីពីខ្លឹមសារសំខាន់ៗនៃប្រភេទពន្ធនីមួយៗ ។

ចំពោះប្រភេទពន្ធណាមួយដែលរដ្ឋបាលសារពើពន្ធកំណត់ថាគួរចុះធ្វើការពន្យល់ណែនាំនោះ មន្ត្រីពន្ធដារនៅតាមមូលដ្ឋាន ត្រូវចុះអប់រំដល់អ្នកជាប់ពន្ធឱ្យបានយល់អំពីកាតព្វកិច្ច និង សិទ្ធិរបស់អ្នកជាប់ពន្ធទាំងនោះ ។

## មាត្រា ៩៧ : ការលើកទឹកចិត្តចំពោះការប្រមូលពន្ធជាក់ស្តែង និង មានប្រសិទ្ធិភាព

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវកសាងប្រព័ន្ធលើកទឹកចិត្តមួយសម្រាប់មន្ត្រីភ្នាក់ងាររដ្ឋបាលសារពើពន្ធ ។ នីតិវិធីសម្រាប់ដំណើរការប្រព័ន្ធលើកទឹកចិត្តនេះ ត្រូវកំណត់ដោយប្រកាស ។

## មាត្រា ៩៨ : ការកាន់កត់ត្រា ការរក្សាទុកបញ្ជីលិខិតយុត្តិការ និង ឯកសារហិរញ្ញវត្ថុ

អ្នកជាប់ពន្ធត្រូវកាន់កាប់កត់ត្រា និងរក្សាទុកបញ្ជី លិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុផ្សេងៗ ដូចដែលបទប្បញ្ញត្តិស្តីពីពន្ធដារ បានកំណត់ និង ត្រូវដាក់បញ្ជី និងឯកសារទាំងនោះតាមការតម្រូវជូនរដ្ឋបាលសារពើពន្ធដើម្បីពិនិត្យ ។

ចំពោះអ្នកជាប់ពន្ធដែលពុំមានកាតព្វកិច្ចកាន់កាប់បញ្ជីគណនេយ្យតាមប្លង់គណនេយ្យទូទៅនៃព្រះរាជាណាចក្រកម្ពុជា ត្រូវកាន់ទិនានុប្បវត្តិ ដោយកត់ត្រាចុះតាមលំដាប់ថ្ងៃខែនូវចំណូល និងចំណាយផ្សេងៗទាំងអស់ដែលទាក់ទិននឹងអាជីវកម្មទៅតាម ទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់ ។

បុគ្គលដែលត្រូវកាន់កាប់កត់ត្រា ឬរក្សាទុកបញ្ជី ឯកសារនានា ឬទិនានុប្បវត្តិដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារ ឬបទប្បញ្ញត្តិដទៃ ត្រូវរក្សាទុកបញ្ជី ឬឯកសារទាំងនោះក្នុងរយៈពេល ១០ ឆ្នាំ គិតពីដំណាច់ឆ្នាំជាប់ពន្ធ ។

វិក្កយបត្រត្រូវតែចេញឱ្យលើរាល់កិច្ចការជំនួញរវាងអ្នកជាប់ពន្ធនិងបុគ្គលដទៃទៀត ។ វិធាន និងខ្លឹមសារនៃវិក្កយបត្រត្រូវកំណត់ដោយអនុក្រឹត្យ ។

អ្នកជាប់ពន្ធត្រូវកត់ត្រាសេចក្តីរាយលំអិតនៃវិក្កយបត្រឱ្យបានត្រឹមត្រូវចូលក្នុងទិនានុប្បវត្តិ ។

## មាត្រា ៩៩ : សិទ្ធិទទួលពត៌មាន

ក្នុងគោលដៅកំណត់ប្រាក់ពន្ធត្រូវបង់របស់បុគ្គលណាម្នាក់ ឬដើម្បីប្រមូលពន្ធ រដ្ឋបាលសារពើពន្ធអាចធ្វើលិខិតជូនដំណឹងដល់អ្នកជាប់ពន្ធ ឬតតិយជនឱ្យ :

- ផ្តល់ពត៌មានដែលទាក់ទិននឹងអ្នកជាប់ពន្ធដូចមានចែងក្នុងលិខិតជូនដំណឹង ដូចជាពត៌មានស្តីពីអ្នកផ្គត់ផ្គង់ អតិថិជន ឬគណនីនៅធនាគារ
- បង្ហាញខ្លួនទៅតាមពេលវេលា និងទីកន្លែងដែលមានបញ្ជាក់នៅក្នុងលិខិតជូនដំណឹងដើម្បីផ្តល់ពត៌មាន និងដើម្បីបង្ហាញ ឬផ្តល់ឯកសារឬទិន្នន័យដែលបុគ្គលនោះគ្រប់គ្រង ដែលមានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងលិខិតជូនដំណឹង

បន្ថែមលើពត៌មានដែលបានតម្រូវដូចមានចែងនៅក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ លិខិតជូនដំណឹងត្រូវមានចុះឈ្មោះ និងលេខអត្តសញ្ញាណកម្មនៃបុគ្គលអ្នកជាប់ពន្ធ (បើសិនជាមាន) ហើយនិងហត្ថលេខារបស់រដ្ឋបាលសារពើពន្ធដែលចេញលិខិតជូនដំណឹង ។

## មាត្រា ១០០ : អំណាចក្នុងការស៊ើបអង្កេត

ចំពោះមុខ សម្រាប់ការស៊ើបអង្កេតនីមួយៗដោយមានលិខិតបញ្ជាបេសកកម្ម រដ្ឋបាលសារពើពន្ធមានសិទ្ធិចូលទៅក្នុងគ្រឹះស្ថានអាជីវកម្ម ទីកន្លែងដែលបានចាត់ទុកថាជាគ្រឹះស្ថានអាជីវកម្ម ជាកន្លែងដែលបើកជាសាធារណៈ ឬទីកន្លែងដទៃទៀតដើម្បីធ្វើការកំណត់ប្រាក់ពន្ធត្រូវបង់របស់បុគ្គលណាម្នាក់ ឬដើម្បីប្រមូលពន្ធ ៖

- នៅក្នុងពេលម៉ោងអាជីវកម្ម
- នៅគ្រប់ពេលទាំងអស់ស្របតាមលក្ខខណ្ឌ និងហេតុផលដែលមានបញ្ជាក់នៅក្នុងដីកាដែលចៅក្រមបានចេញឱ្យ

រដ្ឋបាលសារពើពន្ធដែលបានចូលដោយស្របច្បាប់ទៅក្នុងទីកន្លែងដូចដែលមានចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះអាចៈ

- ធ្វើសម្រង់ ឬចម្លងឯកសារនានាដែលស្ថិតនៅក្នុងកន្លែងនោះ
- រឹបអូសឯកសារនានា ឬវត្ថុតាងដទៃទៀតដែលអាចក្លាយជាពត៌មានសម្រាប់កំណត់ប្រាក់ពន្ធត្រូវបង់របស់បុគ្គលណាម្នាក់
- ដាក់ឧបករណ៍សម្រាប់ត្រួតពិនិត្យផ្សេងៗ ឬបោះត្រាបិទសំគាល់ឃាត់ទុកទំនិញ បើសិនជាមានជាប់ទាក់ទងដល់ការអនុវត្តន៍ពន្ធណាមួយ
- ធ្វើសារពើភ័ណ្ឌទ្រព្យសកម្ម វត្ថុធាតុដើម ផលិតផលកំពុងផលិត ផលិតផលសម្រេច និងស្តុកដទៃទៀត ។

រដ្ឋបាលសារពើពន្ធអាចតម្រូវឱ្យស្ថាប័នធនាគារដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ផ្តល់ពត៌មានអំពីគណនីរបស់អ្នកជាប់ពន្ធនៅធនាគារ ។

ពេលចូលទៅធ្វើការស៊ើបអង្កេត រដ្ឋបាលសារពើពន្ធត្រូវមានអាកប្បកិរិយាសមរម្យ ចៀសវាងប្រការដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងអាជីវកម្មរបស់អ្នកជាប់ពន្ធ ។ ទោះជាយ៉ាងណាក៏ដោយ ការស៊ើបអង្កេតដល់ទីកន្លែងនេះពុំត្រូវអនុវត្តឱ្យហួសកំរិតនៃការចាំបាច់ឡើយ ។

## មាត្រា ១០១ ៖ ភាតព្វកិច្ចចុះបញ្ជី

បុគ្គលទាំងឡាយត្រូវទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងកំឡុង ១៥ថ្ងៃ ក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច។

បុគ្គលទាំងឡាយត្រូវជូនដំណឹងទៅរដ្ឋបាលសារពើពន្ធក្នុងរយៈពេល ១៥ ថ្ងៃ ក្រោយពីការផ្លាស់ប្តូរអាសយដ្ឋានទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម ការផ្ទេរ ការបញ្ឈប់អាជីវកម្ម សមាសភាពអ្នកគ្រប់គ្រងឬអ្នកទទួលបន្ទុកកិច្ចការពន្ធដាររបស់សហគ្រាស។

## មាត្រា ១០២ ៖ លិខិតបញ្ជាក់ការចុះបញ្ជី និង លេខអត្តសញ្ញាណកម្មសារពើពន្ធ

នៅពេលបានអនុវត្តការចុះបញ្ជីរួចរាល់ហើយ រដ្ឋបាលសារពើពន្ធត្រូវចេញនូវលិខិតបញ្ជាក់ការចុះបញ្ជីមួយដែលមានចុះលេខអត្តសញ្ញាណកម្មសារពើពន្ធរបស់បុគ្គល ។ លេខអត្តសញ្ញាណកម្មនេះ ត្រូវយកទៅប្រើលើគ្រប់ឯកសារទាក់ទិននឹងពន្ធដារ ។

គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវតែប្រើលេខអត្តសញ្ញាណកម្មក្នុងមាត្រានេះ ។ រាល់កិច្ចសន្យាជាមួយស្ថាប័នរដ្ឋ ត្រូវតែមានចុះលេខអត្តសញ្ញាណកម្មសារពើពន្ធទើបទុកជាបានការ ។

### មាត្រា ១០៣ : សិទ្ធិរបស់រដ្ឋបាលសារពើពន្ធក្នុងការចុះបញ្ជីអ្នកជាប់ពន្ធ

រដ្ឋបាលសារពើពន្ធមានសិទ្ធិចុះបញ្ជីចំពោះបុគ្គលទាំងឡាយដែលច្បាប់បានកំណត់ឱ្យចុះបញ្ជីហើយពុំបានមកចុះបញ្ជី ក្នុងករណីនេះរដ្ឋបាលសារពើពន្ធអាចកំណត់កាលបរិច្ឆេទមានប្រសិទ្ធិភាពនៃការចុះបញ្ជី ។

## ផ្នែកទី ៤

## ប្រកាសសារពើពន្ធ

### *មាត្រា ១០៤ (ថ្មី) : ការរៀបចំ និង ដាក់លិខិតប្រកាសសារពើពន្ធ*

*១- អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ត្រូវដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ ពេលវេលា និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់ ។*

*២- លិខិតប្រកាសសារពើពន្ធ ត្រូវចុះហត្ថលេខាដោយអ្នកជាប់ពន្ធ ឬតំណាងស្របច្បាប់របស់អ្នកជាប់ពន្ធ ។*

*៣- អ្នកវិនិយោគទាំងអស់ត្រូវដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែសម្រាប់ខែនីមួយៗ និង លិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំ សម្រាប់ឆ្នាំសារពើពន្ធនោះ និង បង់ពន្ធអាករទាំងអស់ទៅតាមបទប្បញ្ញត្តិនៃពន្ធនីមួយៗ*

*៤- អ្នកវិនិយោគទាំងអស់ត្រូវភ្ជាប់នូវវិញ្ញាបនបត្ររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បញ្ជាក់ពីការគោរពប្រតិបត្តិជាមួយលិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំសារពើពន្ធនោះ ។*

### មាត្រា ១០៥ : ការរៀបចំ និង ដាក់លិខិតប្រកាសពត៌មាន និង ឯកសារផ្សេងទៀត

បុគ្គលណាមួយដែលបានបើកប្រាក់អោយទៅបុគ្គលផ្សេងទៀត ត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធនូវលិខិតប្រកាសពត៌មានស្តីពីការបើកប្រាក់នោះទៅតាមបែបបទដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ ។

### មាត្រា ១០៦ : តំណាងអ្នកជាប់ពន្ធ

បុគ្គលដែលជាតំណាងអ្នកជាប់ពន្ធ ត្រូវមានសិទ្ធិជំនួសមុខឱ្យអ្នកជាប់ពន្ធដើម្បី :

- ដាក់លិខិតប្រកាសសារពើពន្ធ
- បង្ហាញរបាយការណ៍ ឬលិខិតស្នាមផ្សេងៗ
- បង់ពន្ធអាករទាំងឡាយដែលកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារ
- ធ្វើបណ្តឹងតវ៉ា និង បណ្តឹងឧទ្ធរណ៍

-　បំពេញរាល់កាតព្វកិច្ច ដែលអ្នកជាប់ពន្ធត្រូវទទួលខុសត្រូវចំពោះមុខបទប្បញ្ញត្តិស្តីពីពន្ធដារ ។

អ្នកជាប់ពន្ធអាចធ្វើការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរទៅឱ្យបុគ្គលម្នាក់ទៀត ឱ្យធ្វើសកម្មភាពជំនួសមុខខ្លួនក្នុងបញ្ហាពន្ធដារ ដោយមានសិទ្ធិ និងកាតព្វកិច្ចដូចមានចែងនៅក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ ។ អ្នកជាប់ពន្ធអាចកំណត់ព្រំដែនសិទ្ធិអំណាចនៃការផ្ទេរសិទ្ធិនេះ ។

រដ្ឋបាលសារពើពន្ធ អាចតម្រូវឱ្យបុគ្គលដែលធ្វើសកម្មភាពក្នុងនាមអ្នកជាប់ពន្ធលើមូលដ្ឋាននៃការផ្ទេរសិទ្ធិដាក់ជូនពិនិត្យនូវភស្តុតាងជាលាយលក្ខណ៍អក្សរនៃការផ្ទេរសិទ្ធិនោះ ។

អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចទទួលខុសត្រូវដោយផ្ទាល់ចំពោះរាល់សកម្មភាពរបស់បុគ្គលដែលជាតំណាងតាមផ្លូវច្បាប់របស់ខ្លួន ឬបុគ្គលដែលបានទទួលការផ្ទេរសិទ្ធិពីខ្លួន រហូតដល់ពេលណាដែលរដ្ឋបាលសារពើពន្ធបានទទួលសេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សរពីអ្នកជាប់ពន្ធស្តីអំពីការលុបចោលនូវការផ្ទេរសិទ្ធិនោះ ។

បុគ្គលដែលជាតំណាងរបស់អ្នកជាប់ពន្ធ ត្រូវចុះបញ្ជីនូវទំនាក់ទំនងរបស់ខ្លួននៅរដ្ឋបាលសារពើពន្ធក្នុងកំឡុងពេល ១៥ ថ្ងៃ ក្រោយពេលដែលទំនាក់ទំនងនោះបានកើតឡើង ។

## ផ្នែកទី ៥
## ការប្រមូលពន្ធ

### មាត្រា ១០៧ : ការបង់ពន្ធ

ការបង់ពន្ធត្រូវបានកំណត់ដូចតទៅ :

១- ប្រាក់ពន្ធត្រូវដល់កំណត់ និង ត្រូវបង់នៅក្នុងរយៈពេលដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានតម្រូវឱ្យធ្វើការដាក់លិខិតប្រកាសសារពើពន្ធ ។

២- បំណុលសារពើពន្ធត្រូវដល់កំណត់ និងត្រូវបង់ក្នុងរយៈពេល ៣០ ថ្ងៃក្រោយពីការប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធ។

៣- ប្រាក់ពន្ធត្រូវដល់កំណត់ និងត្រូវបង់ក្នុងរយៈពេល ៣ ថ្ងៃក្រោយពីការប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធដូចមានចែងក្នុងកថាខ័ណ្ឌ ៤ មាត្រា ១១៦ នៃច្បាប់នេះ ។

៤- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងកំណត់ដោយប្រកាសនូវវិធាន និង នីតិវិធី ដើម្បី :

ក- កំណត់កាលបរិច្ឆេទទារបំណុលពន្ធដើម្បីចៀសវាងការខាតបង់ដោយទារបំណុលពន្ធមិនបាន ។

ខ- ចាត់ទុកបំណុលពន្ធជាប្រាក់ពន្ធដែលមិនអាចប្រមូលបាន ។

### មាត្រា ១០៨ : ការទទួលខុសត្រូវរបស់អភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករ

ប្រសិនបើអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិកររបស់សហគ្រាសណាមួយដឹងឮ ឬមានចេតនាធ្វើឱ្យសហគ្រាសមិនរាយការណ៍ ឬរាយការណ៍បន្ថយនូវប្រាក់ពន្ធដោយរំលោភទៅលើបទប្បញ្ញត្តិស្តីពីពន្ធដារ ឬមិនឱ្យបង់ពន្ធកាត់ទុកជូនរដ្ឋបាលសារពើពន្ធ អភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករទាំងនោះត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះប្រាក់ពន្ធដែលត្រូវបង់ ។

## ផ្នែកទី ៦

## អំណាចរបស់រដ្ឋបាលសារពើពន្ធក្នុងការប្រមូលប្រាក់ពន្ធ

### មាត្រា ១០៩ : សិទ្ធិឃុំគ្រងលើទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ

ប្រសិនបើបុគ្គលដែលមានកាតព្វកិច្ចបង់ពន្ធតាមការតម្រូវនៃបទប្បញ្ញត្តិស្តីពីពន្ធដារ ធ្វេសប្រហែស ឬបដិសេធមិនព្រមបង់ពន្ធ ក្រោយពេលដែលលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធត្រូវបានប្រគល់ត្រឹមត្រូវ រដ្ឋបាលសារពើពន្ធត្រូវមានសិទ្ធិឃុំគ្រងលើទ្រព្យសម្បត្តិបុគ្គលនោះសមស្របនឹងបំណុលពន្ធ ។ សិទ្ធិឃុំគ្រងលើទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធកើតមានឡើងនៅថ្ងៃដែលលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ ត្រូវបានប្រគល់ទៅអោយអ្នកជាប់ពន្ធ ដូចមានចែងក្នុងមាត្រា ៩៥ថ្មី នៃច្បាប់នេះ។

បើលក្ខខ័ណ្ឌទាំងឡាយនៃមាត្រានេះត្រូវបានបំពេញត្រឹមត្រូវហើយនោះ សិទ្ធិឃុំគ្រងលើទ្រព្យសម្បត្តិដូចមានចែងក្នុងកថាខ័ណ្ឌ ១ មានសុពលភាព និងអាទិភាពលើសិទ្ធិដទៃទៀតទាំងអស់ដែលមានពីមុនមក ឬដែលកើតឡើងក្រោយសិទ្ធិឃុំគ្រងលើទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ ។

បុគ្គលទាំងឡាយអាចធ្វើការតវ៉ាទៅរដ្ឋបាលសារពើពន្ធ ដើម្បីសុំឱ្យលើកសិទ្ធិឃុំគ្រងលើទ្រព្យសម្បត្តិរបស់ខ្លួន ដូចមានចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ ដោយលើកឡើងនូវកំហុសឆ្គងក្នុងការដាក់សិទ្ធិនោះ ។

ប្រសិនបើរដ្ឋបាលសារពើពន្ធបានពិនិត្យឃើញថា ការដាក់សិទ្ធិឃុំគ្រងលើទ្រព្យសម្បត្តិនោះមានការខុសឆ្គង រដ្ឋបាលសារពើពន្ធ ត្រូវចេញលិខិតបញ្ជាក់អំពីការលើកសិទ្ធិឃុំគ្រងលើទ្រព្យសម្បត្តិក្នុងរយៈពេល១០ ថ្ងៃបន្ទាប់ពីពិនិត្យឃើញ ព្រមទាំងចុះក្នុងលិខិតបញ្ជាក់នោះថា ការដាក់សិទ្ធិឃុំគ្រងនោះមានការខុសឆ្គង ។

### មាត្រា ១១០ : លិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ

រដ្ឋបាលសារពើពន្ធត្រូវផ្ញើលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធទៅអ្នកជាប់ពន្ធយ៉ាងតិច១៥ ថ្ងៃមុនអនុវត្តវិធានការតឹងទារ ។

### មាត្រា ១១១ : ការរឹបអូស

ការរឹបអូសទ្រព្យសម្បត្តិអ្នកជាប់ពន្ធ ត្រូវបានកំណត់ដូចតទៅ :

១- ប្រសិនបើអ្នកជាប់ពន្ធមិនបានបង់បំណុលពន្ធក្នុងរយៈពេល ១៥ ថ្ងៃ ក្រោយពីបានទទួលលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ រដ្ឋបាលសារពើពន្ធអាចរឹបអូសទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធដើម្បីធានាបំណុលពន្ធ ព្រមទាំងសោហ៊ុយចំណាយក្នុងការប្រមូលពន្ធនោះ ។ សម្រាប់គោលដៅនៃច្បាប់នេះ ពាក្យ "ការរឹបអូស" សំដៅដល់ការរឹបអូសតាមគ្រប់មធ្យោបាយ និងការលក់ទ្រព្យសម្បត្តិអ្នកជាប់ពន្ធដោយរដ្ឋបាលសារពើពន្ធ តែមិនត្រូវរឹបអូសទ្រព្យសម្បត្តិឱ្យហួសពីបំណុលពន្ធ និងចំណាយក្នុងការប្រមូលពន្ធឡើយ ។

២- បុគ្គលដែលមានភារៈកាន់កាប់ និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធដែលត្រូវរដ្ឋបាលសារពើពន្ធរឹបអូស ដូចក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ មិនអាចបង្វិលទ្រព្យសម្បត្តិនោះទៅឱ្យអ្នកជាប់ពន្ធវិញ ឬក៏យកទ្រព្យសម្បត្តិនោះទៅធ្វើការទូទាត់ផ្សេងៗបានទេ លើកលែងតែការទូទាត់ដែលរដ្ឋបាលសារពើពន្ធបានអនុញ្ញាត ។

៣- រដ្ឋបាលសារពើពន្ធ អាចអនុវត្តការរឹបអូសទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធដែលកាន់កាប់ និង គ្រប់គ្រងដោយបុគ្គលដទៃទៀតយ៉ាងតិច ១៥ ថ្ងៃក្រោយពេលជូនដំណឹងដល់អ្នកកាន់កាប់ និង គ្រប់គ្រងទ្រព្យសម្បត្តិនោះ ។

៤- បុគ្គលអ្នកកាន់កាប់ និង គ្រប់គ្រងលើទ្រព្យសម្បត្តិដែលត្រូវរឹបអូស ត្រូវប្រគល់ទ្រព្យសម្បត្តិនោះ ឬក៏បង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម ការប្រាក់ និងសោហ៊ុយចំណាយក្នុងការប្រមូលពន្ធជូនរដ្ឋបាលសារពើពន្ធ លើកលែងតែចំណែកទ្រព្យសម្បត្តិណាមួយដែលស្ថិតនៅក្នុងដំណើរការជំរះបញ្ជីរំលាយសកម្មភាពអាជីវកម្ម ។

៥- បុគ្គលដែលមិនបានប្រគល់ទ្រព្យសម្បត្តិដូចមានចែងក្នុងកថាខ័ណ្ឌ ៤ នៃមាត្រានេះ ត្រូវទទួលខុសត្រូវលើចំនួនទឹកប្រាក់នៃតម្លៃសទ្រព្យសម្បត្តិនោះ ប៉ុន្តែមិនលើសពីចំនួនទឹកប្រាក់ដែលជាកម្មវត្ថុនៃការរឹបអូសនោះទេ ។

៦- បុគ្គលណាដែលបានប្រតិបត្តិតាមការតម្រូវក្នុងកថាខ័ណ្ឌ ២ និងកថាខ័ណ្ឌ ៤ នៃមាត្រានេះ ត្រូវបានរួចផុតអំពីការទទួលខុសត្រូវចំពោះអ្នកជាប់ពន្ធ ឬតតិយជនលើទ្រព្យសម្បត្តិ ប្រាក់ពន្ធ ឬកាតព្វកិច្ចផ្សេងទៀតដែលបានប្រគល់ជូនទៅរដ្ឋបាលសារពើពន្ធ ។

៧- ប្រសិនបើរដ្ឋបាលសារពើពន្ធមានមូលដ្ឋានត្រឹមត្រូវជឿជាក់ថា ការប្រមូលពន្ធអាចមានឧបសគ្គ រដ្ឋបាលសារពើពន្ធអាចទាមទារឱ្យអ្នកជាប់ពន្ធបង់ពន្ធភ្លាម ហើយបើអ្នកជាប់ពន្ធមិនបានបំពេញតាមការទាមទារនេះទេ អាចរឹបអូសទ្រព្យសម្បត្តិអ្នកជាប់ពន្ធភ្លាម ។

៨- ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ដូចមានកំណត់ក្នុងអនុក្រឹត្យ ត្រូវបានរួចផុតពីការរឹបអូស ។

៩- ការលក់ទ្រព្យសម្បត្តិរឹបអូសត្រូវធ្វើឡើងតាមការដាក់ឱ្យដេញថ្លៃ ។ សោហ៊ុយចំណាយផ្សេងៗក្នុងការលក់ទ្រព្យសម្បត្តិ គឺជាបន្ទុករបស់អ្នកជាប់ពន្ធ ។

## មាត្រា ១១២ : កិច្ចការពារអ្នកជាប់ពន្ធ

ទ្រព្យសម្បត្តិដែលត្រូវរឹបអូសដោយច្បាប់នេះ ត្រូវរឹបអូស កាន់កាប់ និងទទួលខុសត្រូវដោយរដ្ឋបាលសារពើពន្ធតែប៉ុណ្ណោះ។ ស្ថាប័នផ្សេងរបស់រាជរដ្ឋាភិបាលមិនអាចប្រើច្បាប់នេះដើម្បីរឹបអូស ឬកាន់កាប់ទ្រព្យសម្បត្តិនោះដោយផ្ទាល់ឡើយ ។ បើមានការលក់នូវទ្រព្យសម្បត្តិដែលបានរឹបអូសដោយច្បាប់នេះ ចំណែកណាមួយនៃប្រាក់លក់បានដែលលើសអំពីបំណុលពន្ធរបស់អ្នកជាប់ពន្ធនៅក្រោមច្បាប់នេះត្រូវបង្វិលទៅឱ្យម្ចាស់កម្មសិទ្ធិទ្រព្យសម្បត្តិនោះវិញ។

## មាត្រា ១១៣ : ការឃាត់ទុកគណនីធនាគារ

ការរឹបអូសក្នុងមាត្រា ១១១ នៃច្បាប់នេះ អាចមានទាំងការឃាត់ទុកគណនីរបស់អ្នកជាប់ពន្ធនៅធនាគារ តាមលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ ហើយដែលមានប្រសិទ្ធិភាពអនុវត្តភ្លាម ក្រោយពីការប្រគល់លិខិតនោះទៅឱ្យធនាគារ ។

តាមរយៈការជូនដំណឹងឱ្យឃាត់ទុកគណនីធនាគារនេះ ធនាគារមិនអាចបើកគណនីថ្មីទៀតឱ្យអ្នកជាប់ពន្ធដដែលបានទេ ហើយក៏មិនអាចធ្វើការទូទាត់ផ្សេងៗចេញពីគណនីនោះបានឡើយ លើកលែងតែការបង់ប្រាក់ដែលរដ្ឋបាលសារពើពន្ធកំណត់ឱ្យដើម្បីទូទាត់ប្រាក់ពន្ធត្រូវបង់ការប្រាក់ ហើយនិងពន្ធបន្ថែមផ្សេងទៀត ។

គណនីធនាគារដែលបានឃាត់ទុក អាចបើកឱ្យប្រើវិញបានលុះត្រាតែមានលិខិតជូនដំណឹងពីរដ្ឋបាលសារពើពន្ធ ។

ធនាគារដែលមិនបានអនុវត្តតាមលិខិតជូនដំណឹងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ត្រូវទទួលខុសត្រូវចំពោះរដ្ឋបាលសារពើពន្ធនូវកំរិតទឹកប្រាក់ដែលមាននៅក្នុងគណនីរបស់អ្នកជាប់ពន្ធនៅពេលដែលលិខិតជូនដំណឹងត្រូវបានប្រគល់ឱ្យ ។

## មាត្រា ១១៤ : ការបញ្ឈប់ប្រតិបត្តិការនាំចេញ-នាំចូល

ការរឹបអូសនៅក្នុងមាត្រា១១១ នៃច្បាប់នេះ អាចរួមបញ្ចូលផងដែរនូវការបញ្ឈប់ប្រតិបត្តិការនាំចេញ-នាំចូល ។ ការបញ្ឈប់ប្រតិបត្តិការនាំចេញ-នាំចូល សំដៅដល់ការឃាត់ទុកដោយរដ្ឋបាលគយនូវទំនិញនាំចូលបញ្ជូនឱ្យអ្នកជាប់ពន្ធ និងទំនិញដែលត្រូវនាំចេញដោយអ្នកជាប់ពន្ធតាមលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធដែលមានប្រសិទ្ធិភាពអនុវត្តភ្លាម ក្រោយពេលដែលលិខិតនោះបានប្រគល់ឱ្យរដ្ឋបាលគយ ។

រដ្ឋបាលសារពើពន្ធអាចរឹបអូស និងលក់ទំនិញរបស់អ្នកជាប់ពន្ធដែលបានឃាត់ទុកដោយរដ្ឋបាលគយទៅតាមល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងមាត្រា ១១១ នៃច្បាប់នេះ ។

ការអនុញ្ញាតឱ្យប្រតិបត្តិការនាំចេញ-នាំចូលរួចពីការបញ្ឈប់ ត្រូវអនុវត្តតាមលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ។

ទំនិញឃាត់ទុកដោយរដ្ឋបាលគយដែលមិនមែនជារបស់អ្នកជាប់ពន្ធ ត្រូវបានរួចផុតពីការឃាត់ទុកដោយមានការយល់ព្រមពីរដ្ឋបាលសារពើពន្ធ ។

## មាត្រា ១១៥ : ការទុកជាមោឃៈនូវលិខិតអនុញ្ញាត និង អាជ្ញាប័ណ្ណ

ការរឹបអូសក្នុងមាត្រា ១១១ នៃច្បាប់នេះ អាចមានទាំងការចេញលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ ទៅកាន់អាជ្ញាធរមានសមត្ថកិច្ចស្នើសុំឱ្យទុកជាមោឃៈនូវលិខិតអនុញ្ញាត និង អាជ្ញាប័ណ្ណផ្សេងៗរបស់អ្នកជាប់ពន្ធដើម្បីអនុវត្តសកម្មភាពណាមួយ ។

# ផ្នែកទី ៧

# ការកំណត់ពន្ធ

## មាត្រា ១១៦ : ការកំណត់ពន្ធ

ចំនួនប្រាក់ពន្ធត្រូវបានកំណត់ដូចតទៅ :

១- ក្នុងករណីដែលប្រាក់ពន្ធរបស់អ្នកជាប់ពន្ធត្រូវបានបង់តាមវិធីកាត់ទុក ហើយអ្នកជាប់ពន្ធគ្មានកាតព្វកិច្ចធ្វើប្រកាសសារពើពន្ធទេនោះ ការកំណត់ពន្ធរបស់អ្នកជាប់ពន្ធ គឺជាការកំណត់ចំនួនប្រាក់ពន្ធដែលបានកាត់ទុកនៅក្នុងឆ្នាំប្រតិទិន ។

២- ក្នុងករណីដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកមានកាតព្វកិច្ចត្រូវដាក់លិខិតប្រកាសសារពើពន្ធ ការកំណត់ពន្ធរបស់អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក គឺជាការកំណត់ពន្ធដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកបានគណនានៅលើលិខិតប្រកាសសារពើពន្ធ ដែលដាក់ជូនរដ្ឋបាលសារពើពន្ធ ។

៣- ក្នុងករណីដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកមានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធ ប៉ុន្តែមិនបានធ្វើលិខិតប្រកាស មិនបានរក្សាទុកឱ្យបានត្រឹមត្រូវនូវបញ្ជីកាគណនេយ្យ ឬឯកសារផ្សេងទៀតតាមការតម្រូវ ឬមិនបានផ្តល់ពត៏មានចាំបាច់

ជូនរដ្ឋបាលសារពើពន្ធដើម្បីកំណត់ពន្ធឱ្យបានត្រឹមត្រូវ ការកំណត់ពន្ធរបស់អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកគឺជាការកំណត់ពន្ធជាឯកតោភាគីដែលរដ្ឋបាលសារពើពន្ធបានធ្វើ និងបានប្រគល់ឱ្យបុគ្គលនោះ ។ ការកំណត់ពន្ធជាឯកតោភាគីត្រូវផ្អែកលើ :

ក- ពត៌មានដែលមានចុះនៅក្នុងលិខិតប្រកាសសារពើពន្ធនានា ឬឯកសារផ្សេងទៀតដែលអ្នកជាប់ពន្ធបានដាក់ជូនរដ្ឋបាលសារពើពន្ធ ។

ខ- ពត៌មានដែលមានចុះក្នុងលិខិតប្រកាសពត៌មាន ។

គ- ពត៌មានផ្សេងទៀតដែលរដ្ឋបាលសារពើពន្ធបានទទួល ។

៤- បើសិនជាមានមូលដ្ឋានបញ្ជាក់ថា ការប្រមូលពន្ធអាចមានឧបសគ្គ រដ្ឋបាលសារពើពន្ធអាចធ្វើការកំណត់ពន្ធលើអ្នកជាប់ពន្ធនៅពេលណាមួយក៏បាន ។

## មាត្រា ១១៧ : ការកំណត់ពន្ធឡើងវិញ និង រយៈពេលកំណត់ពន្ធឡើងវិញ

ការកំណត់ពន្ធឡើងវិញ និង រយៈពេលកំណត់ពន្ធឡើងវិញ ត្រូវដំណើរការដូចតទៅ :

១- ចំពោះការកំណត់ពន្ធដែលផ្អែកតាមកថាខ័ណ្ឌ១ នៃមាត្រា ១១៦ នៃច្បាប់នេះ រដ្ឋបាលសារពើពន្ធអាចធ្វើការកំណត់ពន្ធឡើងវិញក្នុងរយៈពេល ៣ ឆ្នាំ បន្ទាប់ពីឆ្នាំប្រតិទិនដែលការកាត់ទុកបានកើតឡើង ។

២- ចំពោះការកំណត់ពន្ធដែលផ្អែកតាមកថាខ័ណ្ឌ ២ និងកថាខ័ណ្ឌ ៣ នៃមាត្រា ១១៦ នៃច្បាប់នេះ រដ្ឋបាលសារពើពន្ធអាចធ្វើការកំណត់ពន្ធឡើងវិញក្នុងរយៈពេលណាមួយខាងក្រោមនេះ :

ក- ក្នុងរយៈពេល ៣ ឆ្នាំ ក្រោយថ្ងៃដាក់លិខិតប្រកាសសារពើពន្ធ

ខ- ក្នុងរយៈពេល ១០ ឆ្នាំ ក្រោយកាលបរិច្ឆេទដែលតម្រូវឱ្យដាក់លិខិតប្រកាសសារពើពន្ធ ប្រសិនបើមានភស្តុតាងបញ្ជាក់ថាមានអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ

គ- ក្នុងរយៈពេលណាមួយក៏បានតាមការយល់ព្រមជាលាយលក្ខ័អក្សររបស់អ្នកជាប់ពន្ធ ។

៣- អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកអាចស្នើសុំធ្វើការកែតម្រូវលិខិតប្រកាសសារពើពន្ធក្នុងរយៈពេល ៣ ឆ្នាំក្រោយកាលបរិច្ឆេទនៃការដាក់លិខិតប្រកាសសារពើពន្ធតាមកថាខ័ណ្ឌ ២ នៃមាត្រា ១១៦ នៃច្បាប់នេះ ដោយផ្អែកលើមូលដ្ឋាននៃការភ័ន្តច្រឡំ ឬការភ្លាំងភ្លាត់ដែលអ្នកជាប់ពន្ធបានធ្វើនៅក្នុងលិខិតប្រកាសពីមុន ។ ប្រសិនបើលទ្ធផលប្រកាសសារពើពន្ធកែតម្រូវនោះបណ្តាលឱ្យមានការបង្វិលសងប្រាក់ពន្ធ ឬឥណទានពន្ធ រដ្ឋបាលសារពើពន្ធអាចធ្វើការពិនិត្យបញ្ជាក់តាមនីតិវិធីត្រួត-ពិនិត្យសារពើពន្ធ ។

៤- អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកអាចស្នើសុំឱ្យរដ្ឋបាលសារពើពន្ធធ្វើការកែតម្រូវការកំណត់ពន្ធឡើងវិញក្នុងរយៈពេល ៣ ឆ្នាំ ក្រោយកាលបរិច្ឆេទដែលរដ្ឋបាលសារពើពន្ធកំណត់ពន្ធឡើងវិញដោយផ្អែកលើពត៌មានបន្ថែមដែលអ្នកជាប់ពន្ធ ឬរដ្ឋបាលសារពើពន្ធមិនបានទទួលក្នុងពេលកំណត់ពន្ធឡើងវិញនោះ ។

៥- ក្នុងករណីដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកធ្វើការកែតម្រូវការកំណត់ពន្ធរបស់ខ្លួន ឬស្នើសុំឱ្យរដ្ឋបាលសារពើពន្ធកែតម្រូវ ការកំណត់ពន្ធឡើងវិញ អាជ្ញាយុកាលនៃការកំណត់ពន្ធឡើងវិញក្នុងកថាខ័ណ្ឌ១ និងកថាខ័ណ្ឌ២ នៃមាត្រានេះ

ត្រូវចាប់ផ្តើមគិតពីកាលបរិច្ឆេទនៃការដាក់លិខិតប្រកាសសារពើពន្ធកែតម្រូវ ឬកាលបរិច្ឆេទដែលរដ្ឋបាលសារពើពន្ធធ្វើការកែតម្រូវការកំណត់ពន្ធឡើងវិញ ។

## មាត្រា ១១៨ : នីតិវិធីនៃការកំណត់ពន្ធឡើងវិញ

ការកំណត់ពន្ធឡើងវិញ ត្រូវបានដំណើរការតាមនីតិវិធីដូចតទៅ :

១- រដ្ឋបាលសារពើពន្ធត្រូវជូនលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញដល់អ្នកជាប់ពន្ធ ។

២- អ្នកជាប់ពន្ធមានរយៈពេល ៣០ ថ្ងៃ ដើម្បីឆ្លើយតបចំពោះការកំណត់ពន្ធឡើងវិញទៅការិយាល័យរបស់នាយកដ្ឋានពន្ធដារដែលទទួលបន្ទុកធ្វើការកំណត់ពន្ធឡើងវិញនោះ។ក្នុងរយៈពេលនេះអ្នកជាប់ពន្ធអាចទទួលយកឬជំទាស់ចំពោះការកំណត់ពន្ធឡើងវិញ ។ អ្នកជាប់ពន្ធត្រូវចាត់ទុកថាយល់ព្រមចំពោះការកំណត់ពន្ធឡើងវិញបើសិនជាពុំបានឆ្លើយតប ។

៣- បើសិនជាមានការជំទាស់ចំពោះការកំណត់ពន្ធឡើងវិញអ្នកជាប់ពន្ធត្រូវដាក់ពាក្យតវ៉ាទៅប្រធាននាយកដ្ឋានពន្ធដារតាមនីតិវិធីដែលមានចែងក្នុងមាត្រា ១២០ នៃច្បាប់នេះ ។

៤- ការិយាល័យទទួលបន្ទុកការកំណត់ពន្ធឡើងវិញរបស់នាយកដ្ឋានពន្ធដារ ត្រូវបញ្ជូនលទ្ធផលនៃការកំណត់ពន្ធឡើងវិញ ទៅការិយាល័យប្រមូលពន្ធក្នុងរយៈពេល ៣០ ថ្ងៃ ក្រោយការចេញលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញ ។

## មាត្រា ១១៩ : បន្ទុកភស្តុតាង

នៅពេលដែលអ្នកជាប់ពន្ធមិនបានរក្សាទុកឯកសារគ្រប់គ្រាន់ ឬក៏មិនបានផ្តល់ពត៌មានគ្រប់គ្រាន់ រដ្ឋបាលសារពើពន្ធមានសិទ្ធិកំណត់ពន្ធលើអ្នកជាប់ពន្ធដោយផ្អែកលើមូលដ្ឋាននៃពត៌មានជាក់លាក់ដែលរដ្ឋបាលសារពើពន្ធមាន ។ បន្ទុកភស្តុតាងដើម្បីបញ្ជាក់ថាប្រាក់ពន្ធ ដែលរដ្ឋបាលសារពើពន្ធកំណត់មិនត្រឹមត្រូវ គឺស្ថិតនៅលើអ្នកជាប់ពន្ធ ។

នៅពេលណាដែលប្រាក់ចំណូលជាប់ពន្ធ ឬប្រាក់ចំណូលដែលបានប្រកាសដោយអ្នកជាប់ពន្ធមានភាពខុសគ្នាច្រើនធៀបទៅនឹងការទិញទ្រព្យសកម្ម ឬវត្ថុនានាដែលធ្វើឱ្យឃើញចំណាយរបស់អ្នកជាប់ពន្ធលេចធ្លោឡើងនោះ រដ្ឋបាលសារពើពន្ធមានសិទ្ធិកំណត់ពន្ធ ដោយផ្អែកលើមូលដ្ឋាននៃប្រាក់ចំណូលប៉ាន់ស្មានសមស្របទៅនឹងទំហំនៃចំណាយដើម្បីទិញទ្រព្យសកម្ម ឬវត្ថុនានាដែលលេចធ្លោនោះ។ បន្ទុកភស្តុតាងដើម្បីបញ្ជាក់ថាប្រាក់ពន្ធដែលរដ្ឋបាលសារពើពន្ធកំណត់មិនត្រឹមត្រូវ គឺស្ថិតនៅលើអ្នកជាប់ពន្ធ ។

# ផ្នែកទី ៨
# ដំណោះស្រាយការតវ៉ារបស់អ្នកជាប់ពន្ធ

## មាត្រា ១២០ : វិធាននៃបណ្តឹងតវ៉ាខាងរដ្ឋបាល

វិធាននៃដំណោះស្រាយការតវ៉ារបស់អ្នកជាប់ពន្ធអំពីបញ្ហាសារពើពន្ធ ត្រូវបានកំណត់ដូចតទៅ :

១- អ្នកជាប់ពន្ធដែលមិនពេញចិត្តនឹងការកំណត់ពន្ធឡើងវិញ ឬសេចក្តីសម្រេចផ្សេងទៀតដែលធ្វើឡើងដោយរដ្ឋបាលសារពើពន្ធ អាចធ្វើការតវ៉ាទៅប្រធាននាយកដ្ឋានពន្ធដារ ។ ការតវ៉ាត្រូវមានកំរិតព្រំដែនតែត្រឹមដើមហេតុ ឬពត៌មានផ្សេងទៀតដែលមាននៅក្នុងការកំណត់ពន្ធឡើងវិញ សេចក្តីសម្រេច ឬនីតិវិធីនៃការកំណត់ពន្ធឡើងវិញប៉ុណ្ណោះ ។

២-	ការតវ៉ាខាងរដ្ឋបាល ត្រូវធ្វើជាលាយលក្ខអក្សរទៅតាមទម្រង់ដែលមានចែងនៅក្នុងមាត្រា ១២១ នៃច្បាប់នេះ និងត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធក្នុងរយៈពេល ៣០ ថ្ងៃ ក្រោយថ្ងៃដែលអ្នកជាប់ពន្ធបានទទួលលិខិតជូនដំណឹងទារបំណុលពន្ធរបស់រដ្ឋបាលសារពើពន្ធ។

៣-	ការតវ៉ាខាងរដ្ឋបាលពុំធ្វើឱ្យអ្នកជាប់ពន្ធរួចផុតពីកាតព្វកិច្ចបង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗដែលបញ្ជាក់នៅក្នុងលិខិតជូនដំណឹងទារបំណុលពន្ធឡើយ ។

## មាត្រា ១២១ : ខ្លឹមសារបណ្តឹងតវ៉ាខាងរដ្ឋបាលរបស់អ្នកជាប់ពន្ធ

ការតវ៉ាខាងរដ្ឋបាលអាចនឹងទទួលយកបាន បើសិនជាក្នុងពាក្យតវ៉ានោះមានខ្លឹមសារដូចខាងក្រោម :

១-	លេខអត្តសញ្ញាណកម្មរបស់អ្នកជាប់ពន្ធដែលធ្វើពាក្យតវ៉ា បើសិនជាមាន ។

២-	សេចក្តីយោងទៅរកការកំណត់ សេចក្តីសម្រេច ឬលទ្ធផលដែលជាកម្មវត្ថុនៃពាក្យតវ៉ា ។

៣-	ដើមហេតុ ឬអំពើដែលជាកម្មវត្ថុនៃពាក្យតវ៉ា ។

៤-	ហេតុផលនៃការតវ៉ា ។

៥-	កាលបរិច្ឆេទ និង ហត្ថលេខារបស់អ្នកជាប់ពន្ធ និង ហត្ថលេខារបស់តំណាងមានការអនុញ្ញាតរបស់អ្នកជាប់ពន្ធ បើសិនមានភាពចាំបាច់ ។

## មាត្រា ១២២ : សេចក្តីសំរេចរបស់រដ្ឋបាលសារពើពន្ធ

រដ្ឋបាលសារពើពន្ធត្រូវចេញសេចក្តីសម្រេចជាថ្មីក្នុងរយៈពេល ៦០ ថ្ងៃ ក្រោយពីថ្ងៃបានទទួលពាក្យតវ៉ាដើម្បីបញ្ជាក់ភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវទាំងស្រុង ឬចំណែកណាមួយនៃការកំណត់ពន្ធ ឬសេចក្តីសម្រេចផ្សេងៗដែលអ្នកជាប់ពន្ធតវ៉ា ។ រដ្ឋបាលសារពើពន្ធត្រូវបញ្ជាក់ផងដែរនូវមូលដ្ឋាននៃការសម្រេចនេះ ។

ប្រសិនបើអ្នកជាប់ពន្ធមិនយល់ព្រមលើសេចក្តីសម្រេចថ្មីនេះរបស់រដ្ឋបាលសារពើពន្ធទេនោះ អ្នកជាប់ពន្ធអាចដាក់ពាក្យតវ៉ាទៅគណៈកម្មាធិការសម្រុះសម្រួលសារពើពន្ធក្នុងរយៈពេលយ៉ាងយូរ ៣០ ថ្ងៃ ។

## មាត្រា ១២៣ : គណៈកម្មការសំរុះសំរួលសារពើពន្ធ

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្រុះសម្រួលសារពើពន្ធត្រូវកំណត់ដោយអនុក្រឹត្យ តាមសេចក្តីស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## មាត្រា ១២៤ : បណ្តឹងទៅតុលាការ

អ្នកជាប់ពន្ធមានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ច ជំទាស់នឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការសម្រុះសម្រួលសារពើពន្ធក្នុងរយៈពេល ៣០ ថ្ងៃក្រោយពីបានទទួលដំណឹងស្តីពីសេចក្តីសម្រេចនោះ ។

អ្នកជាប់ពន្ធត្រូវតម្កល់ទុកនៅរតនាគារជាតិនូវប្រាក់ចំនួនស្មើនឹងប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និង ការប្រាក់ផ្សេងៗដែលទាក់ទិននឹងវិវាទតាមការកំណត់របស់រដ្ឋបាលសារពើពន្ធ មុននឹងដាក់ពាក្យបណ្តឹងទៅតុលាការ ។

# ផ្នែកទី ៩
# បទល្មើសបទប្បញ្ញត្តិស្តីពីពន្ធដារ

## មាត្រា ១២៥ : ការធ្វេសប្រហែស

អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ត្រូវបានចាត់ទុកថាមានការធ្វេសប្រហែស បើសិនជាប្រាក់ពន្ធដែលបានបង់មានចំនួនតិចជាងប្រាក់ពន្ធដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារមិនលើសពី ១០ ភាគរយ ។

អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវបានចាត់ទុកថាមានការធ្វេសប្រហែស បើសិនជាមិនបានដាក់លិខិតប្រកាសសារពើពន្ធ ឬមិនបានបង់ពន្ធតាមកាលបរិច្ឆេទដែលច្បាប់បានកំណត់ ។

## មាត្រា ១២៦ : ការធ្វេសប្រហែសធ្ងន់ធ្ងរ

អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ត្រូវបានចាត់ទុកថាមានការធ្វេសប្រហែសធ្ងន់ធ្ងរ បើសិនជាប្រាក់ពន្ធដែលបានបង់មានចំនួនតិចជាងប្រាក់ពន្ធដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារលើសពី ១០ ភាគរយ ។

## មាត្រា ១២៧ : ការគេចវេសពន្ធ

ការគេចវេសពន្ធ គឺជាបទល្មើសដោយចេតនាដោយដឹងជាមុន មានការរៀបចំទុក និងច្រើនដងទៅលើបទប្បញ្ញត្តិស្តីពីពន្ធដារ ក្នុងបំណងបន្ថយ ឬបំបាត់ប្រាក់ពន្ធដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវឱ្យបង់ ។

ត្រូវបានចាត់ទុកថាជាការគេចវេសពន្ធផងដែរ ក្នុងករណីដែលការធ្វេសប្រហែសធ្ងន់ធ្ងរដូចមានចែងក្នុងមាត្រា១២៦នៃច្បាប់នេះបានប្រព្រឹត្តឡើង :

១- ពីរលើកដាច់ពីគ្នាក្នុងរយៈពេល ៣ឆ្នាំ នៃឆ្នាំប្រតិទិន ។

២- បីលើកឬច្រើនជាងនេះដាច់ពីគ្នាក្នុងរយៈពេលណាមួយក៏ដោយ ។

## មាត្រា ១២៨ : អំពើរាំងស្ទះការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារ

អំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ រួមមាន :

១- ករណីដែលបុគ្គល :

ក- មិនបានរក្សាបញ្ជីកាគណនេយ្យ និង ឯកសារផ្សេងទៀត ឬមិនបានចេញវិក្កយបត្រលើកិច្ចការជំនួញ ។

ខ- មិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធធ្វើការពិនិត្យបញ្ជីកាគណនេយ្យ ឬឯកសារផ្សេងៗ។

គ- មិនបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ។

ឃ- មិនបានជូនដំណឹងទៅរដ្ឋបាលសារពើពន្ធអំពីការផ្លាស់ប្តូរក្នុងការចុះបញ្ជីដូចមានចែងក្នុងច្បាប់នេះ ។

ង- កសាង ឬផ្តល់នូវកំណត់ត្រា ឯកសារ របាយការណ៍ ឬពត៌មានក្លែងបន្លំផ្សេងៗ ។

ច- លាក់ទុក ឬបំផ្លាញចោលដោយចេតនានូវបញ្ជីគណនេយ្យ កំណត់ត្រា ឯកសារ របាយការណ៍ ឬពត៌មានផ្សេងៗ ទៀត។

ឆ- ព្យាយាមធ្វើឱ្យរាំងស្ទះដល់ការកំណត់ និង ការប្រមូលពន្ធ ។

ជ- មិនបានដាក់លិខិតប្រកាសសារពើពន្ធដែលគ្មានប្រាក់ពន្ធត្រូវបង់ក្នុងរយៈពេល ៣០ ថ្ងៃ ក្រោយកាលបរិច្ឆេទដែលច្បាប់បានកំណត់ ។

ឈ- ជួយជ្រោមជ្រែងដោយចេតនាដល់អំពើទាំងឡាយខាងលើ ។

២- ករណីដែលមន្ត្រីរាជការ :

ក- ធ្វើអោយធ្លាយពត៌មានសម្ងាត់ដោយគ្មានការអនុញ្ញាត ។

ខ- ព្យាយាមធ្វើឱ្យរាំងស្ទះដល់ការកំណត់ និង ការប្រមូលពន្ធ ។

គ- ជួយជ្រោមជ្រែងដោយចេតនាដល់អំពើទាំងឡាយខាងលើ ។

**មាត្រា ១២៩ : បទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ**

ក្រៅពីទោសទណ្ឌផ្នែករដ្ឋបាលផ្សេងទៀត បុគ្គលណាមួយបានធ្វើសកម្មភាពគេចវេសពន្ធដូចមានចែងក្នុងមាត្រា១២៧ នៃច្បាប់នេះ ឬធ្វើការរាំងស្ទះដល់ការគ្រប់គ្រងប្រព័ន្ធសារពើពន្ធ ដូចមានចែងក្នុងមាត្រា ១២៨ នៃច្បាប់នេះ ត្រូវចាត់ទុកថាបានប្រព្រឹត្តបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ។

## ផ្នែកទី ១០
## ពន្ធបន្ថែម

**មាត្រា ១៣០ : ពន្ធបន្ថែម**

ពន្ធបន្ថែមត្រូវអនុវត្តចំពោះបទល្មើសបទប្បញ្ញត្តិស្តីពីពន្ធដារ ។

ពន្ធបន្ថែមសម្រាប់ការបង់ពន្ធខ្វះ ឬការបង់យឺត ត្រូវគណនាដាច់ដោយឡែកពីពន្ធបន្ថែមសម្រាប់ការរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ។

ក្នុងករណីមានការបង់ពន្ធខ្វះ ពន្ធបន្ថែម និងការប្រាក់ ត្រូវដល់កំណត់ និងត្រូវបង់តាមបែបបទដូចប្រាក់ពន្ធដែលបានបង់ខ្វះនោះ ។

ទោះជាក្នុងករណីណាក៏ដោយ ការដាក់ឱ្យអនុវត្តពន្ធបន្ថែមមិនមានផលប៉ះពាល់ដល់ការអនុវត្តន៍ទោសទណ្ឌចំពោះបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារឡើយ ។

**មាត្រា ១៣១ : ពន្ធបន្ថែមចំពោះការបង់ពន្ធខ្វះ**

ចំពោះបុគ្គលដែលមានការធ្វេសប្រហែស ប្រាក់ពន្ធបន្ថែមត្រូវស្មើនឹង ១០ ភាគរយនៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់ ២ ភាគរយនៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួនប្រាក់ពន្ធខ្វះមិនទាន់បានបង់ ។

ចំពោះបុគ្គលដែលមានការធ្វេសប្រហែសធ្ងន់ធ្ងរ ប្រាក់ពន្ធបន្ថែមត្រូវស្មើនឹង ២៥ ភាគរយនៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់ ២ ភាគរយនៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធខ្វះមិនទាន់បានបង់ ។

ក្នុងករណីការកំណត់ពន្ធជាឯកតោភាគី ប្រាក់ពន្ធបន្ថែមត្រូវស្មើ ៤០ ភាគរយនៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់ ២ ភាគរយនៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធខ្វះមិនទាន់បានបង់ ។

ការប្រាក់មិនត្រូវអនុវត្តទេក្នុងរយៈពេលកំណត់ពន្ធឡើងវិញតាមមាត្រា ១១៨ នៃច្បាប់នេះ ឬក្នុងរយៈពេល ៣០ ថ្ងៃ ក្រោយការប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធ ។

## មាត្រា ១៣២ : ពន្ធបន្ថែមចំពោះការយឺតយ៉ាវក្នុងការបង់ពន្ធ

ចំពោះបុគ្គលដែលមិនបានបង់ពន្ធតាមកាលកំណត់ ពន្ធបន្ថែមត្រូវកំណត់តាមអត្រា ១០ ភាគរយនៃទឹកប្រាក់ពន្ធបង់យឺត បូកនឹងការប្រាក់ ២ ភាគរយនៃទឹកប្រាក់ពន្ធបង់យឺតសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួនប្រាក់ពន្ធនោះនៅមិនទាន់បានបង់ ។

បើសិនជាបុគ្គលមិនបានបង់ពន្ធក្នុងរយៈ ១៥ ថ្ងៃ ក្រោយពេលបានទទួលលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ ពន្ធបន្ថែម ត្រូវកំណត់តាមអត្រា ២៥ ភាគរយនៃទឹកប្រាក់ពន្ធបង់យឺត បូកនឹងការប្រាក់ ២ ភាគរយនៃទឹកប្រាក់ពន្ធបង់យឺតសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួនប្រាក់ពន្ធនោះនៅមិនទាន់បានបង់ ។

ក្នុងករណីការកំណត់ពន្ធជាឯកតោភាគី សម្រាប់ការមិនដាក់លិខិតប្រកាសប្រាក់ពន្ធបន្ថែមត្រូវស្មើ ៤០ ភាគរយនៃចំនួនប្រាក់ពន្ធដែលបានកំណត់ បូកបន្ថែមការប្រាក់ ២ ភាគរយនៃចំនួនប្រាក់ពន្ធដែលបានកំណត់សម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធមិនទាន់បានបង់ ។

ការប្រាក់យឺតយ៉ាវត្រូវគិតចាប់ពីថ្ងៃទី ០១ នៃខែបន្ទាប់ពីខែដែលត្រូវបង់ពន្ធ ។ ចំពោះពន្ធលើប្រាក់ចំណេញ ការប្រាក់យឺតយ៉ាវត្រូវ គិតចាប់ពីថ្ងៃទី ០១ នៃខែបន្ទាប់ដែលជាខែផុតរយៈពេលកំណត់សម្រាប់ការដាក់លិខិតប្រកាសលទ្ធផលប្រចាំឆ្នាំ ។

ពន្ធបន្ថែមចំពោះការយឺតយ៉ាវក្នុងការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនត្រូវស្មើនឹង ១០០ ភាគរយនៃប្រាក់ពន្ធត្រូវបង់ ។

## មាត្រា ១៣៣ : ពន្ធបន្ថែមចំពោះអំពើរាំងស្ទះការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារ

ចំពោះការប្រព្រឹត្តអំពើរាំងស្ទះការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារ ពន្ធបន្ថែមត្រូវកំណត់ដូចខាងក្រោមនេះ សម្រាប់អំពើនីមួយៗ:

១- ២.០០០.០០០ រៀល (ពីរលានរៀល) ចំពោះបុគ្គលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកក្រោមរបបពិត ឬមន្ត្រីរាជការ ។

២- ៥០០.០០០ រៀល (ប្រាំសែនរៀល) ចំពោះអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកក្រោមរបបបំព្រួញ ឬរបបម៉ៅការ ។

## ផ្នែកទី ១១

## អំពីបទល្មើសព្រហ្មទណ្ឌ

### មាត្រា ១៣៤ : អំណាចក្នុងការប្តឹងចោទប្រកាន់ខាងបទព្រហ្មទណ្ឌ

លើកលែងតែចំពោះបទល្មើសមានចែងនៅក្នុងមាត្រា ១៣៩ និងមាត្រា ១៤០ នៃច្បាប់នេះ ការប្តឹងចោទប្រកាន់ និងទាមទារ ការដាក់ទោសចំពោះបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ត្រូវធ្វើឡើងដោយប្រធាននាយកដ្ឋានពន្ធដារ ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

### មាត្រា ១៣៥ : ការគេចវេសពន្ធ

ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀត អភិបាល បណ្ណាធិការ កម្មសិទ្ធិកររបស់សហគ្រាសណាមួយ ឬបុគ្គល ទទួលខុសត្រូវឱ្យសហគ្រាសណាមួយដែលបានប្រព្រឹត្តិអំពើគេចវេសពន្ធដូចមានចែងក្នុងមាត្រា១២៧ នៃច្បាប់នេះ ត្រូវរងការ ផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ រៀល (ដប់លានរៀល) ដល់ ២០.០០០.០០០ រៀល (ម្ភៃលានរៀល) ឬជាប់ពន្ធនាគារពី ១ ឆ្នាំដល់ ៥ ឆ្នាំ ឬទោសទាំងពីរនេះ ។

### មាត្រា ១៣៦ : អំពើរាំងស្ទះដល់ការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារ

ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀត បុគ្គលណាដែលបានប្រព្រឹត្តិអំពើរាំងស្ទះដល់ការអនុវត្តន៍បទប្បញ្ញត្តិស្តីពី ពន្ធដារដូចមានចែងក្នុងមាត្រា១២៨ នៃច្បាប់នេះត្រូវរងការផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ រៀល (ប្រាំលានរៀល) ដល់ ១០.០០០.០០០ រៀល (ដប់លានរៀល) ឬជាប់ពន្ធនាគារពី ១ ខែ ដល់ ១ ឆ្នាំ ឬទោសទាំងពីរនេះ ។

### មាត្រា ១៣៧ : អំពើជ្រោមជ្រែង និង អូសទាញ

បុគ្គលណាដែលមានចេតនាជួយជ្រោមជ្រែង ឬអូសទាញបុគ្គលម្នាក់ទៀតឱ្យប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌចំពោះច្បាប់ នេះ ឬក៏ដោយចេតនាបានផ្តល់គំនិត ឬជំរុញបុគ្គលម្នាក់ទៀតឱ្យប្រព្រឹត្តិបទល្មើសបែបនេះ ត្រូវជាប់ពិរុទ្ធ ហើយត្រូវទទួលរងការ ផ្តន្ទាទោស ដូចគ្នានឹងការប្រព្រឹត្តិបទល្មើសផ្ទាល់ខ្លួនផងដែរ ។

### មាត្រា ១៣៨ : ការធ្វើអោយធ្លាយការសម្ងាត់

ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀត បុគ្គលណាដែលបានបំពានមាត្រា ៩៤ នៃច្បាប់នេះ ត្រូវជាប់ពិរុទ្ធអំពី បទល្មើសនឹងច្បាប់ ហើយត្រូវទទួលរងការផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ រៀល(ប្រាំលានរៀល) ដល់ ១០.០០០.០០០រៀល (ដប់លានរៀល) ឬជាប់ពន្ធនាគារពី ១ ខែ ដល់ ១ ឆ្នាំ ឬទោសទាំងពីរនេះ ។

### មាត្រា ១៣៩ : បទល្មើសនៃមន្ត្រីពន្ធដារ

បុគ្គលណាដែលបានទទួលការចាត់តាំងជាអ្នកអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ហើយដោយចេតនាបានប្រព្រឹត្តអំពើដូច ខាងក្រោមនេះ ត្រូវជាប់ពិរុទ្ធអំពីបទល្មើសនឹងច្បាប់ ហើយត្រូវទទួលរងការផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ រៀល (ប្រាំលានរៀល) ដល់ ១០.០០០.០០០ រៀល (ដប់លានរៀល) ឬជាប់ពន្ធនាគារពី១ ខែ ដល់១ ឆ្នាំ ឬទោសទាំងពីរនេះ :

១- ដកប្រាក់ពន្ធសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ឬការប្រើប្រាស់ណាផ្សេងដែលគ្មានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ។

២- ធ្វើរបាយការណ៍មិនត្រឹមត្រូវ អំពីចំនួនប្រាក់ពន្ធដែលខ្លួនប្រមូលបាន ឬទទួលបាន ។

៣- ប្រើប្រាស់តួនាទីជាមន្ត្រីពន្ធដារដើម្បីទទួលយកប្រាក់ ឬអត្ថប្រយោជន៍ផ្សេងទៀតពីអ្នកជាប់ពន្ធ ឬបុគ្គល ផ្សេងទៀត។

៤-	ប្រមូល ឬព្យាយាមប្រមូលប្រាក់ពន្ធដោយគ្មានការអនុញ្ញាត ។

បុគ្គលណាដែលបានទទួលការចាត់តាំងជាអ្នកអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ហើយដោយចេតនា បានទាមទារប្រាក់លើសពីច្បាប់អនុញ្ញាត ត្រូវទទួលទោសវិតិក្រមតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

បុគ្គលណាដែលបានទទួលការចាត់តាំងជាអ្នកអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ហើយដោយចេតនាបានទាមទារ ឬទទួលសំណូក ត្រូវទទួលទោសពីបទស៊ីសំណូកតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។ អ្នកសូកត្រូវទទួលទោសពីបទសូកតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ១៤០ : សំណងចំពោះការប្រព្រឹត្តិការខុសឆ្គង**

បើសិនជាអ្នកជាប់ពន្ធយល់ឃើញថា ខ្លួនបានទទួលរងនូវការខូចខាតខាងហិរញ្ញវត្ថុ ឬការរងគ្រោះផ្ទាល់ខ្លួនអំពីសកម្មភាពខុសឆ្គង ឬខុសច្បាប់ពីសំណាក់រដ្ឋបាលសារពើពន្ធ អ្នកជាប់ពន្ធអាចប្តឹងទាមទារសំណងនៃការខូចខាត ឬការរងគ្រោះនោះទៅតុលាការក្នុងរយៈពេលបីឆ្នាំក្រោយកាលបរិច្ឆេទនៃការខូចខាតខាងហិរញ្ញវត្ថុ ឬការរងគ្រោះផ្ទាល់ខ្លួនចុងក្រោយបំផុត ។

# ជំពូកទី ៦

# អវសានប្បញ្ញត្តិ

**មាត្រា ១៤១ :**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៤២ :**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ១៩៩៧ នាសម័យប្រជុំ
សរដ្ឋសភាលើកទី ៧ នីតិកាលទី ១ ។
ច្បាប់នេះត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ
នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ១៩៩៧
ឡាយព្រះហស្តលេខាដោយព្រះករុណា **ព្រះបាទនរោត្តមសីហនុ**
ព្រះចៅក្រុងកម្ពុជា ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...០០៥......សហវ.......

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ [illegible] ឆ្នាំ២០១៥

## សេចក្តីជូនដំណឹង
## ស្តីពី
## ការកែសម្រួលមូលដ្ឋានគិតអាករពិសេសលើមុខទំនិញមួយចំនួនដែលផលិតក្នុងស្រុកក្រៅពីបារីនិងស្រា

យោងតាមប្រការ ១ នៃប្រកាសលេខ ១៣៩ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការអនុវត្តឱ្យមានភាពទន់ភ្លន់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំការអនុវត្តមូលដ្ឋានគិតអាករពិសេសលើមុខទំនិញដែលផលិតក្នុងស្រុកក្រៅពីបារីនិងស្រា ដូចជា÷ ស្រាបៀរ ភេសជ្ជៈគ្មានជាតិសុរា និងមុខទំនិញជាប់អាករពិសេសដទៃទៀត ត្រូវបានកំណត់ស្មើនឹង ៩០ ភាគរយ នៃថ្លៃផ្គត់ផ្គង់កត់ត្រាក្នុងវិក្កយបត្រឱ្យទៅអតិថិជន ដោយមិនរួមបញ្ចូល÷

- អាករលើតម្លៃបន្ថែម និងអាករពិសេសខ្លួនឯង សម្រាប់អ្នកជាប់ពន្ធក្នុងរបបស្វ័យប្រកាស (របបពិត)
- អាករលើផលរបរ និងអាករពិសេសខ្លួនឯង សម្រាប់អ្នកជាប់ពន្ធក្នុងរបបម៉ៅការ។

មូលដ្ឋានគិតអាករពិសេសថ្មីនេះនឹងត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៥ តទៅ។

អាស្រ័យហេតុនេះ សូមលោក-លោកស្រីជានាយកសហគ្រាសផលិតទំនិញជាប់អាករពិសេសក្នុងស្រុកទាំងអស់ជ្រាប និងអនុវត្តឱ្យបានត្រឹមត្រូវប្រកបដោយប្រសិទ្ធភាពខ្ពស់។

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៧៧៥ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការលើកទឹកចិត្តពន្ធបន្ថែមចំពោះការដាំដុះស្រូវ ការប្រមូលទិញស្រូវ និងការផលិតអង្ករនាំចេញ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៩ ចុះថ្ងៃ ទី២០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៩
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរសព្ទ៍ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម
- បានឃើញប្រកាសលេខ ១០៥៩ សហវ.បក.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់ចំណេញ
- យោងប្រកាសលេខ ៣០៣ សហវ.ពដ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០១ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែម លើការនាំចូល និងផ្គត់ផ្គង់ទំនិញមួយចំនួន
- យោងគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០
- យោងការសម្រេចដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១១ លើលិខិតលេខ ៥៨៩៨.សហវ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ របស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមការចាំបាច់នៃការងារ

## សម្រេច

**ប្រការ ១.** ស្របតាមគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្កររបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដាក់ចេញនូវយន្តការលើកទឹកចិត្តពន្ធមួយចំនួនបន្ថែម ចំពោះសហគ្រាសដាំដុះស្រូវ ប្រមូលទិញស្រូវ និងផលិតអង្ករនាំចេញ ដូចខាងក្រោមនេះ ៖

### អាករលើតម្លៃបន្ថែម

១. ការផ្គត់ផ្គង់ស្រូវក្នុងស្រុក ត្រូវជាប់អាករលើតម្លៃបន្ថែមតាមអត្រា 0% (សូន្យភាគរយ)
២. ការផ្គត់ផ្គង់អង្ករក្នុងស្រុក ត្រូវជាប់អាករលើតម្លៃបន្ថែមតាមអត្រាធម្មតា ១0% (ដប់ភាគរយ)
៣. ការនាំចេញអង្ករ ត្រូវជាប់អាករលើតម្លៃបន្ថែមតាមអត្រា 0% (សូន្យភាគរយ)
៤. អាករលើធាតុចូលដែលទាក់ទិននឹងការដាំដុះស្រូវ ប្រមូលទិញស្រូវ និងផលិតអង្ករនាំចេញ ត្រូវបាន អនុញ្ញាតជាឥណទាន ឬបង្វិលសង ។

### ពន្ធលើប្រាក់ចំណេញ និងពន្ធអប្បបរមា

១. សហគ្រាសដាំដុះស្រូវ ប្រមូលទិញស្រូវ និងផលិតអង្ករនាំចេញ ត្រូវទទួលបានការលើកទឹកចិត្ត ៖
ក- លើកលែងពន្ធអប្បរមា ១% (មួយភាគរយ) លើផលរបរប្រចាំឆ្នាំ ។
ខ- រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញជាអតិបរមា ដែលក្នុងនោះមាន ៖ រយៈពេលគន្លឹះ បូករយៈពេល ៣ (បី) ឆ្នាំ បូកនឹងរយៈពេលអាទិភាព ៣ (បី) ឆ្នាំ ។

រយៈពេលគន្លឹះ ៖ ចាប់ផ្តើមពីការចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារ និងបញ្ចប់នៅចុងក្រោយនៃឆ្នាំសារពើពន្ធណាមួយដែលឆាប់ជាង ៖

- ប្រសិនបើសហគ្រាសមានប្រាក់ចំណេញ គឺឆ្នាំសារពើពន្ធមុនឆ្នាំដែលសហគ្រាសមានប្រាក់ចំណេញដំបូង និង
- ប្រសិនបើសហគ្រាសមានប្រាក់ចំណូល គឺជាឆ្នាំសារពើពន្ធទី៣បន្ទាប់ពីសហគ្រាសទទួលបានប្រាក់ចំណូលដំបូង ។

រយៈពេល ៣ (បី) ឆ្នាំ ៖ ចាប់ផ្តើមគិតភ្លាមពីឆ្នាំសារពើពន្ធ បន្ទាប់ពីរយៈពេលគន្លឹះ និង២ (ពីរ) ឆ្នាំបន្តបន្ទាប់មកទៀត ។

**រយៈពេលអាទិភាព ៣ (បី) ឆ្នាំ ៖** ចាប់ផ្តើមគិតភ្លាមបន្ទាប់ពីឆ្នាំសារពើពន្ធទី៣ នៃរយៈពេល៣ (បី) ឆ្នាំ ។

គ- ក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញខាងលើនេះ សហគ្រាសមិនត្រូវបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ១% (មួយភាគរយ) លើផលរបរប្រចាំខែ ។

២. ដើម្បីទទួលបានការលើកទឹកចិត្តអាករលើតម្លៃបន្ថែម ពន្ធលើប្រាក់ចំណេញ និងពន្ធអប្បបរមា ដូចមានចែងខាងលើនេះ សហគ្រាសដាំដុះស្រូវ ប្រមូលទិញស្រូវ និងផលិតអង្ករនាំចេញ ត្រូវស្នើសុំចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារ ។

**ប្រការ ២.** សហគ្រាសដាំដុះស្រូវ ប្រមូលទិញស្រូវ និងផលិតអង្ករនាំចេញ ដែលបានទទួលការលើកទឹកចិត្តដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ ប្រចាំឆ្នាំ និងបង់ពន្ធអាករដទៃទៀតតាមបទប្បញ្ញត្តិស្តីពីសារពើពន្ធជាធរមាន ។ ក្នុងករណីមិនអនុវត្តតាមកាតព្វកិច្ចខាងលើនេះ អគ្គនាយកដ្ឋានពន្ធដារនឹងធ្វើការដកហូតមកវិញនូវការលើកទឹកចិត្ត ដូចមានចែងក្នុងប្រការ១ ។

**ប្រការ ៣.** អគ្គលេខាធិការ នាយកខុទ្ទកាល័យនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ប្រធាននាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសហគ្រាសដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១១

គាត ឈន់

**ចម្លងជូន ៖**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃអង្គារ ៣ កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីសិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យស្តីពី
## "ការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់សហគ្រាសធុនតូច និងមធ្យម ក្នុងវិស័យអាទិភាព"

នាព្រឹកថ្ងៃអង្គារ ៣ កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៩, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី ០២ ខែតុលា ឆ្នាំ ២០១៨ ស្តីពី "**ការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់សហគ្រាសធុនតូច និងមធ្យម ក្នុងវិស័យអាទិភាព**" ដោយមានការអញ្ជើញចូលរួមពីតំណាងវិស័យឯកជន, សមាគមនានានៃសហគ្រាសធុនតូច និងមធ្យម, តំណាងអគ្គនាយកដ្ឋានពន្ធដារ និងមន្រ្តីជំនាញនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួន សរុបប្រមាណ ១៨០ នាក់ ។

ការរៀបចំសិក្ខាសាលានេះ គឺមានគោលបំណងផ្សព្វផ្សាយឱ្យសាធារណៈជន ជាពិសេសម្ចាស់សហគ្រាសធុនតូច និងមធ្យមបានជ្រាបជាព័ត៌មាន និង អាចចាប់យកនូវអត្ថប្រយោជន៍ពីការលើកទឹកចិត្តផ្នែកពន្ធដារ ដែលរាជរដ្ឋាភិបាលបានដាក់ចេញនេះ ដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម (SMEs) ដែលជាចលករមួយដ៏សំខាន់ក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច, បង្កើតការងារបន្ថែម និង បង្កើនសមត្ថភាពផលិតកម្មក្នុងស្រុក ។ ស្របជាមួយនេះ, រាជរដ្ឋាភិបាលបានរៀបចំបង្កើតមូលនិធិអភិវឌ្ឍន៍ជំនាញ, ធនាគារសហគ្រាសធុនតូច និងមធ្យម, មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព និង មជ្ឈមណ្ឌលលើកកម្ពស់សហគ្រិនភាព ផងដែរ ។

វិស័យអាទិភាពសម្រាប់ផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដារ រួមមាន៖ (១) ផលិតផលកសិកម្ម ឬកសិ-ឧស្សាហកម្ម, (២) ផលិត និងកែច្នៃម្ហូបអាហារ, (៣) កម្មន្តសាលដែលផលិតទំនិញប្រើប្រាស់ក្នុងស្រុក, កែច្នៃកាកសំណល់, និងផលិតទំនិញសម្រាប់វិស័យទេសចរណ៍, (៤) កម្មន្តសាលដែលផលិតនូវផលិតផលសម្រេច ឬផ្នែក ឬគ្រឿងបង្គុំ ដើម្បីផ្គត់ផ្គង់ឱ្យកម្មន្តសាលដទៃទៀត, (៥) ស្រាវជ្រាវ និង អភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រួមទាំងការផ្គត់ផ្គង់សេវាគ្រប់គ្រងតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលមានលក្ខណៈនវានុវត្តន៍ និង (៦) សហគ្រាសដែលស្ថិតក្នុងតំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យម, និង សហគ្រាសដែលអភិវឌ្ឍតំបន់នេះ ។

សូមបញ្ជាក់ថា វិស័យអាទិភាពទាំងនេះ មិនរួមបញ្ចូលវិស័យដែលប៉ះពាល់ដល់សន្តិសុខសង្គម សុខភាព និងបរិស្ថាននោះទេ ។

សហគ្រាសធុនតូច និងមធ្យម ក្នុងវិស័យដូចបានរៀបរាប់ខាងលើអាចទទួលបាននូវការលើកទឹកចិត្តដូចជា៖

**(១)** លើកលែងពន្ធលើប្រាក់ចំណូលចំនួន ៣ (បី) ឆ្នាំ ដោយគិតចាប់ពីថ្ងៃដែលចុះបញ្ជីពន្ធដារសម្រាប់សហគ្រាសចុះបញ្ជីថ្មី ឬ ចាប់ពីថ្ងៃដែលសហគ្រាសមកធ្វើបច្ចុប្បន្នកម្មសម្រាប់សហគ្រាសដែលបានចុះបញ្ជីពន្ធដាររួចហើយ ចាប់ពីពេលអនុក្រឹត្យនេះចូលជាធរមាន ឬ

(២) លើកលែងពន្ធលើប្រាក់ចំណូលរយៈពេល ៥ (ប្រាំ) ឆ្នាំ ដោយគិតចាប់ពីថ្ងៃដែលចុះបញ្ជីពន្ធដារសម្រាប់សហគ្រាសចុះបញ្ជីថ្មី ឬ ចាប់ពីថ្ងៃដែលសហគ្រាសមកធ្វើបច្ចុប្បន្នកម្មសម្រាប់សហគ្រាសដែលបានចុះបញ្ជីពន្ធដាររួចហើយ ចាប់ពីពេលអនុក្រឹត្យនេះចូលជាធរមាន ដែលបំពេញលក្ខខណ្ឌណាមួយ ដូចខាងក្រោម÷

- ប្រើវត្ថុធាតុដើមក្នុងស្រុក ចាប់ពី ៦០%ឡើងទៅ ឬ
- បង្កើនចំនួននិយោជិតបន្ថែមយ៉ាងតិច ២០% ឬ
- មានទីតាំងក្នុងតំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យម (SME Cluster)

(៣) លើកលែងការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បរមា ក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល ។

(៤) លើកទឹកចិត្តចំណាយដែលអាចកាត់កងបាន ដូចខាងក្រោម÷

ក- អនុញ្ញាតកាត់កងចំណាយ ២០០% ចំពោះចំណាយលើការប្រើប្រាស់បញ្ជីគណនេយ្យតាមប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មាន,

ខ- អនុញ្ញាតកាត់កងចំណាយ ២០០% ចំពោះចំណាយលើការបណ្តុះបណ្តាលការកាន់បញ្ជីគណនេយ្យ ឬ ការបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់និយោជិត,

គ- អនុញ្ញាតកាត់កងចំណាយ ១៥០% ចំពោះចំណាយវិនិយោគលើម៉ាស៊ីន ឬ ឧបករណ៍បច្ចេកវិទ្យា ដែលមានលក្ខណៈនវានុវត្តន៍ សម្រាប់បម្រើនិងលើកកម្ពស់ផលិតភាពផលិតកម្ម ។

ក្នុងការទទួលបានការលើកទឹកចិត្តដូចបានរៀបរាប់ខាងលើ, សហគ្រាសធុនតូច និងមធ្យម ត្រូវកាន់បញ្ជីគណនេយ្យ និងដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ទៅតាមកាលកំណត់ជូនរដ្ឋបាលសារពើពន្ធ ទោះបីជាត្រូវបានលើកលែងពន្ធលើប្រាក់ចំណូល និងត្រូវដាក់លិខិតប្រកាសបង់ពន្ធអាករដទៃទៀតតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន ។ ផ្ទុយទៅវិញ សហគ្រាសធុនតូច និងមធ្យម ដែលមិនបានបំពេញលក្ខខណ្ឌដូចបានកំណត់នៅក្នុងអនុក្រឹត្យនេះ ឬ ខកខានមិនបានបំពេញកាតព្វកិច្ចសារពើពន្ធនានា ដូចមានចែងក្នុងច្បាប់ និង បទប្បញ្ញត្តិស្តីពីពន្ធដារ ការលើកទឹកចិត្តដែលបានផ្តល់ជូននឹងត្រូវបានដកហូតវិញ ។

*ចុងក្រោយ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានថ្លែងអំណរគុណចំពោះការផ្តល់ធាតុចូលល្អៗបន្ថែមទៀតសម្រាប់ជាការគិតគូរបន្ត ព្រមទាំងបានស្នើឱ្យវិស័យឯកជន, សមាគមនានានៃសហគ្រាសធុនតូច និងមធ្យម និង ភាគីពាក់ព័ន្ធធ្វើការស្វែងយល់ និង ជួយផ្សព្វផ្សាយបន្តអំពីគោលនយោបាយលើកទឹកចិត្តនេះ ដើម្បីឱ្យសហគ្រាសប្រភេទតូច និងមធ្យមទាំងអស់ មានឱកាសចាប់យកអត្ថប្រយោជន៍ដូចមានចែងនៅក្នុងអនុក្រឹត្យខាងលើ ឱ្យបានជាអតិបរិមា ។*

# ច្បាប់
# ស្តីពី
# វិសោធនកម្ម
# នៃច្បាប់ស្តីពីវិនិយោគ
# នៃព្រះរាជាណាចក្រកម្ពុជា

# ព្រះរាជក្រម

នស/រកម/០៣០៣/០០៩

អគ្គលេខាធិការដ្ឋាន (ព្រឹទ្ធសភា)
លេខ ៣៤០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបាន អនុម័តកាលពីថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាល ទី ២ ហើយដែលព្រឹទ្ធសភាបានយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៣ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុង ដូចតទៅ ៖

**មាត្រាតែមួយ .-**

ត្រូវបានកែប្រែមាត្រា ១, មាត្រា ២, មាត្រា ៦, មាត្រា ៧, មាត្រា ៨, មាត្រា ១០, មាត្រា ១២, មាត្រា ១៤, មាត្រា ១៥, មាត្រា ១៦, មាត្រា ១៨, មាត្រា ២០, មាត្រា ២១, មាត្រា ២២, មាត្រា ២៣ ជំពូកទី ៩ មាត្រា ២៤ និងជំពូកទី ១០ មាត្រា ២៥ មាត្រា ២៦ និងមាត្រា ២៧ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដូចតទៅ :

**មាត្រា ១.-ថ្មី**

ច្បាប់នេះមានវិសាលភាពចំពោះរាល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងកំណត់នីតិវិធីនៃការបង្កើតគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលធ្វើឡើងដោយបុគ្គលណាមួយ ។

មានតែគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទេ ដែលមានសិទ្ធិទទួលបាននូវផលប្រយោជន៍ដែលស្ថិតក្នុងក្របខ័ណ្ឌនៃច្បាប់នេះ ។

**មាត្រា ២.-ថ្មី**

ក្នុងន័យនៃច្បាប់នេះ វាក្យសព្ទដូចខាងក្រោម :

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់** ហៅកាត់ គ.ល.គ មានន័យថា គម្រោងវិនិយោគដែលទទួលបានវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ** មានន័យថា ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលផលិតផលរបស់គម្រោងត្រូវបាននាំចេញ ដែលនឹងកំណត់ដោយអនុក្រឹត្យ

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាប្រភេទឧស្សាហកម្មគាំទ្រ** មានន័យថា គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលផលិតផលរបស់ខ្លួន ១០០% (មួយរយភាគរយ) ត្រូវផ្គត់ផ្គង់ដល់ឧស្សាហកម្មនាំចេញជានូវវត្ថុធាតុដើម ឬសម្ភារៈបន្ទាប់បន្សំដែលតែងតែនាំចូល

**ថ្ងៃធ្វើការ** មានន័យថា ថ្ងៃប្រតិទិនដែលជាថ្ងៃធ្វើការជាផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជា

**នីតិបុគ្គលសញ្ជាតិខ្មែរ** មានន័យថា ក្រុមហ៊ុនដែលមានទីកន្លែងធ្វើអាជីវកម្ម និងដែលបានធ្វើការចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជានិងភាគហ៊ុន ៥១%(ហាសិបមួយភាគរយ) ឬលើសក្នុងក្រុមហ៊ុន ត្រូវបានកាន់កាប់ដោយបុគ្គលមានសញ្ជាតិជាខ្មែរ

**បុគ្គល** មានន័យថា រូបវ័ន្តបុគ្គល ឬនីតិបុគ្គល

**វិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌ** មានន័យថា ឯកសារដែលចេញដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដូចមានចែងក្នុងកថាខណ្ឌ ៣ មាត្រា ៧ ថ្មី នៃច្បាប់នេះ

**វិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ** មានន័យថា ឯកសារដែលចេញដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដូចមានចែងក្នុងកថាខណ្ឌ ៧ មាត្រា ៧ ថ្មី នៃច្បាប់នេះ

**សំណើវិនិយោគ** មានន័យថា សំណើដែលបានដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដោយបុគ្គលណាមួយក្នុងគោលបំណងបង្កើតគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

**អ្នកដាក់ពាក្យសុំ** មានន័យថា បុគ្គលឬក្រុមបុគ្គលដែលដាក់សំណើវិនិយោគនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**អ្នកវិនិយោគ** មានន័យថា បុគ្គលដែលអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

## មាត្រា ៦.-ថ្មី

រាល់បុគ្គលដែលមានបំណងបង្កើតគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវដាក់សំណើវិនិយោគនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតាមទម្រង់និងតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់នេះនិងអនុក្រឹត្យ ។

## មាត្រា ៧.-ថ្មី

ក្នុងរយៈពេល ០៣(បី)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាទទួលបានសំណើវិនិយោគ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញវិញ្ញាបនបត្រចុះបញ្ជីមានលក្ខខណ្ឌឬលិខិតបដិសេធទៅឱ្យអ្នកស្នើសុំ ។

ប្រសិនបើសំណើវិនិយោគផ្តល់ជូននូវពត៌មានទាំងអស់ដែលតម្រូវដោយអនុក្រឹត្យ និងប្រសិនបើសកម្មភាពដែលបានស្នើសុំពុំមានបញ្ជាក់នៅក្នុងបញ្ជីគម្រោងហាមឃាត់ដែលមានចែងនៅក្នុងអនុក្រឹត្យទេនោះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ។ ផ្ទុយទៅវិញ បើសំណើវិនិយោគនោះពុំឆ្លើយតបតាមលក្ខខណ្ឌខាងលើនោះទេ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញលិខិតបដិសេធជូនទៅអ្នកស្នើសុំ ។

វិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ពីការយល់ព្រម ការអនុញ្ញាត ការជំរះបញ្ជី អាជ្ញាប័ណ្ណ លិខិតអនុញ្ញាតឬបញ្ជិកានានា ដែលត្រូវជាតម្រូវការសម្រាប់ដំណើរការគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់រួមទាំងបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលដែលទទួលបន្ទុកក្នុងការចេញលិខិតយល់ព្រមការជំរះបញ្ជី អាជ្ញាប័ណ្ណលិខិតអនុញ្ញាតឬបញ្ជិកាទាំងនោះផង ។ វិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌត្រូវបញ្ជាក់ផងដែរនូវការលើកទឹកចិត្តនានា ដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធិទទួល ដូចមានចែងក្នុងមាត្រា ១៤ ថ្មី នៃច្បាប់នេះ និងការទទួលស្គាល់លើលក្ខន្តិកៈនៃនីតិបុគ្គលដែលជាអ្នកអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

ប្រសិនបើក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាខកខានពុំបានចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌឬលិខិតបដិសេធក្នុងរយៈពេល ៣ថ្ងៃ(បី) នៃថ្ងៃធ្វើការទេ វិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌត្រូវបានចាត់ទុកថា បានយល់ព្រមដោយស្វ័យប្រវត្តិ តាមទម្រង់ដូចមានកំណត់ដោយអនុក្រឹត្យ ។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវទទួលយកនូវអាជ្ញាប័ណ្ណទាំងអស់ពីក្រសួងស្ថាប័នពាក់ព័ន្ធ ដូចមានចែងក្នុងវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ជំនួសមុខឱ្យអ្នកស្នើសុំ ។

រាល់ស្ថាប័នមានសមត្ថកិច្ចរបស់រដ្ឋាភិបាលដែលទទួលបន្ទុកចេញលិខិតអនុញ្ញាតការជំរះបញ្ជី អាជ្ញាប័ណ្ណ លិខិតយល់ព្រមឬបញ្ជិកាដែលមានរាយបញ្ជាក់នៅក្នុងវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ត្រូវចេញឯកសារទាំងនេះ យ៉ាងយូរបំផុតអោយបានមុន ២៨ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទនៃវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ។

មន្ត្រីរាជការណាមួយដែលខកខានពុំបានឆ្លើយតបទៅនឹងពាក្យស្នើសុំដោយគ្មានមូលហេតុត្រឹមត្រូវតាមកាលកំណត់ ត្រូវផ្តន្ទាទោសតាមច្បាប់ ។

ក្នុងរយៈពេល ២៨ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ។ ការចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ មិនមែនជាការលើកលែងឱ្យគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់រួចផុតពីការទទួលនូវលិខិតអនុញ្ញាតនានាដែលក្រសួងស្ថាប័នមានសមត្ថកិច្ចបានកំណត់ឡើយ ។ ទោះបីផុតរយៈពេល ២៨ថ្ងៃ ដូចមានចែងក្នុងកថាខណ្ឌ ៦ ខាងលើក៏ដោយ រាល់ស្ថាប័នមានសមត្ថកិច្ចត្រូវតែចេញលិខិតអនុញ្ញាតតាមការកំណត់ដោយច្បាប់និងបទប្បញ្ញត្តិនានា ។ កាលបរិច្ឆេទនៃការចេញជូននូវវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរគឺជាកាលបរិច្ឆេទនៃការចាប់ផ្តើមគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

រាល់លិខិតបដិសេធត្រូវមានបញ្ជាក់មូលហេតុច្បាស់លាស់ពីការមិនអាចទទួលសំណើវិនិយោគរួមទាំងព័ត៌មានបន្ថែម ដើម្បីផ្តល់លទ្ធភាពឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាអាចចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌបាន ។

**មាត្រា ៨.–ថ្មី**

អ្នកវិនិយោគបរទេសត្រូវបានទទួលស្គាល់និងមិនត្រូវជាកម្មវត្ថុនៃការរើសអើងដោយសារតែមូលហេតុសញ្ជាតិបរទេសទេ លើកលែងតែចំពោះដីធ្លី ដូចដែលមានចែងនៅក្នុងច្បាប់ភូមិបាល ។

**មាត្រា ១០.–ថ្មី**

រាជរដ្ឋាភិបាលមិនកំណត់ថ្លៃផលិតផលឬថ្លៃសេវានានានៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នោះឡើយ ។

**មាត្រា ១២.–ថ្មី**

រាជរដ្ឋាភិបាលផ្តល់ការលើកទឹកចិត្តដែលមានចែងក្នុងជំពូកនេះ ដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

**មាត្រា ១៤.–ថ្មី**

ការលើកទឹកចិត្តដែលមានចែងក្នុងមាត្រា ១៣ រួមមានដូចខាងក្រោម ៖

១-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធិទទួលការលើកលែងពន្ធលើប្រាក់ចំណេញដែលមានកំណត់ក្នុងច្បាប់ស្តីពីសារពើពន្ធ ដោយទទួលបាននូវរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ ។ រយៈពេលលើកលែងពន្ធរួមមាន ៖ រយៈពេលគន្លឹះបូករយៈពេល ៣(បី)ឆ្នាំបូករយៈពេលអាទិភាព ។ រយៈពេលអាទិភាពនឹងត្រូវកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ។ រយៈពេលគន្លឹះជាអតិបរមាគឺជាឆ្នាំទី ១ ដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបានប្រាក់ចំណេញ ឬរយៈពេល ៣(បី)ឆ្នាំ បន្ទាប់ពីគម្រោងវិនិយោគនោះបានទទួលប្រាក់ចំណូលដំបូងរបស់ខ្លួនដោយជ្រើសយកជម្រើសណាមួយដែលឆាប់ជាង ។

២-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធិទទួលបាននូវការលើកទឹកចិត្តផ្នែកតាមកថាខណ្ឌ ១ ខាងលើ លុះត្រាតែគម្រោងនោះទទួលបានពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានូវវិញ្ញាបនប័ត្រប្រចាំឆ្នាំបញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៣-បន្ទាប់ពីផុតរយៈពេលលើកលែងពន្ធ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវជាប់ពន្ធលើប្រាក់ចំណេញ ។

៤-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលប្រើប្រាស់សិទ្ធិទទួលបាននូវការលើកទឹកចិត្តផ្នែកតាមកថាខណ្ឌ ១ ខាងលើ ពុំមានសិទ្ធិធ្វើការទាមទារការរំលោះពិសេសណាមួយឡើយ ។

៥-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលបម្រើទីផ្សារក្នុងស្រុក មានសិទ្ធិនាំចូលដោយរួចពន្ធគយនូវគ្រឿងសម្ភារៈបរិក្ខាផលិតកម្ម សម្ភារៈសាងសង់ បម្រើផលិតកម្ម ដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៦-ក្រៅពីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញដែលជ្រើសរើសឬបានជ្រើសរើសយកឃ្លាំងយន្តការ ភណ្ឌាគារផលិតកម្មក្រោមការគ្រប់គ្រងរបស់គយ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញផ្សេងទៀត មានសិទ្ធិនាំចូលដោយរួចពន្ធគយនូវគ្រឿងសម្ភារៈបរិក្ខាផលិតកម្ម សម្ភារៈសាង

សង់ វត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេចនិងសម្ភារៈបន្ទាប់បន្សំបម្រើផលិត-កម្ម ដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៧-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាប្រភេទឧស្សាហកម្មគាំទ្រមានសិទ្ធិនាំចូល ដោយរួចពន្ធគយ នូវគ្រឿងសម្ភារៈបរិក្ខាផលិតកម្មសម្ភារៈសាងសង់ វត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេចនិងសម្ភារៈបន្ទាប់បន្សំបម្រើផលិតកម្មដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៨-បុគ្គលណាដែលបានទិញឬវិនិយោគដែលបានរំលាយបញ្ចូលគ្នាជាមួយអ្នកវិនិយោគណាមួយ អាចទទួលស្នងពីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយធ្វើសំណើទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានូវរាល់ការធានា សិទ្ធិ បុព្វសិទ្ធិ និងកាតព្វកិច្ចទាំងអស់ ដោយយោងទៅតាមនីតិវិធីនៃការទិញឬការរំលាយបញ្ចូលគ្នាដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៩-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមានទីតាំងនៅក្នុងតំបន់អភិវឌ្ឍន៍ពិសេសឬតំបន់ផលិតកែច្នៃនាំចេញដែលមានក្នុងបញ្ជីអាទិភាពសម្រាប់អភិវឌ្ឍន៍ ប្រកាសដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានសិទ្ធិទទួលបាននូវការលើកទឹកចិត្តនិងបុព្វសិទ្ធិដូចគ្នានឹងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ផ្សេងៗទៀតដូចមានចែងនៅក្នុងច្បាប់នេះ ។

១០-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធិទទួលបាននូវការលើកលែងពន្ធនាំចេញ ១០០%(មួយរយភាគរយ) លើកលែងតែចំពោះសកម្មភាពទាំងឡាយ ដូចមានចែងនៅក្នុងច្បាប់ជាធរមាន ។

១១-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានសិទ្ធិទទួលបាននូវទិដ្ឋាការនិងប័ណ្ណការងារ ដើម្បីធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ជនបរទេសដែលធ្វើជាអ្នកគ្រប់គ្រង អ្នកបច្ចេកទេសនិងកម្មករជំនាញ រួមទាំងទិដ្ឋាការស្នាក់នៅសម្រាប់សហព័ទ្ធនិងអ្នកនៅក្នុងបន្ទុករបស់ជនបរទេសទាំងនោះ ដែលអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្របតាមច្បាប់ស្តីពីអន្តោប្រវេសន៍និងច្បាប់ស្តីពីការងារ ។

**មាត្រា ១៥.–ថ្មី**

សិទ្ធិ បុព្វសិទ្ធិនិងសិទ្ធិដទៃទៀតដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បានទទួល មិនអាចផ្ទេរឬប្រគល់ជូនទៅតតិយជនណាមួយឡើយ លើកលែងតែក្នុងករណីទិញ ឬរំលាយបញ្ចូលគ្នា ដូចមានចែងនៅក្នុងកថាខណ្ឌ ៨ នៃមាត្រា ១៤ ថ្មី ។

**មាត្រា ១៦.–ថ្មី**

កម្មសិទ្ធិដីធ្លីរបស់អ្នកវិនិយោគសម្រាប់មម្រើឱ្យគោលដៅអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានអនុញ្ញាតចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរ ។

អ្នកវិនិយោគអាចប្រើប្រាស់ដីធ្លីតាមរយៈដីសម្បទានឬការជួលរយៈពេលមិនកំណត់ និងការជួលរយៈពេលមានកំណត់ដែលអាចបន្តជាថ្មីបាន ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់ភូមិបាល ។

អ្នកវិនិយោគមានសិទ្ធិកាន់កាប់និងដាក់បញ្ចាំសម្រាប់ធានានិងផ្ទេរនូវចលនទ្រព្យនិងអចលនទ្រព្យដែលស្ថិតនៅលើដីនិងដីដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ប្រើប្រាស់ តាមរយៈពេលមិនលើសពីរយៈពេលដែលមានកំណត់ក្នុងកិច្ចសន្យាសម្បទានដី ឬកិច្ចសន្យាជួល ដូចដែលបានអនុញ្ញាតដោយច្បាប់ ។

ចំពោះដីសម្បទានណាដែលពុំទាន់បានដំណើរការ អ្នកវិនិយោគមិនអាចផ្ទេរ ឬបញ្ចាំបន្តទៀតជាដាច់ខាត ។

**មាត្រា ១៨.–ថ្មី**

អ្នកវិនិយោគត្រូវបានអនុញ្ញាតឱ្យជួលនិយោជិតបរទេសតាមលក្ខខណ្ឌដូចតទៅ :

- គុណភាព សមត្ថភាពនិងជំនាញមិនអាចរកបាននៅព្រះរាជាណាចក្រកម្ពុជាក្នុងចំណោមប្រជាពលរដ្ឋខ្មែរ ។ ក្នុងករណីមានការជួលនិយោជិតប្រភេទនេះ ត្រូវផ្ញើជូនមកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានូវឯកសាររួមមាន សេចក្ដីចម្លងលិខិតឆ្លងដែនសញ្ញាប័ត្រនិងប្រវត្តិរូបសង្ខេបរបស់និយោជិតនោះ

- ត្រូវមានលិខិតអះអាងពីតម្រូវការជួលនិយោជិតបរទេស ។ អ្នកវិនិ-យោគត្រូវមានការយល់ព្រម និងលិខិតអនុញ្ញាតពីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា

- មុននឹងចូលបម្រើការងារឱ្យអ្នកវិនិយោគ និយោជិតបរទេសត្រូវមានលិខិតអនុញ្ញាតឱ្យធ្វើការនៅព្រះរាជាណាចក្រកម្ពុជាពីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា ។

អ្នកវិនិយោគមានកាតព្វកិច្ចដូចតទៅ :

- ធ្វើការបណ្តុះបណ្តាលសមស្របជូននិយោជិតខ្មែរជាប្រចាំ

- ជំរុញលើកកំពស់ដល់និយោជិតខ្មែរដើម្បីអាចក្លាយទៅជាអ្នកមានតួនាទីដែលមានកម្រិតខ្ពស់ ត្រូវធ្វើជាប្រចាំ ។

## មាត្រា ២០.-ថ្មី

វិវាទដែលទាក់ទងទៅនឹងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ពាក់ព័ន្ធទៅនឹងសិទ្ធិនិងកាតព្វកិច្ចដែលមានចែងនៅក្នុងច្បាប់នេះ លើកលែងតែករណីទាក់ទងនឹងវិវាទដីធ្លី ត្រូវដោះស្រាយដោយសម្រុះសម្រួលតាមដែលអាចធ្វើទៅបាន តាមរយៈការពិគ្រោះគ្នារវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អ្នកវិនិយោគ និងភាគីណាមួយផ្សេងទៀតដែលពាក់ព័ន្ធក្នុងវិវាទ ។

ក្នុងរយៈពេលពីរខែ បន្ទាប់ពីកាលបរិច្ឆេទនៃសំណើជាលាយលក្ខណ៍អក្សរដំបូងដែលស្នើសុំធ្វើការពិគ្រោះគ្នានេះ ប្រសិនបើភាគីមានវិវាទពុំអាចដោះស្រាយតាមការសម្រុះសម្រួលគ្នាទេ ភាគីណាមួយអាចលើកយកវិវាទនោះទៅ :

- សុំការផ្សះផ្សាសម្រុះសម្រួលនៅចំពោះមុខក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬ

- សុំធ្វើមជ្ឈត្តវិនិច្ឆ័យពីក្នុង ឬក្រៅប្រទេសកម្ពុជាតាមការព្រមព្រៀងរបស់គូភាគី ឬ

សុំការជំនុំជំរះពីសាលាជំរះក្តីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២១.–ថ្មី**

ក្នុងករណីអ្នកវិនិយោគមានបំណងចង់បញ្ឈប់សកម្មភាពរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា អ្នកវិនិយោគនោះត្រូវជូនពត៌មានទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមរយៈលិខិតអនុសិដ្ឋឬលិខិតប្រគល់ផ្ទាល់ដៃ ដោយបញ្ជាក់អំពីមូលហេតុនៃការបញ្ឈប់សកម្មភាពនោះ និងចុះហត្ថលេខាដោយអ្នកវិនិយោគ ឬមេធាវីតំណាងផ្ទាល់របស់ខ្លួន ។

**មាត្រា ២២.–ថ្មី**

ប្រសិនបើអ្នកវិនិយោគមានបំណងចង់បញ្ឈប់សកម្មភាពនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់ខ្លួនក្រៅផ្លូវតុលាការ អ្នកវិនិយោគត្រូវផ្តល់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានូវភ័ស្តុតាងបញ្ជាក់ថា គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បានដោះស្រាយជំរះបំណុលរបស់ខ្លួនយ៉ាងត្រឹមត្រូវ រួមមានអ្នកប្តឹងឬការទាមទារណាមួយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទើបអ្នកវិនិយោគនោះត្រូវបានអនុញ្ញាតឱ្យបញ្ឈប់សកម្មភាពនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាផ្លូវការឬរំលាយដោយយោងទៅតាមច្បាប់ជាធរមានពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម ។

**មាត្រា ២៣.–ថ្មី**

